ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំ
## ស្តីពី
# ការងារបណ្ណាល័យ



ឆ្នាំ ២០០៩

www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំ
## ស្តីពី
# ការងារបណ្ណាល័យ

ឆ្នាំ ២០០៩

ហាមលក់ NOT FOR SALE
អង្គការសន្តិស្ម័គ្រចិត្ត Shanti Volunteer Association (SVA)
ផ្ទះ 32 ផ្លូវ 288 សង្កាត់បឹងកេងកង ខណ្ឌចំការមន ភ្នំពេញ
Tel: 219080 220864, Fax: 216924

www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ...... អយក.

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ជម្រាបមក

## លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត

**កម្មវត្ថុ** : ការអនុញ្ញាតឱ្យប្រើប្រាស់សៀវភៅណែនាំ ស្តីពីការងារបណ្ណាល័យ

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រីប្រធានថា ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងការងារបណ្ណាល័យនៅតាមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តសាលាអនុវត្ត និងសាលាបឋមសិក្សាទូទាំងប្រទេស ឱ្យមានការឯកភាពគ្នា ក្រសួងអនុញ្ញាតឱ្យប្រើប្រាស់ "សៀវភៅណែនាំ ស្តីពីការងារបណ្ណាល័យ" ចាប់ពីឆ្នាំ ២០០៩ តទៅ ។

អាស្រ័យហេតុនេះសូមលោក លោកស្រីអនុវត្តការងារនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

**ចម្លងជូន**

-សាលារាជធានី-ខេត្ត ដែលពាក់ព័ន្ធ

"ដើម្បីសូមជ្រាបជាព័ត៌មាន"

-អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

" ដើម្បីជាព័ត៌មាន "

-សាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្ត

-មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

" ដើម្បីអនុវត្ត "

-កាលប្បវត្តិ

-ឯកសារ: នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

អ៊ឹម_សិទ្ធី



www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅណែនាំស្តីពីការងារបណ្ណាល័យត្រូវបាននិពន្ធ និងចងក្រងឡើង បន្ទាប់ពីបានផ្សព្វផ្សាយឱ្យប្រើប្រាស់សៀវភៅណែនាំ ស្តីពីសកម្មភាពបណ្ណាល័យ និងការនិទានរឿង ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩។

តាមគំនិតនេះ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសន្តិស្ម័គ្រចិត្ត (SVA) ក្រោមការឧបត្ថម្ភពីអង្គការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានរៀបចំកែលំអចំណុចខ្វះខាត និងកំហុសឆ្គងដែលមាននៅក្នុងសៀវភៅណែនាំស្តីពីសកម្មភាពបណ្ណាល័យ និងការនិទានរឿង រួមផ្សំនឹងមតិកែលំអ និងបទពិសោធផ្សេងៗ ក្នុងពេលអនុវត្តសៀវភៅនេះកន្លងមក សៀវភៅថ្មីមួយទៀតត្រូវបានបង្កើតឡើងដែលមានចំណងជើងថា “សៀវភៅណែនាំស្តីពីការងារបណ្ណាល័យ” ដោយផ្តោតជាសំខាន់ទៅលើការងារគ្រប់គ្រង ការងារបច្ចេកទេស និងការអនុវត្ត សំដៅឱ្យដំណើរការបណ្ណាល័យនៅគ្រប់សាលារៀនប្រកបដោយជោគជ័យ និងជួយដល់ការបង្រៀន និងរៀន ឱ្យទទួលបានលទ្ធផលប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្វីបើសៀវភៅណែនាំស្តីពីការងារបណ្ណាល័យនេះ មានខ្លឹមសារគ្រប់ដណ្តប់ក៏មែនពិត តែក៏វាអាចនឹងមានខ្វះចន្លោះខ្លះៗមិនលែងឡើយ ហើយយើងខ្ញុំសង្ឃឹមថា គ្រប់អ្នកពាក់ព័ន្ធនឹងជួយផ្តល់គំនិត និងអនុសាសន៍ល្អៗ សម្រាប់កែលំអឯកសារនេះ ឱ្យបានល្អប្រសើរនាពេលអនាគតជាមិនខាន ។

យើងខ្ញុំរង់ចាំទទួលរាល់មតិកែលំអ និងអនុសាសន៍ដោយក្តីសោមនស្សរីករាយ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៩

គណៈកម្មការនិពន្ធ និងរៀបរៀង



www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

គណៈកម្មាការនិពន្ធ និងរៀបរៀងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ :

- អង្គការសន្តិស្ម័គ្រចិត្ត (SVA) ដែលបានបញ្ជូនអ្នកឯកទេសជំនាញចូលរួមសរសេរសៀវភៅនេះ ។

- មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ខេត្តកណ្តាល ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ តាកែវ និង ខេត្តកំពត ដែលបានបញ្ជូនគ្រូឧទ្ទេសផ្នែកបណ្ណាល័យ និងបណ្ណារក្សដែលមានបទពិសោធល្អឱ្យចូលរួមកែលំអសៀវភៅណែនាំ ស្តីពីការងារបណ្ណាល័យ ។

- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានធានាគុណភាពអប់រំ ព្រមទាំងនាយកដ្ឋានពាក់ពន្ធ័ទាំងអស់ដែលបានចូលរួមសរសេរ និងកែលំអសៀវភៅណែនាំនេះ ។

- បណ្ណាល័យជាតិ បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវ បណ្ណាល័យមជ្ឈមណ្ឌលវប្បធម៌បារាំង បណ្ណាល័យហ៊ុនសែន បណ្ណាល័យតាមបណ្តាស្ថាប័នជាតិ និងអន្តរជាតិ ដែលបានផ្តល់ព័ត៌មានសម្រាប់បញ្ចូលក្នុងសៀវភៅនេះ ។

សូមអរគុណ និងកោតសរសើរដល់ក្រុមការងារដែលបានចូលរួមនិពន្ធ និងរៀបរៀងសៀវភៅណែនាំស្តីពីការងារបណ្ណាល័យ ។

ជាពិសេសអង្គការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដែលបានជួយផ្តល់ឱកាសសម្រាប់បោះពុម្ពសៀវភៅណែនាំនេះ ។



www.elibraryofcambodia.org

# សេចក្តីផ្តើម

ផែនការអប់រំសម្រាប់ទាំងអស់គ្នា ២០០៣-២០១៥ ក្នុងគោលដៅទី ៦ បានចែងថា "កែលំអគ្រប់ទិដ្ឋភាពនៃការអប់រំ និង ធានាបានគុណភាពប្រសើរបំផុតគ្រប់ផ្នែក ដើម្បីឱ្យមនុស្សគ្រប់រូបដណ្តើមបានលទ្ធផលរៀនសូត្រមានកម្រិត និងមានការទទួលស្គាល់ ជាពិសេសផ្នែកភាសាសាស្ត្រ លេខនព្វន្ត និងជំនាញចាំបាច់សម្រាប់ចិញ្ចឹមជីវិត (បំណិនជីវិត)" ។

ឆ្លើយតបនឹងផែនការនេះ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងនោះមានទាំងដៃគូអភិវឌ្ឍន៍ដើម្បីធ្វើយ៉ាងណាឱ្យសម្រេចបានតាមផែនការអប់រំសម្រាប់ទាំងអស់គ្នា នាឆ្នាំ២០១៥ ខាងមុខនេះ ។

ដោយឡែកនៅ ឆ្នាំ១៩៩៣ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសន្តិស្ម័គ្រចិត្ត បានធ្វើសកម្មភាព ដោយផ្តោតជាសំខាន់ទៅលើការងារបណ្ណាល័យសម្រាប់បឋមសិក្សា ដែលពេលនោះយើងបានបង្កើត និងដាក់ឱ្យប្រើប្រាស់ជាដំបូងនូវឯកសារមួយមានឈ្មោះថា "ពីនេះ ពីនោះស្តីពីការនិទានរឿង" ។

បន្ទាប់មកទៀតតាមរយៈបទពិសោធ និងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា នៅឆ្នាំ១៩៩៤ យើងបានបង្កើតឯកសារថ្មីជាបន្ត គឺ "សៀវភៅណែនាំស្តីពីសកម្មភាពបណ្ណាល័យ និងការនិទានរឿង" ។

បច្ចុប្បន្នដោយបរិបទសង្គមមានការរីកចម្រើន និងដើម្បីសម្របខ្លួនទៅនឹងការអភិវឌ្ឍកម្មវិធីសិក្សាថ្មី ព្រមទាំងមានការឧបត្ថម្ភពីអង្គការ JICA ផងនោះ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការសន្តិស្ម័គ្រចិត្តបានសហការរៀបចំប្រជុំក្រុមជំនាញដែលមាននៅក្នុងអង្គការសន្តិស្ម័គ្រចិត្ត នាយកដ្ឋានពាក់ព័ន្ធ មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្តមួយចំនួន ដើម្បីពិភាក្សាផ្លាស់ប្តូរបទពិសោធ ពីការអនុវត្តសៀវភៅណែនាំស្តីពីសកម្មភាពបណ្ណាល័យ និងការនិទានរឿងកន្លងមក ដើម្បីបង្កើតបានជាសៀវភៅមួយថ្មីថែមទៀត គឺ "សៀវភៅណែនាំស្តីពីការងារបណ្ណាល័យ"នេះ ។

ការរៀបចំសៀវភៅថ្មីនេះមានគោលបំណង ជួយដល់សាលារៀនបឋមសិក្សាទាំងអស់ ឱ្យសម្រេចបាននូវប្រសិទ្ធភាពក្នុងការបង្រៀន និងរៀន ជាពិសេសជួយដល់អ្នកគ្រប់គ្រងសាលា និងបណ្ណារក្ស ឱ្យយល់ដឹងអំពី:

- ការផ្សព្វផ្សាយការអាន និងសារៈសំខាន់នៃការផ្សព្វផ្សាយការអាន
- បណ្ណាល័យ និង ការគ្រប់គ្រងបណ្ណាល័យ

យើងខ្ញុំសង្ឃឹមជឿជាក់ថា សៀវភៅថ្មីនេះ នឹងក្លាយជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើន ដែលជាមូលដ្ឋានក្នុងការធ្វើឱ្យសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា នៅឆ្នាំ ២០១៥ ជាក់ជាមិនខាន ។



www.elibraryofcambodia.org

# គណៈកម្មការ

## I. គណៈកម្មការត្រួតពិនិត្យ

១. ឯកឧត្តម ណាត ប៊ុនរឿន — រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា — ប្រធាន

២. លោក លាង សេងហាក់ — ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ — អនុប្រធាន

៣. លោក យ៉ោក សុវណ្ណ — ប្រធាននាយកដ្ឋានបឋមសិក្សា — សមាជិក

៤. លោក អេង គីមលី — ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា — សមាជិក

៥. លោកស្រី យឹម ចាន់ស្រី — ប្រធាននាយកដ្ឋានអប់រំកុមារតូច — សមាជិក

៦. លោក ជា ផុន — អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ — សមាជិក

៧. លោក មួង ចាន់ទូច — អនុប្រធានការិយាល័យបណ្តុះបណ្តាល — សមាជិក

## II. គណៈកម្មការនិពន្ធ និង រៀបរៀង

១. លោក មួង ចាន់ទូច — អនុប្រធានការិយាល័យបណ្តុះបណ្តាល នៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ — ប្រធាន

២. កញ្ញា យឹម មុំរី — ប្រធានការិយាល័យ ទទួលបន្ទុកផ្នែកបណ្ណាល័យ នៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា — អនុប្រធាន

៣. លោក ឈាង ស៊ីម — មន្ត្រីជំនាញនៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ — សមាជិក

៤. លោកស្រី ណែត ពេជ្រចិន្តា — មន្ត្រីជំនាញនៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ — សមាជិក

៥. លោក ម៉ិត សំអុល — មន្ត្រីជំនាញនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា — សមាជិក

៦. លោក ម៉ុក រ៉ាស៊ុំ — មន្ត្រីជំនាញនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា — សមាជិក

៧. លោក ណៃ សច្ចា — មន្ត្រីការិយាល័យសកម្មភាពប្រតិបត្តិ នៃនាយកដ្ឋានបឋមសិក្សា — សមាជិក

៨. លោកស្រី ស៊ីណា សាន្តី — មន្ត្រីការិយាល័យសកម្មភាពប្រតិបត្តិ នៃនាយកដ្ឋានបឋមសិក្សា — សមាជិក

៩. កញ្ញា យក់ វណ្ណា — អនុប្រធានការិយាល័យនាយកដ្ឋាន ធានាគុណភាពអប់រំ — សមាជិក

១០. លោក អ៊ុង ប្រសិទ្ធ — មន្ត្រីជំនាញនៃនាយកដ្ឋានធានាគុណភាពអប់រំ — សមាជិក

## III. គណៈកម្មការជំនួយការបច្ចេកទេស

១. លោក តេហ្ស៊ូកា កូជី — ទីប្រឹក្សាអង្គការសទ្ធិស្ម័គ្រចិត្ត — ប្រធាន



www.elibraryofcambodia.org

| | | |
|---|---|---|
| ២. កញ្ញា ស៊ុយហ៊្សូគី អាគីកុ | អ្នកសម្របសម្រួលផ្នែកអន្តរជាតិ អង្គការសន្តិស៊ុំគ្រចិត្ត | អនុប្រធាន |
| ៣. លោក ទឹម ចិត្រា | អ្នកសម្របសម្រួលផ្នែកបណ្ណាល័យ អង្គការសន្តិស៊ុំគ្រចិត្ត | អនុប្រធាន |
| ៤. លោក ស៊ូ សោភ័ណ | អ្នកជំនួយការផ្នែកបណ្ណាល័យ អង្គការសន្តិស៊ុំគ្រចិត្ត | សមាជិក |
| ៥. លោក ឆាយ ផល្លី | អ្នកទទួលការងារបោះពុម្ពសៀវភៅ អង្គការសន្តិស៊ុំគ្រចិត្ត | សមាជិក |
| ៦. លោក ម៉ែត ធឿន | គ្រូឧទ្ទេសផ្នែកបណ្ណាល័យ អង្គការសន្តិស៊ុំគ្រចិត្ត | សមាជិក |
| ៧. លោកស្រី ម៉ិត្យ ផល្លិកា | គ្រូឧទ្ទេសផ្នែកបណ្ណាល័យ អង្គការសន្តិស៊ុំគ្រចិត្ត | សមាជិក |
| ៨. លោក ស៊ីវ ហឿន | គ្រូឧទ្ទេសផ្នែកបណ្ណាល័យ អង្គការសន្តិស៊ុំគ្រចិត្ត | សមាជិក |
| ៩. លោក មូល កិត្តិនាម | គ្រូឧទ្ទេសផ្នែកបណ្ណាល័យ អង្គការសន្តិស៊ុំគ្រចិត្ត | សមាជិក |
| ១០. កញ្ញា ហួន សុធារ័ត្ន | គ្រូឧទ្ទេសផ្នែកបណ្ណាល័យ អង្គការសន្តិស៊ុំគ្រចិត្ត | សមាជិក |



www.elibraryofcambodia.org

## មាតិកា

- សេចក្ដីណែនាំ/ប្រកាស/ជម្រាបជូន
- អារម្ភកថា....................i
- សេចក្ដីថ្លែងអំណរគុណ....................ii
- សេចក្ដីផ្ដើម....................iii
- គណៈកម្មការ....................iv
- មាតិកា....................vi

I. គោលនយោបាយ

ក. ផ្សព្វផ្សាយការអាន និង បណ្ណាល័យ....................1

១. សកម្មភាពផ្សព្វផ្សាយការអាន....................1

២. កិច្ចការ និងមុខងារបណ្ណាល័យ....................1

៣. បណ្ណាល័យសាធារណៈ និង បណ្ណាល័យតាមសាលារៀន ឬបន្ទប់អាន....................2

- មុខងារទី១: ការសិក្សាអស់មួយជីវិត....................3
- មុខងារទី២: ទំនាក់ទំនងរវាងអ្នកប្រើប្រាស់ និង បណ្ណារក្ស លោកគ្រូ អ្នកគ្រូ....................4
- មុខងារទី៣: ភាពជោគជ័យចំពោះវប្បធម៌ប្រពៃណី....................4

ខ. សារៈសំខាន់នៃការផ្សព្វផ្សាយការអាន....................4

១. ការអានគឺជាអ្វី? ....................5

២. សិទ្ធិក្នុងការរៀនសូត្រ....................5

៣. ការអានជាការអភិវឌ្ឍធនធានមនុស្ស....................7

II. បណ្ណាល័យ

ក. និយមន័យបណ្ណាល័យ....................10

ខ. កិច្ចការ និងមុខងារបណ្ណាល័យ....................10

១. ការផ្សព្វផ្សាយព័ត៌មានបណ្ណាល័យ....................10

២. ការទំនាក់ទំនងជាមួយសាធារណជន....................11

គ. ប្រវត្តិបណ្ណាល័យ ....................11

១. បណ្ណាល័យនៅលើពិភពលោក....................11

២. បណ្ណាល័យនៅប្រទេសកម្ពុជា....................15



www.elibraryofcambodia.org

ឃ. ប្រភេទបណ្ណាល័យ ......27
ង. ការបង្កើតបណ្ណាល័យសាលារៀន......33
ច. ធនធានឯកសារ សម្ភារ និងថវិកា ......37
ឆ. អំពីបណ្ណារក្ស ......42
ជ. ការរៀបចំបណ្ណាល័យ ......44

III. អំពីសៀវភៅ

ក. ប្រវត្តិសៀវភៅ......46
ខ. ប្រវត្តិសៀវភៅនៅកម្ពុជា......47
គ. ជ្រើសរើសសៀវភៅរូបភាពសម្រាប់កុមារ......50

IV. ការគ្រប់គ្រងបណ្ណាល័យ

ក. រដ្ឋបាលបណ្ណាល័យ......51
ខ. ការរៀបចំចងក្រង និងការគ្រប់គ្រងឯកសារ......52
គ. សេវាកម្មបណ្ណាល័យ......58
ឃ. ការការពារ និងថែរក្សាឯកសារ......61
ង. ការធានានិរន្តរភាពរបស់បណ្ណាល័យ......62
ច. សកម្មភាពបណ្ណាល័យកុមារ......62

V. ប្រវត្តិរឿងនិទាន និងការនិទានរឿង

ក. ប្រវត្តិរឿងព្រេង......81
ខ. ប្រភពរឿងព្រេង......85
គ. ការនិទានរឿង......89
ឃ. ប្រភេទនៃការនិទានរឿង......91
១. ការនិទានរឿងដោយផ្ទាល់មាត់......92
២. ការនិទានរឿងដោយសៀវភៅរូបភាព......92
៣. ការនិទានរឿងដោយផ្ទាំងរូបភាព......93
៤. ការនិទានរឿងដោយប្រើអាវអៀម......93
៥. ការនិទានរឿងដោយតុក្កតា ម៉ារ៉ុកែត ឬអាយ៉ង ......96
៦. ការនិទានរឿងដោយល្ខោនស្រមោលស្បែក......96



www.elibraryofcambodia.org

ង. ការផ្លាស់ប្តូរឥរិយាបថរបស់កុមារក្រោយពីការនិទានរឿង....99
ច. ឥទ្ធិពលរបស់កុមារទៅលើឪពុកម្តាយ និងសហគមន៍....99

VI. សិប្បកម្មបត់ក្រដាស
ក. ប្រវត្តិនៃការបត់ក្រដាស....101
ខ. របៀបរៀបចំសម្រាប់ការបត់ក្រដាស....101
គ. អត្ថប្រយោជន៍នៃការបត់ក្រដាស....102

VII. ការប្រើប្រាស់ឧបករណ៍បោះពុម្ពដោយដៃ
ក. ប្រវត្តិឧបករណ៍បោះពុម្ពដោយដៃ....132
ខ. ឧបករណ៍បោះពុម្ពដោយដៃជាអ្វី?....133
គ. ផលប្រយោជន៍ឧបករណ៍បោះពុម្ពដោយដៃ....133
ឃ. ការបង្ហាញពីរបៀបប្រើប្រាស់ឧបករណ៍បោះពុម្ពដោយដៃ....134

VIII. ការផលិតសម្ភារៈ
ក. ល្បែងទាយឈ្មោះសត្វ....142
ខ. ការផ្គុំរូបភាព....145
គ. ល្បែងដាំផ្កា....146
ឃ. ផ្ទាំងរូបភាព (គូរ កាត់ បិទ និងបត់)....147
ង. បន្ទប់ចម្លែក....147
ច. រ៉ូមវ៉ះអើ....150
ឆ. ប្រអប់៦ជ្រុង....152

☆ ឧបសម្ព័ន្ធ
១. បទបញ្ជាផ្ទៃក្នុង....155
២. គំរូត្រារាងពងក្រពើ....155
៣. ចំណាត់ថ្នាក់ជីវេ....155
៤. ចំណាត់ថ្នាក់លម្អិតជីវេ....160
៥. គំរូបញ្ជីទស្សនាវដ្តី....200
៦. គំរូបញ្ជីសារព័ត៌មាន....201



www.elibraryofcambodia.org

៧. គំរូលិខិតរំលឹក ........................................................................ 202
៨. គំរូផែនការសកម្មភាពបណ្ណាល័យ ........................................................ 203
៩. ពាក្យសម្រាប់ប្រើនៅក្នុងសៀវភៅ ........................................................ 204
១០. សម្ភារចាំបាច់សម្រាប់ដំណើរការបណ្ណាល័យ ............................................ 205
១១. គំរូរបាយការណ៍ប្រចាំខែ ................................................................ 206
១២. បញ្ជីខ្ទី សង ............................................................................ 209
១៣. គំរូប័ណ្ណខ្ទី សង ......................................................................... 210
១៤. គំរូបញ្ជីរួម ............................................................................. 211
១៥. គំរូបញ្ជីសារពើភ័ណ្ឌសៀវភៅ ............................................................ 212
១៦. តារាងស្រង់ចំនួនអ្នកចូលអានប្រចាំខែ .................................................. 213
១៧. តារាងស្រង់ចំនួនអ្នកចូលអានប្រចាំឆ្នាំសិក្សា .......................................... 214
១៨. ប្លង់បណ្ណាល័យ .......................................................................... 215
១៩. កម្រងសំណួរពិនិត្យតាមដានសកម្មភាពបណ្ណាល័យ.............. ........................... 216



www.elibraryofcambodia.org

I. គោលនយោបាយ

ក. ផ្សព្វផ្សាយការអាន និងបណ្ណាល័យ

ការអភិវឌ្ឍបំណិនក្នុងការអាន គឺជាកត្តាចាំបាច់ដែលក្រសួងអប់រំ យុវជន និងកីឡា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងដើម្បីអភិវឌ្ឍវិស័យអប់រំនៅប្រទេសកម្ពុជាឱ្យប្រសើរឡើង ក្នុងនោះបណ្ណាល័យកុមារ គឺជាសកម្មភាពមួយក្នុងសមាសភាគទី២ នៃកម្មវិធីសាលាកុមារមេត្រីដែលត្រូវ បានរៀបចំឡើងក្នុងគោលបំណង ជួយឱ្យអ្នកពាក់ព័ន្ធ ទាំងអស់យល់ពីសារៈសំខាន់ និងដំណើរការនៃបណ្ណាល័យកុមារតាមរយៈការជំរុញ និងផ្សព្វផ្សាយការអានដល់សិស្សានុសិស្ស ។

វត្ថុបំណង:

- បង្កើនប្រសិទ្ធភាពការងារបណ្ណាល័យនៅ២៤ រាជធានី/ខេត្ត ដើម្បីពង្រឹងគុណភាពសិក្សារបស់សិស្សតាមកម្មវិធីសិក្សាថ្មី ។

- អភិវឌ្ឍ និងកែលំអសៀវភៅណែនាំស្តីពីការងារបណ្ណាល័យសម្រាប់ប្រើប្រាស់ នៅសាលាបឋមសិក្សាទូទាំងប្រទេស ។

- បង្កើនសមត្ថភាពបណ្ណារក្សក្នុងការគ្រប់គ្រងបណ្ណាល័យតាមកម្មវិធីសិក្សាថ្មី ។

១. តើសកម្មភាពផ្សព្វផ្សាយការអានជាអ្វី ?

បំណងសំខាន់នៃសកម្មភាពផ្សព្វផ្សាយការអាន គឺការអភិវឌ្ឍចំណេះដឹង ឥរិយាបថ និងតម្លៃរបស់កុមារដោយផ្សារភ្ជាប់ជាមួយនឹងតម្រូវការជាបឋមនៃសិទ្ធិកុមារដើម្បីទទួលបាននូវការអប់រំ និងវប្បធម៌ ។

ការផ្សព្វផ្សាយ ការអាននៅក្នុងសៀវភៅណែនាំនេះមានគោលបំណង:

- ទី១: អភិវឌ្ឍ "បំណិនជីវិត" ដែលជួយឱ្យកុមារចេះគិត ស្វែងយល់ និងអនុវត្តការងារដោយខ្លួនឯង ។

- ទី២: អភិវឌ្ឍ "ស្មារតីមនុស្សធម៌" ដែលគេអាចគោរពវប្បធម៌ សាសនា ភាសារបស់ខ្លួន និង ជនជាតិផ្សេងៗទៀត ហើយធ្វើការដោះស្រាយបញ្ហាតាមរយៈការប្រាស្រ័យទាក់ទងគ្នា ។

២. កិច្ចការ និងមុខងារបណ្ណាល័យ

នៅពេលអនុវត្ត "ការផ្សព្វផ្សាយការអាន" តើទីកន្លែងណាសមរម្យសម្រាប់ធ្វើជាគ្រឹះស្ថាននៃការផ្សព្វផ្សាយ? ដូចដែលបានពណ៌នា នៅក្នុងផ្នែកមុនរួចមកហើយ "សិទ្ធិនៃការអប់រំ" ត្រូវបានផ្តល់ជូនដល់មនុស្សគ្រប់ៗរូប ។

បណ្ណាល័យគឺជាគ្រឹះស្ថានដែលគាំទ្រ "សិទ្ធិនៃការអប់រំ" ។ យោងទៅតាមសេចក្តីថ្លែងការណ៍អំពីបណ្ណាល័យសាធារណៈរបស់អង្គការ UNESCO (នៅឆ្នាំ១៩៧២ ដែលបានកែសម្រួលនៅឆ្នាំ១៩៩៤) បណ្ណាល័យ



www.elibraryofcambodia.org

សាធារណៈផ្ដោតទៅលើការអភិវឌ្ឍ សេរីភាព វឌ្ឍនភាព ការអភិវឌ្ឍសង្គម និង បុគ្គលដែលជាមូលដ្ឋានគ្រឹះនៃតម្លៃរបស់មនុស្ស។

ការចូលរួមក្នុងន័យស្ថាបនា និងអភិវឌ្ឍ "លទ្ធិប្រជាធិបតេយ្យ" អាស្រ័យទៅលើការអប់រំដែលទទួលយកបានដោយពេញចិត្ត ដូចគ្នានឹងការទទួលយកព័ត៌មាន ចំណេះដឹង វប្បធម៌ដោយសេរី និងមិនមានការកំណត់ឡើយ។

បណ្ណាល័យសាធារណៈ ជាច្រកនៅមូលដ្ឋានសម្រាប់ចំណេះដឹង ដែលផ្ដល់មូលដ្ឋានគ្រឹះនៃ "ការសិក្សាវែងឆ្ងាយ" (ការសិក្សាអស់មួយជីវិត) ការធ្វើការសម្រេចចិត្តដោយឯករាជ្យ និងការអភិវឌ្ឍវប្បធម៌របស់បុគ្គលក៏ដូចជាសង្គម (ដកស្រង់ពី គេហទំព័រ UNESCO ឆ្នាំ ១៩៧២)។

ដូច្នេះបណ្ណាល័យសាធារណៈត្រូវបានទទួលស្គាល់ថា "ជាគ្រឹះស្ថានសិក្សាអស់មួយជីវិត" ដែលបានផ្ដល់ឱកាសនៃការសិក្សាដល់ជនគ្រប់រូបនៅក្នុងបរិបទជាសកល។

ក្នុងសេចក្ដីថ្លែងការណ៍ដដែលនេះ សេវាកម្មនៃបណ្ណាល័យសាធារណៈគឺ "ការផ្ដល់នូវសមភាពជាមូលដ្ឋានក្នុងការទទួលយកនូវការសិក្សាសម្រាប់ទាំងអស់គ្នា ដោយមិនគិតពីអាយុ ជាតិសាសន៍ ភេទ សាសនា សញ្ជាតិ ភាសា ឬឋានៈនៅក្នុងសង្គមឡើយ"។ សេចក្ដីថ្លែងការណ៍បានបញ្ជាក់ផងដែរថា "សេវាកម្ម និងសម្ភារ ពិសេសត្រូវតែបានផ្ដល់ដល់ជនគ្រប់រូប ទោះបីជាជននោះ ពុំមានលទ្ធភាពនឹងទទួលយកក្នុងហេតុផលណាក៏ដោយ"។ ឧទាហរណ៍: ភាសារបស់ជនជាតិភាគតិច ជនដែលបាត់បង់កាយសម្បទា មនុស្សនៅក្នុងមន្ទីរពេទ្យ ឬពន្ធនាគារ ។ ចេញពីសេចក្ដីថ្លែងការណ៍នេះ បង្ហាញឱ្យឃើញថា បណ្ណាល័យសាធារណៈ គឺជាគ្រឹះស្ថានអប់រំ ដែលបើកចំហចំពោះជនដែល ទទួលការគម្រាមកំហែងលើសិទ្ធិភាសារបស់ខ្លួន និងមានការលំបាកក្នុងការអានភាសារបស់ខ្លួន ។

សមភាពក្នុងការផ្ដល់សេវាកម្មបណ្ណាល័យសាធារណៈ បានដើរតួយ៉ាងសំខាន់ក្នុងការនាំមកនូវព័ត៌មាននៃវប្បធម៌ទាំងឡាយ ដូច្នេះមនុស្សទាំងអស់នឹងត្រូវបានកាត់បន្ថយនូវគម្លាតនៃការទទួលយកព័ត៌មានដោយប្រើប្រាស់ឱកាសនៃការសិក្សាសម្រាប់ទាំងអស់គ្នា។

ហេតុនេះបណ្ណាល័យសាធារណៈ គឺជាគ្រឹះស្ថានសមរម្យមួយសម្រាប់ "បណ្ដុះបណ្ដាលជីវិតដែលជាគោលដៅនៃការផ្សព្វផ្សាយការអាន" ។

៣. បណ្ណាល័យសាធារណៈ និងបណ្ណាល័យតាមសាលារៀន ឬបន្ទប់អាន

បណ្ណាល័យ គឺជាកន្លែងដ៏ល្អបំផុតមួយដើម្បីអនុវត្តការផ្សព្វផ្សាយការអាន។ ដោយអនុលោមទៅតាមតួនាទីរបស់បណ្ណាល័យ គេអាចបែងចែកបណ្ណាល័យជាពីរប្រភេទ គឺបណ្ណាល័យសាធារណៈ និងបណ្ណាល័យសាលារៀន ឬបន្ទប់អាន។ បណ្ណាល័យសាធារណៈ ត្រូវបានគេបង្កើតនៅក្នុងសហគមន៍ ដើម្បីប្រើប្រាស់ជាសាធារណៈ រីឯបណ្ណាល័យសាលារៀន ឬ បន្ទប់អាន ត្រូវបានបង្កើតនៅតាមសាលារៀន សម្រាប់ប្រើប្រាស់ជាពិសេសគ្រូ និង សិស្ស។



www.elibraryofcambodia.org

នៅឆ្នាំ ១៩៩៩ អង្គការ UNESCO បានប្រកាសនូវសេចក្តីថ្លែងការណ៍របស់អង្គការ UNESCO/IFLA ស្តីពីបណ្ណាល័យសាលារៀនដោយគាំទ្រទៅលើគោលការណ៍នៃសេចក្តីថ្លែងការរបស់អង្គការ UNESCO ចំពោះបណ្ណាល័យសាធារណៈ ។

ការផ្សព្វផ្សាយការអាននៅតាមបណ្ណាល័យសាធារណៈ មានសារប្រយោជន៍យ៉ាងសំខាន់ ក្នុងការប្រតិបត្តិសកម្មភាពទាំងឡាយជូនដល់ជនគ្រប់រូបនៅក្នុងសហគមន៍ ។ បណ្ណាល័យសាធារណៈក៏ផ្តល់ផងដែរ នូវសេវាកម្មចំពោះកុមារមិនទាន់បានចូលរៀន អនក្ខរជន និង ជនពិការ ។

ផ្ទុយទៅវិញការផ្សព្វផ្សាយការអាននៅបណ្ណាល័យសាលារៀន ឬបន្ទប់អាន ផ្តល់សេវាកម្មស្មើភាពចំពោះសិស្សានុសិស្សគ្រប់កម្រិតអាយុទាំងអស់ ។

មុខងារផ្សព្វផ្សាយការអាននៅក្នុងបណ្ណាល័យត្រូវបានរកឃើញថាមានបីទិដ្ឋភាព:

១. ការសិក្សាអស់មួយជីវិត

២. សកម្មភាពទំនាក់ទំនងក្នុងសហគមន៍

៣. ភាពជោគជ័យនៃវប្បធម៌ប្រពៃណី ។

- <u>មុខងារទី១</u> : ការសិក្សាអស់មួយជីវិត

បណ្ណាល័យជាមជ្ឈមណ្ឌលសិក្សាអស់មួយជីវិត និងជាគ្រឹះស្ថានអប់រំ សម្រាប់ជនគ្រប់រូបដែលធានាលើការការពារសិទ្ធិនៃការអប់រំរបស់គេ ។ វាមានភាពខុសគ្នាពីការអប់រំក្នុងប្រព័ន្ធ ដែលជាស្ថាប័នអប់រំមួយផ្សេងទៀតគឺការគោរព "ស្វ័យភាពនៃការចូលរួម និងសិក្សា" ។ វាគ្មានការប្រឡង ឬការទន្ទេញចាំមាត់នោះទេ ។ ពួកគេអាចមកកាន់បណ្ណាល័យនៅពេលណាក៏បាន ហើយអាចជ្រើសរើសសៀវភៅអានណាមួយក៏បាន តាមដែលគេចូលចិត្ត ។

ការសិក្សាដោយរីករាយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការអភិវឌ្ឍសតិបញ្ញារបស់កុមារ ។ កុមារខ្លះអាចស្រមើស្រមៃ និងសុបិនថាខ្លួនគេជាវីរបុរស ឬវីរនារី ដូចជាតួអង្គនៅក្នុងសៀវភៅដែលគេពេញចិត្តបំផុត ។

កុមារខ្លះទៀតអាចអភិវឌ្ឍវាក្យស័ព្ទ និង សំនួនវោហារស័ព្ទផ្ទាល់របស់គេ ដោយសួរសំណួរពិបាកៗទៅឪពុក ម្តាយ លោកគ្រូ អ្នកគ្រូ និងបណ្ណារក្សជាញឹកញាប់ ។ បទពិសោធដោយប្រយោលតាមរយៈសៀវភៅជួយដល់ការអប់រំដោយខ្លួនឯងរបស់កុមារ រួមជាមួយនឹងបទពិសោធផ្ទាល់ដែលកុមារទទួលបានពីធម្មជាតិ និងសង្គមមនុស្ស ។

ចេញពីទស្សនវិស័យទាំងនេះ ការផ្សព្វផ្សាយការអាននៅបណ្ណាល័យបង្ហាញពីសកម្មភាព ដែលជួយដល់ "ការសិក្សាអស់មួយជីវិត" និង "អភិវឌ្ឍភាពឈ្លាសវៃ" របស់កុមារតាំងពីកុមារភាពតាមរយៈបទពិសោធដោយប្រយោលជាមួយការអានកំសាន្ត និង រឿងនិទាន ។



www.elibraryofcambodia.org

- <u>មុខងារទី២</u> : ទំនាក់ទំនងរវាងអ្នកប្រើប្រាស់ ( អាន ) ជាមួយបណ្ណារក្ស/លោកគ្រូ អ្នកគ្រូ

មុខងារដ៏សំខាន់បំផុតនៃការផ្សព្វផ្សាយការអាននៅតាមបណ្ណាល័យ គឺការទំនាក់ទំនងជាមួយមនុស្ស ។ ក្នុងករណីនេះ បណ្ណារក្ស និងលោកគ្រូ អ្នកគ្រូរៀបចំសកម្មភាពផ្សព្វផ្សាយផ្សេងៗ ដូចជាការនិទានរឿង ក៏ដូចជាសេវាកម្ម បណ្ណាល័យតាមបែបបទលំដាប់លំដោយ ។

ក្នុងវិធីសាស្ត្រផ្សព្វផ្សាយការអាន បណ្ណារក្ស និងលោកគ្រូ អ្នកគ្រូដើរតួយ៉ាងសំខាន់ដោយនាំយកការសប្បាយរីករាយនៃការអាន និងសិក្សាជូនដល់មនុស្សទាំងឡាយដែលបានចូលរួម ។ បណ្ណារក្ស និងលោកគ្រូ អ្នកគ្រូត្រូវមានទំនាក់ទំនងជាមួយអ្នកចូលរួមតាមរយៈការសម្លឹងមើលភ្នែករបស់ពួកគេ ការជជែក និងការចែករំលែកវប្បធម៌នៃការអាន ដោយមិនត្រឹមតែជាមួយកុមារប៉ុណ្ណោះទេ គឺត្រូវរាប់បញ្ចូលទាំងសហគមន៍មូលដ្ឋាន និងលោកគ្រូ អ្នកគ្រូផងដែរ ដែលធ្វើឱ្យសកម្មភាពបណ្ណាល័យកាន់តែសម្បូរបែប ។

- <u>មុខងារទី៣</u> : ភាពជោគជ័យនៃវប្បធម៌ប្រពៃណី

ការផ្សព្វផ្សាយការអាន ផ្តល់ផលប្រយោជន៍សំខាន់ចំពោះមនុស្សទាំងឡាយដែលប្រកាន់ខ្ជាប់នូវប្រពៃណីរបស់ខ្លួន ចេះគោរព និងទទួលស្គាល់វប្បធម៌ផ្សេងៗទៀត ។ ដើម្បីសម្រេចគោលដៅនេះ ការផ្សព្វផ្សាយភាសាកំណើត ត្រូវបានគេទទួលស្គាល់ថាជាសកម្មភាពមូលដ្ឋាន ដូចជាការគោរពប្រពៃណី និង វប្បធម៌របស់ជាតិសាសន៍នីមួយៗ ។ បណ្ណាល័យបានថែរក្សាមរតកវប្បធម៌សង្គមដល់មនុស្សគ្រប់ជំនាន់ ។

ឧទាហរណ៍: ការស្តាប់រឿងនិទាន និងចម្រៀងដែលបន្សល់ពីជំនាន់មួយទៅជំនាន់មួយ ទៅតាមវ័យរបស់មនុស្ស និងការអភិវឌ្ឍរឿងព្រេងនិទាន ជាល្ខោនក្រដាសត្រូវបានរៀបចំឡើង ដើម្បីថែរក្សាវប្បធម៌ប្រពៃណី ។ រឿងព្រេងនិទាន និងចម្រៀងទាំងនេះបង្កប់នូវចំណេះដឹង ប្រពៃណី មេរៀន និងក្រមសីលធម៌ របស់មនុស្សជាតិទូទៅ ។ ដូច្នេះវប្បធម៌ទាំងឡាយដែលចេញពីជនជាតិ និងប្រទេសនានា អាចផ្តល់ឱកាសនូវការគោរពប្រតិបត្តិវប្បធម៌ដោយឡែកៗពីគ្នា ដូចជាការបត់ក្រដាសនឹងនាំមកនូវភាពសប្បាយរីករាយក្នុងការបង្កើតរបស់ផ្សេងៗដែលចេញពីសន្លឹកក្រដាស ។

ខ. សារៈសំខាន់នៃការផ្សព្វផ្សាយការអាន

កុមារដែលមិនបានទទួលការអប់រំពីតូច នៅពេលធំឡើងគេពុំបានទទួលឥទ្ធិពលពីការអប់រំ ។ ដូច្នេះពួកគេពុំមានបទពិសោធពីការសិក្សា ។ នេះជាមរតកដ៏គ្រោះថ្នាក់មួយ ដែលជះឥទ្ធិពលបន្តទៅមនុស្សជំនាន់ក្រោយទៀត ។ កុមារមិនអាចស្ថិតនៅជាកុមារភាពជារៀងរហូតឡើយ ។ ដូច្នេះ ក្នុងវ័យកុមារភាព ការការពារសិទ្ធិនៃការអប់រំ ក៏ដូចជាសុខភាព វាមានសារៈសំខាន់ចំពោះការអភិវឌ្ឍជាមូលដ្ឋានរបស់មនុស្សជាតិ ព្រោះមនុស្សអាចមានសមត្ថភាពក្នុងការគិត និងច្នៃប្រឌិតតាំងពីកុមារភាព ។



www.elibraryofcambodia.org

### ១. ការអានគឺជាអ្វី?

ការអាន ជាសកម្មភាពមួយដែលមិនអាចខ្វះបានចំពោះមនុស្សគ្រប់ៗរូប ក្នុងន័យដើម្បីទទួលបានអក្ខរភាព បង្កើនទូវភាពឈ្លាសវៃ និងស្តែងចេញនូវមនោសញ្ចេតនា បង្កើនឥទ្ធិពលក្នុង ការស្រមើស្រមៃ និងសមត្ថភាពសិក្សា ដើម្បីធ្វើឱ្យជីវិតកាន់តែប្រសើរឡើង ។ ការចាប់ផ្តើមការអានពីវ័យក្មេង អាចបណ្តុះ "បំណិនជីវិត" ដែលនាំឱ្យគេចេះគិត យល់ដឹង និងធ្វើការសម្រេចចិត្តក្នុងជីវិតរបស់គេកាន់តែប្រសើរឡើង ។

ជាគោលការណ៍ ឱកាសនៃការសិក្សាអំពី "បំណិនជីវិត" ដែលមនុស្សទទួលបានតាមរយៈការអានត្រូវបានផ្តល់ដល់ជនគ្រប់រូបដោយស្មើភាព ដោយមិនគិតថាមនុស្សទាំងនោះកំពុងរស់ក្នុងប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍ឡើយ ។

### ២. សិទ្ធិក្នុងការរៀនសូត្រ

នៅឆ្នាំ ១៩៨៥ សន្និបាតអន្តរជាតិលើកទី៤ របស់អង្គការ UNESCO ស្តីពី ការអប់រំសម្រាប់មនុស្សពេញវ័យ បានថ្លែងថា "សិទ្ធិនៃការសិក្សា គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានរបស់មនុស្សដែលមិនអាចខ្វះបាន" ។ យោងតាមសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិនៃការសិក្សាគឺ:

- សិទ្ធិក្នុងការអាន និង សរសេរ
- សិទ្ធិក្នុងការសួរ និង វិភាគ
- សិទ្ធិក្នុងការស្រមើស្រមៃ និង ច្នៃប្រឌិត
- សិទ្ធិក្នុងការអានព័ត៌មានពិភពលោក និង សរសេរប្រវត្តិសាស្ត្រ
- សិទ្ធិក្នុងការទទួលបានធនធានផ្សេងៗនៃការអប់រំ
- សិទ្ធិក្នុងការអភិវឌ្ឍបំណិនជាបុគ្គល និង សមូហភាព ។

សេចក្តីថ្លែងការណ៍នេះបានបញ្ជាក់យ៉ាងច្បាស់ថា "ការសិក្សា" មិនមែនជាវប្បធម៌ឆើតឆាយ ឬជាសិទ្ធិដែលកើតឡើងក្រោយពីតម្រូវការការពារជាមូលដ្ឋាននោះទេ ។ ម្យ៉ាងទៀតក៏មិនមែនជាសិទ្ធិដាច់មុខចំពោះបុគ្គលដែលមានឯកសិទ្ធិណាម្នាក់មកបែងចែកពីភេទ អាយុ និងឋានៈ ក្នុងសង្គមឡើយ ។

សិទ្ធិនៃការអប់រំ ត្រូវបានធានាចំពោះជនគ្រប់រូប នៅគ្រប់ពេលវេលា និង គ្រប់ទីកន្លែងក្នុងជីវិតរបស់គេ ។

#### ២.១ អនុសញ្ញាស្តីពីសិទ្ធិកុមារ

អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៨៩ បានថ្លែងថាកុមារមានសិទ្ធិដូចមនុស្សពេញវ័យ ហើយសិទ្ធិនេះត្រូវបានទទួលស្គាល់ និងឱ្យគោរពស្មើភាពគ្នាដូចជាមនុស្សពេញវ័យផងដែរ ។ កុមារអាចទាមទារសិទ្ធិនៃការអភិវឌ្ឍ និងការការពារសុវត្ថិភាពសង្គមដោយអនុលោមទៅតាមការវិវឌ្ឍ



www.elibraryofcambodia.org

កាយសម្បទា និង សតិបញ្ញារបស់គេ ។

សិទ្ធិនៃការអប់រំ ជាមជ្ឈមណ្ឌលសន្តិសុខនៃរូបកាយ និង សតិបញ្ញា។ លោក ជេ ពីអាចេត (Mr. J. Piajet) ជាអ្នកដឹកនាំនៃចលនាអប់រំថ្មីអន្តរជាតិ បានពន្យល់ថាកត្តាសំខាន់បំផុតដែលមនុស្សមាន គឺការអភិវឌ្ឍរបស់បុគ្គលម្នាក់ៗបានមកពីការសិក្សា មិនមែនបានមកពីមរតកតំណពូជ សង្គម និង វិស័យអប់រំដែលមានលក្ខណៈផ្សេងៗគ្នានៃការអភិវឌ្ឍនៅក្នុងដំណាក់កាលណាមួយនៃការអភិវឌ្ឍនោះទេ ។

អនុសញ្ញាស្តីពីសិទ្ធិកុមារបានប្រកាសថាគ្រប់កុមារទាំងអស់ដែលមានអាយុក្រោម១៨ឆ្នាំ មានសិទ្ធិទទួលការអប់រំ ( មាត្រា ១ និង ២៨ ) ។

- គោលដៅនៃការអប់រំ :

អភិវឌ្ឍបុគ្គលិកលក្ខណៈរបស់កុមារ ការប៉ិនប្រសប់ សតិបញ្ញា និង សម្បទាប្រកបដោយសក្តានុពលភាពពេញលេញ។

អភិវឌ្ឍការគោរពសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ដើម្បីជាគោលការណ៍ផ្សេងៗនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។

អភិវឌ្ឍការគោរពសិទ្ធិកុមារពីសំណាក់ឪពុកម្តាយ អត្តសញ្ញាណ វប្បធម៌ ភាសា និងតម្លៃរបស់គេផ្ទាល់ ដើម្បីឱ្យតម្លៃជាតិនៃប្រទេសដែលកុមារកំពុងរស់នៅប្រទេសដែលកុមារចាប់កំណើត និងដើម្បីអរិយធម៌ផ្សេងៗគ្នាពីអរិយធម៌របស់គេផ្ទាល់ ។

ការរៀបចំកុមារក្នុងការទទួលខុសត្រូវជីវិតរបស់ពួកគេនៅក្នុងសង្គមសេរី ក្នុងស្មារតីនៃការយល់ដឹង ពីសន្តិភាព ការអត់ឱន ភាពស្មើគ្នានៃភេទ និងមិត្តភាពជាមួយមនុស្សទាំងអស់ ក្រុមជនជាតិភាគតិច ក្រុមជាតិសាសន៍ ក្រុមសាសនា និងមនុស្សអន្តោប្រាណ ។

អភិវឌ្ឍការគោរពបរិស្ថានធម្មជាតិ ( មាត្រា ២៩ ) បានប្រកាសផងដែរថា ក្រៅពីម៉ោងសិក្សា នៅឯសាលាជាផ្លូវការ កុមារមានសិទ្ធិចូលរួមក្នុងវប្បធម៌នៃការរស់នៅ និងជីវិតសិល្បៈផ្សេងៗ ។

### ២.២ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស

នៅលើពិភពលោក ទោះបីជាមានមនុស្សចេះអាន និងចេះសរសេរ ក៏នៅមានមនុស្សខ្លះស្ថិតក្នុងស្ថានភាពលំបាកចំពោះការអាន និងសរសេរភាសាកំណើតរបស់ខ្លួន ។

ឧទាហរណ៍ :

- ក្រុមអ្នកស្រុកដើម ដែលបានរក្សាទុកអត្តសញ្ញាណកំណើត ភាសា និងវប្បធម៌ដើមរបស់គេអស់រយៈពេលដ៏យូរលង់ណាស់មកហើយ ។

- ជនភៀសខ្លួនដែលសុំការការពារ

- ក្រុមជនជាតិភាគតិចអន្តោប្រវេសន៍



www.elibraryofcambodia.org

- ក្រុមជនដែលមានទិដ្ឋាការស្នាក់នៅរយៈពេលខ្លី និងពលករដែលគេបង្ខំឱ្យធ្វើការ ។

ទោះបីជាពួកគេ ចេះអក្សរ ឬភាសាផ្លូវការនៃប្រទេសដែលពួកគេរស់នៅក៏ដោយ ក៏ពួកគេនៅតែប្រឈមមុខនឹងការលំបាកចំពោះ ការអានភាសាកំណើតរបស់គេ ជាញឹកញាប់ដូចគ្នានឹងការអាន ភាសាជាផ្លូវការផងដែរ ។

ក្នុងមាត្រា ២៧ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយដែលបានលើកឡើងនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៥៦ បានបញ្ជាក់ពីសុវត្ថិភាព នៃភាសាកំណើតរបស់ខ្លួនជាសិទ្ធិរបស់ជនជាតិដើមភាគតិច បានរៀបរាប់ដូចតទៅ:

នៅក្នុងរដ្ឋដែលមានជនជាតិភាគតិចរស់នៅ មនុស្សដែលជាម្ចាស់ស្រុកមិនអាចបដិសេធបានឡើយនូវសិទ្ធិនៃការប្រើប្រាស់ភាសាដើម ការគោរពប្រតិបត្តិ សាសនានៅក្នុងសហគមន៍ដទៃទៀតនៃក្រុមរបស់ពួកគេដែលរីករាយជាមួយនឹងវប្បធម៌របស់គេផ្ទាល់ ។

លើសពីនេះទៀត សេចក្តីប្រកាសជាសកលនៃសិទ្ធិប្រើភាសាត្រូវបានបង្កើតឡើងនៅទីក្រុងបាសេឡូណា (Barcelona) ប្រទេសអេស្ប៉ាញ (Spain) ដែលដឹកនាំដោយគណៈកម្មការអន្តរជាតិនៃការបកប្រែ និងសិទ្ធិនៃការប្រែភាសា ‹ ភ្លឹប ភីអ៊ីអ៊ីន› នៅឆ្នាំ១៩៩៦។ លក្ខណៈពិសេសបំផុតនៃសេចក្តីប្រកាសនេះថាសិទ្ធិនៃការប្រើប្រាស់ភាសាជាសិទ្ធិផ្ទាល់ខ្លួន និង សិទ្ធិរួមដែលគេប្រើប្រាស់ភាសាផ្ទាល់ខ្លួនរបស់ពួកគេនៅជាលក្ខណៈឯកជន និង សាធារណៈដោយគ្មានអន្តរាគមន៍អ្វីទាំងអស់ ។ នៅពេលដែលកំពុងពិចារណាថាសេចក្តីប្រកាសនេះស្ថិតនៅក្នុងការបញ្ចុះបញ្ចូល ដើម្បីអនុម័តនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ ។ ជាការពិតណាស់ដែលថាមានចលនាសកលមួយដើម្បីធ្វើការពិចារណាលើសិទ្ធិនៃការប្រើប្រាស់ភាសា គឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស ក្នុងការសរសេរជាលាយលក្ខណ៍អក្សរ។ ទោះយ៉ាងណាក៏ដោយសេចក្តីប្រកាសជាមូលដ្ឋាននៃសិទ្ធិទាំងនេះ មិនជះឥទ្ធិពលអ្វីទេ ប្រសិនបើគេយកសិទ្ធិទាំងនោះទៅអនុវត្តឱ្យចេញជាសកម្មភាពជាក់ស្តែង។ ការអភិវឌ្ឍរបស់បុគ្គលម្នាក់ៗ ដើម្បីអានយល់ដឹង និង គិតពិចារណាសម្រាប់បង្កើតបានជាសង្គម និងរកឃើញនូវប្រវត្តិសាស្ត្រផងដែរ។ ការអានពិតជាមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយទាំងឡាយដើម្បីធ្វើសកម្មភាពដែលជាប្រយោជន៍សម្រាប់សិទ្ធិមនុស្សទាំងអស់នេះ។

៣. ការអានជាការអភិវឌ្ឍធនធានមនុស្ស

នៅពេលយើងអានសៀវភៅ វាមានគោលបំណងផ្សេងៗ ក្នុងការអាន យើងអាចអានសៀវភៅដើម្បីសប្បាយ ដើម្បីរកមើលអ្វីមួយ និងបង្កើនបញ្ញាជាដើម ។ វប្បធម៌សរសេរខុសប្លែកពីវប្បធម៌រូបភាពបានផ្តល់ឱ្យយើងនូវរបៀបទំនាក់ទំនងសកម្មមួយបែប អាចឱ្យយើងពិចារណាពីបញ្ហានេះបាន សម្រាប់នឹកគិតពីស្ថានភាពមួយ ដើម្បីឯកភាពធ្វើការទិញទៀន និង ដាក់បញ្ចូលនូវគំនិតផ្ទាល់ខ្លួនដទៃទៀត។ រៀនសូត្រអំពីបែបផែននៃការទំនាក់ទំនងទាំងនេះជាបន្តបន្ទាប់ អាចលើកតម្កើងមនុស្សជាតិ ដូចជាភាពរីកចម្រើន សតិបញ្ញា ការសម្រេចដោយសេរីភាពឈ្លាសវៃក្នុងការស្រមើស្រមៃ និងទំនាក់ទំនងសមស្របជាមួយអ្នកដទៃ ។ លើសពីនេះទៀត



www.elibraryofcambodia.org

ការអានផ្តល់នូវឱកាសល្អប្រសើរបំផុត ដើម្បីរៀនសូត្រអំពីពាក្យពេចន៍ទាំងឡាយ ដែលប្រជាជនមិនអាចដឹងបាននៅក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ។ ប្រការនេះ គេអាចនិយាយបានថាពាក្យពេចន៍ ទាំងឡាយដែលកើតចេញពីការអានមានកម្រិត១០ដង ល្អជាងពាក្យពេចន៍ដែលកើតចេញពីការនិយាយប្រចាំថ្ងៃ ។ មនុស្សអាចនឹងធ្វើឱ្យប្រសើរឡើង នូវសមត្ថភាពក្នុងការទាក់ទងរបស់ខ្លួន ជាមួយការប្រើពាក្យពេចន៍ដ៏សម្បូរបែបដើម្បីឱ្យមតិសំដែងចេញរបស់ពួកគេល្អប្រសើរ និងមានទំនាក់ទំនងថ្មែមល្អែមទៀតផង ។

### ៣.១ ការអានដើម្បីអភិវឌ្ឍកុមារភាព

ការថែបំប៉នសុខភាពកុមារ ធ្វើឡើងតាមរយៈការបរិភោគចំណីអាហារ ។ រីឯការអាន និងស្តាប់រឿងបានច្រើនធ្វើឱ្យកុមារកើនឡើងនូវសតិបញ្ញា និងការស្រមើស្រមៃ ព្រមទាំងជួយដល់ការរីកចម្រើនខាងផ្លូវចិត្តទៀតផង ។ ហេតុដូច្នេះ ដើម្បីថែរក្សាសតិបញ្ញា ការអភិវឌ្ឍខាងផ្លូវកាយ និង ផ្លូវចិត្តរបស់កុមារ ចាំបាច់ត្រូវមានការផ្គត់ផ្គង់អាហារគ្រប់គ្រាន់ ការផ្តល់បទពិសោធផ្ទាល់ទាំងឡាយ ក្នុងបរិស្ថានធម្មជាតិ ក្នុងសង្គមមនុស្ស និងការផ្តល់បទពិសោធដោយប្រយោលតាមរយៈការស្រមើស្រមៃក្នុងពិភពសៀវភៅរឿង ។

ចំពោះកុមារ ការស្រមើស្រមៃជាមនោគតិក្នុងពិភពសៀវភៅរឿងព្រេងទាំងឡាយ សម្រាប់ការសប្បាយប៉ុណ្ណោះ មិនផ្តល់ប្រយោជន៍ជាមេរៀនអ្វីទេ ។ រឿងនិទានដែលចាប់អារម្មណ៍ធ្វើឱ្យកុមារមានការ ចងចាំរឿងទាំងនោះ និងមានចិត្តចង់អាន។ កុមារអាចអភិវឌ្ឍសតិបញ្ញារបស់ខ្លួន ដូចជាសេចក្តីសង្ឃឹម សេចក្តីក្លាហានភាពជឿជាក់ ការជួយសង្គ្រោះ ការស្ងើចសរសើរ ការស្រមើស្រមៃ បទពិសោធខាងផ្លូវអារម្មណ៍ និងផ្លូវចិត្តផ្ទៃកមនោសញ្ចេតនាក្នុងសៀវភៅរឿងទាំងឡាយនោះ ។ ភាពស្ទាត់ជំនាញទាំងនេះ បានជួយលើកទឹកចិត្តកុមារដើម្បីពុះពារជាមួយការលំបាកនឹងមានសិទ្ធិអំណាចក្នុងការរស់នៅ ។ កុមារដែលមានបទពិសោធជាច្រើនក្នុងការអានសៀវភៅអាចយល់ដឹងបានអំពីក្តីសប្បាយរីករាយទៅលើការអានសៀវភៅ ហើយមានទម្លាប់ក្នុងការអានទៀតផង ។

ពេលកុមារមានបទពិសោធច្រើន វាហាក់ដូចជាធ្វើឱ្យត្រេកអរ សប្បាយរីករាយ និងនាំឱ្យមានសុភមង្គលហើយពួកគេអាចនឹងចូលរួមចែករំលែកអ្វីដែលមានក្នុងអារម្មណ៍ចំពោះអនាគតរបស់ខ្លួនថែមទៀត ។

### ៣.២ សមត្ថភាពកើតចេញមកពីការអាន

- ការគិត ... ពង្រីកចំណេះដឹងជាមូលដ្ឋាន និង រៀនសូត្រពីសារៈសំខាន់ក្នុងការសួរសំណួរ
- ការស្រមើស្រមៃ ... ពិភពដែលនាំឱ្យចេះអក្សរដោយការស្រមើស្រមៃ និង មានការយល់ចិត្ត
- ការស្តាប់ ... ការស្តាប់រឿង
- និយាយ ... បង្កើនពាក្យពេចន៍ ជាការសិក្សាភាសាផ្ទាល់ខ្លួនបានត្រឹមត្រូវ និងចាប់ផ្តុងចូនឱ្យបានល្អដើម្បីធ្វើទំនាក់ទំនងជាមួយអ្នកដទៃ



www.elibraryofcambodia.org

- ការអាន ... ស្ម័គ្រចិត្តអានសៀវភៅ
- អារម្មណ៍ធុញទ្រាន់ ... អារម្មណ៍ផ្សេងគ្នាពេលចេញពីសាលារៀន ។

ទទួលបានសមត្ថភាពដែលចែងពីចំណុចខាងលើ អាចជួយឱ្យកុមារមានឥរិយាបថ ប្រសើរឡើងចំពោះការរៀនសូត្រ និងបង្កើនមិត្តភាពជាមួយលោកគ្រូ អ្នកគ្រូ ។



www.elibraryofcambodia.org

## II. បណ្ណាល័យ

### ក. និយមន័យបណ្ណាល័យ

បណ្ណាល័យគឺជាឃ្លាំងផ្ទុកនូវចំណេះដឹង និងចំណេះវិជ្ជាសព្វបែបយ៉ាង ដូចជាសៀវភៅ គម្ពីរ ក្បួនច្បាប់ កំណត់ត្រា ព្រឹត្តិការណ៍ផ្សេងៗ ដែលបញ្ញវ័ន្ត អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រខិតខំសិក្សាស្រាវជ្រាវ សរសេរចងក្រង គូរ ថត ផលិតទុកជាស្នាដៃកេរដំណែលសម្រាប់ឱ្យកូនចៅជំនាន់ក្រោយរៀនសូត្រ ចេះដឹងដើម្បីជាទុនធ្វើការ សិក្សាស្រាវជ្រាវបន្ត បង្កើតនូវអ្វីដែលថ្មី ឬយ៉ាងហោចណាស់យកការចេះដឹងនេះទៅអនុវត្តក្នុងជីវភាពរស់នៅរបស់ពួកគេ។

វាក៏ជាកន្លែងសម្រាប់កុមារអាន ស្រាវជ្រាវ និង ជាកន្លែងផ្តល់បរិយាកាសសប្បាយរីករាយ ដោយមានសកម្មភាពនិទានរឿង បត់រូប គូរគំនូរ សិល្បៈងាយៗ ដែលអាចជួយជំរុញបន្ថែមដល់កុមារឱ្យចង់អាន ចង់មករៀន និង មានចំណេះដឹងទូលាយ ជួយកាត់បន្ថយអត្រាត្រួតថ្នាក់ និង បោះបង់ការសិក្សារបស់កុមារ។

### ខ. កិច្ចការ និងមុខងារបណ្ណាល័យ

កិច្ចការ និង មុខងារចម្បងរបស់បណ្ណាល័យ គឺផ្សារភ្ជាប់រវាងសៀវភៅ និងមនុស្ស ។ មានចំណុចជាច្រើនដែលទាក់ទងលើកិច្ចការ និង មុខងារ ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងនូវសេវាកម្មបណ្ណាល័យ:

១. ការផ្សព្វផ្សាយព័ត៌មានបណ្ណាល័យ

❑ មុខសញ្ញា ឬ សមាសភាព

- អ្នកប្រតិបត្តិ: បណ្ណារក្ស

- អ្នកដឹកនាំ និងអ្នកចូលរួម: ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋាន មន្ទីរ ការិយាល័យ សាលា និង អ្នកពាក់ព័ន្ធ

- អ្នកប្រើប្រាស់: គ្រូ សិស្ស បុគ្គលិក សហគមន៍

❑ ខ្លឹមសារនៃការផ្សព្វផ្សាយ ( ផ្ទាល់មាត់ ការជូនដំណឹង និង របាយការណ៍ )

- ផលប្រយោជន៍បណ្ណាល័យ និង ការអាន: បង្កើនចំណេះដឹង និង ទម្លាប់ក្នុងការអាន

- ព័ត៌មានផ្សេងៗស្តីពីការងារបណ្ណាល័យ: ធនធាន ឯកសារ សម្ភារ សកម្មភាព ឬកម្មវិធីនានា ពេលម៉ោងធ្វើការ និង បទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យ ...។

- របាយការណ៍ពីការលំបាករបស់បណ្ណាល័យ: បច្ចេកទេសការងារ កង្វះខាតឯកសារ សម្ភារ ខ្វះការជួសជុល ការខ្វះខាតផ្សេងៗ និងការចូលរួមគាំទ្រពីនាយក គ្រូ សិស្ស សហគមន៍ អង្គការជាតិ អង្គការអន្តរជាតិលើការងារបណ្ណាល័យ ។



www.elibraryofcambodia.org

២. ការទំនាក់ទំនងជាមួយសាធារណជន

- ការទទួលភ្ញៀវ: អាកប្បកិរិយា និង ការអនុវត្តរបស់បណ្ណារក្ស
- ការឆ្លើយតបរាល់សំណួរផ្សេងៗ: ការស្នើជួយពីកុមារ និង តម្រូវការឯកសារ
- សេវាកម្ម: ការផ្ដល់ឯកសារអាននៅនឹងកន្លែង ការខ្ចី សង
- ការបង្រៀនកុមារ: ពីរបៀបស្វែងរក និងប្រើប្រាស់ឯកសារ
- សកម្មភាពផ្សេងៗ: និទានរឿង គូររូប បត់រូប សិល្បៈ ចម្រៀង និង ពិព័រណ៍សៀវភៅ ។

គ. ប្រវត្តិបណ្ណាល័យ

១. បណ្ណាល័យនៅលើពិភពលោក

បណ្ណាល័យបង្កើតមុនគេ គឺនៅ "បាប៊ីឡោន" តាមរយៈកាកសំណល់ ដូចជាកំទេចក្បឿង ដុំឥដ្ឋ គឺនៅស.វ ២១មុនគ.ស ។ នៅប្រទេសអេហ្ស៊ីបតាមរយៈអ្នកនិពន្ធជនជាតិក្រិក ម្នាក់ឈ្មោះ ឌីយូដូរូស ស៊ីគូឡូស (Diodorus Siculus) បានអធិប្បាយអំពីកាតាឡុកបណ្ណាល័យរបស់ស្ដេច រ៉ាមសែស Ramses III ឆ្នាំ១២០០ មុនគ.សនៃ Assurbanipal នៅតំបន់ Nineveh ដែលបានកត់សម្គាល់ពី អាឡិចហ្សង់ដ្រា Alexandria ។ តាមប្រាសាទនៅហ្សេរូសាឡឹម Jerusalem មានប្រាសាទដ៏ពិសិដ្ឋ (Sacred) មួយ ។ បណ្ណាល័យសាធារណៈដែលគេបង្កើតជាលើកដំបូងនៅប្រទេសក្រិកក្នុងឆ្នាំ៣៣០ មុនគ.ស ដើម្បីការពារកិច្ចការស្នាដៃល្បោន (Great Dramatists ) ។ ក្នុងចំណោមបណ្ណាល័យបុរាណនោះ បណ្ណាល័យអាឡិចហ្សង់ដ្រា Alexandria ល្បីជាងគេ ដែលបានកសាងដោយ (PtoLemyl) ក្នុងនោះមានឯកសារក្រិកចំនួន ៧០០.០០០។ បណ្ណាល័យនៅភើហ្គាមូម Pergamum ចំណាយក្នុងការកសាងដោយ អ៊ឺម៉ែនីស II ជាគូប្រជែងនឹង Alexandria ។

បណ្ណាល័យនៅក្រុងរ៉ូមត្រូវនាំយកពីប្រទេសក្រិកនៅតំបន់ Asia Minor និងប្រទេសស៊ីរីជាលទ្ធផលមួយនៃការច្បាំងដណ្ដើមគ្នានៅក្នុង ស.វ ទី១ និង ស.វ ទី២មុន គ.ស ។

បណ្ណាល័យ Caius Asinius Pollio បានបង្កើតនៅឆ្នាំ ៤០ មុនគ.ស គឺជាបណ្ណាល័យសាធារណៈដំបូងគេនៅប្រទេស រ៉ូម៉ាំង ។ ប៉ុន្តែបណ្ណាល័យសាធារណៈដែលធំ និងល្បីជាងគេនៃចក្រភពរ៉ូម៉ាំង ឈ្មោះ អុកតាវីយ៉ង់ Octavian ដែលបានខូចខាតនៅ ឆ្នាំ ៨០នៃ គ.ស ហើយបណ្ណាល័យឈ្មោះ បាឡាទីន Palatine បានខូចខាត នៅឆ្នាំ ១៩០នៃគ.ស។ បណ្ណាល័យដែលសំខាន់ជាងគេនោះគឺបណ្ណាល័យ Ulpian ដែលកសាងក្នុងរជ្ជកាល Trajan ។ លើសពីនេះ នៅមានបណ្ណាល័យឯកជនល្អៗច្រើនទៀត នៅពេលដែលបណ្ណាល័យសាធារណៈរបស់ចក្រភពរ៉ូមបានបាត់បង់នៅឆ្នាំ មុនគ.ស ហើយនៅសេសសល់តែកំទេចបាក់បែកនៅតំបន់ Herculaneum ។

បណ្ណាល័យផ្នែកគ្រិស្តសាសនាដំបូងគេ គឺនៅក្នុងវិហារគ្រិស្តសាសនាដែលគេបានប្រមូលផ្ដុំនូវការប្រសិទ្ធិពរជ័យនៅវិហារ Mote Cassino ។ ប្រទេសរ៉ូម៉ាំងបាននាំយកសៀវភៅទៅប្រទេសអង់គ្លេស ប៉ុន្តែបណ្ណាល័យវិហារសំខាន់ដំបូងគេបានកសាងឡើងនៅទីក្រុងយ៉កវៀរមូត York Wearmouth កង់តែប៊ូរី Canterbury និងទីកន្លែង



www.elibraryofcambodia.org

ផ្សេង១ទៀតក្នុងប្រទេសអង់គ្លេស និងប្រទេសអៀកឡង់ ដោយព្រះសង្ឃប្រើភាសាអង់គ្លេស (Anglo-Saxon) ។ អត្ថបទល្អជាងគេ គឺកម្រងអត្ថបទ Illumination ដែលបាននិពន្ធឡើងនៅក្នុងបណ្ណាល័យទាំងនេះ ។ លោកសន្តបុគ្គលគូឡូមបង់ (St.Columban) និងសហការីផ្សេងទៀតបានស្ថាបនាបណ្ណាល័យ ក្នុងព្រះវិហារគ្រិស្តសាសនានៅសតវត្សទី៦ ។ អត្ថបទក្រិក និងអត្ថបទឡាតាំងដែលបុរាណជាងគេ ហើយដែលបានថែរក្សាទុករហូតមកដល់សម័យទំនើប គឺរក្សាទុកនៅបណ្ណាល័យ Medieval European Monastory Libraries ។

ការប្រមូលផ្តុំ និងការរក្សាបណ្ណាល័យអារ៉ាប់នៅក្នុងស.វទី៩-១៥ ជនជាតិជ្វីស (Jews) និង ប៊ីហ្សង់ទីនក៏បានអភិវឌ្ឍបណ្ណាល័យល្អ១ផងដែរ នៅក្នុងមជ្ឈិមសម័យ ( Medieval period ) ។ នៅ ស.វ ទី១៤ និងទី១៥ ស្តេចឆាលទី V (Charles V) នៃប្រទេសបារាំង Lerenzo de'Medici & Frederick , duke of urbino អ្នកទាំងនោះបានបង្កើតបណ្ណាល័យល្អ១ ជាច្រើនដែលជាផ្នែកនៃបណ្ណាល័យ Urbino ឥឡូវស្ថិតនៅក្នុងបណ្ណាល័យប្រទេសវ៉ាទីកង់ ។

នៅ ស.វ ទី ១៥ បណ្ណាល័យវ៉ាទីកង់ ជាបណ្ណាល័យចាស់ជាងគេនៅទ្វីបអឺរ៉ុប ។ លោកផ្លាទីណា Platina ជាបណ្ណារក្សដំបូងគេនៅឆ្នាំ ១៤៧៥ ដែលបានបង្កើតកាតាឡុករួមបញ្ចូលទាំងអត្ថបទ ២៥២៧ ខ្សែ (Volumes) ។ នៅឆ្នាំ ១២៥៧ បណ្ណាល័យ Sorbonne នៅទីក្រុងប៉ារីសត្រូវបានបង្កើតឡើង ។ ឆ្នាំ ១៥២៥ បណ្ណាល័យ (Laurentien) បានបង្កើតឡើងនៅទីក្រុង Florence ដែលគូរប្លង់ (Designed) ដោយលោក មីឆែលេនហ្សេឡូ (Michelangelo) ហើយបណ្ណាល័យល្បី១នៅតាមសាកលវិទ្យាល័យជាច្រើន ត្រូវបានបើកឱ្យប្រើប្រាស់នៅ ស.វ ទី ១៤ ដូចជា ( Pologna, Prague, Oxford និង Heidelberg ) ។

នៅសហរដ្ឋអាមេរិក បណ្ណាល័យបានរីកសាយភាយនៅ Philadelphia នៅឆ្នាំ ១៧៣២ បានប្រារព្ធឡើងនៅ Benjamin Franklin ។ ទោះជាយ៉ាងណាក៏ដោយ បណ្ណាល័យសាធារណៈបានបើកនៅទីក្រុង Boston ដំបូងនៅឆ្នាំ ១៦៥៣ ។ ហើយបណ្ណាល័យពីដើម១ផ្សេងទៀតព្រមទាំងបណ្ណាល័យនៅ Boston Athenaeum បណ្ណាល័យសង្គមនៅ New York និង បណ្ណាល័យសង្គមនៅ Charleston ។ ក្នុងឆ្នាំ ១៨៣៣ ការយកពន្ធលើកទីមួយដើម្បីជួយដល់បណ្ណាល័យនៅក្នុងប្រទេសបើកនៅ Peterborough ។ សមាគមបណ្ណាល័យអាមេរិកត្រូវបានបង្កើតក្នុងឆ្នាំ ១៨៧៦ ហើយអង្គការនេះពង្រឹងក្នុងវិធីសាស្ត្រគ្រប់គ្រងបណ្ណាល័យ និង បណ្តុះបណ្តាលបណ្ណារក្ស ។

បណ្ណាល័យនៅសហរដ្ឋអាមេរិក និង ចក្រភពអង់គ្លេស (Great Britain) ទទួលផលប្រយោជន៍យ៉ាងធំសម្បើមពីការចំណាយរបស់ Andrew Carnegie ដែលជាអ្នកផ្តល់លុយលើសពី ៦៥លានដុល្លា សម្រាប់សាងសង់អគារបណ្ណាល័យសាធារណៈ ហើយជួយពង្រឹងដល់ការគាំទ្របណ្ណាល័យជាសាធារណៈក្នុងចំណោមអ្វីដែលប្លែកថ្មី១នៅចុងស.វ ទី ១៩ គឺការយកសៀវភៅអានដោយសេរី ( ទាក់ទងនឹងគ្រោងការចាត់ថ្នាក់សៀវភៅយ៉ាងល្អិតល្អន់ ) ហើយសាខាបណ្ណាល័យដាក់តាមស្ថានីយសៀវភៅច្រើនកន្លែងនៅក្នុងទីក្រុងនៅដើមស.វទី២០ ។ បណ្ណាល័យចល័ត (Traveling libraries or book mobile ) បានចាប់ផ្តើមនាំយកសៀវភៅទៅដល់អ្នកអានតាមតំបន់ជនបទ ។



www.elibraryofcambodia.org

• Alexandria Arabic A/ Iskandariyah, city (1996 pop.3,328,196), N Egypt នៅលើសមុទ្រមេឌីទែរ៉ាណេប៉ែកខាងលិចនៃដីសណ្ដរទន្លេនីលតាំងនៅ Situate ដីតូចរវាងសមុទ្រ និង បឹង Marcotis (Maryut) ទីក្រុងប្រទេសអេហ្ស៊ីបជាកំពង់ផែ និងជាមជ្ឈមណ្ឌលដឹកជញ្ជូន (មជ្ឈមណ្ឌលពាណិជ្ជកម្ម) ហើយជាបេះដូងនៃសហគ្រាសដ៏ធំដែលផលិតប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នល់ (Asphalt) និង រោងចក្រវាយណភណ្ឌ (cottom textiles) ម្ហូបអាហារក្រដាស និង ក្រដាសផ្លាស្ទិច ។ សាកលវិទ្យាល័យ Alexandria វិទ្យាស្ថាន Alexandria និង សាកលវិទ្យាល័យ AL Azhar ។ នៅក្រុង Cairo មានសាលាតិលានុបដ្ឋាន ឱសថស្ថាន និងមជ្ឈមណ្ឌលវាយណភណ្ឌ ហើយក៏ជាកន្លែងតាំងនៅនៃអង្គការសុខភាពពិភពលោក (WHO) ឯមជ្ឈិមបូព៌ា (Middle East) ។

សារមន្ទីរក្រិក រ៉ូម៉ាំង (Greco-Roman) នៅក្នុងAlexandria នៃបណ្តុំ Coptic ដែលវិចិត្របែបសិល្បៈរ៉ូម៉ាំងក្រិច ។ គន្លិនទេសដែលគួរចាប់អារម្មណ៍នៅ Alexandria មានបណ្ណាល័យ សារមន្ទីរសំណៅចក្រវាឡ (Planetarium) និង បរិក្ខារសម្រាប់កិច្ចប្រជុំ (Conference facilities ) ។ របស់របរជាច្រើនពី Alexandria នៅសម័យបុរាណដែលត្រូវគ្របដណ្ដប់ដោយអគារទំនើបទាន់សម័យ ឬលិចនៅក្នុងទឹក ។ មានទីកន្លែងសម្គាល់តិចតួចដែលបានជួបប្រទះរួមទាំងកម្ទេចបាក់បែកបុរាណនៃ Emporium & Serapeum និង បំណែកថ្មក្រានីត ដែលហៅថា សសរ Pompey ។ គ្មានអ្វីសេសសល់នៃពន្លឺនៅលើ Pharos (3[d] cent.BC) ដែលជារបស់មួយក្នុងចំណោមអច្ឆរិយវត្ថុក្នុងលោកទាំង៧ ហើយជាផ្នែកនៃរាជវាំងដែលនៅក្រោមកំពង់ផែចំណាស់ខាងកើត ។

• **Pergamum** ជាទីក្រុងបុរាណមួយនៅពាយ័ព្យនៃ Asia Minor នៅក្នុងតំបន់ Mysia (Modern Turkey) នៅក្នុងដែនដីមានជីជាតិនៃជ្រលង Caicus ។ វាក្លាយទៅជាទីដ៏សំខាន់នៅឆ្នាំ ៣០០ មុនគ.ស បន្ទាប់ពីការបែកបាក់នៃចក្រភពម៉ាសេដន់ ។ នៅពេលនោះ ក្រិកបានកសាងមជ្ឈមណ្ឌលអារ្យធម៌ដ៏ស្អាតមួយឈ្មោះ Hellenistic ។ វាជាណាចក្រនោះបានទទួលសមិទ្ធិផលដ៏សំខាន់ចម្បង ក្រោមរបបស្ដេច Attalus I (d.1978 BC) Eumenes II (d.160 or 159) & Attalus II (d.138) ។ ស្ដេចទាំងនេះដើរតាមគោលនយោបាយសហរ៉ូម៉ាំងស្ដេចចក្រពត្តិ Philip V នៃចក្រភពម៉ាសេដន់ និងស្ដេច Antiochus III នៃប្រទេសស៊ើរី ។ ឯករាជ្យភាពនៃ Pergamun ត្រូវបានបញ្ចប់យ៉ាងលឿននៅពេលដែលស្ដេច Attalus III (d.133) ទុកកេរ្តិ៍ឱ្យជនជាតិរ៉ូម៉ាំង ។ ភាពល្បីល្បាញខ្ពង់ខ្ពស់នៃ Pergamum គឺសិល្បៈនៃជាងចម្លាក់ មានពីរដំណាក់កាល ដំណាក់កាលទីមួយ Pergamum school (C.250 –200) បានប្រារព្ធពីជោគជ័យ (C.230 ) នៃស្ដេច Attalus I លើ Galatians ការស្លាប់របស់ពួក Gaul គឺជាឧទាហរណ៍មួយនៃឥទ្ធិភាពរបស់សិល្បៈ ។ ដំណាក់កាលទី២ (200-150) បានឆ្លាក់ចម្លាក់លើជញ្ជាំងពីហ្សីស (Great Altar Zeus) ជាពិសេសការបរាជ័យនៃពួក Antiochus III ប្រទេសស៊ើរីនៃតំបន់ Magnesia ។ Pergamum ជាកន្លែងកំណើតរបស់ Galem ។ តាមវប្បធម៌នៃ Pergamum បានកសាងបណ្ណាល័យ ជាលើកទីពីរបែប Alexandria ។ ករណីពិសេសរបស់បណ្ណាល័យគឺការប្រើប្រាស់នូវ Parchmant ដែលយកឈ្មោះពីទីក្រុង ។ តាមធម្មតាបណ្ណាល័យផ្ដល់ដោយ Angtony ទៅ Cleo Patra ។



www.elibraryofcambodia.org

ក្រោមការគ្រប់គ្រងរបស់ប្រទេសរ៉ូម៉ាំង Pergamum ជាខេត្តនៃ Asia ។ Pergamum ជាទីក្រុងច្បងនៃ Asia Minor ។ Pergamum បានទទួលលទ្ធិសាសនាគ្រិស្តដំបូងគេ ក្នុងចំណោមព្រះវិហារទាំងប្រាំពីរនៅ Asia ។

· បណ្ណាល័យទំនើប

បណ្ណាល័យទំនើបមានទាំងភ្ញៀវចូលបណ្ណាល័យព្រមទាំងដំណើរការអាន ខ្ចីសៀវភៅ និងការប្រើប្រាស់សម្ភារផ្សេងទៀតដូចជា បញ្ជីបោះពុម្ព សេវាកម្មផ្តល់ប្រឹក្សាដល់អ្នកអាន ។ បណ្ណាល័យអន្តរៈផ្តល់នូវសេវាកម្មខ្ចីសៀវភៅ វគ្គបទឧទ្ទេសសៀវភៅសាធារណៈ និងការថែទាំសម្រាប់កូនចៅជំនាន់ក្រោយដោយមានការប្រមូលឯកសារ ។ ប្រពន្ធ័នៃការចាត់ថ្នាក់សៀវភៅមានបី ដែលបានប្រើប្រាស់យ៉ាងទូលំទូលាយគឺប្រពន្ធ័ Dewey គឺប្រពន្ធ័ទសភាគ Melvil dewey ប្រពន្ធ័ Culture ជាប្រពន្ធ័របស់ Charles Ammi និង ប្រពន្ធ័បណ្ណាល័យ Congress (មាននៅក្នុង Catolog) តាំងពីទសវត្សរ៍ឆ្នាំ ១៩៣០ ។ បណ្ណាល័យសាធារណៈមានប្រព័ន្ធបច្ចេកវិទ្យាជាច្រើនមានទាំងមីក្រូហ្វូត សម្រាប់ថតចម្លងប្រព័ន្ធ Computer បញ្ចូល និងផ្ទុកព័ត៌មានយ៉ាងច្រើន និងប្រពន្ធ័ស្រាវជ្រាវតាម Computer បានយ៉ាងឆាប់រហ័ស ហើយមានព័ត៌មានច្រើនតាមរយៈប្រព័ន្ធ Internet គេអាចស្រាវជ្រាវបានទូទាំងពិភពលោកយ៉ាងសម្បូរបែប ។

យើងដឹងហើយថា បណ្ណាល័យរីកចម្រើនស្របនឹងសម័យកាលវិទ្យាសាស្ត្រ ។ កាលពីដើម មនុស្សចេះកត់ត្រាព្រឹត្តិការណ៍ផ្សេងៗ តែលើស្បែកសត្វ ដីឥដ្ឋ ផ្ទាំងសិលា សំបកឈើ ស្លឹកឈើ ឆ្អឹងសត្វ ដីសន្ទឹកលោហៈ ដុំឈើ បន្ទះឈើ ... រហូតដល់ចារលើស្បែកមនុស្សទៀតផង ។ ពេលនោះបណ្ណាល័យពុំសូវមានច្រើនទេ ហើយពុំទាន់បើកទូលាយដល់អ្នកប្រើប្រាស់ដែរ ។ រហូតដល់សម័យប្រើក្រដាសក្នុងការចារ កត់ត្រាចម្លងរឿងរ៉ាវផ្សេងៗ ក៏នៅពុំទាន់បានបើកទូលាយជាសាធារណៈនៅឡើយទេ ដូចជាបណ្ណាល័យនៅវត្តដូនជីនៃគ្រិស្តសាសនា នាមជ្ឈិមសម័យគេឃើញមានបណ្ណាល័យហើយ ប៉ុន្តែអ្នកដែលអាចប្រើប្រាស់បានលុះត្រាតែអ្នកនោះ ជាសមាជិករបស់បណ្ណាល័យ ។ បណ្ណាល័យភាគច្រើនជាកម្មសិទ្ធិរបស់អ្នកមានអំណាច ។ អ្នកគ្រប់គ្រង បណ្ណាល័យជាអ្នកជិតស្និទ្ធនឹងអ្នកដែលមានអំណាច ។ ចំពោះសៀវភៅ ឬ ឯកសារដែលគេដាក់ឱ្យប្រើត្រូវបានចោះដាក់ច្រវ៉ាក់ជាប់នឹងទូ ហើយពុំអនុញ្ញាតឱ្យខ្ចីយកទៅក្រៅបានទេ ។ ដោយវិទ្យាសាស្ត្រជឿនលឿន បច្ចេកវិទ្យាបានផលិតក្រដាស ការបោះពុម្ពក៏មានសន្ទុះរីកចម្រើនឡើង សៀវភៅ ឯកសារក៏មានចំនួនកើនឡើងដែរ ។ បណ្ណាល័យត្រូវបានពង្រីកដល់គ្រប់ភូមិសិក្សា ការប្រើប្រាស់បណ្ណាល័យក៏មានការបើកទូលាយជូន សាធារណជនទូទៅ ។ បច្ចុប្បន្ននេះ បណ្ណាល័យធំៗត្រូវបានបំពាក់ប្រព័ន្ធអេឡិចត្រូនិច ។ គេអាចស្រាវជ្រាវបានយ៉ាងទូលំទូលាយទូទាំងពិភពលោកតាមប្រព័ន្ធសារ Internet & E-mail ។



www.elibraryofcambodia.org

២. បណ្ណាល័យនៅប្រទេសកម្ពុជា

តើបណ្ណាល័យនៅកម្ពុជាមានតាំងពីសម័យណា?

បើតាមឯកសារប្រវត្តិសាស្ត្រ ខ្មែរជាជនជាតិមួយមានចំណាស់ជាងគេនៅភូមិភាគអាស៊ីអាគ្នេយ៍ ។ ខ្មែរបានបង្កើតជាអាណាចក្រដ៏រឹងមាំនៅក្នុងអំឡុងស.វទី១នៃគ.ស ហើយបានរៀបចំរចនាសម្ព័ន្ធក្នុងការគ្រប់គ្រងប្រទេសបានល្អ ។ នៅសម័យនគរភ្នំ ទឹកដីខ្មែរមានវិសាលភាពធំធេង ។ តាមកំណត់ត្រាចិន "កាំងថៃ" និង "លោកជូយីង" ប្រទេសខ្មែរមានទីក្រុងដែលព័ទ្ធជុំវិញទៅដោយកំផែង មានព្រះរាជវាំង និងផ្ទះអ្នកស្រុកជាច្រើន ។ ខ្មែរមានបណ្ណាល័យ មានកំណត់ហេតុ និង របស់របរផ្សេងទៀតជាច្រើន (តាមឯកសារប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាពីបុរាណសម័យដល់ស.វ ទី៨ ទំព័រ ៧៨)។ ឯកសារខ្លះបានសរសេរថា ខ្មែរនៅសម័យនោះចេះធ្វើពាណិជ្ជកម្មជាមួយបរទេស ជាពិសេសជាមួយឥណ្ឌា ចិន...។ វត្ថុដែលខ្មែរធ្វើពាណិជ្ជកម្មជាមួយបរទេសមានភ្លុក ខ្ទឹម ក្រវាញ គ្រាប់ធញ្ញជាតិ ស្បែកសត្វ... ។ រីឯវត្ថុដែលនាំចូលពីបរទេសមានគ្រឿងអលង្ការ គ្រឿងទេសកំណាត់សំពត់ គ្រឿងក្រអូប...។ ពេលនោះខ្មែរមានឯកសារកត់ត្រា ទំនិញចេញ ចូល មានឃ្លាំង មានបណ្ណាល័យសម្រាប់តម្កល់ឯកសារ ។

ក្នុងភាគខ្លះបានសរសេរថា សម័យនគរភ្នំ និង សម័យចេនឡាជាវប្បធម៌សំស្ក្រឹត។ ការសិក្សាសិលាចារឹក និងការប្រៀបធៀបកំណត់ហេតុចិន បានបង្ហាញឱ្យឃើញថា ភាសាសំស្ក្រឹតជាភាសាដែលគេប្រើប្រាស់ជាផ្លូវការ រីឯប្រជាពលរដ្ឋប្រើភាសាក្នុងអំបូរខ្មែរមន ។ ថ្វីត្បិតតែប្រជាពលរដ្ឋមិនទាន់ចេះសរសេរអក្សរបានគ្រប់គ្នាក៏ដោយ ក៏ប្រជាពលរដ្ឋប្រើភាសាខ្មែរក្នុងការទំនាក់ទំនងយ៉ាងទូលំទូលាយ ។ សូមបញ្ជាក់ថាអក្សរខ្មែរដំបូងបង្អស់ដែលបានចារជាមួយអក្សរសំស្ក្រឹត ហើយដែលចុះកាលបរិច្ឆេទយ៉ាងច្បាស់លាស់ គឺផ្ទាំងសិលាចារឹកអង្គរបុរីដែលប្រតិស្ឋានឡើងនៅឆ្នាំ ៦១២ នៃគ.ស ។ ដោយពឹងផ្អែកលើសិលាចារឹកវាលកន្ទេល និងអត្ថបទចិននានា បង្ហាញថា ក្នុងសម័យនោះ ខ្មែរយើងមានបណ្ណាល័យសម្រាប់តម្កល់ព្រះរាជពង្សាវតារ ប្រចាំជាតិរបស់ខ្លួន ព្រមទាំងមានឯកសារ ក្បួនខ្នាត និងគម្ពីរសាសនាជាច្រើនដូចជា រឿងរាមាយណៈ រឿងមហាភារតៈជាដើម (ឯកសារប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាពីបុព្វសម័យ ទំព័រ៦៧)។ សិលាចារឹកជាច្រើនផ្ទាំង បានឱ្យដឹងថាខ្មែរបុរាណចូលចិត្តចារគម្ពីរសាសនាព្រាហ្មណ៍ឱ្យបានច្រើនដើម្បីយកទៅតម្កល់ទុកក្នុងបូជនីយដ្ឋាន ក្នុងបណ្ណាល័យ ពីព្រោះគេមានជំនឿថា បើអ្នកណាចារសិលាចារឹក ឬចារគម្ពីរបានច្រើនពួកគេនឹងទទួលបានបុណ្យកុសល ក្នុងបច្ចុប្បន្ន និងអនាគត។ នៅពេលនោះ ឯកសារមានច្រើនដោយសារជំនឿនេះផង ដោយសារស្នាដៃពីរាជគ្រូនៃសាសនាព្រាហ្មណ៍ រាជបណ្ឌិត កវី អ្នកចេះដឹងបានចារ និង ចងក្រងឯកសារផ្សេងៗទៀត ។ ក្រោយពីនេះខ្មែរបានបញ្ជូនគម្ពីរព្រះពុទ្ធសាសនាទៅប្រទេសចិន ហើយជាភស្តុតាងមួយនៃការនិយម ឬ ស្គាល់គម្ពីរដោយជនជាតិខ្មែរ តាំងពីបុរាណ រហូតដល់បច្ចុប្បន្ន។



www.elibraryofcambodia.org

តាមឯកសារខ្លះទៀតបាននិយាយថា ខ្មែរច្រើនតែកសាងប្រាសាទជាទីបូជនីយដ្ឋាន ជាទីសក្ការៈបូជា ព្រមទាំងបានកសាងបណ្ណាល័យសម្រាប់តម្កល់គម្ពីរសាសនាជាច្រើន។ នៅគ្រប់ប្រាសាទចំនួន ១០៨០ ប្រាសាទសុទ្ធតែមានបណ្ណាល័យ ។ ដោយផ្អែកលើទស្សនៈ និងសេចក្ដីបង្ហាញខាងលើ យើងអាចសន្និដ្ឋានបានថាបណ្ណាល័យកម្ពុជាកើតមានតាំងពីយូរយារណាស់មកហើយ គឺតាំងពីមុនសម័យអង្គរ( ប្រហែលជាក្នុងសម័យនគរភ្នំ) ។ តែគួរឱ្យស្ដាយដោយយើងពុំមានភស្តុតាងបញ្ជាក់ច្បាស់លាស់ ប្រហែលសំណង់បណ្ណាល័យទាំងនោះមានការខូចខាតដោយសង្គ្រាមធម្មជាតិ ឬសំណង់នោះជាសំណង់ឈើ ។

រហូតដល់សម័យអង្គរ ខ្មែរបានក្លាយជាចក្រភពដែលមានឥទ្ធិពលយ៉ាងខ្លាំងនៅអាស៊ីអាគ្នេយ៍ ខ្មែរមានការរីកចម្រើនគ្រប់វិស័យ ក្នុងនោះវិស័យអប់រំក៏មានការរីកចម្រើនដែរ ។ គេបានបង្កើតបណ្ណាល័យ បង្កើតសាលារៀន និងឯកសារសម្បូរបែបដោយសារយើងមានធនធានមនុស្សច្រើន។

នៅពេលពុទ្ធសាសនាមហាយានចូលមកជំនួសសាសនាព្រាហ្មណ៍វិញ ប្រាសាទទាំងឡាយមិនត្រឹមតែជាទីសក្ការៈបូជា និង ជាបណ្ណាល័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសាលារៀន ជាមហាវិទ្យាល័យរបស់ជាតិផងដែរ។ នៅក្នុងសម័យមហានគរនេះ ខ្មែរមានភាពរុងរឿងណាស់ ហើយវិស័យផ្សេងៗក៏មានការរីកចម្រើនដែរ។ សំណង់បណ្ណាល័យបានបង្កើតឡើងយ៉ាងច្រើននៅតាមប្រាសាទ និងតាមវត្តអារាម ជាអាទិ៍គ្រាន់តែក្នុងបរិវេណប្រាសាទអង្គរវត្តមានបណ្ណាល័យរហូតដល់ទៅប្រាំមួយ យើងអាចឃើញតឹកតាងពិតប្រាកដ មានបណ្ណាល័យក្នុងបរិវេណប្រាសាទអង្គរវត្តអមសងខាងផ្លូវចូល។



www.elibraryofcambodia.org

## បណ្ណាល័យប្រាសាទអង្គរវត្ត



បណ្ណាល័យនៅជាន់ទី១ ខាងជើងផ្លូវចូល ( អង្គរវត្ត )



បណ្ណាល័យនៅជាន់ទី១ ខាងត្បូងផ្លូវចូល ( អង្គរវត្ត )



www.elibraryofcambodia.org



បណ្ណាល័យនៅជាន់ទី២ ខាងត្បូង ( អង្គរវត្ត )



បណ្ណាល័យនៅជាន់ទី២ ខាងជើង ( អង្គរវត្ត )



www.elibraryofcambodia.org



បណ្ណាល័យនៅជាន់ទី៣ ខាងត្បូង ( អង្គរវត្ត )



បណ្ណាល័យនៅជាន់ទី៣ ខាងជើង ( អង្គរវត្ត )



www.elibraryofcambodia.org



បណ្ណាល័យប្រាសាទបាយ័ន ( ខាងត្បូង )



បណ្ណាល័យប្រាសាទបាយ័ន ( ខាងជើង )



www.elibraryofcambodia.org



បណ្ណាល័យប្រាសាទបន្ទាយស្រី ( ខាងជើង )



បណ្ណាល័យប្រាសាទបន្ទាយស្រី ( ខាងត្បូង )



www.elibraryofcambodia.org



បណ្ណាល័យប្រាសាទតាសោម ( ខាងត្បូង )



បណ្ណាល័យប្រាសាទតាសោម ( ខាងជើង )



www.elibraryofcambodia.org

ទាំងនេះ គឺជាភស្តុតាងសំណង់បណ្ណាល័យដែលមាននៅតាមប្រាសាទខាងលើ តែក៏នៅមានបណ្ណាល័យតាមប្រាសាទនានាជាច្រើនទៀត ។ នៅពេលនោះយើងមានបណ្ណាល័យ មានឯកសារច្រើន ប្រទេសជាតិសម្បូរធនធានមនុស្សដ៏ឆ្នើមជាច្រើនដូចជាព្រះរាជាប្រកបដោយទសពិធរាជធម៌ មេទ័ពដ៏ខ្លាំងពូកែ រាជបណ្ឌិត្យ វិស្វករ អ្នកប្រាជ្ញកវី អ្នកនិពន្ធដ៏ពូកែជាច្រើន ។ តាមរយៈមហាបុរសខាងលើ ធនធានពុទ្ធិត្រូវបានកសាងឡើង ដោយចារទុកលើផ្ទាំងសិលា ចារជាគម្ពីរ សាស្ត្រា ក្បួនច្បាប់ជាច្រើន ហើយយកទៅតម្កល់រក្សាទុកនៅបណ្ណាល័យនៃប្រាសាទនានា និងនៅតាមវត្តអារាម ។ ព្រះរាជាខ្មែរក៏បានឱ្យតម្លៃ និង យកចិត្តទុកដាក់ទៅលើបណ្ណាល័យ ដូចជារាជព្រះបាទជ័យវរ្ម័នទី ៧ (៩៦៨-១០០១) ព្រះអង្គបានកសាងប្រទេសជាតិព្រមទាំងពង្រីកសាលារៀន និងបណ្ណាល័យជាច្រើនសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ រជ្ជកាលនេះគេឱ្យឈ្មោះថា "រជ្ជកាលសិក្សា" ។

ឯកសារដ៏ច្រើនជាសាស្ត្រាផ្នែកសាសនា ត្រូវចារចម្លងឡើងវិញក្នុងរយៈពេល ២០០ ឆ្នាំម្តង ចំពោះសាស្ត្រាដែលមានការពុកផុយ និងកែលំអរាល់កំហុសឆ្គងទាំងឡាយ ។ បុព្វបុរសយើងបានបកប្រែពីភាសាបាលី សំស្ក្រឹតមកភាសាខ្មែរ ខ្លះចារចម្លងពីគម្ពីរសាសនា និងខ្លះតាក់តែងច្នៃប្រឌិតចងក្រងជាឯកសារថ្មីសម្រាប់កូនចៅជំនាន់ក្រោយ។ ពេលនោះរាជបណ្ណាល័យតាមប្រាសាទក្នុងទីក្រុង និងតាមវត្តអារាមមានឯកសារជាច្រើន។ ប៉ុន្តែជាអកុសល ដោយសារល្បិចកលសត្រូវតូបផ្សំនឹងសង្គ្រាមផ្ទៃក្នុង និងពីខាងក្រៅបានវាយបំបែកកម្លាំង សម្ភារនិងស្មារតី។ ភាពរុងរឿងត្រូវបានស្រុតចុះវិញយ៉ាងខ្លាំង។ ស្រុកទេសច្របូកច្របល់វឹកវរ ឯកសារ សាស្ត្រា គម្ពីរក្បួនខ្នាតផ្សេងៗត្រូវបាត់បង់ដោយខ្មាំងសត្រូវប្លន់យក និង ដុតបំផ្លាញចោលជាបន្តបន្ទាប់ ។

### ២.១ សម័យមហានគរ

- ឆ្នាំ១១៧៧ ចាមចូលដុតទីក្រុងអង្គរ ខ្មែរបាត់បង់ឯកសារជាលើកដំបូង ។
- ពាក់កណ្តាលស.វទី ១៤ សៀមចូលដុតក្រុងអង្គរធំ ។
- ឆ្នាំ១៤៣១ ខ្មែរបាត់បង់ឯកសាររហូតដល់ដើមមុខលែងរួច ។

### ២.២ សម័យកណ្តាល

- នៅចុងស.វ ទី១៦ សៀមវាយបន្ទាយលង្វែក ដុតបំផ្លាញទីក្រុងយកទ្រព្យសម្បត្តិ និងឯកសារជាច្រើនទៀត ។

នៅពេលដែលស្រុកទេសកើតសង្គ្រាមវឹកវរច្របូកច្របល់ ឯកសារ គម្ពីរ សាស្ត្រា ក្បួនខ្នាតផ្សេងៗ ត្រូវបាត់បង់ដោយខ្មាំងដុតបំផ្លាញចោលខ្ទេចខ្ទី ។ ចំណេះដឹងមួយចំនួនមានតែនៅក្នុងខួរក្បាលអ្នកស្នេហាជាតិ ស្នេហាវប្បធម៌និងសាសនាប៉ុណ្ណោះ។ ចំណេះដឹងដែលត្រូវផ្ទេរមកឱ្យកូនចៅជំនាន់ក្រោយកាន់តែបាត់បង់ទៅៗ។ នៅពេល



www.elibraryofcambodia.org

ដែលសត្រូវចូលអុកឡុកប្រទេសខ្មែរម្ដងៗ ពួកវាតែងតែកៀរគ្រួសារខ្មែរ ប្រមូលទ្រព្យសម្បត្តិ ឯកសារ ព្រមទាំងអ្នកប្រាជ្ញខ្មែរឱ្យទៅបម្រើប្រទេសវា ហើយបណ្ដុះយុវជនជំនាន់ក្រោយឱ្យទទួលយកមនោគមន៍វិជ្ជាពីពួកវា ។ ជាពិសេសគឺសៀម នៅពេលដែលខ្មែរធ្លាក់ខ្លួនដោយសារចាញ់សង្គ្រាម គេយកយុវជនខ្មែរឱ្យទៅរៀនសូត្រ ពេលរៀនចប់វិលត្រឡប់មកស្រុកខ្មែរវិញ ត្រូវធ្វើការបម្រើការឱ្យពួកគេក្នុងនោះមានខ្សែរាជវង្សជាដើម ដូចជា ព្រះបាទអង្គឌួង ព្រះបាទនរោត្តម ។ ដោយសារព្រះបញ្ញាញាណ និងទឹកព្រះទ័យស្នេហាជាតិរបស់ព្រះអង្គ ព្រះអង្គបានតស៊ូរាល់ការគាបសង្កត់របស់ពួកបរទេសបែរមកបម្រើផលប្រយោជន៍ជាតិវិញ។

ប៉ុន្តែទោះបីជាមានការបំផ្លិចបំផ្លាញដោយសារសង្គ្រាមអស់កាលជាយូរអង្វែងក៏ដោយ ក៏នៅមានព្រះសង្ឃអ្នកស្នេហាជាតិ ស្នេហាវប្បធម៌ សហការគ្នាជាមួយប្រជាពលរដ្ឋបង្កើតកុដិហោត្រ័យ (បណ្ណាល័យតាមវត្ត) ដើម្បីរក្សាទុកក្បួនខ្នាត គម្ពីរសាស្ត្រាខ្លះៗ សម្រាប់កូនចៅជំនាន់ក្រោយ ។ លុះចូលមកដល់ក្នុងនឹមអាណានិគមនិយមបារាំង (១៨៦៣-១៩៥៣ ) ។ ៤៨ឆ្នាំក្រោយពីបារាំងបានដាក់អាណាព្យាបាលរបស់ខ្លួនមកលើប្រទេសកម្ពុជា នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩១១ តំណាងជាន់ខ្ពស់បារាំង (Resident Supèrieur au Cambodge) បានចេញផ្សាយ នូវក្រឹត្យមួយស្ដីពីការតាំងបណ្ណាសារដ្ឋានកណ្ដាលមួយនៅភ្នំពេញ ក្រោមការត្រួតពិនិត្យរបស់មន្ត្រីចាត់តាំងស៊ីវិល ម្នាក់ដែលមានឋានៈជាបណ្ណារក្ស និងបណ្ណាសារក្ស ហើយទាក់ទងផ្ទាល់ទៅតំណាងជាន់ខ្ពស់បារាំង។ ក្រឹត្យនេះមានច្បាប់ និងបទបញ្ជាសរុប ១៥មាត្រា។ តាមបណ្ដាខេត្តក៏មានបង្កើតរចនាសម្ព័ន្ធដូចគ្នានេះដែរ។ លុះមកដល់ ឆ្នាំ១៩១៧ មានរបាយការណ៍មួយដែលគ្មានចុះហត្ថលេខា បានយល់ព្រមឱ្យអនុវត្តជាបន្ទាន់ទៅលើការដាក់ក្រឹត្យ ឆ្នាំ១៩១១ ឱ្យចូលជាធរមានក្នុងការបង្កើតមូលដ្ឋានមួយសម្រាប់បណ្ណាសារដ្ឋាន និងតែងតាំងមន្ត្រីស៊ីវិលម្នាក់មានសមត្ថភាពឱ្យទទួលខុសត្រូវ ហើយមន្ត្រីរូបនោះបានធ្វើសំណើសុំកសាងអគារថ្មីមួយសម្រាប់ជាបណ្ណាល័យ និង បណ្ណាសារដ្ឋាន។

នៅឆ្នាំ១៩១៥ លោកឡេអុងសាំងម៉ារ៉ទីត្រូវបានតែងតាំងជាអនុប្រធាន ក្រោយពីការបង្កើតបណ្ណាល័យកណ្ដាលនៅហាណូយ ។ លោកត្រូវបានគេចាត់ឱ្យចុះរៀបចំឡើងវិញនូវរបៀបតម្កល់នៅបណ្ណាសារដ្ឋាន បណ្ណាល័យនៅភ្នំពេញ និងព្រៃនគរ។ លោកឡេអុងសាំងម៉ារទីបានធ្វើរបាយការណ៍យ៉ាងលំអិតមួយ ស្ដីពីការសុំថវិកាសម្រាប់ការងារបណ្ណាល័យ និងបណ្ណាសារដ្ឋាន និងការសាងសង់អគារ ហើយថវិកាមួយចំនួនត្រូវបានគេផ្ដល់សម្រាប់គម្រោងថវិកាឆ្នាំ១៩២២។

នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩២១ មានព្រះរាជបញ្ញត្តិមួយអនុញ្ញាតឱ្យបង្កើតបណ្ណាល័យជាតិដែលមានភារៈ "ថែរក្សារាល់កិច្ចការទាំងអស់ជាភាសាខ្មែរ និងឯកសារដែលសរសេរ ឬ និពន្ធដោយជនជាតិខ្មែរ"។ ផ្នែកនេះបង្កើតឡើងជាបន្ទាន់ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មការផលិត Chronique Cambodgienne ដែលបានយល់ព្រមឱ្យដាក់សាស្ត្រាស្លឹករឹតតម្កល់នៅបរមរាជវាំង និង វត្តអារាម ដែលជាកន្លែងតម្កល់ទុកនូវឯកសារទាំងឡាយខាងផ្នែកព្រះពុទ្ធសាសនា។ តាមរយៈឯកសារដែលនិយាយពីប្រវត្តិនៃបណ្ណាល័យ គឺនៅឆ្នាំ១៩៥២ ទីនេះ



www.elibraryofcambodia.org

ត្រូវបានគេស្គាល់ថា ជាព្រះរាជបណ្ណាល័យដែលមានលោកស្រី ស៊ូហ្សាន ការ៉េប៊ែលឡេស ជាអ្នកដឹកនាំផ្ទាល់ ។

បណ្ណាល័យបើកទ្វារជូនសាធារណជននៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩២៤ ។ ៣០ឆ្នាំក្រោយមក ស្ថាប័នអាណានិគម នេះត្រូវបានប្តូរឈ្មោះមកជា "បណ្ណាល័យជាតិកម្ពុជា" ។ នៅឆ្នាំ១៩៣០ បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យត្រូវបាន បង្កើតឡើង ។ ចំពោះបណ្ណាល័យជាតិកម្ពុជាអគារមានបីផ្នែកៈ

- ផ្នែកធំជាងគេនៅខាងមុខសម្រាប់បន្ទប់អានមានផ្ទាំងស្ថាបត្យករធំមួយ ដែលបានតុបតែងឡើងជា របៀបខ្មែរ ក្នុងបន្ទប់អាននេះអាចផ្ទុកអ្នកអានប្រហែល៣០នាក់ ។

- មានអគារស្លាបពីរសងខាង មួយជាបន្ទប់ខ្ចីអាចផ្ទុកសៀវភៅពី ៨០០០ ទៅ ១០០០០ក្បាល ហើយ ម្ខាងទៀតជាការិយាល័យបុគ្គលិក ។ អគារនេះត្រូវបានសាងឡើងដោយក្រុមហ៊ុន ឡាម៉ក់ទី តាមប្លង់ដែល គូរដោយស្ថាបត្យករទៅចុង ។ មានការតុបតែងយ៉ាងស្អាត និង សាមញ្ញបំផុតដោយមានចម្លាក់ ពីរខ្សែរបៀប "Sgraffite" វិលេចដោយពណ៌ក្រហមផ្ទៃស ហើយគេជឿថាពណ៌ដែលតុបតែងនេះមានជាលើកដំបូងបំផុតនៅ ឥណ្ឌូចិន ។

- ពេលបើកទ្វារជូនសាធារណជន នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៤ បណ្ណាល័យមានឯកសារចំនួន ២៨៧៩ច្បាប់ គឺ ១០៥៩ច្បាប់ បានមកពីអាណាព្យាបាលជាន់ខ្ពស់បារាំង ១៦៨៧ច្បាប់ ត្រូវបានគេទិញ និង ១៣៣ច្បាប់ ជាអំណោយ ។ លុះមកដល់ឆ្នាំ១៩២៧-១៩២៨ មានសេចក្តីរាយការណ៍មួយបានឱ្យដឹងពីការកែប្រែ កាតាឡុក "អនុញ្ញាតឱ្យអ្នកអានជ្រើសរើសនូវអ្វីដែលគេចង់បានដោយខ្លួនឯង" ។ ឆ្នាំ១៩២៨ សៀវភៅកើន ឡើងដល់ ១០ ០០០ក្បាល ហើយភ្ញៀវចូលអានមាន ៩ ៦៩៨ និង អ្នកខ្ចីកើនដល់ ១១ ១៩២នាក់ ។

ក្នុងអំឡុងសង្គ្រាមលោកលើកទី២ រដ្ឋបាលនៃអាណាព្យាបាលកម្ពុជាមានការផ្លាស់ប្តូរបន្តិចបន្តួច ។ រដ្ឋាភិបាល Vichy នៅប្រទេសបារាំងចង់ឱ្យអាណានិគមឥណ្ឌូចិន ដែលធ្លាប់នៅក្រោមការគ្រប់គ្រងរបស់ខ្លួន សហប្រតិបត្តិការជាមួយកងទ័ពជប៉ុនបានចូលមកលុកលុយនៅទីនេះ ហើយមន្ត្រីភាគច្រើននៃអាណានិគមនៅមាន តួនាទីដូចដើម ។

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ នៅពេលដែលជប៉ុនសម្រេចចិត្តដកការគ្រប់គ្រងអាណានិគមរបស់ខ្លួនចេញ ពីអ្វីដែលគេបានដឹង គឺមានការធ្វើរដ្ឋប្រហារកងទ័ពមួយ ។ ពីរថ្ងៃក្រោយមក ព្រះករុណាព្រះបាទនរោត្តមសីហនុ ទ្រង់បានប្រកាសពីការបញ្ចប់អាណាព្យាបាលបារាំង ។ ឥទ្ធិពលនៃការអភិវឌ្ឍទាំងនេះ លើបណ្ណាល័យជាតិកម្ពុជា ត្រូវបានរាយការណ៍មួយដោយ ហ្សាកកេសណែល ជាអភិបាលតាំងពីឆ្នាំ ១៩៣១ ដូចខាងក្រោមៈ

ប្រសិនបើសេវាកម្មបណ្ណាល័យនេះមិនរងនូវផលប៉ះពាល់ផ្ទាល់ពីព្រឹត្តិការណ៍ខែមីនា ឆ្នាំ១៩៤៥ ដែលបាន ជួបប្រទះនោះទេ ត្រូវបញ្ជាក់ឱ្យឃើញការប្រឆាំង និងរដ្ឋប្រហារគួរឱ្យចុញនេះ តាមរយៈបុគ្គលិក និងឯកសារីតែ



www.elibraryofcambodia.org

ច្បាស់ជាងនេះទៅទៀត។ អគារដែលត្រូវបានគេបិទទ្វារពីថ្ងៃទី១០-១៦ ខែមីនា ហើយត្រូវបានបើកទ្វារឡើងវិញពីថ្ងៃទី១៧ បានតែក្នុងរយៈពេលខ្លីប៉ុណ្ណោះជាមួយអភិរក្សបារាំងម្នាក់។ បន្ទាប់មកបណ្ណាសារដ្ឋាន និងបណ្ណាល័យត្រូវបានប្រគល់នៅថ្ងៃទី២៧ ខែមីនា ឱ្យអភិរក្សកម្ពុជា "លោក ម៉ាក អុក" ដែលជាមន្ត្រីជាន់ខ្ពស់កម្ពុជា និង អតីតលេខាធិការដែលមានចំណាត់ថ្នាក់លេខមួយ ។ ហ្សាកកេសណែល បន្តរាយការណ៍ថា បណ្ណារក្ស និងបណ្ណាសារក្សជនជាតិវៀតណាមពីរនាក់ត្រូវបានជំនួសដោយមន្ត្រីកម្ពុជានៅឆ្នាំ១៩៤៥។ ពេលនោះ ឯកសារជាច្រើនត្រូវបាត់ពីបន្ទប់អាន ដូចជាសៀវភៅមួយចំនួនដែលទាក់ទិននឹងកម្ពុជាត្រូវបានខ្ចីយកចេញដោយមន្ត្រីកម្ពុជា និងឯកសារមួយចំនួនទៀត ត្រូវបានបាត់បង់ដោយគ្មានការតាមដាន។ ក្នុងអំឡុងពេលនោះ សេវាបណ្ណាល័យ និងបណ្ណាសារដ្ឋានត្រូវគ្រប់គ្រងដោយជនជាតិកម្ពុជា។ គ្មានឯកសារណាមួយបញ្ជាក់ពីប្រវត្តិរបស់បណ្ណាល័យជាតិ ក្នុងរយៈកាលនេះទេ ។

មកដល់ខែមករា ឆ្នាំ១៩៥១ លោក ប៉ាច ឈឺន បានទទួលភារកិច្ចដឹកនាំបណ្ណាល័យបន្តមកទៀត ។ តាមព័ត៌មាន លោក ប៉ាច ឈឺន អាយុប្រហែលនឹងលោក ម៉ាក អុក ហើយជាអ្នកមានតំណែងគួរជាទីចាប់អារម្មណ៍បំផុត ។ លោកបានទទួលការបណ្តុះបណ្តាលជំនាញលើកទីមួយ និង ចូលរួមវគ្គបណ្តុះបណ្តាលផ្នែកបណ្ណាល័យ និងបណ្ណាសារដ្ឋាននៅហាណូយឆ្នាំ១៩២៦ ។ លោក ប៉ាច ឈឺន ត្រូវបានគេស្គាល់ថាជាអ្នកមានទស្សនៈគាំទ្រចលនាឯករាជ្យ ហើយត្រូវគេចាប់ខ្លួននៅខែកក្កដា ឆ្នាំ១៩៤២ ក្នុងតួនាទីជាអ្នកដឹកនាំធ្វើបាតុកម្មប្រឆាំងបារាំង ។ គាត់ត្រូវបានគេដោះលែងវិញក្រោយពីរដ្ឋប្រហារសឹកជប៉ុននៅខែមីនា ឆ្នាំ១៩៤៥ ហើយទទួលតំណែងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនៅខែសីហា ក្នុងរយៈពេលដ៏ខ្លីមួយ រហូតដល់បារាំងដាក់ការត្រួតត្រារបស់ខ្លួនឡើងវិញ។ ក្នុងខែមេសា ឆ្នាំ១៩៤៦ គាត់ត្រូវបានគេចាប់ម្តងទៀត ហើយត្រូវបានគេនិរទេសទៅបារាំង។ ក្រោយពីការដោះលែង គាត់បានត្រឡប់មកកម្ពុជាវិញ ហើយធ្វើជាអភិរក្សបណ្ណាល័យជាតិ និង ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងពត៌មាន នៅខែតុលា ឆ្នាំ១៩៥១ ។ នៅថ្ងៃទី១០ ខែមករា គាត់បានដាក់ឈ្មោះស្ថាប័ននេះថា បណ្ណាល័យជាតិ ( Bibliothèque Nationale ) ដែលកាលពីឆ្នាំ១៩៣១ ត្រូវបានឧទ្ទេសនាមថាបណ្ណាល័យកណ្តាល (Bibliothèque Centrale)។ នៅថ្ងៃទី៨ ខែមីនា លោក ប៉ាច ឈឺន បានសរសេរស្នើសុំទៅនាយករដ្ឋមន្ត្រីដើម្បីសុំសេចក្តីយល់ព្រមជាផ្លូវការមួយឈ្មោះថា បណ្ណាល័យ និងបណ្ណាសារដ្ឋានជាតិ ។

ការបំផ្លិចបំផ្លាញដែលនៅក្រោមការគ្រប់គ្រងនៃរបបប៉ុល ពត ពីឆ្នាំ១៩៧៥-១៩៧៩ មានភាពតានតឹងជាខ្លាំង ដូចរចនាសម្ព័ន្ធសង្គមកម្ពុជាទាំងមូលដែរ ។ ក្រោយពីមហន្តរាយនេះ រាល់បញ្ហានៅតែទន់ខ្សោយនៅឡើយរហូតដល់សព្វថ្ងៃនេះ។

បណ្ណាល័យជាតិកម្ពុជាបានបើកទ្វារឡើងវិញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៨០ ហើយមានការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័ស។ លោក អ៊ុំ នាង ជាអតីតជំនួយការនៅផ្នែកបច្ចេកទេសបានទទួលភារកិច្ចជាប្រធាន



www.elibraryofcambodia.org

បណ្ណាល័យ ។ លោក ម៉ៅ គិន អតីតឆ្មាំប្រចាំការនៅទីនោះបានវិលមកកន្លែងដើមវិញនៅឆ្នាំ១៩៧៩ ។ មន្ត្រីជាច្រើននាក់បានស្លាប់ក្នុងរបបប៉ុល ពត និងខ្លះទៀតបានទៅជ្រកកោននៅប្រទេសទី៣ ។ នៅឆ្នាំ១៩៧៩ លោក យក់ គុណ ក៏បានមកជួយរៀបចំបណ្ណាល័យជាមួយលោក ម៉ៅ គិន ដែរ ។ មកដល់ឆ្នាំ១៩៩២ នៅ៩ខែដំបូង បណ្ណាល័យមានភ្ញៀវចូលអានដល់ទៅ ៦១ ៩៧២នាក់ និងភ្ញៀវខ្ចី ១៦ ១៩២នាក់ ហើយមានសៀវភៅចំនួន ៣០០០ក្បាលទៀតផង ។ នៅឆ្នាំ១៩៨៦ បណ្ណាសារដ្ឋានត្រូវផ្តាច់ចេញពីបណ្ណាល័យជាតិ ។ សព្វថ្ងៃនេះ បណ្ណាល័យជាតិស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានសៀវភៅ និងការអាន នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ឃ. ប្រភេទបណ្ណាល័យ

នៅប្រទេសកម្ពុជា មានប្រភេទបណ្ណាល័យជាច្រើនខុសៗគ្នា ដែលក្នុងនោះបែងចែកទៅតាមកម្រិតសិក្សា ឯកទេស និង ស្ថាប័នផ្សេងៗ ។ ប្រភេទបណ្ណាល័យរួមមាន :

- បណ្ណាល័យជាតិ

បណ្ណាល័យជាតិ ស្ថិតនៅខាងលិចវត្តភ្នំ កសាងឡើងក្នុងសម័យអាណានិគមនិយមបារាំងនៅអំឡុងឆ្នាំ ១៩២៤ ។ បណ្ណាល័យនេះ បានទទួលការអនុញ្ញាតពីភ្នាក់ងារអន្តរជាតិ ពីទីក្រុងប៉ារីស ក្នុងការចែកចាយលេខ International Standard Book Number (ISBN) និង International Standard Serial Number (ISSN) ដល់អ្នកបោះពុម្ពនៅក្នុងប្រទេសកម្ពុជា ។ បច្ចុប្បន្ន បណ្ណាល័យជាតិកំពុងធ្វើការប្រមូលឯកសារ ដើម្បីកសាងកម្រងឯកសារនៃសៀវភៅជាបេតិកភ័ណ្ឌជាតិដ៏ទូលំទូលាយមួយដែលទាក់ទងនឹងប្រទេសកម្ពុជា ។




បណ្ណាល័យជាតិ



www.elibraryofcambodia.org



កន្លែងទទួលភ្ញៀវនៅបណ្ណាល័យជាតិ

- បណ្ណាល័យសាធារណៈ

បណ្ណាល័យមជ្ឈមណ្ឌលវប្បធម៌បារាំងបង្កើតឡើងនៅឆ្នាំ ១៩៩១ បានបើកបម្រើសាធារណជនទូទៅ ចាប់ពីកុមារ រហូតដល់មនុស្សចាស់ ។ បណ្ណាល័យនេះមានបំពាក់ទៅដោយសម្ភារ ឧបករណ៍ទំនើប និង ឯកសារល្អៗ ដែលចែកចេញជាពីរផ្នែកគឺបណ្ណាល័យកុមារ និង បណ្ណាល័យមនុស្សធំ ។



បណ្ណាល័យមជ្ឈមណ្ឌលវប្បធម៌បារាំង



www.elibraryofcambodia.org

បណ្ណាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន និងលោកជំទាវ ជាអគារដ៏ធំស្កឹមស្កៃមានទីតាំងស្ថិតនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក រាជធានីភ្នំពេញ បានសាងសង់ឡើងនៅឆ្នាំ ២០០៨ ជាអំណោយដ៏ថ្លៃថ្លា របស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ។ បណ្ណាល័យនេះ ចែកចេញជាច្រើនបន្ទប់រួមមាន: បន្ទប់មធ្យមសិក្សា និងសេវាកម្ម បន្ទប់ឯកសារពិគ្រោះ បន្ទប់ឯកសារឧត្តមសិក្សា បន្ទប់អានផ្នែកឧត្តមសិក្សា បន្ទប់ការងារសៀវភៅ បន្ទប់បុគ្គលិក បន្ទប់កុំព្យូទ័រ បន្ទប់ទស្សនាវដ្តី និងបន្ទប់ប្រជុំ ។ បណ្ណាល័យនេះជាប្រភេទបណ្ណាល័យសាធារណៈ ដែលបើកបម្រើជូនសាធារណជនទូទៅ និងមានបំពាក់នូវសម្ភារបរិក្ខារទំនើបៗ សម្រាប់ជួយសម្រួលដល់ដំណើរការការងារ និងការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិតផងដែរ។ បច្ចុប្បន្នបណ្ណាល័យនេះស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ។



បណ្ណាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវ

- បណ្ណាល័យសាលារៀន

បណ្ណាល័យសាលារៀន ដែលបានបង្កើតឡើង សម្រាប់បម្រើឱ្យការបង្រៀន និងរៀនរបស់សិស្សានុសិស្ស និងគ្រូ ដែលជាកត្តារីកចម្រើនរបស់វិស័យអប់រំ ។ បណ្ណាល័យទាំងនោះ ទោះបីជាមានរូបភាពជាបណ្ណាល័យក្តី មិនមែនជាបណ្ណាល័យក្តី ក៏ជាផ្នែកមួយយ៉ាងសំខាន់ជួយរក្សានូវមរតកវប្បធម៌សង្គម និង លើកទឹកចិត្តដល់សិស្ស ទាំងការសិក្សា និង ល៉ៃហែកំសាន្ត ។ ទិសដៅសំខាន់ នៃការបង្កើតនេះ គឺការកសាងទម្លាប់នៃការអានរបស់កុមារទាំងក្នុង និងក្រៅសាលារៀន ជាពិសេសកុមារក្រីក្រ ដែលគ្មានលទ្ធភាពរៀនសូត្រឱ្យពួកគេ



www.elibraryofcambodia.org

មានឱកាសបានទទួលនូវការអប់រំ ដើម្បីបម្រើឱ្យការអប់រំសម្រាប់ទាំងអស់គ្នា។ បច្ចុប្បន្ននេះ បណ្ណាល័យនៅសាលាបឋមសិក្សាចំណេះទូទៅភាគច្រើនមានភាពល្អប្រសើរ និងរីកចម្រើនគួរឱ្យកត់សម្គាល់ រួមទាំងការបង្កើតបណ្ណាល័យចល័តផងដែរ ។



បណ្ណាល័យសាលាបឋមសិក្សា



សកម្មភាពអាននៅសាលាបឋមសិក្សា

- បណ្ណាល័យឧត្តមសិក្សា

បណ្ណាល័យឧត្តមសិក្សាទាំងផ្នែកសាធារណៈ និង ឯកជនត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីបម្រើឱ្យការសិក្សារបស់និស្សិត និងសាស្ត្រាចារ្យ ។ សព្វថ្ងៃនៅតាមបណ្ណាល័យខ្លះ មានបំពាក់នូវសម្ភារបរិក្ខារ ទំនើបៗ



www.elibraryofcambodia.org

ដូចជា Internet E-mail ដើម្បីស្វែងរកព័ត៌មានសម្បូរបែប និងឆាប់រហ័ស ។

បណ្ណាល័យ ហ៊ុន សែន ស្ថិតនៅបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បង្កើតឡើងនៅឆ្នាំ ១៩៩៧ ។ បណ្ណាល័យនេះមានតួនាទីបម្រើសេចក្តីត្រូវការខាងឯកសារដល់និស្សិត សាស្ត្រាចារ្យ អ្នកអាន អ្នកស្រាវជ្រាវ ទាំងក្នុង និងក្រៅសាកលវិទ្យាល័យ ព្រមទាំងបុគ្គលិកអង្គការជាតិ និងអន្តរជាតិផងដែរ ។




បណ្ណាល័យ ហ៊ុន សែន




សកម្មភាពអ្នកអាន អ្នកស្រាវជ្រាវ នៅបណ្ណាល័យ ហ៊ុន សែន

- បណ្ណាល័យតាមក្រសួង ឬ ស្ថាប័ន

បង្កើតឡើងនៅតាមក្រសួងនានាដើម្បីប្រមូលផ្តុំ និង រក្សាទុកនូវរាល់ឯកសារតាមជំនាញរបស់ក្រសួង



www.elibraryofcambodia.org

ទីមួយ៦ ។ ក្នុងនោះបណ្ណាល័យខ្លះ អនុញ្ញាតឱ្យអ្នកអាន អ្នកស្រាវជ្រាវពីក្រៅមកប្រើប្រាស់បាន ។

បច្ចុប្បន្ន បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យស្ថិតក្រោមក្រសួងធម្មការ និងសាសនា មានទីតាំងជិតស្ទូនឡារសម្ដេចហ៊ុន សែន ។ បណ្ណាល័យនេះបានរក្សាទុកនូវសម្បត្តិដ៏មានតម្លៃ គឺសាស្ត្រាស្លឹករឹតស្ដីពីគម្ពីរធម៌ ។



បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ



សកម្មភាពអាន ស្រាវជ្រាវនៅបណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ



www.elibraryofcambodia.org

- បណ្ណាល័យអង្គការជាតិ និងអន្តរជាតិ

ជាបណ្ណាល័យដែលទាក់ទិននឹងការសិក្សាស្រាវជ្រាវតាមតំបន់ ដើម្បីបម្រើឱ្យវិស័យសហប្រតិបត្តិ និងការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជា ដែលអង្គការជាតិ និងអន្តរជាតិបានបង្កើតឡើងដើម្បីរក្សាទុកឯកសារសម្រាប់ឱ្យបុគ្គលិកគេប្រើប្រាស់ទៅតាមជំនាញនីមួយៗ។ បណ្ណាល័យអង្គការខ្លះ អនុញ្ញាតឱ្យអ្នកអានអ្នកស្រាវជ្រាវពីខាងក្រៅចូលមកប្រើប្រាស់បណ្ណាល័យបាន ។

បណ្ណាល័យវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI) បង្កើតឡើងនៅឆ្នាំ ១៩៩២ ដើម្បីបម្រើការជាមជ្ឈមណ្ឌលធនធានសាធារណៈ សម្រាប់ការស្រាវជ្រាវដែលទាក់ទិននឹងការអភិវឌ្ឍ។ បេសកកម្ម របស់ វបសអ គឺពង្រឹងសមត្ថភាពធនធានមនុស្សនៅកម្ពុជា ធ្វើការស្រាវជ្រាវ និងវិភាគដើម្បីបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍មានចីរភាព ។



សកម្មភាពអាន ស្រាវជ្រាវនៅបណ្ណាល័យវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ង. ការបង្កើតបណ្ណាល័យសាលារៀន

បណ្ណាល័យសាលារៀន មិនមែនកើតឡើងដោយចៃដន្យទេ ត្រូវធានាឱ្យបាននូវសកម្មភាព និងដំណើរការរបស់បណ្ណាល័យ ដោយមិនមែនបង្កើតបានរយៈពេលខ្លី ហើយបិទទៅវិញនោះឡើយ ព្រោះនាំឱ្យខាតបង់ពេលវេលា សេចក្តីប្រឹងប្រែង និងថវិកាដែលចំណាយទៅលើការបង្កើតបណ្ណាល័យនោះ។ ដូច្នេះត្រូវជឿជាក់ និងឱ្យតម្លៃបណ្ណាល័យជាសារវន្ត ។



www.elibraryofcambodia.org

- ស្ថានភាព និងទីតាំងបណ្ណាល័យ

ថ្នាក់ដឹកនាំសាលា គប្បីយកចិត្តទុកដាក់សិក្សាពីស្ថានភាព និង ទីតាំងរបស់បណ្ណាល័យដែលត្រូវស្ថិតនៅចំណុចកណ្តាលនៃសាលារៀន ដើម្បីជួយសម្រួលដល់ពេលវេលារបស់កុមារតាមថ្នាក់នីមួយៗ ឱ្យបានចូលបណ្ណាល័យ។ ថ្នាក់ដឹកនាំសាលាគួរពិចារណាពីទីតាំង មុនពេលសាងសង់អគារបណ្ណាល័យ ដែលត្រូវស្ថិតនៅចំណុចកណ្តាលនៃសាលារៀន មានស្ថានភាពខ្ពស់មិនលិចទឹក ធានាថាមិនផ្លាស់ប្តូរចុះឡើង មានបន្ទប់សមរម្យ មានពន្លឺគ្រប់គ្រាន់ និងមានអាកាសធាតុល្អ ។

- អគារបណ្ណាល័យ

ជាអគារដាច់ដោយឡែក ដែលមានបន្ទប់ធំទូលាយ សមរម្យ មានពន្លឺគ្រប់គ្រាន់ មានអាកាសធាតុល្អ មានឃ្លាំងសម្រាប់ស្តុកឯកសារថែមទៀតផង។ បណ្ណាល័យនេះ ផ្ទុកអ្នកអានបានច្រើន និងអាចបើកជាសាធារណៈ ដើម្បីផ្តល់ឱកាសឱ្យកុមារពីខាងក្រៅបានចូលអាន និង ប្រើប្រាស់បណ្ណាល័យផងដែរ ។



អគារបណ្ណាល័យនៅបឋមសិក្សា

- បន្ទប់បណ្ណាល័យ

ជាបន្ទប់ដាច់ដោយឡែក ដែលថ្នាក់ដឹកនាំសាលា បានសម្រេចជ្រើសរើសយកថ្នាក់រៀនមួយសម្រាប់ធ្វើជាបន្ទប់បណ្ណាល័យ ដើម្បីបំពេញតម្រូវការរបស់គ្រូ សិស្ស និងបម្រើឱ្យការបង្រៀន និងរៀន ។ ដោយសារទំហំនៃបន្ទប់បណ្ណាល័យនេះនៅមានកម្រិត មិនអាចទទួលអ្នកអានបានច្រើន គឺសម្រាប់បម្រើឱ្យការសិក្សារបស់សិស្ស



www.elibraryofcambodia.org

គ្រូ នៅតាមសាលារៀននីមួយៗតែប៉ុណ្ណោះ ។



បន្ទប់បណ្ណាល័យនៅបឋមសិក្សា

- បណ្ណាល័យនៅទីចាត់ការ

ដោយសារកង្វះខាតបន្ទប់រៀន ថ្នាក់ដឹកនាំសាលា បានរៀបចំផ្នែក ឬជ្រុងមួយនៅក្នុងទីចាត់ការធ្វើជាបណ្ណាល័យសម្រាប់តម្កល់ឯកសារសិក្សារបស់សិស្ស និងគ្រូ។ ការបង្កើតបណ្ណាល័យនៅក្នុងទីចាត់ការ ធ្វើឱ្យមានសម្ពាធខ្លាំងដល់កុមារនឹងធ្វើឱ្យពួកគេបាត់បង់ឱកាសក្នុងការចូលបណ្ណាល័យ និងរំខានដល់បុគ្គលិកទីចាត់ការ ។



បន្ទប់បណ្ណាល័យនៅក្នុងទីចាត់ការសាលា



www.elibraryofcambodia.org

- បណ្ណាល័យនៅក្នុងថ្នាក់រៀន ( ជ្រុង ឬកៀនបណ្ណាល័យ)

ជាការរៀបចំទូ ឬធ្នើរឯកសារ សម្រាប់ដាក់តាមថ្នាក់រៀន ដើម្បីឱ្យសិស្សបានអាន និងស្រាវជ្រាវទៅតាមការចាំបាច់របស់ពួកគេ ។ អ្នកដែលទទួលខុសត្រូវគឺគ្រូប្រចាំថ្នាក់ ឬប្រធានក្រុមសិស្ស ។ ប្រសិនបើសាលារៀនពីរវេន វានឹងផ្តល់ការលំបាកដល់គ្រូប្រចាំថ្នាក់ ឬប្រធានក្រុមសិស្ស ក្នុងការគ្រប់គ្រងឯកសារ ដែលមានក្នុងបណ្ណាល័យ ។



ជ្រុង ឬកៀនបណ្ណាល័យ

- បណ្ណាល័យចល័ត

ជាប្រភេទបណ្ណាល័យសាធារណៈ និងជាបណ្ណាល័យដែលអាចផ្លាស់ប្តូរទីកន្លែងបាន។ បណ្ណាល័យចល័តមានរូបភាពខុស១គ្នា ដែលបានបង្កើតឡើងតាមភូមិសាស្ត្រ តាមធនធាន និង មធ្យោបាយដែលខ្លួនមាន ដើម្បីជួយសម្រួលឱ្យប្រជាជនដែលរស់នៅទីកន្លែងនោះ មានលទ្ធភាពប្រើប្រាស់សៀវភៅ និង ឯកសារផ្សេង១ ។ ដូច្នេះបណ្ណាល័យចល័តអាចជារទេះ ទូក កាណូត កង់ ម៉ូតូ ស៊ីក្លូ រថយន្ត ... ។ ការបង្កើតបណ្ណាល័យចល័តគឺដើម្បីផ្តល់ឱកាសដល់ប្រជាជន ជាពិសេសកុមារដែលគ្មានឱកាសរៀនសូត្រ បានទទួលនូវចំណេះដឹង ដូចកុមារនៅតាមសាលាដែរ ។ ការបង្កើតបណ្ណាល័យចល័តក្នុងសាលារៀន គឺជាមធ្យោបាយល្អបំផុត ដើម្បីជួយដល់សាលាដែលគ្មានបណ្ណាល័យ ។



www.elibraryofcambodia.org



បណ្ណាល័យចល័ត

ច. ធនធានឯកសារ សម្ភារ បរិក្ខារ និងថវិកា

ការបំពាក់ធនធានឯកសារ សម្ភារ បរិក្ខារ និង ថវិកា គឺអាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់សាលា
នីមួយៗដែលអាចរកបាន។ ប្រសិនបើសាលាមានលទ្ធភាព និង ថវិកាច្រើន បណ្ណាល័យនឹងមានធនធានឯកសារ
សម្ភារ បរិក្ខារ ថ្មីៗ ល្អៗ និង សម្បូរបែប ។ ផ្ទុយមកវិញ ចំពោះសាលាមានថវិកាខ្សត់ខ្សោយ ការបំពាក់ធនធាន
ឯកសារ សម្ភារ បរិក្ខារ គឺអាស្រ័យទៅលើគំនិតច្នៃប្រឌិតរបស់ថ្នាក់ដឹកនាំសាលា និង បណ្ណារក្ស ។ ប៉ុន្តែកត្តាដែល
សំខាន់ គឺធ្វើយ៉ាងណាត្រូវប្រើប្រាស់ធនធានទាំងនោះឱ្យអស់លទ្ធភាព ។

ឯកសារ

ជាសៀវភៅ ឬឯកសារស្តីពីកម្មវិធីសិក្សា ឯកសារចំណេះដឹងទូទៅ និង ឯកសារផ្សេងៗទៀតសម្រាប់ឱ្យ
សិស្ស គ្រូប្រើប្រាស់ដើម្បីបង្កើននូវចំណេះដឹង បម្រើឱ្យការបង្រៀន និងរៀន ។ បណ្ណារក្សគប្បីចងចាំថា សៀវភៅ
មួយក្បាល មិនគ្រាន់តែមានតម្លៃក្នុងការអានទេ តែវាក៏បានផ្តល់នូវព័ត៌មានផ្សេងៗបន្ថែមទៀតផងដែរ។ ពោលគឺ
មិនត្រូវបំពេញបណ្ណាល័យទៅដោយសៀវភៅ ឬឯកសារដែលគ្រាន់តែលំអតាមធ្នើរនោះទេ គឺត្រូវធ្វើយ៉ាងណា
បំពេញរាល់តម្រូវការ និង គោលការណ៍របស់បណ្ណាល័យកម្រិតបឋមសិក្សា។ម្យ៉ាងទៀត បណ្ណាល័យមិនគួរស្តុក
សៀវភៅគ្មានតម្លៃហួសសម័យ និងមិនទាក់ទងដល់ការអប់រំនោះទេ ព្រោះវាធ្វើឱ្យមានភាពខ្ជីខ្ជានូវទីកន្លែង
សម្រាប់ស្តុកសៀវភៅ។



www.elibraryofcambodia.org



ស្បៀវភៅរឿង និងស្បៀវភៅសិក្សាគោល

សម្ភារៈ

ជាសម្ភារឧបទេស ដូចជាកាសែត វីស៊ីឌី ផែនទី ផ្ទាំងរូបភាព និងជាឧបករណ៍សម្រាប់ជំនួយដល់គ្រូក្នុងការបង្រៀន ។ ល្បែងសិក្សា និងឧបករណ៍ភ្លេង ជាជំនួយដល់សកម្មភាពកំសាន្តនានា ដើម្បីធ្វើឱ្យកុមារមានភាពសប្បាយរីករាយ។ ដូច្នេះបណ្ណារក្សត្រូវរៀបចំទុកដាក់ដាច់ដោយឡែក ដើម្បីមានភាពងាយស្រួលក្នុងការចាត់ចែង និងថែរក្សា ហើយធ្វើឱ្យអ្នកប្រើប្រាស់ងាយស្រួលរកសម្ភារដែលពួកគេត្រូវការ ។



សម្ភារឧបទេស



www.elibraryofcambodia.org

### បរិក្ខារ

មានដូចជា តុ ទូ កៅអី ជាដើម ។ ការធ្វើទូមានកញ្ចក់រូតចុះឡើង ដើម្បីការពារធូលី និងភាពងាយស្រួលក្នុងការគ្រប់គ្រងឯកសារ ប៉ុន្តែវាអាចនឹងបង្កគ្រោះថ្នាក់ដល់កុមារ ។ ហេតុនេះថ្នាក់ដឹកនាំសាលា និងបណ្ណារក្ស គប្បីគិតគូរឱ្យបានហ្មត់ចត់ចំពោះបញ្ហាទាំងនេះ រួមទាំងសមាមាត្រនៃកម្ពស់របស់កុមារ ជាពិសេសកុមារនៅកម្រិតបឋមសិក្សា ។



គំរូធ្នើរមុខសង្ខាង





www.elibraryofcambodia.org



គំរូធ្នើរមុខសង្ខាង



គំរូធ្នើរមុខម្ខាង



www.elibraryofcambodia.org



គំរូធ្នើរមុខម្ខាង

ថវិកា

ដើម្បីឱ្យបណ្ណាល័យមានដំណើរការល្អ ថ្នាក់ដឹកនាំសាលា និងបណ្ណារក្សត្រូវរៀបចំផែនការ និងធ្វើគម្រោងចំណាយឱ្យច្បាស់លាស់សម្រាប់ប្រចាំខែ ត្រីមាស ឆមាស ឬឆ្នាំនីមួយ១។ គម្រោងចំណាយចែកចេញជា៖

- ចំណាយសម្រាប់រៀបចំបង្កើតបណ្ណាល័យ
  - កសាងអគារ ឬបណ្ណាល័យ
  - ទិញសម្ភារ បរិក្ខារ និង សង្ហារិម ( តុ ទូ កៅអី ...)
  - ទិញឯកសារសម្រាប់ប្រើប្រាស់នៅបណ្ណាល័យ ( សៀវភៅ ទស្សនាវដ្តី ...)
  - ទិញសម្ភារការិយាល័យ ( ប៊ិក សៀវភៅ ស្កុត កន្ត្រៃ ...)

- ចំណាយសម្រាប់ដំណើរការរបស់បណ្ណាល័យ
  - ចំណាយលើការជួសជុល ថែទាំ ទូទៅ ( អគារ សម្ភារ បរិក្ខារ)
  - ចំណាយលើសោហ៊ុយ ថែទាំ សង្ហារិម ឬការទិញថ្មី
  - ចំណាយលើការទិញឯកសារបន្ថែម
  - ចំណាយទិញសម្ភារការិយាល័យ
  - ចំណាយផ្សេង១ក្នុងការកសាងសមត្ថភាពបណ្ណារក្ស ( ចូលរួមសិក្ខាសាលា មធ្យោបាយធ្វើដំណើរក្នុងការធ្វើទស្សនកិច្ចសិក្សាស្វែងរកបទពិសោធបន្ថែមពីបណ្ណាល័យគំរូ) ។

ចំណាយប្រចាំឆ្នាំនីមួយ១ អាចជួយឱ្យថ្នាក់ដឹកនាំសាលា និងបណ្ណារក្សរៀបចំគម្រោងថវិកាសម្រាប់ឆ្នាំបន្តបន្ទាប់ ។



www.elibraryofcambodia.org

ឆ. អំពីបណ្ណារក្ស

១. លក្ខណៈនៃការជ្រើសរើស

សមាសភាពសំខាន់បំផុតរបស់បណ្ណាល័យ គឺបណ្ណារក្ស ។ ទោះបីជាសាលាមានអគារបណ្ណាល័យធំទូលាយហើយមានសៀវភៅច្រើនយ៉ាងណាក៏ដោយ ប៉ុន្តែបើបណ្ណាល័យគ្មានការនិទានរឿងឱ្យកុមារស្ដាប់ គ្មានកម្មវិធីណែនាំឱ្យកុមារចេះគូររូប បត់រូប ផាត់ពណ៌ និង លេងល្បែងកំសាន្ត ហើយបណ្ណារក្សចាំតែស្ដីបន្ទោស និងបង្ហាញនូវអាកប្បកិរិយាធុញទ្រាន់នឹងកុមារ នោះធ្វើឱ្យកុមារមិនចង់ចូលបណ្ណាល័យឡើយ ។ បណ្ណារក្សត្រូវដឹងថាអ្នកនៅធ្វើការក្នុងបណ្ណាល័យ គឺដើម្បីបម្រើដល់សាលាក្នុងការទំនាក់ទំនងជាមួយគ្រូ សិស្ស ហើយការយល់ដឹងពីចំណុចនេះ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីធានាថាគ្រូ សិស្ស បានទទួលនូវសេវាកម្មពិតប្រាកដពីបណ្ណាល័យ ។ សរុបមក បណ្ណារក្សគឺជាអ្នកជួយសម្របសម្រួលក្នុងការទំនាក់ទំនងរវាងសៀវភៅ និងកុមារតាមរយៈការផ្ដល់ភាពសប្បាយរីករាយដល់កុមារ ។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការបង្កើតបរិយាកាសដែលអាចធ្វើទៅបានចំពោះកុមារ ដើម្បីឱ្យពួកគេមានអារម្មណ៍ធូរស្រាល សប្បាយរីករាយ ហើយមានចិត្តរំភើបក្នុងការចូលបណ្ណាល័យ ។

អ្នកទទួលខុសត្រូវបណ្ណាល័យ គួរតែយល់ដឹងចំពោះគោលបំណងរបស់បណ្ណាល័យសាលារៀន ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់ជួយដល់សាលាក្នុងការទំនាក់ទំនងជាមួយគ្រូ និងសិស្ស ។ ការយល់ដឹងបានច្បាស់ពីកត្តានេះ គឺជាមធ្យោបាយដ៏ល្អបំផុត ដែលអាចធានាបានថា បុគ្គលិក គ្រូ និងសិស្សានុសិស្ស បានទទួលនូវសេវាកម្មពិតប្រាកដពីបណ្ណាល័យ ។



សកម្មភាពបណ្ណារក្ស



www.elibraryofcambodia.org

- សមត្ថភាពរបស់បណ្ណារក្ស :

- មានចំណេះដឹងខាងសៀវភៅ យល់ពីខ្លឹមសារ អត្ថន័យ និងគ្រប់គ្រងសៀវភៅបាន បណ្ណារក្សគួរមានកម្រិតវប្បធម៌បង្គួរ មានចំណេះដឹងទូលាយ ចេះពីរបៀបរៀបចំចងក្រងប្រើប្រាស់ និងថែទាំសៀវភៅឱ្យបានល្អប្រសើរ ។

- មានចំណេះដឹងអំពីកុមារ ត្រូវយល់ដឹងពីចំណាប់អារម្មណ៍របស់កុមារ សមត្ថភាពរបស់កុមារក្នុងការអានមធ្យោបាយក្នុងការយល់របស់កុមារ ទស្សនៈរបស់កុមារ ភាសាកុមារ និងលទ្ធភាពស្រមើស្រមៃរបស់កុមារ ។

- មានជំនាញក្នុងការនិទានរឿង និងសកម្មភាពអប់រំផ្សេងៗ ដើម្បីផ្សារភ្ជាប់ជាមួយកុមារ និងសៀវភៅ។ កិច្ចការដំបូង បណ្ណារក្សត្រូវទទួលនូវចំណេះដឹង និងជំនាញក្នុងការអានសៀវភៅឱ្យបានច្រើនដងចាប់អារម្មណ៍ និងសប្បាយរីករាយក្នុងពិភពនៃសៀវភៅ ហើយហាត់និទានរឿងឱ្យបានញឹកញាប់ ដើម្បីយកមកនិទានឱ្យកុមារស្តាប់ប្រកបដោយភាពសប្បាយរីករាយ និងមានសិល្បវិធីធ្វើឱ្យកុមាររំភើបជាមួយសៀវភៅនោះដែរ ។

ម្យ៉ាងទៀតការងារបណ្ណាល័យ គឺជាការងារមមាញឹក និងកំប៉ិកកំប៉ុកច្រើន ដូច្នេះទាមទារឱ្យបណ្ណារក្សមានសមត្ថភាព មានមនសិការវិជ្ជាជីវៈ មានគំនិតច្នៃប្រឌិតខ្ពស់ មានភាពឈ្លាសវៃ ប៉ិនប្រសប់ក្នុងការដោះស្រាយរាល់បញ្ហាផ្សេងៗ ចេះគ្រប់គ្រងធនធាន សម្ភារ បរិក្ខារ ឯកសារបានល្អ និងមានទំនាក់ទំនងល្អជាមួយមជ្ឈដ្ឋាននានា។

- អាកប្បកិរិយារបស់បណ្ណារក្ស

បណ្ណារក្សចាំបាច់ត្រូវមានអាកប្បកិរិយាវិជ្ជមាន ឧស្សាហ៍ ព្យាយាម និងស្រឡាញ់ចូលចិត្តការងារ មានទំនាក់ទំនងល្អជាមួយមជ្ឈដ្ឋានជុំវិញ ម្ចាស់ការទទួលខុសត្រូវលើការអនុវត្តការងារ ជានិច្ចកាលបង្កើននូវចំណេះដឹងសមត្ថភាព និងជំនាញបន្ថែម ។ ម្យ៉ាងទៀតបណ្ណារក្សត្រូវតែចេះពីរបៀបរៀបចំ និងចេះបង្ហាញពីរបៀបប្រើប្រាស់បណ្ណាល័យដល់សិស្ស និងគ្រូ ដើម្បីឱ្យមានប្រសិទ្ធភាព ។

២. តួនាទីបណ្ណារក្ស

តួនាទីរបស់បណ្ណារក្ស គឺអ្នករៀបចំចងក្រង គ្រប់គ្រង ថែទាំឯកសារដែលមាននៅក្នុងបណ្ណាល័យ ជាអ្នកបម្រើសេវាកម្មបណ្ណាល័យ ជាអ្នកសម្របសម្រួល និងជំរុញសកម្មភាពផ្សេងៗជាមួយកុមារ តាមរយៈការអាននិទានរឿង ល្បែងសិក្សា សិល្បៈ ...។

៣. ភារកិច្ចបណ្ណារក្ស

❒ ការផ្សព្វផ្សាយព័ត៌មានបណ្ណាល័យ :

- ផលប្រយោជន៍បណ្ណាល័យ និងការអាន ដើម្បីបង្កើនចំណេះដឹង និងបង្កើនទម្លាប់ក្នុងការអានរបស់ពួកគេ ។



www.elibraryofcambodia.org

- ព័ត៌មានផ្សេងៗស្ដីពីបណ្ណាល័យ រួមមានធនធានឯកសារ សម្ភារ បរិក្ខារដែលអ្នកអានមានសិទ្ធិប្រើប្រាស់បាន ពេលម៉ោងធ្វើការ ច្បាប់ផ្ទៃក្នុងរបស់បណ្ណាល័យ និង ព័ត៌មានផ្សេងៗដែលទាក់ទងនឹងបណ្ណាល័យ ។

- របាយការណ៍ពីការលំបាករបស់បណ្ណាល័យដែលកំពុងជួបប្រទះ ការងារបច្ចេកទេស កង្វះខាតឯកសារ តម្រូវការឧបត្ថម្ភគាំទ្រ និងសហការពីថ្នាក់ដឹកនាំសាលា គ្រូ សិស្ស សហគមន៍ អង្គការជាតិ អន្តរជាតិ ។

- តម្រូវការជួសជុលសម្ភារ បរិក្ខារ ឯកសារ បន្ទប់ ឬអគាររបស់បណ្ណាល័យ ។

❒ ការអនុវត្តការងារបណ្ណាល័យ៖

- ការទទួលភ្ញៀវ និងការឆ្លើយតបរាល់សំណួរផ្សេងៗ រួមមានការផ្ដល់ឱ្យកុមារនូវមធ្យោបាយស្វែងរកព័ត៌មានអ្វីមួយដែលគេត្រូវការបណ្ណារក្សមានតួនាទីជំរុញឱ្យពួកគេមានទម្លាប់ក្នុងការអានសៀវភៅ ។

- ការបង្រៀនកុមារពីវិធីក្នុងការស្វែងរកឯកសារតាមធ្នើរ និងពីរបៀបប្រើប្រាស់ឯកសារ ។ បណ្ណារក្សត្រូវធ្វើអ្វីៗគ្រប់យ៉ាងដែលមានក្នុងបណ្ណាល័យ ដើម្បីជាមធ្យោបាយក្នុងការជួយសម្រួលដល់ សិស្ស គ្រូ នូវសម្ភារបង្រៀន និងរៀន ។

- ការបម្រើសេវាកម្មការងារមាន ការអាននៅទីងកន្លែង ការខ្ចី សង ការនិទានរឿង ការគូររូប ការបត់រូប និងល្បែងសិក្សា ការរៀបចំកាលវិភាគសម្រាប់ចូលអានតាមថ្នាក់ និងការសម្របសម្រួលជាមួយកុមារ ។ ការជួសជុល និងការថែទាំឯកសារ គឺជាកត្តាចាំបាច់បំផុតដែលបណ្ណារក្សត្រូវយកចិត្តទុកដាក់ ដើម្បីឱ្យឯកសារ និងសម្ភារទាំងអស់ប្រើប្រាស់បានយូរ ។

- សកម្មភាពផ្សេងៗ មានដូចជាការតាំងពិព័រណ៍សៀវភៅថ្មីៗ ការដាក់បង្ហាញនូវរូបភាព ឬសៀវភៅស្នាដៃរបស់កុមារ ដើម្បីទាក់ទាញការចូលរួមប្រឡងប្រណាំងស្នាដៃ ឬលទ្ធផលថ្មីៗ ដែលពួកគេបានរួមចំណែកជួយឧបត្ថម្ភដល់បណ្ណាល័យ កត្តានេះធ្វើឱ្យកុមារចង់ចូលបណ្ណាល័យ ។

- ការនិទានរឿងជាកត្តាសំខាន់សម្រាប់សាលារៀននៅបឋមសិក្សា ។ ដូច្នេះបណ្ណារក្សត្រូវរៀបចំកម្មវិធីចូលអាន និងនិទានរឿងឱ្យដាច់ដោយឡែកពីគ្នា ព្រោះការអានត្រូវការភាពស្ងៀមស្ងាត់ រីឯការនិទានរឿងមានភាពអ៊ូអរ ។ គ្រូ ឬអ្នកស្ម័គ្រចិត្ត គឺជាដៃគូយ៉ាងសំខាន់របស់បណ្ណារក្ស សម្រាប់ជួយដល់ការនិទានរឿងឱ្យកុមារ និងជាទម្លាប់ដ៏ល្អមួយ សម្រាប់យកទៅអនុវត្តតាមគ្រួសារ ។

ជ. ការរៀបចំបណ្ណាល័យ

ការរៀបចំបណ្ណាល័យ គឺជាកត្តាសំខាន់បំផុតដើម្បីឱ្យសិស្សចង់ចូលអានក្នុងបណ្ណាល័យ ។ ដូច្នេះសិល្បៈនៃការរៀបចំរបស់បណ្ណារក្សមិនដូចគ្នាទេ អាស្រ័យទៅលើភាពប៉ិនប្រសប់ និងការច្នៃប្រឌិតរបស់ពួកគេ ។ ការចំណាយបន្តិចបន្តួចក្នុងការរៀបចំ និងរចនាបន្ទប់អានមិនមែនជាការឥតប្រយោជន៍ទេ គឺធ្វើឱ្យបណ្ណាល័យ



www.elibraryofcambodia.org

កាន់តែមានសោភ័ណភាពប្លែកភ្នែក និងមានផាសុខភាពក្នុងការអង្គុយអាន ។ ម្យ៉ាងទៀតការរៀបចំបណ្ណាល័យត្រូវទឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ធ្វើយ៉ាងណាកុំឱ្យអ្នកប្រើប្រាស់មានភាពខ្មាសអៀនមិនហ៊ានប្រើប្រាស់ធនធានក្នុងបណ្ណាល័យ ។ កត្តាខ្លះដែលបណ្ណារក្សគួរយល់ដឹងពីរបៀបរៀបចំបណ្ណាល័យមាន:

- កន្លែងដាក់តុបណ្ណារក្ស តុសម្រាប់ឱ្យអ្នកអានអង្គុយអាន ទូ ឬធ្នើរដាក់ឯកសារ ផ្លូវសម្រាប់ឱ្យអ្នកអានដើរទៅរកឯកសារ និងទាក់ទងជាមួយបណ្ណារក្ស ។ ការរៀបទូ ត្រូវដាក់ចម្ងាយឃ្លាតពីគ្នាយ៉ាងតិច ០.៧០ម៉ែត្រ ដើម្បីឱ្យអ្នកអានអាចបង្វិលខ្លួនទៅមកបានស្រួល ។

- រៀបចំសៀវភៅតាមទូ ឬធ្នើរទៅតាមប្រធានបទ និងលំដាប់អក្ខរក្រមនៃអ្នកនិពន្ធ ។ បណ្ណារក្សត្រូវបិទសម្គាល់ពីចំណាត់ថ្នាក់ឯកសារតាមទូ ឬធ្នើរ ដើម្បីឱ្យអ្នកអានងាយរក ។

- ប្លង់ស្ដីពីការរៀបចំសម្ភារ និង សង្ហារិមក្នុងបណ្ណាល័យ ដើម្បីឱ្យអ្នកអានបានដឹង ។

- បទបញ្ជាផ្ទៃក្នុង ដែលទទួលស្គាល់ដោយថ្នាក់ដឹកនាំសាលា ដើម្បីរក្សារបៀបរៀបរយនៅក្នុងបណ្ណាល័យ និង ឱ្យសិស្ស គ្រូ គោរពតាមគោលការណ៍របស់បណ្ណាល័យ ។

- ក្ដារខៀនទុកបិទព័ត៌មាន និងសកម្មភាពផ្សេងៗ ដែលបណ្ណាល័យមាន ដើម្បីជូនដំណឹងដល់អ្នកអាន ។

- តាំងផ្កាភ្ញី រូបភាព ផែនទី ពាក្យស្លោកខ្លះៗ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់កុមារ ។

- ដាក់តុមួយនៅក្បែរមាត់ទ្វារ សម្រាប់ឱ្យអ្នកអានចុះឈ្មោះចូលអានក្នុងបណ្ណាល័យ (ដាក់ជុំក្រួស ឬបំពង់ប៊ិត ដើម្បីរាប់ចំនួនអ្នកអានប្រចាំថ្ងៃ) ។

- ផ្លាស់ប្តូរទីតាំងតុអាន ឬវត្ថុផ្សេងៗដែលស្រាលៗ ដើម្បីឱ្យបណ្ណាល័យមានសោភ័ណ និងមានភាពប្លែកភ្នែកជានិច្ច ។

- សម្អាតបណ្ណាល័យ ឯកសារ និងសម្ភារ បរិក្ខារ ដើម្បីឱ្យមានភាពស្អាត និងរៀបរយជាប្រចាំ ។ ប្រសិនបើបណ្ណាល័យនោះគ្របដណ្តប់ដោយធូលី ធ្វើឱ្យប៉ះពាល់ដល់សុខភាពបណ្ណារក្ស និងអ្នកអាន ហើយបណ្តាលឱ្យពួកគេអស់ទឹកចិត្តក្នុងការចូលអានក្នុងបណ្ណាល័យ ។



ការរៀបចំទូ ឬធ្នើរ



www.elibraryofcambodia.org

## III. អំពីសៀវភៅ

### ក. ប្រវត្តិសៀវភៅ

សៀវភៅបានចាប់កំណើតជាច្រើនពាន់ឆ្នាំមកហើយ មុនការបង្កើតក្រដាស និងមុនការបង្កើតម៉ាស៊ីនបោះពុម្ព ។ សៀវភៅ គឺពុំចាំបាច់តែធ្វើពីក្រដាសនោះទេ ព្រោះកាលពីដំនាន់ដើម មនុស្សសរសេរអក្សរលើសំបកឈើ ស្លឹករុក្ខជាតិ ឬស្បែកសត្វ... ដែលគេកាត់តម្រឹមឱ្យមានរាងជាបួនជ្រុងធំៗអាចមូរបាន។

ក្រោយមកមនុស្សបានបង្កើតអក្សរក្រោមរូបភាពផ្សេងៗ ខុសៗពីគ្នា ហើយបានឆ្លាក់អក្សរនោះនៅលើថ្មដែលបង្ហាញឱ្យឃើញពីប្រវត្តិ ព្រឹត្តិការណ៍ រឿងរ៉ាវ ច្បាប់ទម្លាប់ ឬធម៌អាថ៌ជាដើម។ ហេតុនេះហើយអក្សរ គឺជាអាទិភាពដំបូងបង្អស់នៃអត្ថបទដែលនាំឱ្យកើតជាសៀវភៅ ។

ក្រោយមកទៀត នៅមេសូប៉ូតាមី (Mèsopotamie) គេបានរកឃើញបន្ទះដីឥដ្ឋស្ងួតៗរាប់ពាន់បន្ទះមានអាយុ ៣០០០ឆ្នាំ មុនគ្រិស្តសករាជ ដែលនៅលើបន្ទះទាំងនោះបានសរសេរជាអក្សរ។ នៅស.វ ទី៧ មុន គ.ស អ្នកស្រាវជ្រាវជនជាតិអង់គ្លេសបានរកឃើញបន្ទះដីឥដ្ឋចំនួន ២០ ០០០បន្ទះ នៅវិហារនីនីវ (Ninive) ដែលចម្លងខ្លឹមសារពីមេសូប៉ូតាមីមកប្រើប្រាស់ ។ បន្ទះដីឥដ្ឋទាំងនោះមានអាយុប្រហាក់ប្រហែលគ្នានឹងបន្ទះដីឥដ្ឋនៅមេសូប៉ូតាមីដែរ។

នៅប្រទេសអេហ្ស៊ីប គេសរសេរអក្សរលើសំបករុក្ខជាតិម៉្យាង ឈ្មោះ ប៉ាពីរុស្ស (Papyrus) ដែលដុះតាមជ្រលងភ្នំក្បែរទន្លេនីល ។ អ្នកស្រាវជ្រាវបានរកឃើញរមូរសំបកឈើជាច្រើន ដែលមានសរសេរអក្សរ។ ក្នុងឆ្នាំ១៨០០ មុនគ.ស អ្នកអក្សរសាស្ត្របុរាណអេហ្ស៊ីបបានយកដើមប៉ាពីរុស្ស ដែលជាប្រភេទដើមត្រែងទៅបកសំបកចេញ និងកាត់ជាបន្ទះតូចៗ រួចតម្រៀបគរលើគ្នា បន្ទាប់មកគេដំវាទឹងដំបងឱ្យសំប៉ែតហើយយកហាលថ្ងៃ ដោយសង្កត់ឱ្យរាបស្មើ ទើបយកទៅបិទបន្តគ្នាបង្កើតបានជារមូរយ៉ាងវែងដូចជាកន្ទេលសម្រាប់សរសេរអក្សរ រួចគេមូរទុកក្នុងបំពង់រាងស៊ីឡាំង ។ ទាំងអស់នេះហៅថា វ៉ូលូម៉ង់ (Volumen) ។

នៅពែរហ្គាម (Pergame) នៅតំបន់អាស៊ីមីណើរ (Asie Mineure) គេយកស្បែកគោ ចៀម ប្រើស និងពពែ ដែលគេដាក់ថ្នាំសម្លាប់ស្បែក រួចច្នៃដើម្បីសរសេរអក្សរបានហៅថា ប៉ាស៊ីម៉ាំង (Parchemin)។ ការរកឃើញនេះបាននាំឱ្យមានការបង្កើតជាគម្ពីរតម្រាតូដិច (Codex) នៅស.វ ទី៤។ គម្ពីរនេះគេបង្កើតឡើងដោយផ្ទាំងសន្លឹកបត់ និងដេរភ្ជាប់គ្នាទាំងអស់ដែលអាចសរសេរ គឺជំនួសឱ្យវ៉ូលូម៉ង់។

លុះមកដល់ស.វ ទី២នៃគ្រិស្តសករាជ ទើបមានជនជាតិចិនម្នាក់ឈ្មោះ សាយ លន់ បានរកឃើញវិធីបង្កើតក្រដាសតាមរយៈសំបុកសត្វឪម៉ាល់។ គាត់បានសង្កេតឃើញនៅលើមាត់រន្ធនៃសំបុកសត្វឪម៉ាល់ មានភ្នាសពណ៌សស្វិត អាចធន់នឹងកំដៅថ្ងៃ ភ្លៀង និងខ្យល់។ សម្មតិកម្មទាំងនេះ ជាមូលដ្ឋាននៃការសិក្សាស្រាវជ្រាវរបស់គាត់។ គាត់តាមដានឃើញសត្វឪម៉ាល់ហើរទៅកកេរដើមឫស្សី ឬដើមមនជាកំទេចល្អិតៗ រួចពាំយកមកធ្វើជាភ្នាសស្តើងពណ៌សដោយបានបញ្ចេញទឹកមាត់របស់វាក្នុងការផ្សារភ្ជាប់ជាបន្ទះស្តើង។ គាត់គិតថា ប្រសិនបើអាចកិនដើមឈើឱ្យម៉ដ្ឋ រួចផលិតទឹកម៉្យាងដែលមានសមាសធាតុផ្សំដូចគ្នានឹងទឹកមាត់សត្វឪម៉ាល់មកលាយ ហើយវាស



www.elibraryofcambodia.org

ឱ្យស្អើង តើនឹងអាចទទួលបានភ្នាសពណ៌ស (ក្រដាស) នោះដែរឬទេ?

ក្រោមការព្យាយាមរបស់គាត់ ការផលិតក្រដាសត្រូវបានបង្កើតក្នុងឆ្នាំ១០៥ នៃគ.ស ធ្វើឱ្យគាត់ក្លាយជាជនទីមួយលើពិភពលោកក្នុងការផលិតក្រដាស។ ប៉ុន្តែប្រទេសចិនបានលាក់ការសម្ងាត់នេះអស់រយៈពេលជិត ៧០០ ឆ្នាំ។ មកដល់ឆ្នាំ ៧១៥ នៃគ.ស ក្នុងពេលមានសង្គ្រាមពួកអារ៉ាប់បានចាប់អ្នកផលិតក្រដាសជនជាតិចិនដាក់គុក។ ចិនក៏ផ្ទេរមុខរបរនេះឱ្យពួកអារ៉ាប់ ហើយក្រដាសត្រូវគេយកមកផលិតសៀវភៅតាំងពីពេលនោះមក។

ការរកឃើញក្រដាសត្រូវបានគេយកមកអនុវត្តដោយប្រទេសឥស្លាមនៅជាប់សមុទ្រមេឌីទែរ៉ាណេ បន្ទាប់មកបានរីកសាយភាយនៅក្នុងទ្វីបអឺរ៉ុបទាំងមូលចាប់ពីស.វ ទី១៣មក។ ស្របពេលជាមួយគ្នានោះ នៅប្រទេសចិនសិល្បៈនៃចម្លាក់លើឈើ ដែលគេត្រូវអនុវត្តច្រើនសតវត្សមកហើយ ក៏មានការរីកចម្រើនដែរ គឺជាបន្ទះចម្លាក់ឈើដែលនៅលើនោះគេបានឆ្លាក់ជាទម្រង់ក្បាច់មួយ បន្ទាប់មកគេលាបទឹកខ្មៅ រួចយកសន្លឹកអ្វីមួយ ឬកំណាត់សំពត់មួយផ្ទាំងមកប្រថាប់ពីលើដើម្បីថ្លិតយករូបនោះ ។ បន្ទាប់មក បច្ចេកទេសនេះក៏ត្រូវគេប្រើប្រាស់លើអកំណាត់សំពត់ដើម្បីឆ្លាក់រូបភាពពីសាសនា ឬដើម្បីធ្វើសន្លឹកបៀរសម្រាប់លេងដែរ។ ក្រៅពីការបង្កើតក្រដាស និងរូបចម្លាក់បច្ចេកទេសផ្សំគ្នាបីទៀតដែលនាំឱ្យមានការបង្កើតរោងពុម្ពនៅស.វ ទី១៥ គឺ:

- ការផលិតសញ្ញាចល័តអំពីលោហធាតុ (សញ្ញាជាអក្សរពុម្ព អក្សរ សញ្ញាវណ្ណយុត្តិ ឬក្បាច់) ដែលគេផ្គុំដើម្បីបង្កើតជាពាក្យ និងអត្ថបទ។

- ការប្រើប្រាស់ឃ្នាបគាប (ដែលគេបានស្គាល់រួចមកហើយ ឃ្នាបនេះត្រូវបានគេប្រើសម្រាប់សង្កត់គាបទំពាំងបាយជូដើម្បីផលិតស្រា) ។

- ការបង្កើតទឹកខ្មៅដែលមិនស្រូវរាវ ដូចជាទឹកថ្នាំដែលស្មេរធ្លាប់ប្រើ ។ រោងពុម្ពត្រូវបានបង្កើតឡើងដោយលោក ហ្គុយ តំប៊ែរ (Gutemberg) នៅមេយ៉ង់ស៍ (Mayence) ប្រទេសអាល្លឺម៉ង់ នាឆ្នាំ ១៤៥០។ សៀវភៅទីមួយលើពិភពលោក ដែលត្រូវបានគេបោះពុម្ពដំបូង គឺសៀវភៅគម្ពីរប៊ីប ៤២បន្ទាត់ (ព្រោះវាមាន ៤២បន្ទាត់ក្នុងមួយទំព័រ) ។ ក្នុងរយៈពេល៥០ឆ្នាំក្រោយមក សៀវភៅត្រូវបានបោះពុម្ពផ្សាយជាភាសាអាល្លឺម៉ង់ បារាំង និងអេស្ប៉ាញ ដោយទទួលបានជោគជ័យយ៉ាងធំធេង។ ដូច្នេះសៀវភៅ និងចំណេះដឹងត្រូវបានចែករំលែកយ៉ាងទូលាយពាសពេញពិភពលោក។

ខ. ប្រវត្តិសៀវភៅនៅកម្ពុជា

អត្ថបទសរសេរដែលមានវ័យចំណាស់ជាងគេនៅប្រទេសកម្ពុជា សុទ្ធសឹងជាអត្ថបទអក្សរសិលាចារឹក ដែលគេឆ្លាក់នៅលើផ្ទាំងសិលា លើសសរ លើថ្ពែរជាភាសាសំស្ក្រឹត ភាសាខ្មែរបុរាណ មានប្រភពតាំងពីស.វ ទី៦ នៃគ.ស មកម្ល៉េះ។ អក្សរចារឹកទាំងអស់នេះ គឺជាសក្ខីភាពសំណេរយ៉ាងសំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ហើយអាចឱ្យគេស្គាល់ពីតួនាទី និងមុខងារនៃលទ្ធិព្រាហ្មណ៍និយមនៅក្នុងប្រទេសនាសម័យបុរាណ ស្គាល់ពីការរៀបចំនយោបាយ រដ្ឋបាល សេដ្ឋកិច្ច ព្រមទាំងរឿងតំណាល និងរឿងវីរភាពព្រះមហាក្សត្រ ។ បច្ចេកទេស



www.elibraryofcambodia.org

នេះត្រូវបានប្រើពាសពេញប្រទេសនៅសម័យបុរាណ រហូតដល់ស.វ ទី២០ ហើយអត្ថបទចុងក្រោយត្រូវបានគេចារនៅឆ្នាំ១៩១៦។

ចាប់តាំងពីស.វ ទី១៥មក ទម្រង់អក្សរសិល្ប៍ថ្មីៗបានលេចឡើង និងអភិវឌ្ឍរហូតដល់ចុងស.វ ទី១៩ ។ សំណេរទាំងនេះត្រូវបានសរសេរនៅលើស្លឹករឹតធ្វើអំពីស្លឹកទ្រាំង ។ ស្លឹកទ្រាំងត្រូវបានគេកាប់យកទៅហាលថ្ងៃ ដោយសង្កត់ឱ្យរាបស្មើ បន្ទាប់មកគេចៀរជាបន្ទះប៉ុនគ្នា និងចោះប្រហោងដោតខ្សែដាក់តម្រៀបលើគ្នាជាទម្រង់ដូចសៀវភៅសព្វថ្ងៃនេះ។ គេយកវត្ថុរឹងដែលមានចុងស្រួចទៅចារលើស្លឹកនោះឱ្យមានស្នាមឆូតជា អក្សររួចហើយទើបយកម្រ័ក្សណ៍ខ្មៅមកជូតពីលើស្នាមឆូតនោះ អក្សរក៏លេចឆ្នោឡើង។ ទន្ទឹមនឹងនេះ ក៏មានការរកឃើញសំណេរនៅលើក្រាំងផងដែរ ក្រាំងនេះគេផលិតពីស្លឹកមន ហើយបត់ផ្លាស់លើគ្នា និងសរសេរតែម្ខាង។

នៅចុងសតវត្សទី១៩ ប្រទេសកម្ពុជាមានការអភិវឌ្ឍវិស័យបោះពុម្ពផ្សាយ ក្រោមរបបអាណាព្យាបាលបារាំង។ អត្ថបទបោះពុម្ពផ្សាយដំបូង គឺទាក់ទងទៅនឹងអត្ថបទសាសនា អត្ថបទច្បាប់ទូទៅ និងអក្សរសិល្ប៍បុរាណ។ រហូតមកដល់បច្ចុប្បន្ន ស្នាដៃទាំងនោះបានចម្លង ឬចារទុក និងបានប្រើប្រាស់នៅតាមវត្តប៉ុណ្ណោះ។ អត្ថបទពុទ្ធសាសនាសំខាន់ៗចងក្រងឡើងនៅក្នុងកម្រងមួយដែលមាន ១១០ភាគ (ព្រះត្រៃបិដក) ត្រូវបានកែសម្រួលពីភាសាបាលីមកជាភាសាខ្មែរនៅដើមស.វ ទី២០ ដើម្បីឱ្យព្រះសង្ឃ និង ពុទ្ធបរិស័ទមានចំនួនកាន់តែច្រើនអាចអានបាន ។ អត្ថបទដែលឆ្លាក់ដោយដៃ ឬសរសេរមានលក្ខណៈស័ក្តិសិទ្ធិមិនត្រឹមតែខ្លឹមសារទេ ចម្លាក់ផ្ទាល់នោះក៏មានភាពស័ក្តិសិទ្ធផងដែរ ហើយក៏ត្រូវគេចាត់ទុកថាជាវត្ថុគួរឱ្យគោរព និងកោតសរសើរពីជំនាន់មួយទៅជំនាន់មួយទៀត ។ បន្ទាប់មកមានការបះបោរប្រឆាំងយ៉ាងខ្លាំងពីសំណាក់ពួកបព្វជិត នៅទីបំផុតសំណេរមួយចំនួនត្រូវបានបោះពុម្ពលើក្រដាស និងផ្សព្វផ្សាយកាន់តែទូលំទូលាយ។ ការចែកផ្សាយនោះបានធ្វើឱ្យមាន "ប្រជាធិបតេយ្យកម្ម" នៃអំណាន។ ចាប់ពីទស្សវត្សរ៍ឆ្នាំ១៩២០មក ទស្សនាវដ្ដីវប្បធម៌បានលេចឡើង ហើយបានកត់ត្រាថា ជាដើមដំបូងនៃការផ្សព្វផ្សាយអក្សរសិល្ប៍ខ្មែរ។

- កំណើតនៃសៀវភៅរូបភាព

នៅក្នុងឆ្នាំ ១៦៥៨ លោក ជូហាន អាម៉ូសខាំនៀស (Johann Amos Comenius) ជាជនជាតិអាល្លឺម៉ង់បានបង្ហាញឱ្យគេឃើញរូបភាពមានសារៈសំខាន់ គឺថាពិភពលោកបានបង្ហាញដោយរូបភាព។ ក្នុងសម័យនោះសៀវភៅភាគច្រើនជាប្រភេទសព្វវចនាធិប្បាយ (Encyclopedai) ដែលមានអក្សរច្រើន ប៉ុន្តែមានរូបភាពតិច ត្រូវបានបោះពុម្ពដោយបន្ទះឈើ ។

នៅក្នុងឆ្នាំ១៨៤៥ លោកបណ្ឌិត ហេនរីច ហូមេន ជាជនជាតិអាល្លឺម៉ង់បានសរសេរសៀវភៅរូបភាពអំពីសីលធម៌ ការទូន្មានប្រៀនប្រដៅទៅកូនប្រុសគាត់។ គេឃើញថាសៀវភៅរូបភាពនោះ មិនទាន់ពេញចិត្តអ្នកអាននៅឡើយទេ ជាពិសេសកុមារ ។

នៅក្នុងឆ្នាំ ១៨៤៦ លោក អិនវ៉ត់ទ៍ លៀរ ជាជនជាតិអង់គ្លេស បានសរសេរសៀវភៅរូបភាពអំពី "មិនសមហេតុផល" ។



www.elibraryofcambodia.org

- នៅក្រោយពាក់កណ្ដាលសតវត្សរ៍ទី ១៩

ស្របទឹងការអភិវឌ្ឍន៍បច្ចេកទេសនៃការបោះពុម្ពពណ៌ធម្មជាតិនោះ ការបោះពុម្ពសៀវភៅរូបភាពបានកើនចំនួនយ៉ាងច្រើន។ ព្រឹត្តិការណ៍នេះបានជំរុញឱ្យវិចិត្រករធ្វើសៀវភៅរូបភាព។ ដូច្នេះសៀវភៅរូបភាពពណ៌ធម្មជាតិត្រូវបានផលិតជាបន្តបន្ទាប់ ។

- នៅដើមសតវត្សរ៍ទី ២០

សៀវភៅរូបភាពដែលមានគុណភាពល្អៗត្រូវបានគេបោះពុម្ពផ្សាយពាសពេញទ្វីបអឺរ៉ុប ជាពិសេសប្រទេសអង់គ្លេស។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩១០ អំឡុងសង្គ្រាមលោកលើកទី ១ ការបោះពុម្ពសៀវភៅរូបភាពបានថយចុះ។ ប៉ុន្តែក្រោយពាក់កណ្ដាលទសវត្សឆ្នាំ ១៩២០ ការបោះពុម្ពសៀវភៅនៅសហរដ្ឋអាមេរិកមានសកម្មភាពរស់រវើក ។

- នៅទសវត្សរ៍ឆ្នាំ ១៩៣០

នៅអំឡុងពេលនោះជាជំនាន់ដែលនៅទ្វីបអឺរ៉ុប និងអាមេរិកមានសៀវភៅរូបភាពយ៉ាងច្រើន ហើយសៀវភៅរូបភាពទាំងនោះមាននាដកម្មនៃការនិពន្ធកាន់តែប្រសើរថែមទៀត។

លក្ខណៈទីមួយ : ផ្ទៃរឿងលាតត្រដាងពីភាពស្វាហាប់ ។ រូបភាពនៃរឿងបង្ហាញប្រាប់ពីខ្លឹមសាររឿងនៃសៀវភៅរូបភាព ។ ចំនួនសៀវភៅរូបភាព ដែលមានរូបភាពបង្ហាញប្រាប់ពីខ្លឹមសាររឿងមានចំនួនកើនឡើង។ រីឯសៀវភៅរូបភាពដែលមានពាក្យពេចន៍រាយរ៉ាប់ពន្យល់អំពីខ្លឹមសារនៃរឿង ក៏ស្ទើរតែចាំបាច់ផងដែរ។

លក្ខណៈទីពីរ : វត្ថុ ឬយានជំនិះមានលក្ខណៈជាមនុស្ស ដែលបានតួរតួអង្គនោះជាវីរបុរស នៃរឿងក្នុងសៀវភៅរូបភាព។

- នៅទសវត្សរ៍ឆ្នាំ ១៩៤០

ក្រោយសង្គ្រាមលោកលើកទី ២ នៅពេលសេដ្ឋកិច្ចបានល្អប្រសើរឡើងវិញ ជីវភាព និងការរស់នៅរបស់ពលរដ្ឋមានស្ថេរភាព សៀវភៅរូបភាពក៏មានបច្ចេកទេសថ្មីផ្សេងៗជាច្រើនទៀត បានធ្វើការបោះពុម្ព។ ពេលនោះសៀវភៅរូបភាពត្រូវបានពិចារណាចាត់ជាក្រុមមួយនៃសិល្បៈ ហើយគំនិតនេះបានសម្តែងឡើងនូវមនោសញ្ចេតនាទាក់ទាញអារម្មណ៍ ធ្វើឱ្យចំនួនវិចិត្រករងាកមកធ្វើសៀវភៅរូបភាព ។ សៀវភៅរូបភាពបានកើនឡើងជាបន្តបន្ទាប់ ។

- នៅក្រោយឆ្នាំ ១៩៦០ មកដល់បច្ចុប្បន្ន

វិចិត្រករបានស្វែងរកមូលបញ្ហា (Themes) នៃរឿង និងបច្ចេកទេសថ្មីៗដើម្បីការអភិវឌ្ឍន៍សៀវភៅរូបភាព។



www.elibraryofcambodia.org

ពួកគេបានព្យាយាមបង្កើត និងច្នៃវិធីដែលមិនប្រក្រតីសម្រាប់សៀវភៅរូបភាព ។ សៀវភៅរូបភាពដែលគ្មានពាក្យពេចន៍ បានបោះពុម្ពផ្សាយចេញជារូបរាងឡើង ហើយបានទទួលការទាក់ទាញចិត្តយ៉ាងខ្លាំងពីពលរដ្ឋ ជាពិសេសនៅក្នុងរង្វង់អ្នកអានសៀវភៅរូបភាពបានរីកសុះសាយមិនត្រឹមតែកុមារប៉ុណ្ណោះទេ ក៏មានមនុស្សគ្រប់វ័យផងដែរ ។

គ. ជ្រើសរើសសៀវភៅរូបភាពសម្រាប់កុមារ

និយមន័យ

តើសៀវភៅរូបភាពជាអ្វី? គឺជាសៀវភៅដែលមានរូបភាពសមស្របនឹងអត្ថបទ ហើយអត្ថបទនោះងាយៗទាក់ទងទៅនឹងមូលបញ្ហាជាសាកលនៃរឿងដែលកុមារអាចស្វែងយល់បាន ។

តើមូលបញ្ហាជាសាកលនៃរឿងជាអ្វី? គឺជាគំនិត ឬសារដ៏មានសារសំខាន់ដែលអ្នកនិពន្ធ និងវិចិត្រករចង់ប្រាប់ដល់អ្នកអាន ។

លក្ខណៈវិនិច្ឆ័យលើសៀវភៅរូបភាពសម្រាប់កុមារ

សៀវភៅរូបភាពដែលបានអានជាយូរមក មនុស្សចាស់ ឬកុមារមានការគាំទ្រក្នុងការអានសៀវភៅនោះ គឺជាការចង្អុលបង្ហាញដើម្បីធ្វើការវិនិច្ឆ័យលើគុណភាពសៀវភៅ ។ សៀវភៅទាំងអស់មិនមែនសុទ្ធតែមានមូលបញ្ហាក្នុងការអប់រំឡើយ ។ ដូច្នេះបណ្ណារក្សត្រូវជ្រើសរើសសៀវភៅដែលមានការអប់រំដល់ពួកគេ ដើម្បីអាន ឬយកទៅនិទានឱ្យពួកគេ គឺថាសៀវភៅរូបភាពដែលបង្កប់នូវមូលបញ្ហានៃរឿង ដែលអ្នកនិពន្ធបានផ្ដល់ពិសោធន៍របស់គេដល់កុមារទាំងនេះជាឧទាហរណ៍ខ្លះៗ ដែលយើងគួរជ្រើសរើសសារសំខាន់ដើម្បីបញ្ជូនទៅកុមារ :

- ការគោរព ឬឱ្យតម្លៃខ្លួនឯង
- ការទទួលខុសត្រូវ
- ការចែករំលែក
- សច្ចៈភាព សេចក្ដីស្មោះត្រង់
- ការដោះស្រាយបញ្ហាដោយសន្តិវិធី
- ការគោរព និង ការគួរសមចំពោះអ្នកដទៃ
- តម្លៃនៃបរិស្ថានវិទ្យា
- ការព្យាយាម ស្មារតីលះបង់ និង ភាពអត់ធ្មត់
- សេចក្ដីស្រឡាញ់ដោយគ្មានលក្ខខ័ណ្ឌ

ដោយហេតុថាសៀវភៅរូបភាពសម្រាប់កុមារ បានឆ្លុះបញ្ចាំងពីតម្លៃនៃការអភិវឌ្ឍន៍ នៃដំណើរការលូតលាស់ស្មារតី និងបញ្ញា ដូច្នេះមូលបញ្ហារឿងនៃសៀវភៅរូបភាពគឺជាសារ របស់អ្នកនិពន្ធប្រកបដោយប្រសិទ្ធភាពជាក់លាក់ ដែលអាចជួយកុមារឱ្យជំនះបាននូវអ្វីៗដែលអវិជ្ជមាន ។



www.elibraryofcambodia.org

## IV. ការគ្រប់គ្រងបណ្ណាល័យ

### ក. រដ្ឋបាលបណ្ណាល័យ

#### ១. ការគ្រប់គ្រង និង ចាត់ចែងបុគ្គលិក

ការងារគ្រប់គ្រងបុគ្គលិក គឺជាកត្តាចាំបាច់ក្នុងការជំរុញសកម្មភាពការងារដើម្បីសម្រេចគោលដៅអង្គភាព ឬស្ថាប័ន ហើយក៏ជាកម្លាំងចលករដ៏សំខាន់នៅពេលដែលការគ្រប់គ្រងបុគ្គលិកបានល្អ។ ហេតុនេះ ដើម្បីឱ្យការងារបណ្ណាល័យដំណើរការទៅបានល្អ ថ្នាក់ដឹកនាំគួររៀបចំចាត់ចែងទៅតាមនិយាមដែលក្រសួងអប់រំ យុវជន និងកីឡារួមជាមួយស្ថានភាពជាក់ស្តែងនៅក្នុងសាលារៀននីមួយៗ។

ប្រសិនបើបណ្ណាល័យមានបណ្ណារក្សតែម្នាក់ ត្រូវរកអ្នកជំនួយបន្ថែមក្នុងបណ្ណាល័យ ដូចជា គ្រូ សិស្ស បុគ្គលិកសិក្សាដែលស្ម័គ្រចិត្តជួយការងារបណ្ណាល័យក្រៅម៉ោងធ្វើការ បង្រៀន និងរៀនរបស់ពួកគេ ។ បណ្ណារក្សអាចបណ្តុះបណ្តាលពួកគេឱ្យចេះពីការងារបណ្ណាល័យខ្លះៗ រួមទាំងការនិទានរឿង ល្បែងសិក្សា សិល្បៈ ដើម្បីជាជំនួយក្នុងការងារបណ្ណាល័យ និងជំនួសពេលដែលបណ្ណារក្សជាប់រវល់ ឬអវត្តមាន។

ផ្ទុយទៅវិញ បើបណ្ណាល័យមានបណ្ណារក្សចាប់ពី ២នាក់ឡើងទៅ អ្នកគ្រប់គ្រងបណ្ណាល័យត្រូវបែងចែកភារកិច្ចឱ្យពួកគេធ្វើ និងទទួលខុសត្រូវចំពោះសកម្មភាពការងារដែលបណ្ណារក្សម្នាក់ៗត្រូវបំពេញប្រចាំថ្ងៃ ដូចជា ការរៀបចំចងក្រងឯកសារ ការបម្រើសេវាកម្មបណ្ណាល័យ និទានរឿង ល្បែងសិក្សា សិល្បៈ ការធ្វើគម្រោងផែនការ និងការធ្វើរបាយការណ៍ពីសកម្មភាពរបស់បណ្ណាល័យ ។

#### ២. ការតាមដាន និង វាយតម្លៃបុគ្គលិក

អ្នកទទួលខុសត្រូវបណ្ណាល័យ ត្រូវពិនិត្យមើលចំនួនបុគ្គលិកអាចរ៉ាប់រងការងារអ្វីបានខ្លះ តើចំនួនសម្ភារបរិក្ខារសម្រាប់ផ្តល់ឱ្យបណ្ណារក្សប្រើប្រាស់គ្រប់គ្រាន់ដែរឬទេ? តើការបំពេញការងាររបស់ពួកគេ និង បន្ទុកការងារដែលត្រូវរ៉ាប់រង និងឥរិយាបថរបស់បណ្ណារក្សជាមួយកុមារដូចម្តេចដែរ? តើត្រូវបណ្តុះបណ្តាលបណ្ណារក្សបន្ថែមដែរឬទេ? តើត្រូវបណ្តុះបណ្តាលលើជំនាញអ្វី? ត្រូវពិនិត្យមើលថាតើការស្នើសុំនោះសមស្របទៅនឹងថវិកាសម្រាប់ទ្រទ្រង់ដែរឬទេ? ជាពិសេសត្រូវរៀបចំឱ្យមានការប្រជុំប្រចាំខែក្នុងទិសដៅកែលំអការងារ ដែលបានអនុវត្តកន្លងមក និងលើកទិសដៅការងារបន្ត ។ ម្យ៉ាងទៀត ភារកិច្ចរបស់ប្រធាន គឺធ្វើការទំនាក់ទំនងខាងក្រៅដើម្បីដកស្រង់បទពិសោធន៍ល្អៗ សម្រាប់ធ្វើការកែលំអបណ្ណាល័យឱ្យអភិវឌ្ឍជាលំដាប់ ។

#### ៣. ការស្វែងរកឯកសារ

ការបង្កើនមូលនិធិឯកសារសម្រាប់ប្រើប្រាស់នៅបណ្ណាល័យ គឺជាកត្តាចាំបាច់បំផុត ដែលបណ្ណារក្សត្រូវយកចិត្តទុកដាក់ ព្រោះនៅពេលដែលបណ្ណាល័យមានឯកសារសម្បូរបែប ហើយថ្មីៗជានិច្ច ដើម្បីធ្វើឱ្យអ្នកអានពេញចិត្តនឹងចូលមកប្រើប្រាស់នៅបណ្ណាល័យ ។វិធីស្វែងរកឯកសារមាន :



www.elibraryofcambodia.org

❒ ការទិញ

ជាទូទៅតាមសាលារៀននីមួយៗ តែងតែគ្រោងថវិកាសម្រាប់ចំណាយទិញសម្ភារដើម្បីដំណើរការ និងទិញឯកសារដាក់បន្ថែមសម្រាប់ប្រើប្រាស់ក្នុងបណ្ណាល័យផងដែរ ។ សាលារៀនខ្លះបានរៀបចំគណៈកម្មាការសម្រាប់ធ្វើការជ្រើសរើស និងសម្រេចលើចំណងជើងសៀវភៅ ឬឯកសារដែលត្រូវទិញដាក់បណ្ណាល័យរបស់ខ្លួន ។

❒ អំណោយ

ជារឿយៗសាលារៀនបានទទួលអំណោយឯកសារពីអ្នកនិពន្ធ សប្បុរសជន អង្គការនានា ឬជួនកាលថ្នាក់ដឹកនាំសាលាបានធ្វើលិខិតស្នើសុំដោយមិនរង់ចាំគេឱ្យឡើយ ។

❒ ការដោះដូរ

ប្រសិនបើសាលារៀននោះបានផលិតបោះពុម្ពសៀវភៅ ឯកសារស្រាវជ្រាវ ព្រឹត្តិបត្រ ទស្សនាវដ្ដី បណ្ណារក្សអាចប្ដូរឯកសារទាំងនេះជាមួយបណ្ណាល័យផ្សេងទៀត ។

៤. ការងារទំនាក់ទំនង

ការទំនាក់ទំនងចែកចេញជា ២ ប្រភេទគឺ :

❒ ការទំនាក់ទំនងក្នុងសាលារៀន

បណ្ណារក្សរាយការណ៍ពីសកម្មភាព ផលវិបាក និងតម្រូវការរបស់បណ្ណាល័យដល់សិស្ស គ្រូ បុគ្គលិកសិក្សា និងថ្នាក់ដឹកនាំសាលារៀនដើម្បីជួយជំរុញដល់សកម្មភាពបណ្ណាល័យកាន់តែល្អប្រសើរឡើង ។

❒ ការទំនាក់ទំនងក្រៅសាលារៀន

បណ្ណារក្សស្រង់ និងផ្លាស់ប្ដូរនូវបច្ចេកទេស បទពិសោធន៍ និងចំណុចល្អៗពីបណ្ណាល័យដទៃទៀត សម្រាប់យកមកធ្វើការកែលំអបណ្ណាល័យឱ្យមានការអភិវឌ្ឍន៍ជាលំដាប់ ។

៥. ការផ្គត់ផ្គង់ និងថែទាំសម្ភារ បរិក្ខារ

សម្ភារ បរិក្ខារ មិនអាចប្រើប្រាស់បានរហូតនោះទេ ទាមទារឱ្យមានការផ្គត់ផ្គង់ និងថែរក្សាជាប្រចាំ ទើបបណ្ណាល័យអាចដំណើរការបានល្អ ។

ខ. ការរៀបចំចងក្រង និងការគ្រប់គ្រងឯកសារ

១. ការផ្ទៀងផ្ទាត់ឯកសារ និងការបោះត្រា :

ភាគច្រើនឯកសារបញ្ជូនមកបណ្ណាល័យ តែងភ្ជាប់មកជាមួយនូវលិខិតបញ្ជូនដែលរៀបរាប់ពីសៀវភៅ ឬឯកសារបានផ្ញើមក ។ ដូច្នេះបណ្ណារក្សត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ឯកសារជាមួយបញ្ជី តើត្រឹមត្រូវឬទេ? ប្រសិនជារហែក សើម ឬខូចគុណភាពត្រូវរាយការណ៍ទៅថ្នាក់ដឹកនាំសាលាដើម្បីមានវិធានការ ឬបញ្ជូន



www.elibraryofcambodia.org

ទៅម្ចាស់ដើមវិញ។ ក្រោយពិនិត្យឃើញថាត្រឹមត្រូវហើយ យើងត្រូវបោះត្រាសម្គាល់ថាជាសៀវភៅឯកសាររបស់បណ្ណាល័យសាលារៀនយើង ។

២. ការចុះបញ្ជីសៀវភៅចូល

ប្រការដែលល្អ គួរជ្រើសរើសប្រភេទសៀវភៅក្រាស់ (Journal Book) ព្រោះងាយស្រួលក្នុងការចុះចូល និងប្រើប្រាស់បានយូរ ។ ក្រោយពីបោះត្រារួច យើងត្រូវចុះចូលក្នុងបញ្ជីសៀវភៅចូលដូចគំរូខាងក្រោមៈ

- លេខរៀងសៀវភៅ ឬលេខសារពើភ័ណ្ឌសៀវភៅ Inventory Number
- ថ្ងៃ ខែ ឆ្នាំ Date
- ឈ្មោះអ្នកនិពន្ធ Author
- ចំណងជើងសៀវភៅ Title
- អ្នកបោះពុម្ព Publisher
- ទីកន្លែងបោះពុម្ព Place of Publisher
- ឆ្នាំបោះពុម្ព Date of Publisher
- ចំណាត់ថ្នាក់សៀវភៅ Book Classification
- លេខសៀវភៅខ្នាតអន្តរជាតិ **(ISBN = International Standard Book Number)**
- ប្រភពផ្តល់ Source
- ផ្សេងៗ Divers

ក្រោយពីចុះបញ្ជីសៀវភៅចូលរួចហើយ សៀវភៅត្រូវបានបញ្ជូនទៅកន្លែងធ្វើចំណាត់ថ្នាក់សៀវភៅ ប័ណ្ណសៀវភៅ ឬកាតាឡុក (Catalogue) ។

៣. ការចុះបញ្ជីទស្សនាវដ្តី

បណ្ណារក្សអាចធ្វើលើក្រដាស A4 ហើយកឹបចូលគ្នា ឬដាក់ក្នុងសឺមី ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។ គំរូបញ្ជីទស្សនាវដ្តីៈ

- ចំណងជើង Title
- រយៈពេលផ្សាយ Period of Publishing
- ឆ្នាំ Year
- មករា January
- កុម្ភៈ February



www.elibraryofcambodia.org

- មីនា March
- មេសា April
- ឧសភា May
- មិថុនា June
- កក្កដា July
- សីហា August
- កញ្ញា September
- តុលា October
- វិច្ឆិកា November
- ធ្នូ December

៤. ការធ្វើចំណាត់ថ្នាក់សៀវភៅ

ហេតុអ្វីយើងចាំបាច់ធ្វើចំណាត់ថ្នាក់សៀវភៅ?

ការធ្វើចំណាត់ថ្នាក់ ឬការដាក់លេខកូដសៀវភៅ គឺជាការងារមួយដ៏សំខាន់អាចឱ្យយើងប្រមូលឯកសារដែលមានប្រធានបទដូចគ្នា ឬប្រហាក់ប្រហែលគ្នាដាក់នៅជាក្រុមក្បែរគ្នា ហើយជួយសម្រួលដល់បណ្ណារក្សក្នុងការគ្រប់គ្រងឯកសារឱ្យបានល្អ ផ្ដល់ភាពងាយស្រួលក្នុងការរកឯកសារតាមធ្នើរ និងជួយសន្សំពេលវេលារបស់អ្នកអានអ្នកស្រាវជ្រាវបានទៀតផង ។

ការធ្វើចំណាត់ថ្នាក់សៀវភៅ ឬការដាក់កូដសៀវភៅមាន :

- ការដាក់កូដដោយប្រើលេខ
    - ចំណាត់ថ្នាក់ទសភាគឌីវេ (DDC= Dewey Decimal Classification)
    - ចំណាត់ថ្នាក់ផ្ទៃក្នុង (Internal Classification)
    - ចំណាត់ថ្នាក់ទសភាគសាកល (CDU/UDC = Universal DecimalClassification)
- ការដាក់កូដដោយប្រើអក្សរ (Timetable Classification)
- ការដាក់កូដដោយប្រើពណ៌ (Junior Color Classification)

ការចាត់ចំណាត់ថ្នាក់សៀវភៅមានច្រើនយ៉ាង ប៉ុន្តែយើងជ្រើសយកចំណាត់ថ្នាក់របស់លោក Dewey យកមកបង្ហាញសម្រាប់ប្រើប្រាស់នៅសាលារៀនចំណេះទូទៅ ។



www.elibraryofcambodia.org

ចំណាត់ថ្នាក់ទសភាគឌីវើ (Dewey Decimal Classification)

ចំណាត់ថ្នាក់ទសភាគឌីវើ ត្រូវបានបង្កើតឡើងដោយលោក មេលវិល ឌីវើ (Melvil Dewey) ជនជាតិអាមេរិកកាំង ដែលធ្វើការនៅក្នុងបណ្ណាល័យ។ ចំណាត់ថ្នាក់ទសភាគឌីវើ គឺជារបៀបបែងចែកឯកសារជា ១០ ក្រុមធំៗទៅតាមប្រធានបទរបស់វា។ ក្រុមទាំង១០ គឺៈ

-000 ស្នាដៃទូទៅ (Generalities)

-១00 ទស្សនវិជ្ជា ចិត្តសាស្ត្រ (Philosophy-psychology)

-២00 សាសនា (Religion)

-៣00 វិទ្យាសាស្ត្រសង្គម ច្បាប់ (Social Sciences-Laws)

-៤00 ភាសា (Language)

-៥00 វិទ្យាសាស្ត្រពិត គណិតវិទ្យា (Pure Science-mathematics)

-៦00 បច្ចេកទេស វិទ្យាសាស្ត្រអនុវត្ត (Technology -Applied Sciences)

-៧00 សិល្បៈ The Arts

-៨00 អក្សរសាស្ត្រ (Literature)

-៩00 ភូមិវិទ្យា ប្រវត្តិវិទ្យា (Geography-History)

ប្រវត្តិលោក Melvil Dewey (១៨៥១-១៩៣១)

លោក Melvil Dewey កើតនៅឆ្នាំ១៨៥១។ ពេលអាយុបាន ២១ឆ្នាំ គាត់ធ្វើជាជំនួយការនៅបណ្ណាល័យមហាវិទ្យាល័យ Amherst ។ នៅឆ្នាំ១៨៧៣ គាត់បានចាប់ផ្តើមរៀបចំការធ្វើ DDC ហើយបានបោះពុម្ពប្រព័ន្ធនេះ ដំបូងបំផុតនៅឆ្នាំ១៨៧៦ ដែលមានតែ ៤៤ ទំព័រប៉ុណ្ណោះ ហើយគេបានដាក់ចំណងជើងថា A Classification and Subject Index for Cataloguing and Arranging the Books and Pamphlets of a Library។ ការបោះពុម្ពលើកទីពីរ គឺនៅឆ្នាំ១៨៨៥ ហើយនៅឆ្នាំ១៩៣១ Dewey បានលាចាកលោក ដោយបន្សល់ទុកនូវស្នាដៃដ៏សំខាន់នេះរហូតមក។ នៅឆ្នាំ១៩៣២ គេបានបោះពុម្ពឡើងវិញជាលើកទី១៣ ដើម្បីឧទ្ទិសនិងរំលឹកដល់ស្នាដៃរបស់គាត់ ។ គឺចាប់ពីការបោះពុម្ពលើកទី១៣នេះហើយ ដែលគេបានដាក់ឈ្មោះគាត់រហូតមកថា Dewey Decimal Classification។ ឆ្នាំ១៩០៥ ឯកសារនេះត្រូវបានបោះពុម្ពជាភាសាបារាំង លើកទី១ ក្រោយមកត្រូវបានបកប្រែទៅជាភាសាផ្សេងទៀតជាង ៣០ភាសានៅក្នុងសាកលលោក និងមានប្រទេសជាង ១៣៥ នៅក្នុងសាកលលោកដែលប្រើប្រពន្ធ័នេះ ។



www.elibraryofcambodia.org




Melvil Dewey (1851-1931)

ចំណុចដែលបណ្ណារក្សត្រូវចាំក្នុងការចុះឈ្មោះអ្នកនិពន្ធ :

- ប្រជាជនអឺរ៉ុបគេដាក់ឈ្មោះផ្ទាល់ខ្លួនមុនទើបដាក់គោត្តនាមជាក្រោយ ។ ដូច្នេះពេលសរសេរឈ្មោះអ្នកនិពន្ធយើងត្រូវសរសេរគោត្តនាមជាមុន ហើយដាក់សញ្ញាក្បៀស (,) មួយដើម្បីបញ្ជាក់ថាយើងត្រឡប់ឈ្មោះអ្នកនិពន្ធ។ ឧ. ឈ្មោះអ្នកនិពន្ធសរសេរថា: David Chandler យើងត្រូវសរសេរថា: Chandler, David ប៉ុន្តែខាងក្រោយចំណងជើងដែលយើងត្រូវចុះឈ្មោះអ្នកនិពន្ធម្តងទៀតនោះ ក្នុងសៀវភៅសរសេរយ៉ាងណាគឺ យើងត្រូវចុះដូចនោះដែរ ។ ចំពោះគោរមងារ Dr., Prof., Ph.D. គេមិនត្រូវចុះក្នុងបណ្ណសៀវភៅទេ ។

- ចំពោះប្រជាជននៅអាស៊ីដូចជា កម្ពុជា ឡាវ វៀតណាម ចិន ...។ គេដាក់គោត្តនាមពីមុខនាមផ្ទាល់ខ្លួនដូច្នេះយើងមិនចាំបាច់ត្រឡប់ឈ្មោះរបស់អ្នកនិពន្ធទេ និងមិនចាំបាច់ដាក់ក្បៀសដែរ ។

- ឈ្មោះអ្នកនិពន្ធខ្លះ មានដាក់សញ្ញាតំនូសខ្លី (-) ដូចជា Jean-Marie Figo យើងត្រូវសរសេរថា: Figo, Jean-Marie ។

- ជួនកាលតំនូសខ្លីនៅលើឈ្មោះខាងចុង ដូច្នេះយើងត្រូវចាត់ទុកថា ពាក្យដែលជាប់តំនូសខ្លីគឺជាពាក្យតែមួយ ដូចពាក្យថា: Chris Wallace-Crabbe ត្រូវសរសេរថា: Wallace-Crabbe, Chris ។

- ចំពោះឈ្មោះរបស់ជនជាតិអៀឡង់ (Irish) ដែលមានអក្សរ D.J. O'Hearn យើងត្រូវសរសេរថា: O'Hearn, D.J. ។ ឈ្មោះរបស់ជនជាតិស្កុតឡែន (Scottish) Mc ឬ Mac ដូចជា Morris MacClean យើងត្រូវសរសេរ MacClean, Morris ។



www.elibraryofcambodia.org

**លេខ ISBN = International Standard Book Number**

លេខសៀវភៅខ្នាតអន្តរជាតិ (ISBN) គឺជាលេខតែមួយគត់សម្រាប់សម្គាល់ចំណងជើងសៀវភៅណាមួយ លេខនេះពុំអាចសរសេរត្រួតគ្នាបានទេ ។ ជួនកាលសៀវភៅដែលមានចំណងជើងដូចគ្នាតែមានលេខ ISBN ខុសគ្នា ដោយសារការចងជាសៀវភៅមួយដាក់ក្របក្រាស់ (hardback or hardcover) និងមួយទៀតក្របស្តើង (paperback or softcover) លេខ ISBN មាន ១០ខ្ទង់បើរាប់បញ្ចូលទាំងគំនូសខ្ញីផងទាំងអស់មាន ១៣ខ្ទង់ ។

| 0 | 07 | 667501 | X |
|---|---|---|---|
| ប្រទេស | អ្នកបោះពុម្ព | ការបោះពុម្ពសៀវភៅលើកណាមួយ | តួលេខសម្រាប់ផ្ទៀងផ្ទាត់ ឬភាសា |

ISBN ដែលផ្តើមដោយលេខ O ឬលេខ 1. បោះពុម្ពនៅប្រទេសអង់គ្លេស សហរដ្ឋអាមេរិក អូស្ត្រាលី និងកាណាដា ហើយជាភាសាអង់គ្លេស ។

ISBN ចាប់ផ្តើមដោយលេខ ២ បោះពុម្ពនៅប្រទេសបារាំង ប្រទេសបែលហ្ស៊ិក ឬប្រទេសស្វីសហើយជាភាសាបារាំង ។ ISBN ដែលចាប់ផ្តើមដោយលេខ ៩ បោះពុម្ពដោយទីភ្នាក់ងារអង្គការសហប្រជាជាតិ ។

ចំណែកតួលេខសម្រាប់ផ្ទៀងផ្ទាត់ អាចជាលេខណាមួយពីលេខ ១ ដល់ ៩ ឬ X (X=10) ។ តួលេខផ្ទៀងផ្ទាត់មានតួនាទីសម្រាប់បញ្ជាក់ថា លេខខ្ទង់ផ្សេងទៀតត្រឹមត្រូវហើយ ។ លេខ ISSN: International Standard Serial Number លេខ ISSN មានតួនាទីប្រហាក់ប្រហែល នឹងលេខ ISBN ដែរគ្រាន់តែលេខ ISSN មានតែ ៨ខ្ទង់ ហើយគេប្រើសម្រាប់តែការបោះពុម្ពទៀងទាត់ពេលវេលាតែប៉ុណ្ណោះ ។ នៅប្រទេសជាច្រើនក្នុងសកលលោក ការងារនេះជាភារកិច្ចរបស់បណ្ណាល័យជាតិនៃប្រទេសនីមួយៗ ។

### ៥. ការរៀបចំសៀវភៅចូលទូ ឬធ្នើរ

ហេតុអ្វីចាំបាច់សិក្សាពីការរៀបចំសៀវភៅចូលធ្នើរ?

ការរៀបចំសៀវភៅទៅតាមលំដាប់អក្សរក្រម តាមប្រធានបទ និងការយល់ពីរបៀបដាក់សៀវភៅនៅលើធ្នើររបស់បណ្ណាល័យផ្តល់សារៈប្រយោជន៍យ៉ាងខ្លាំងដល់ការគ្រប់គ្រងសៀវភៅបានល្អ ហើយវិធីនេះធ្វើឱ្យបណ្ណារក្សមានភាពងាយស្រួលក្នុងការរកសៀវភៅនៅលើធ្នើរក្នុងកន្លែងដែលត្រឹមត្រូវ ។ ជាពិសេសទៀតនោះ ធ្វើឱ្យសិស្ស គ្រូ អាចជ្រើសរើសយកសម្ភារអានដោយខ្លួនឯង ដោយភាពងាយស្រួល និងតាមតម្រូវការរបស់គេទៀតផង ។

### ៦. ការគ្រប់គ្រង និងវាយតម្លៃឯកសារ

ការគ្រប់គ្រង និងវាយតម្លៃឯកសារ ដើម្បីឱ្យបណ្ណារក្សដឹងពី :

- តើឯកសារដែលមាននៅក្នុងបណ្ណាល័យ និងឯកសារដែលទិញថ្មីៗអាចឆ្លើយតបតាមតម្រូវការរបស់



www.elibraryofcambodia.org

សិស្ស ត្រូវដែរឬទេ?

- តើចំនួនសៀវភៅក្នុងបញ្ជី និងចំនួនសៀវភៅតម្កល់លើធ្នើរ ឬទូមានចំនួនស្មើគ្នាដែរឬទេ? ប្រសិនបើមានការបាត់បង់ត្រូវរកមូលហេតុនេះឱ្យបានច្បាស់លាស់ ។

- ឯកសារខ្លះអ្នកអាននិយមចូលចិត្តអាន និងខ្ចីខ្លាំងណាស់ ប៉ុន្តែឯកសារខ្លះទៀតអ្នកអានមិននិយមចូលចិត្តអានសោះ ដូចនេះបណ្ណារក្សត្រូវកត់ចំណាំប្រភេទឯកសារដែលអ្នកអាននិយមចូលចិត្តនោះ ។

- វិធានការស្វែងរកឯកសារបន្ថែម ក្នុងករណីឯកសារមានចំនួនតិចតួច ក៏ប៉ុន្តែអ្នកអាននិយមប្រើច្រើន និងឯកសារដែលគ្មានរក្សាទៅឃ្លាំងក្នុងបណ្ណាល័យ តែជាតម្រូវការចាំបាច់របស់ពួកគេ ។

- ត្រួតពិនិត្យមើលតាមធ្នើរដាក់សៀវភៅ ព្រោះសៀវភៅខ្លះអ្នកអានយកទៅដាក់ខុសទីកន្លែងដើម ហេតុនេះបណ្ណារក្សត្រូវរៀបចំឱ្យបានត្រឹមត្រូវ និងមានរបៀបរៀបរយឡើងវិញ។ ចំពោះឯកសារដែលត្រូវរៀបចំ និង កែលំអឡើងវិញមានដូចជា :

- ឯកសារដែលហួសសម័យគេលែងនិយមប្រើ
- ឯកសារដែលបាត់ត្រូវរកទិញថ្មី ដើម្បីយកមកដាក់ជំនួសឯកសារដែលបាត់នោះ
- ដកចេញនូវសៀវភៅចាស់ៗដែលអ្នកអានលែងប្រើប្រាស់យកទៅទុកក្នុងឃ្លាំងបណ្តោះអាសន្ន
- ត្រូវរក្សាទុកប្រភេទឯកសារចាស់ៗដែលមានតម្លៃជាប្រវត្តិសាស្ត្រ

### គ. សេវាកម្មបណ្ណាល័យ

#### ១. ការទទួលអ្នកអាន

ការទទួលអ្នកអានគឺជាការងារដំបូងបង្អស់ ដែលបណ្ណារក្សត្រូវធ្វើនៅពេលដែលអ្នកអានថ្មីចូលបណ្ណាល័យ ។ បណ្ណារក្សត្រូវផ្តល់ព័ត៌មាន និង ណែនាំពីស្ថានភាពនានាដល់អ្នកអាន ដើម្បីឱ្យពួកគេយល់ដឹងពីបទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យ និង របៀបប្រើប្រាស់បណ្ណាល័យ ។

#### ២. ការងារខ្ចី សង

បណ្ណាល័យជាច្រើនបានអនុញ្ញាតឱ្យអ្នកអានខ្ចីសៀវភៅចេញពីបណ្ណាល័យ តាមពេលកំណត់ណាមួយ ហើយយកសៀវភៅមកសងបណ្ណាល័យវិញ ។ ដើម្បីធានាថា អ្នកអានបានសងសៀវភៅឱ្យបណ្ណាល័យវិញតាមកាលកំណត់ បណ្ណារក្សត្រូវបង្កើតឱ្យមានចរាចរសៀវភៅសមស្រប ឬប្រព័ន្ធឱ្យខ្ចីមួយ ដើម្បីរក្សាទុកកំណត់ត្រាក្នុងបញ្ជីសៀវភៅដែលឱ្យខ្ចី ឬប័ណ្ណបណ្ណាល័យ ។ បណ្ណារក្សអាចជ្រើសរើសយកកំណត់ត្រាណាមួយក៏បាន (បញ្ជីសៀវភៅដែលឱ្យខ្ចី ឬប័ណ្ណបណ្ណាល័យ) អាស្រ័យលើលទ្ធភាព និងធនធានថវិកាដែលបណ្ណាល័យមាន។ បណ្ណារក្សត្រូវចងចាំថា ចំពោះសៀវភៅដែលមានតម្លៃខ្ពស់ និងឯកសារសំខាន់ៗ មិនអនុញ្ញាតឱ្យខ្ចីចេញពីបណ្ណាល័យឡើយ ។



www.elibraryofcambodia.org

ឧទាហរណ៍

- សៀវភៅសិក្សាគោលអនុញ្ញាតឱ្យខ្ចីរយៈពេល ១ឆ្នាំសិក្សា
- សៀវភៅរឿងនិទានអនុញ្ញាតឱ្យខ្ចីរយៈពេល ៣ថ្ងៃ
- សៀវភៅស្រាវជ្រាវអនុញ្ញាតឱ្យខ្ចីរយៈពេល ២ថ្ងៃ



សកម្មភាពពេលសិស្សខ្ចី សង

❒ បញ្ជីខ្ចី សងសៀវភៅ :

ប្រការដែលល្អគួរជ្រើសរើសប្រភេទសៀវភៅក្រាស់ (Journal Book) ព្រោះងាយស្រួលក្នុងការទុកចូលបញ្ជី និងប្រើប្រាស់បានយូរ ។

- លេខរៀង : Number
- ចំណងជើងសៀវភៅ : Title
- លេខសារពើភ័ណ្ឌសៀវភៅ : Number of Inventory (INV)
- លេខកូដសៀវភៅ : Book Number Classification
- ឈ្មោះ និង អាសយដ្ឋានអ្នកខ្ចី : Name and Address of Borrower
- ថ្ងៃ ខែ ឆ្នាំ ខ្ចី : Borrower Date
- ថ្ងៃ ខែ ឆ្នាំសង : Return Date



www.elibraryofcambodia.org

- ហត្ថលេខាអ្នកខ្ចី : Borrower Signature

- ហត្ថលេខាបណ្ណារក្ស : Librarian Signature

❒ប័ណ្ណបណ្ណាល័យ :

អ្នកប្រើប្រាស់នីមួយៗត្រូវមានប័ណ្ណសមាជិកបណ្ណាល័យ ដោយមានសម្គាល់អត្តសញ្ញាណដូចជាលេខប័ណ្ណបណ្ណាល័យ ឈ្មោះ និងអាសយដ្ឋានសម្រាប់ទំនាក់ទំនង។ បណ្ណារក្សអាចច្នៃធ្វើគំរូប័ណ្ណបណ្ណាល័យទៅតាមលទ្ធភាព និងធនធានរបស់សាលារៀនខ្លួន។ ប័ណ្ណបណ្ណាល័យផ្តល់ផលប្រយោជន៍ច្រើនដល់បណ្ណារក្សក្នុងការតាមដានការប្រើប្រាស់ និងការគោរពពេលការណ៍របស់អ្នកអានចំពោះបណ្ណាល័យ ។

❒ រយៈពេលខ្ចី :

បណ្ណាល័យសាលារៀននីមួយៗ ត្រូវមានវិធានការអនុវត្តផ្ទាល់ខ្លួន ទៅលើរយៈពេលខ្ចីរបស់សិស្ស គ្រូ ។ បណ្ណារក្សអាចធ្វើការបែងចែករយៈពេលខ្ចីជា ២ប្រភេទគឺ : រយៈពេលឱ្យខ្ចីយូរសម្រាប់សៀវភៅកម្មវិធីសិក្សាដើម្បីឱ្យសិស្ស គ្រូ អាចប្រើប្រាស់រយៈពេល ១ឆ្នាំសិក្សា និងរយៈពេលឱ្យខ្ចីឆាប់សម្រាប់សៀវភៅចំណេះដឹងទូទៅ ។

❒ ការរំលឹក :

នៅពេលដែលការអនុញ្ញាតឱ្យខ្ចីបានផុតកំណត់ បណ្ណារក្សត្រូវត្រួតពិនិត្យមើលអ្នកអានបានបង្វិលសៀវភៅឱ្យបណ្ណាល័យវិញតាមកាលកំណត់។ ប្រសិនបើហួសពីការកំណត់រយៈពេល ១សប្តាហ៍ឡើងទៅបណ្ណារក្សត្រូវធ្វើការរំលឹកដល់អ្នកអានណាដែលមិនទាន់បានសងសៀវភៅឱ្យបណ្ណាល័យវិញ។ ការរំលឹកចែកចេញជាបីដំណាក់កាលគឺ:

- ការរំលឹកលើកទី១: បើសិស្សត្រូវធ្វើឡើងតាមប្រធានថ្នាក់ បើគ្រូធ្វើឡើងតាមបុគ្គល
- ការរំលឹកលើកទី២: បើសិស្សត្រូវធ្វើឡើងតាមគ្រូបន្ទុកថ្នាក់ បើគ្រូធ្វើឡើងតាមប្រធានក្រុមបច្ចេកទេស
- ការរំលឹកលើកទី៣: ស្រង់ឈ្មោះ និង រាយការណ៍ទៅថ្នាក់ដឹកនាំសាលាដើម្បីមានវិធានការ ។

ការខ្ចីហួសកំណត់ត្រូវធ្វើលិខិតរំលឹកដើម្បីទារសៀវភៅមកវិញ ក្នុងករណីធ្វើលិខិតទារម្តងហើយនៅមិនព្រមសង គឺត្រូវធ្វើលិខិតទារម្តងទៀត បើមិនព្រមសងបណ្ណារក្សត្រូវចុះទៅទារដល់ទីកន្លែងតែម្តង ។ ការងារខ្ចីសង គឺជាភារកិច្ចចាំបាច់ដែលបណ្ណារក្សគប្បីត្រូវរកវិធានការឱ្យបានល្អិតល្អន់ និងមានសៀវភៅកត់ត្រាឱ្យបានច្បាស់លាស់ទើបអាចកាត់បន្ថយការបាត់បង់បាន ។

### ៣. ការអង្កេត និង វាយតម្លៃអ្នកអាន

តើបណ្ណារក្សគួរយកចិត្តទុកដាក់ចំពោះអ្នកអានយ៉ាងណាខ្លះ? ដើម្បីឱ្យមានភាពងាយស្រួលក្នុងការតាមដានសកម្មភាពអ្នកអានប្រចាំថ្ងៃ ចំនួនអ្នកទស្សនកិច្ច និងកិច្ចការប្រជុំផ្សេងៗក្នុងបណ្ណាល័យដោយធ្វើតារាងមួយសម្រាប់ធ្វើការកត់សម្គាល់។



www.elibraryofcambodia.org

- តាមដានសកម្មភាពរបស់អ្នកអានជាប្រចាំពីប្រភេទអ្នកអានទាំងក្នុង និងក្រៅសាលា
- ចំនួនអ្នកអាននៅហ្នឹងកន្លែងប៉ុន្មាននាក់ក្នុងមួយថ្ងៃ ?
- ចំនួនអ្នកខ្ចី ប៉ុន្មាននាក់ក្នុងមួយថ្ងៃ ត្រូវកត់ចំណាំអ្នកអាន តើគេចូលចិត្តអានឯកសារអ្វី ?
- វិធីសាស្ត្រដែលបណ្ណារក្សត្រូវណែនាំអ្នកអានពីរបៀបប្រើប្រាស់ឯកសារ ។

### ឃ. ការការពារ និង ថែរក្សាឯកសារ

ការការពារ និងថែរក្សាឯកសារ គឺធ្វើឡើងដើម្បីបង្ការរាល់ភាពមហន្តរាយ និងការបំផ្លិចបំផ្លាញដោយសត្វល្អិតផ្សេងៗ ជាពិសេសការពន្យាររាល់ការខូចខាតទាំងឡាយដែលបង្កឡើងដោយបរិយាកាសជុំវិញ សំដៅធ្វើយ៉ាងណាដើម្បីឱ្យការប្រើប្រាស់ឯកសារមានរយៈពេលយូរអង្វែង ។ ហេតុនេះ បណ្ណារក្សគប្បីយល់ដឹងឱ្យបានស៊ីជម្រៅ និងត្រូវមានវិធានការការពារឱ្យបានត្រឹមត្រូវ និងជាប្រចាំ ។

គេចែកវិធានការក្នុងការការពារ និងថែរក្សាជាពីរផ្នែកគឺ:

- ការការពារ និងថែរក្សាតាមបែបប្រពៃណីធម្មជាតិ
- ការការពារ និងថែរក្សាតាមបែបបច្ចេកទេសវិទ្យាសាស្ត្រ

### ១. ការការពារ និងថែរក្សាតាមបែបប្រពៃណីធម្មជាតិ :

ការការពារតាមបែបធម្មជាតិនេះ គឺភាគច្រើនពាក់ព័ន្ធផ្ទាល់ជាមួយគណៈគ្រប់គ្រងសាលាតែម្តង រីឯបណ្ណារក្សគ្រាន់តែជាអ្នកអនុវត្ត និង ជួយផ្តល់ជាគំនិតខ្លះៗប៉ុណ្ណោះ ។ ការងារទាំងនោះរួមមានដូចជា :

- ការសាងសង់បណ្ណាល័យ ត្រូវរើសទីតាំងដែលស្ថិតនៅលើទីខ្ពស់មិនលិចទឹក

- បណ្ណាល័យត្រូវមានពន្លឺ មានខ្យល់អាកាសចេញចូលគ្រប់គ្រាន់ និងត្រូវមានកូនប្រឡាយតូចមួយព័ទ្ធជុំវិញអគារបណ្ណាល័យដើម្បីការពារសត្វល្អិតកុំឱ្យឆ្លងចូល ពិសេស កណ្តៀរ ស្រមោច...

- ការពារមិនឱ្យឯកសាររងនូវភាពសំណើម គឺត្រូវធ្វើបន្ទាប់ពីពេលមានភ្លៀងធ្លាក់ ដោយគ្រាន់តែបើកទ្វារបង្អួចបណ្ណាល័យឱ្យបានមួយម៉ោងទៅពីរម៉ោង ដើម្បីឱ្យអស់ភាពសើមនៅក្នុងបណ្ណាល័យ និងជួយការពារឯកសារកុំឱ្យឆាប់ពុកផុយ

- ការពារធូលីដោយបោសសំអាតជាប្រចាំក្នុងបណ្ណាល័យ
- មិនត្រូវបរិភោគ ចំណីអាហារ ឬយកកែវទឹកដាក់ក្បែរឯកសារ និងសម្ភារអេឡិចត្រូនិច ។

### ២. ការការពារ និងការថែរក្សាតាមបែបបច្ចេកទេសវិទ្យាសាស្ត្រ :

- ការជួសជុលឯកសារដែលខូចខាតធុនស្រាលដោយបិទស្កុតឡើងវិញលើឯកសាររហែកនៃភាគខ្លះ
- ការជួសជុលឯកសាររហែកខ្លាំង ឬរបូតរាយប៉ាយ ដោយការដេរឡើងវិញ



www.elibraryofcambodia.org

- ការជួសជុលដោយធ្វើការថតចម្លងឡើងវិញ ( ដោយផ្នែក ឬថតចម្លងសារជាថ្មី )
- ការរក្សាសីតុណ្ហភាពឱ្យស្ថិតក្នុងកម្រិតមធ្យម ( ជាមធ្យមចន្លោះ ពី១៨-២០ អង្សា )
- ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតសម្រាប់រយៈពេលមួយ ឬពីរសប្តាហ៍ម្តង ។

ង. ការធានានិរន្តរភាពរបស់បណ្ណាល័យ

ដើម្បីធានាឱ្យដំណើរការបណ្ណាល័យបានល្អប្រសើរ និងមាននិរន្តរភាព ថ្នាក់ដឹកនាំសាលាត្រូវត្រួតពិនិត្យតាមដានសកម្មភាពបណ្ណារក្សជាប្រចាំ ដើម្បីឱ្យដឹងគោលដៅដែលបានកំណត់ទុកនោះបានអនុវត្តត្រឹមត្រូវដែរឬទេ? ឬក៏ត្រូវធ្វើការកែប្រែខ្លះដើម្បីឱ្យសមស្របទៅតាមតម្រូវការថ្មីៗរបស់បណ្ណាល័យសាលារៀន? ជាពិសេសទៅទៀតថ្នាក់ដឹកនាំសាលាត្រូវធ្វើការវាយតម្លៃរាល់ការចំណាយ និងលទ្ធផលដែលទទួលបាន គឺត្រូវធ្វើស្ថិតិ និងប្រមាណពីលទ្ធផលដែលទទួលបានដោយប្រៀបធៀបយ៉ាងល្អិតល្អន់ជាមួយនឹងរបាយការណ៍សកម្មភាពបណ្ណាល័យ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ដើម្បីពិនិត្យមើល តើការអនុវត្តត្រឹមត្រូវតាមគោលដៅបណ្ណាល័យសាលារៀនឬទេ?

របៀបត្រួតពិនិត្យ និងវាយតម្លៃការងារគ្រប់គ្រងបណ្ណាល័យ មានកត្តាជាច្រើនដែលត្រូវលើកយកមកវាយតម្លៃ រួមមានតួនាទី និងការទទួលខុសត្រូវរបស់បណ្ណារក្ស ផលប៉ះពាល់មួយចំនួនទាក់ទងជាមួយនឹងតួនាទី និងការទទួលខុសត្រូវរបស់បណ្ណារក្ស ដើម្បីឱ្យការវាយតម្លៃទទួលបានប្រសិទ្ធភាពខ្ពស់ ថ្នាក់ដឹកនាំសាលាត្រូវសិក្សារាល់ចំណុចនីមួយៗឱ្យបានច្បាស់លាស់ និងសិក្សាស្វែងរកចំណុចវិជ្ជមាន និងអវិជ្ជមានសម្រាប់ធ្វើការកែលំអ ។

□ លក្ខណៈវិនិច្ឆ័យពីនិរន្តរភាពនៃដំណើរការរបស់បណ្ណាល័យ

- គុណភាពការងារ ដំណើរការបណ្ណាល័យសម្រេចជោគជ័យ មាននិរន្តរភាព និងមានការអភិវឌ្ឍ
- ការសម្របសម្រួល ផែនការដឹកនាំ ចាត់ចែង ត្រួតពិនិត្យពីថ្នាក់ដឹកនាំក្នុងការអនុវត្តការងារ
- ផលិតភាព លទ្ធផលនៃការងារជាបុគ្គល ជាក្រុមទទួលបាននូវកម្រិតខ្ពស់ ( ធៀបឆ្នាំមុន)
- ប្រសិទ្ធភាពនៃការចំណាយ កំណត់បាននីតិវិធីចំណាយច្បាស់លាស់ និងសមស្រប
- ការបំពេញចិត្ត ទាំងបណ្ណារក្ស និង អ្នកអាន ( បរិយាកាសការងារវិជ្ជមាន)
- ការអភិវឌ្ឍ ការបណ្តុះបណ្តាលបណ្ណារក្សក្នុង និងក្រៅអង្គភាព ( លទ្ធផលការងារផ្លាស់ប្តូរ) ។

ដើម្បីធានានិរន្តរភាពនៃដំណើរការរបស់បណ្ណាល័យបាន មន្ត្រីមន្ទីរ អយក អ្នកអធិការកិច្ច មន្ត្រីការិយាល័យអប់រំស្រុក ផ្នែកបណ្ណាល័យគប្បីចុះពិនិត្យតាមដានឱ្យបានយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ។

ច. សកម្មភាពបណ្ណាល័យកុមារ

- សារៈសំខាន់នៃសកម្មភាពបណ្ណាល័យកុមារៈ

* បណ្ណាល័យត្រូវផ្តល់សេវាកម្មផ្សេងៗគ្នា ចំពោះមនុស្សដែលមានអាយុខុសៗគ្នា



www.elibraryofcambodia.org

* វ័យកុមារជាវ័យជួបប្រទះសៀវភៅលើកដំបូង ជួនកាលបទពិសោធន៍ ការអានរបស់កុមារសម្រេច ដល់អនាគតពួកគេទាំងស្រុង ហើយវត្ថុចាំបាច់របស់កុមារគឺការជួបប្រទះសៀវភៅល្អៗសម្រាប់ឱ្យកុមារមើល និងអាន ។

ដូច្នេះបណ្ណាល័យកុមារ គឺជាបណ្ណាល័យដែលមានសកម្មភាពរស់រវើក ជួយដឹកនាំកុមារឱ្យកាន់តែចូលចិត្តបណ្ណាល័យ និងការអាន ។

សកម្មភាពបណ្ណាល័យកុមារៈ

- ការអាន
- ការនិទានរឿង
- ល្បែងសិក្សា
- សិល្បៈ ( បត់ក្រដាស គូរគំនូរ ចម្រៀង របាំ កំណាព្យ )

ដើម្បីអនុវត្តនូវសកម្មភាពទាំង ៤ ខាងលើបាន :

- បណ្ណារក្សត្រូវរៀបចំកាលវិភាគសកម្មភាពប្រចាំសប្តាហ៍ ដោយឡែកសកម្មភាពអាន និងការនិទានរឿងត្រូវមានជាប់ជាប្រចាំ ។

## ១. ល្បែងសិក្សា

គេសង្កេតឃើញ កុមារចូលចិត្តលេងល្បែង និងបង្កើតល្បែង លេងខ្លួនឯងតាំងពីអាយុពីរឆ្នាំម្ល៉េះ ។ ពេលកុមារចូលដល់វ័យសិក្សា កុមាររឹតតែបង្កើតល្បែងបានច្រើនថែមទៀត តាមរយៈមិត្តភ័ក្តិ បងប្អូន ឪពុកម្តាយ និងសហគមន៍ ។ ដូច្នេះហើយបានជាគេបញ្ចូលសកម្មភាពល្បែងសិក្សាសម្រាប់កុមារក្នុងបណ្ណាល័យ ។ ការជ្រើសរើសល្បែងសិក្សាត្រូវមានលក្ខណៈអប់រំបែបប្រយោល ដែលផ្តល់នូវការរីកចម្រើនខាងបញ្ញា ស្មារតី និងផ្តល់បរិយាកាសរីករាយដល់កុមារ ។

## ២. គំនូរ

គំនូរមានប្រយោជន៍សំខាន់សម្រាប់កុមារ គឺធ្វើឱ្យកុមារចេះស្រមើស្រមៃ បង្កើតរូបបារម្មណ៍ ចេះពិចារណា ព្យាយាមរំលត់អត់ធន់ ពិសេសនាំឱ្យកុមាររំភើបចិត្តចំពោះខ្លួនឯង ដែលអនុវត្តបានជោគជ័យ ។ សកម្មភាពរបស់កុមារនឹងចាប់ផ្តើមល្អជាបណ្តើរៗ រហូតកើតជាទម្លាប់បាន ។ សម្រាប់នៅបឋមសិក្សាគំនូរដែលត្រូវឱ្យកុមារគូរជាដំបូងមានមូលដ្ឋាននៃគំនូរ គំនូរដោយសេរី គំនូរត្រាប់ និងគំនូរមើលឃើញ ។



www.elibraryofcambodia.org

### ២.១ មូលដ្ឋាននៃគំនូរ

មូលដ្ឋាននៃគំនូរ គឺដឹកនាំកុមារឱ្យគូស គំនូសខ្សែបន្ទាត់ ផ្តេក បញ្ឈរ ទ្រេត កោង រង្វង់ ពត់ពែន ខ្វែង ...។ គូសដូច្នេះជាប្រចាំធ្វើឱ្យកុមារមានលំនឹងដៃល្អ និងស្គាល់រំពត់របស់រូបក្នុងការគូរគំនូរ ។



### ២.២ គំនូរដោយសេរី

គំនូរដោយសេរី គឺជាគំនូរដែលធ្វើតាមការនឹកឃើញ និងតាមចិត្តចង់របស់កុមារ ។





www.elibraryofcambodia.org



២.៣ គំនូរគ្រាប់

គំនូរគ្រាប់ គឺជាវិធីដែលដឹកនាំកុមារឱ្យធ្វើតាមគំនូរងាយៗ ដូចមានឧទាហរណ៍ខាងក្រោម :

ឧទាហរណ៍ទី១ :

រង្វង់មូលមួយអាចបង្កើតបានជាវត្ថុជាច្រើន ដែលយើងធ្លាប់ឃើញដូចជា: ផ្លែក្រូច ផ្លែប៉ោម ក្អម គ្រាប់ឃ្លី...។



ឧទាហរណ៍ទី២ :

ខ្សែកោងផ្កាប់ និងផ្ងារពីរជួបគ្នាអាចបង្កើតបានរូបភាពជាច្រើន ដែលប្អូនៗធ្លាប់ឃើញ : ស្លឹកឈើ ត្រី និង ភ្នែកមនុស្ស ...។





www.elibraryofcambodia.org

### ២.៤ គំនូរមើលឃើញ

គំនូរមើលឃើញ ជាគំនូរដែលគូរចម្លងចេញពីធម្មជាតិ និងវត្ថុជាក់ស្តែងដែលនៅជុំវិញខ្លួន ដោយគំនិតច្នៃប្រឌិតរបស់អ្នកគូរដែលមានប្រធានបទច្បាស់លាស់ ។ បណ្តារក្យដាក់ប្រធានបទណាមួយឱ្យកុមារគូរដូចជា:

- ចូរប្អូនគូរអំពីទេសភាពវាលស្រែ នារដូវវស្សា រដូវប្រមូលផលនៃអ្នកភូមិរបស់ប្អូន
- ចូរប្អូនគូររូបផ្កា បន្លែ ផ្លែឈើ ...។







www.elibraryofcambodia.org

**នៅក្នុងបណ្ណាល័យបណ្ណារក្សអាចជួយកុមារក្នុងការគូរគំនូរបាន :**

បណ្ណារក្សត្រូវចេះបង្កលក្ខណៈឱ្យកុមារគូរគំនូរ ដោយរៀបចំតុ សម្ភារ សម្រាប់គូរគំនូរ និងចេះលើកទឹកចិត្តឱ្យកុមារ គូរគំនូរមូលដ្ឋាន គំនូរដោយសេរី គំនូរត្រាប់ និង គំនូរមើលឃើញ ព្រោះគំនូរគឺជាសកម្មភាពមួយយ៉ាងសំខាន់ដែលជួយឱ្យកុមារអភិវឌ្ឍសមត្ថភាពខួរក្បាល កុមារមានគំនិតច្នៃប្រឌិតខ្ពស់ក្នុងការបង្កើតអ្វីដែលថ្មីប្លែកៗ ពិសេសអាចឱ្យពួកគេឈានទៅចាប់អាជីពងាយៗបានក្នុងការចិញ្ចឹមជីវិតរបស់គេ ។

បណ្ណារក្សត្រូវស្គាល់សម្ភារសម្រាប់គំនូរ និងយល់ពីការរៀបចំប្លង់នៃគំនូរឱ្យបានច្បាស់ដើម្បីជួយណែនាំកុមារក្នុងការគូរ ។

**សម្ភារសម្រាប់គូរគំនូរ :**

- ក្រដាសរាម ក្រដាសសម្រាប់គូរគំនូរ និង សៀវភៅគូរគំនូរ
- ខ្មៅដៃគំនូរ គឺសម្គាល់នៅចុងខ្មៅដៃមានលេខ 2B - 6B
- ជ័រលុបពណ៌ស ទន់លុបមិនខ្មៅក្រដាស
- ខ្មៅដៃពណ៌ ហ្វឺត គូល័រទៀន គូល័រទឹក...។

**ការរៀបចំប្លង់ :**

បណ្ណារក្សជួយណែនាំកុមារនូវការរៀបចំប្លង់សម្រាប់គូរ នៅពេលកុមារបានឆ្លងកាត់គំនូរមូលដ្ឋាន គំនូរដោយសេរី គំនូរត្រាប់ រួចមកបណ្ណារក្សដឹកនាំកុមារឱ្យស្គាល់ពីការរៀបចំប្លង់ និងការរៀបចំរូបភាពក្នុងប្លង់ទើបចូលទៅដល់គំនូរមើលឃើញ ព្រោះគំនូរមើលឃើញនេះ មានរូបភាពច្រើន ជាសកម្មភាពមនុស្ស សត្វ វត្ថុ...។

**ការរៀបចំប្លង់មាន២គឺ**

ប្លង់ផ្តេក



ប្លង់បញ្ឈរ





www.elibraryofcambodia.org

**ការរៀបចំរូបភាពក្នុងប្លង់**

រៀបចំរូបភាពកុំឱ្យទៅលើ ឬចុះក្រោម ទៅឆ្វេង ឬស្តាំ





រៀបរូបភាពឱ្យស្ថិតនៅចំកណ្ដាលនៃប្លង់ទើបមានលំនឹងក្នុងក្រដាស



របៀបរៀបចំរូបភាពឱ្យស្ថិតនៅកណ្ដាលនៃប្លង់ក្រដាស ស្របនឹងភ្នែករបស់យើង





www.elibraryofcambodia.org

### ២.៥ *ការផាត់ពណ៌*

ការផាត់ពណ៌ ជាសកម្មភាពមួយដែលផ្ដល់ឱ្យកុមារមានទម្លាប់ហ្វឹកហាត់ម្រាមដៃ ការផ្ចិតផ្ចង់អារម្មណ៍ និងភាពអំណត់អត់ធន់បានល្អ បណ្ណារក្សជួយណែនាំកុមារក្នុងការខ្វងខ្មៅដៃ ផាត់ពណ៌មិនឱ្យធ្លុះក្រដាស និងផាត់មិនឱ្យហួសគំនូសនៃរូបភាព ពិសេសកុំបង្វិលក្រដាសគំនូរតាមខ្លួន ។ នៅពេលឃើញកុមារគូរ ឬផាត់ពណ៌ខុស បណ្ណារក្សមិនត្រូវថាខុសទេ គួរសួរកុមារពីចំណាប់ចំណូលចិត្តរបស់គេ ដើម្បីកុំឱ្យប៉ះពាល់ដល់អារម្មណ៍របស់កុមារ ព្រោះថា គំនូរនិងការផាត់ពណ៌មិនចេះខុសទេ កុមារអាចផាត់ពណ៌តាមការស្រមើស្រមៃរបស់គេ អាស្រ័យទៅលើចិត្តមនុស្ស និងការបកស្រាយរបស់អ្នកគូររូបភាពនោះ ។ បណ្ណារក្សគ្រាន់តែជាអ្នកជួយណែនាំ សម្របសម្រួល ផ្ដល់ដំបូន្មានល្អ លើកទឹកចិត្ត និងរៀបចំសម្ភារសម្រាប់កុមារតែប៉ុណ្ណោះ ។

ប៉ុន្តែបណ្ណារក្សអាចជួយកុមារក្នុងការចេះរក្សាអនាម័យដូចជា:

- លាងដៃឱ្យស្អាតមុននឹងកាន់ក្រដាសគូរ
- កុំលុបខ្លាំងពេក នាំឱ្យខ្មៅក្រដាស
- ផាត់ពណ៌ឱ្យពេញផ្ទៃក្រដាសរូបភាព កុំទុកឱ្យនៅចន្លោះក្រដាសស
- ផាត់ពណ៌ឱ្យច្បាស់ទើបរូបភាពមានសោភ័ណ ។

**របៀបផាត់ពណ៌**

បណ្ណារក្សណែនាំកុមារឱ្យស្គាល់ទម្រង់ធរណីមាត្រ រួចផ្ដល់ក្រដាស១សន្លឹក ខ្មៅដៃ (2B.6B) ដើម្បីឱ្យកុមារផាត់ស្រមោលបណ្ដេញពីចាស់ ទៅខ្ចី ឬពីធ្ងន់ដៃ ទៅស្រាលដៃ ។ បន្ទាប់មកផាត់ស្រមោលបណ្ដេញ ពីចាស់ទៅខ្ចីក្នុងទម្រង់ធរណីមាត្រទាំងនោះ ដោយផាត់មិនឱ្យហួសគំនូសរូប ធ្វើបែបនេះឱ្យកុមារស្គាល់ពីមាឌរបស់វត្ថុនីមួយៗ ។





www.elibraryofcambodia.org



- ពណ៌មូលដ្ឋាន

ពណ៌មានច្រើនបែបណាស់ ដូចជាពណ៌ស្វាយ ពណ៌ស៊ីជម្ពូ ពណ៌ប្រផេះ...។ ប៉ុន្តែពណ៌ដែលបរិសុទ្ធ (ពណ៌ដំបូង ឬពណ៌ដើម) មានបី គឺ ពណ៌លឿង ខៀវ និងក្រហម ។

ដោយសារគ្មានពណ៌ដទៃណាអាចលាយបង្កើតពណ៌នីមួយៗនៃពណ៌ទាំងបីនេះបាន។ ផ្ទុយទៅវិញ ពណ៌ទាំងនេះអាចលាយបង្កើតពណ៌ដទៃបានច្រើនរាប់មិនអស់ ។

- របៀបលាយពណ៌

លាយពណ៌ដំបូងកុំអាលដាក់ពណ៌ច្រើនពេក គឺត្រូវលាយបន្តិចម្តងៗ ហើយពិនិត្យមើលថាកម្លាំង ឬទម្ងន់ពណ៌ប៉ុណ្ណាដែលចង់បាន។ យកពណ៌ទី១លឿង + ពណ៌ទី១ខៀវ បានពណ៌ទី២ ហើយការលាយ គឺយកសាច់ពណ៌ប៉ុនគ្នា ឬស្មើគ្នា ឯពណ៌បន្តបន្ទាប់ទៀតធ្វើដូចគ្នា ។ បើចង់បានពណ៌បៃតង ដែលមានជាតិពណ៌ខៀវ



www.elibraryofcambodia.org

ឬលាំអៀងទៅខៀវ គឺដាក់ពណ៌ខៀវឱ្យច្រើនជាងបន្តិច នឹងបានពណ៌បៃតង មានជាតិខៀវ ឯពណ៌ផ្សេងៗទៀត ដែលចង់បាន ក៏លាយដូចគ្នានេះដែរ ។

សម្ភារៈរួមផ្សំមាន ៖

- កែវទឹក ជក់សម្រាប់លាយពណ៌ ចានសម្រាប់លាយពណ៌
- ក្រដាស ដែកឈាន ខ្មៅដៃ បន្ទាត់...។

យកពណ៌ដើមទី១ មានពណ៌លឿង ខៀវ និងក្រហម មកលាយឱ្យបានពណ៌ទី២ និងយកពណ៌ទី២ មកលាយឱ្យបានពណ៌ទី៣ ។

- ពណ៌លឿង + ខៀវ = បៃតង
- ពណ៌ខៀវ + ក្រហម = ស្វាយ
- ពណ៌ក្រហម + លឿង = ទឹកក្រូច

} ពណ៌ទាំង៣នេះជាពណ៌ទី២

យកពណ៌ទី២ បូកពណ៌ទី១ បានពណ៌ទី៣ និងពណ៌បន្តបន្ទាប់ទៀតច្រើនរាប់មិនអស់ ។

- ពណ៌លឿង + បៃតង = បៃតងខ្ចី
- ពណ៌ខៀវ + បៃតង = បៃតងចាស់
- ពណ៌ខៀវ + ស្វាយ = ស្វាយចាស់
- ពណ៌ក្រហម + ស្វាយ = ស្វាយខ្ចី
- ពណ៌ក្រហម + ទឹកក្រូច = ក្រហមទុំ
- ពណ៌លឿង + ទឹកក្រូច = លឿងទុំ ឬលឿងចាស់

ពណ៌ក្នុងរង្វង់ ពណ៌ដើម ពណ៌ដំបូង ឬពណ៌ទី១ មានបីពណ៌ ( លឿង ខៀវ និង ក្រហម )



រូបភាពទី១: ពណ៌ដើមទាំងបី ក្នុងត្រីកោណ



www.elibraryofcambodia.org



រូបភាពទី២: ពណ៌ទី២ កើតពីការផ្សំពណ៌ទី១ + ពណ៌ទី១ បានពណ៌ទី២ បានបីពណ៌គឺ បៃតង ស្វាយ ទឹកក្រូច ។



ពណ៌ទី៣ កើតពីការផ្សំពណ៌ទី១ + ពណ៌ទី២ ដូចមានរូបបង្ហាញខាងក្រោម ( រូបភាពក្នុងរង្វង់ក្រូម៉ាទិច )



www.elibraryofcambodia.org







www.elibraryofcambodia.org

៣. សិប្បកម្ម

សិប្បកម្មជាផ្នែកមួយជួយដល់ការអភិវឌ្ឍ ផ្នែកបំនិនជីវិតនាំឱ្យកុមារស្គាល់ជំនាញដូចជា កាត់ដេរ តម្បាញ សូនរូប ឆ្លាក់រូប...។ ទាំងអស់នេះសុទ្ធសឹងមានប្រយោជន៍ ជួយលើកស្ទួយដល់សង្គម។ ការបង្កើតសិប្បកម្មដោយដៃតូចតាចតាមថ្នាក់រៀន និងបណ្ណាល័យដើម្បីបណ្តុះកុមារឱ្យមានចិត្តស្រឡាញ់ការងារតាំងពីកុមារភាពទៅ។ សិប្បកម្មបែបកុមារធ្វើឱ្យពួកគេសប្បាយចិត្ត និងជួយឱ្យកុមារចេះសង្កេត ព្យាយាមអំណត់អត់ធន់ និងច្នៃប្រឌិតក្នុងការផលិតដើម្បីសម្រេចលទ្ធផលបានល្អ ។

ដូច្នេះបណ្ណារក្សត្រូវជ្រើសរើសយកសិប្បកម្មណា សមស្របនឹងវ័យរបស់កុមារដែលអាចអនុវត្តបាន។ បណ្ណារក្សត្រូវដាក់តាំងស្នាដៃកុមារដើម្បីលើកទឹកចិត្តដល់ពួកគេ ។

៤. សិល្បៈ ( ចម្រៀង របាំ កំណាព្យ )

ដើម្បីចូលរួមថែរក្សាវប្បធម៌ប្រពៃណីជាតិយើងឱ្យនៅស្ថិតស្ថេរគង់វង្ស បណ្ណាល័យចូលរួមចំណែកបង្កើតឱ្យមានសកម្មភាពសិល្បៈផងដែរ។ ដូច្នេះបណ្ណារក្សគួរស្រាវជ្រាវឡើងវិញ ពីចម្រៀង របាំ រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ ឡាំលាវ និងកំណាព្យខ្មែរយើងមកបង្ហាត់បង្ហាញកុមារ ។សកម្មភាពសិល្បៈក្នុងបណ្ណាល័យពុំមានលក្ខណៈត្រឹមត្រូវដូចច្បាប់ដើមឥតខ្ចោះនោះទេ គ្រាន់តែបង្កលក្ខណៈឱ្យមានបរិយាកាសរីករាយ មានភាពក្លាហាន និងមានសាមគ្គីភាពល្អ។

### ចម្រៀង ឱផ្កាល្ហុង

១. ឱផ្កាល្ហុង ឱផ្កាល្ហុង ដុះក្នុងព្រៃក្បា កើតជាតិណា១ ចង់បេះផ្កាល្ហុងក្នុងព្រៃ ( ២ដង ) ។

២. នែ! បងសូមសួរសិន តើល្ហុងនាងធុំ ឬមួយនៅខ្ចី អូនដាំល្ហុងអី បានល្ហុងស្រីល្អខុសគេ ( ២ដង ) ។

### ចម្រៀង ស្រះ ាំ ា ិ ី

( លំនាំបទកាទ្រឹមបហោ បទយីកេ )

១. ស្រះ ាំ ា ិ ី អឺងអើយ ( ២ដង )
ពីរបូកនិងបីមិត្តអើយយើងលៃបានប្រាំ ( ២ដង ) ។

២. ស្រះ ុ ូ ួ គួរចាំ អឺងអើយ ( ២ដង )
ប្រាំបូក និង ប្រាំមិត្តអើយខ្ញុំចាំថាដប់ ( ២ដង ) ។

៣. អ្នកណាមិនរៀនកុំមកបន្ទប់ អឺងអើយ ( ២ដង )
អ្នកណារៀនចប់មិត្តអើយយើងហៅសិស្សល្អ ( ២ដង ) ។



www.elibraryofcambodia.org

## ចម្រៀង ណាវ៉ៃ ( ភ្លេងយីកេ )

បន្ទរ ណាវ៉ៃ១ចន្ទីអើយណាវ៉ៃស្រីមុំ១ បងអឹងអើយណាវ៉ៃ ( ២ដង )

ម៉ៃយ៉ាំ ម៉ៃយេ ចន្ទីអើយ ម៉ារហ៊ឹម ( ២ដង )

ទោល ខ្ញុំបេះផ្កាអី បេះផ្កាមាក់ប្រាង ( ២ដង )

ស្រីមុំ១បង អឹងអើយមាក់ប្រាង ( ២ដង )

ផ្អែមឆ្ងាញ់ដោយយ៉ាង ម្ចាស់អើយលោកសោយលេង ( ២ដង )

ខ្ញុំបេះផ្លែអី បេះផ្លែអើយ ធុរេន ( ២ដង )

ក្រមុំ១បង អឹងអើយ ធុរេន ( ២ដង )

មាក់ប្រាង ចាន់បែនម្ចាស់អើយលោកសោយលេង ( ២ដង )

( ដកស្រង់ចេញពីសៀវភៅសិក្សាសង្គមថ្នាក់ទី ១ )

## ចម្រៀង នារីជាជួរ

( បទភ្លេងមហោរី )

១. នារីជាជួរតែងតួយ៉ាងស្រស់ចំណាន លើកដៃពត់រាំក្បាច់ខ្មែរ
ព្រមទាំងសឹកសៀតមាលាល្អយល្អប់ស្រស់ ឥតមានទាស់ត្រង់ណា
រាំតាមរបៀបក្បាច់ខេមរាពីបុរាណ ទុកជារបាំមួយស្រស់យ៉ាងចំណាន
គ្រាន់តែកែកំសាន្តនៅពេលស្រាកស្រាន្ត ប្រុសស្រីគ្រប់ប្រាណជុំគ្នាលេង ។

២. សាសន៍គេជិតឆ្ងាយតែងមានក្ដីសរសើរ អំពីដំណើរក្បាច់ខ្មែរ
តាំងពីដើមមកសព្វថ្ងៃឥតកែប្រែ ខ្មែរថែរក្សាទុក
ដំណែលតាំងពីបុរាណអង្វែងមក ជាតិខ្មែរបានថែរក្សាទ្រព្យនេះជាប់
ជាទំនៀមទម្លាប់ល្បីសាយសព្វ លើភពដែលគេតែងសរសើរ ។

( ដកស្រង់ចេញពីសៀវភៅសិក្សាសង្គម ថ្នាក់ទី ៤ )



www.elibraryofcambodia.org

## ចម្រៀង ពង្សាវតារខ្មែរ

( តាមលំនាំបទខ្មែរតម្បាញ )

១. ខ្មែរអើយចូរចាំជាក់ថា តាមពង្សាវតារ
បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
ទឹកដីខ្មែរធំ ទូលំទូលាយ
សព្វសាយរុងរឿង តែឯងតែងលើកតម្កើង
តម្កល់ជាតិយើង ចាត់ទុកឡើងជាជាតិច្បង ។

២. អារ្យធម៌ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយ
គ្រប់ទិសទាំងឡាយ ចុងបូព៌ា
សាសនាសិល្បៈ ចម្លាក់វិចិត្រ
គំនិតសិក្សា តន្ត្រីទស្សនវិជ្ជា
អាចយកសិក្សា ជាគោលការណ៍ដែលខ្មែរផ្សាយទៅ ។

៣. ខ្មែរអើយចូរស្ដាប់សាវតារ ដែលបានចរចារ
បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
តាំងចិត្តឱ្យធំ ខិតខំប្រឹងវិញ
បញ្ចេញតម្កើង តម្លៃនៃជាតិខ្មែរយើង
ឱ្យបានរុងរឿង ជាថ្មីឡើងតាមសាវតារ ។

( ដកស្រង់ចេញពីសៀវភៅសិក្សាសង្គម ថ្នាក់ទី៦ )

## ហាត់ប្រាណ

កូនលើកដៃ ហាត់ធ្វើកាយវិការ
ធ្វើចលនា ឱ្យដៃកូនរឹងមាំ
មកមិត្តអើយ យើងនាំគ្នារាំ
រាំពួកយើងរាំ រាំកាយសិក្សា ( ២ដង ) ។
ដងខ្លួនកូន ហាត់ធ្វើកាយវិការ
ធ្វើចលនា ឱ្យដងខ្លួនកូនរឹងមាំ
ចង្កេះកូន ហាត់ធ្វើកាយវិការ
ធ្វើចលនា ឱ្យចង្កេះកូនរឹងមាំ ( ២ដង ) ។



www.elibraryofcambodia.org

## ចម្រៀង ខ្មែរអើយក្រោកឡើង

( តាមលំនាំបទបំពេកូន )

បើខ្មែរបែកបាក់ ខ្មែរត្រូវធ្លាក់ខ្លួនបរាជ័យ
ខ្មែរត្រូវប្រុងប្រាណ បើខ្មែរបែកបាក់
ខ្មែរយើងជាក់បង់ដីមិនខាន ខ្មែរត្រូវប្រុងជានិច្ច
ខ្មែរអើយកុំភ្លេច ខ្មែរប្រុងជានិច្ចៗ

កុំឱ្យធ្លោយប្រាណ ។

កលល្បិចសត្រូវ បោកខ្មែរយើងច្រើនហួសប្រមាណ
ខ្មែរត្រូវប្រុងប្រាណ កុំជឿសត្រូវ
ថាស្រឡាញ់យើងដោយស្មោះស្មាន ឈាមបងប្អូនប្រុសស្រី
ខ្មែរត្រូវឃ្លាតខ្ទី ផ្ចិតផ្ចង់ស្មារតី ៗ

រួបរួមសាមគ្គី ។

ខ្មែរអើយក្រោកឡើង យើងរួបរួមយើងពួតដៃគ្នា
យើងពួតដៃគ្នា ខ្មែរអើយក្រោកឡើង
យើងថែទាំដែនកម្ពុជា ឱ្យជាតិយើងរស់បាន
សាងជាតិថ្កើងថ្កាន ខ្មែរសុខសម្រាន្តៗ

លុះអវសាន្តអើយ ។

( ដកស្រង់ចេញពីសៀវភៅសិក្សាសង្គម ថ្នាក់ទី៦ )

## ចម្រៀង រៀនលេខ រៀនអក្សរ

( តាមលំនាំបទលលកលោតទុំមែកស្វាយ )

ភ្នែកពីរសំគិតយកធ្ងន់ ត្រចៀកទន់ប្រុងស្តាប់កិច្ចការ ( ២ដង )
មាត់មួយមិនព្រួយឡើយណា មាត់មួយមិនព្រួយឡើយណា

រៀនមើលរៀនថារៀនលេខអក្សរ ។

ដៃឆ្វេងសម្រាប់កាន់ក្តារ ដៃស្តាំណាចាប់កាន់ដីស ( ២ដង )
យើងខំសរសេរឱ្យល្អ យើងខំសរសេរឱ្យល្អ

នូវលេខអក្សរដែលគ្រូដាក់ឱ្យ ។



www.elibraryofcambodia.org

## ចម្រៀង ដើរ ឬដេក

ដើរឬដេកដងខ្លួនឱ្យត្រង់ ត្រូវតម្រង់ទាន់ខ្លួននៅក្មេង
ទោះអង្គុយឬមួយឈរលេង យើងក្មេងៗឈរឱ្យត្រង់ខ្លួន ។
មុខញញឹមសង្ឃឹមជានិច្ច កុំបែរគេចលបមើលក្រោយខ្នង
ងើបមុខឡើងនិយាយឆ្លើយឆ្លង ទើបអ្នកផងគេហៅក្លាហាន ។
យើងមិនមែនជាក្មេងកោងកាច តែមិនខ្លាចមួរមុខបិទមាត់
ហ៊ានសួរហ៊ានឆ្លើយឱ្យចាំស្ទាត់ ជាពលរដ្ឋប្រសើរថ្ងៃក្រោយ ។

## ចម្រៀង វិន័យដែលអ្នកគ្រូផ្តាំ

វិន័យដែលអ្នកគ្រូផ្តាំទៅ ថាឱ្យពាលពៅជម្រាបសួរចាស់ៗ
ហេតុអ្វីបានជាពៅមិនចាំច្បាស់ ( ២ដង )
ភ្លេចទាំងសំពះ ភ្លេចទាំងថាអរគុណ
ក្រោយៗសំពះចាស់ៗមុន ( ២ដង )
រួចថាអរគុណមុនទទួលអ្វី ១ ស្តាយណាស់
អ្នកគ្រូខានចែកចំណី ( ២ដង )
ព្រោះតែថ្នាំថ្ងៃភ្លេចវិន័យអ្នកគ្រូ ( ២ដង ) ។

## ចម្រៀង កន្ទុបមេម៉ែមួយ

កន្ទុប ១ មេម៉ែមួយ មេម៉ែឱ្យៗ ចាំផ្ទះ ( ២ដង )
វវល់ៗទៅណា អើ អើ អើ អើយ ឱ្យទាស៊ីស្រូវ ( ២ដង ) ។
វិពាត់ៗ មេម៉ែមួយ មេម៉ែវាយៗ ឥឡូវ ( ២ដង )
ឱ្យទាៗ ស៊ីស្រូវ អើ អើ អើ អើយ វវល់ទៅណា ( ២ដង )

កន្ទុបៗ មេម៉ែមួយ មេម៉ែឱ្យៗ ចាំចាប ( ២ដង )
វវល់ៗទៅណា អើ អើ អើ អើយ ឱ្យចាបស៊ីស្រូវ ( ២ដង )
សូមមេម៉ែមេត្តាកន្ទុប ព្រោះតុបនាងនៅក្មេងខ្ចី ( ២ដង )
មិនទាន់ៗដឹងក្តី អើ អើ អើ អើយ សូមប្រណីម្តង ( ២ដង )



www.elibraryofcambodia.org

## ចម្រៀង ដើរ ឬដេក

ដើរឬដេកផងខ្លួនឱ្យត្រង់ ត្រូវតម្រង់ទាន់ខ្លួននៅក្មេង
ទោះអង្គុយឬមួយឈរលេង យើងក្មេងៗឈរឱ្យត្រង់ខ្លួន ។
មុខញញឹមសង្ឃឹមជានិច្ច កុំបែរគេចលបមើលក្រោយខ្នង
ងើបមុខឡើងនិយាយឆ្លើយឆ្លង ទើបអ្នកផងគេហៅក្លាហាន ។
យើងមិនមែនជាក្មេងកោងកាច តែមិនខ្លាចមួរមុខបិទមាត់
ហ៊ានសួរហ៊ានឆ្លើយឱ្យចាំស្ទាត់ ជាពលរដ្ឋប្រសើរថ្ងៃក្រោយ ។

## ចម្រៀង វិន័យដែលអ្នកគ្រូផ្ដាំ

វិន័យដែលអ្នកគ្រូផ្ដាំទៅ ថាឱ្យពោលពៅជម្រាបសួរចាស់ៗ
ហេតុអ្វីបានជាពៅមិនចាំច្បាស់ ( ២ដង )
ភ្លេចទាំងសំពះ ភ្លេចទាំងថាអរគុណ
ក្រោយៗសំពះចាស់ៗមុន ( ២ដង )
រួចថាអរគុណមុនទទួលអ្វី ១ ស្ដាយណាស់
អ្នកគ្រូខានចែកចំណី ( ២ដង )
ព្រោះតែថ្នាថ្ងៃភ្លេចវិន័យអ្នកគ្រូ ( ២ដង ) ។

## ចម្រៀង កន្ទុបមេមួយ

កន្ទុប ១ មេមួយ មេឱ្យ១ ចាំផ្ទះ ( ២ដង )
រវល់ៗទៅណា អើ អើ អើ អើយ ឱ្យទាស៊ីស្រូវ ( ២ដង ) ។
រំពាត់១ មេមួយ មេវាយ១ ឥឡូវ ( ២ដង )
ឱ្យទា១ ស៊ីស្រូវ អើ អើ អើ អើយ រវល់ទៅណា ( ២ដង )

កន្ទុប១ មេមួយ មេឱ្យ១ ចាំចាប ( ២ដង )
រវល់១ទៅណា អើ អើ អើ អើយ ឱ្យចាបស៊ីស្រូវ ( ២ដង )
សូមមេមេត្តាកន្ទុប ព្រោះតុបនាងនៅក្មេងខ្ចី ( ២ដង )
មិនទាន់១ដឹងក្ដី អើ អើ អើ អើយ សូមប្រណីម្ដង ( ២ដង )



www.elibraryofcambodia.org

## ចម្រៀង អក្សរក្រម

( លំនាំបទតាចាស់ចង់បានប្រពន្ធក្មេង )

ក ខ ខិតខំសំភី
គ គា គិ គី គីកូនគីង្គក់
ឃ ឃា កុំដេកទ្រមក់
ង ងើបកុំងក់ ក ខ គ ឃ ង ។
ច ចា រាបសាររម្យទម
ឆ ឆី សមរម្យ ជ ជួបសំពះ
ឈ ឈប់ឆាឆៅចាស់ៗ
ញញឹមកុំខ្មាស់ ច ឆ ជ ឈ ញ ។
ដ ឋ ឌ ឍ និង ណ
រីករាយត្រេកអរទៅសាលារៀន
ត តា តាមដំបូន្មាន
សង្វាតសូត្ររៀន ត ថ ទ ធ ន ។
ប ផ ព ភ និង ម
រីករាយសាទរ មិនទាស់ទែងគ្នា
យ រ ល វ សាមគ្គា
ស ហ ឡ អ ជាសាមសិបបីតួ ។





www.elibraryofcambodia.org

## V. ប្រវត្តិរឿងនិទាន និងការនិទានរឿង

ការនិទានរឿងបង្កឱ្យមានភាពសប្បាយរីករាយ និងផ្តល់នូវការអប់រំយ៉ាងច្រើនដល់កុមារ។ កាលណានិទានរឿងបានល្អ កុមារមានអារម្មណ៍សប្បាយរីករាយ រំភើបពេញចិត្តចំពោះរឿងដែលបាននិទាននោះ។ រឿងទាំងនោះនឹងនៅដក់ជាប់ក្នុងអារម្មណ៍របស់កុមារជានិច្ច។ ការនិទាននាំមកនូវបទពិសោធន៍ បណ្តុះរូបារម្មណ៍របស់កុមារ និងផ្តល់គុណតម្លៃ ដូចជាមានចំណង់ចំណូលចិត្តក្នុងការអាន មានសេចក្តីក្លាហាន បញ្ញាឈ្លាសវៃ ចេះស្គាល់ខ្លួនឯង និងមានសន្តានចិត្តល្អចំពោះអ្នកដទៃទៀត។ ការនិទានរឿងមានសារសំខាន់បំផុត ជាពិសេសចំពោះកុមារស្ថិតក្នុងវ័យកុមារភាព (ពីអាយុ ១ឆ្នាំ ទៅ៦ឆ្នាំ) ដែលជាវ័យកំពុងមានការវិវត្តប្រែប្រួលទាំងផ្នែករូបរាងកាយ ស្មារតី និងសតិបញ្ញាក្នុងការចាប់យកអ្វីៗដែលជាគំរូល្អ។

### ក. ប្រវត្តិរឿងព្រេង

ប្រទេសកម្ពុជា ជាទឹកដីមួយដែលមានប្រវត្តិរាប់ពាន់លានឆ្នាំមកហើយ លាតសន្ធឹងទៅលើមួយភាគធំនៃអាស៊ីអគ្នេយ៍ដីគោក ហើយមានវប្បធម៌ អរិយធម៌ដ៏យូរលង់ចំណាស់ជាងគេ ជាហេតុនាំឱ្យប្រទេសខ្មែរមានគ្រឹះអក្សរសិល្ប៍ជាតិ អក្សរសិល្ប៍ប្រជាប្រិយ និង អក្សរសិល្ប៍ចំណារដ៏សម្បូរបែប។

កាលសម័យដើម បុព្វបុរសយើងសរសេរឯកសារទាំងឡាយលើស្បែកសត្វ ដោយប្រើដីសបំពង ប៉ុន្តែឯកសារទាំងនេះមិនអាចទ្រាំទ្រនឹងអាកាសធាតុ ឬត្រូវបំផ្លាញដោយសត្វល្អិតមានកណ្តៀរជាដើម។ ហេតុនេះបានជាបុព្វបុរសយើងមានគំនិតច្នៃប្រឌិតរស់រវើកខ្ពស់បំផុតនឹងទេពកោសល្យដ៏ប៉ិនប្រសប់បានប្រើមធ្យោបាយថ្មីមួយទៀត គឺ "សិលាចារឹក ឬអក្សរថ្ម" ។ "សិលាចារឹក ឬអក្សរថ្ម" នេះអាចទ្រាំទ្រនឹងអាកាសធាតុ ហើយត្រូវបានរក្សារហូតមកដល់សព្វថ្ងៃនេះ ទុកជាកេរដំណែលឱ្យកូនចៅជំនាន់ក្រោយ បានស្គាល់អ្វីដែលកើតមានពីអតីតកាល ។ ម្យ៉ាងទៀត អ្នកប្រាជ្ញបារាំងជាច្រើនបានធ្វើការសិក្សាស្រាវជ្រាវរកឃើញពីតំណពង្សនៃក្សត្រ និងកាលបរិច្ឆេទនៃការកសាងប្រាសាទ ជីវភាពរស់នៅរបស់ប្រជារាស្ត្រខ្មែរ របបសង្គម សាសនា និងទំនៀមទម្លាប់ប្រពៃណីតាមរយៈផ្ទាំងសិលាដែលមានរហូតមកដល់បច្ចុប្បន្ន ។ ភាសាដែលប្រើលើសិលាចារឹកនៅសម័យនោះ ភាគច្រើនជាភាសាសំស្ក្រឹតដែលគេចាត់ទុកជាភាសាផ្លូវការ និង ជាភាសារបស់អ្នកប្រាជ្ញ ។

នៅពេលជនជាតិខ្មែរកសាងអរិយធម៌ដំបូង តាំងពីស.វទី ១ នៃគ.ស គេអាចដឹងថា សិលាចារឹកខ្មែរយើងមាននៅពាសពេញអាណាចក្រខ្មែរបុរាណ។ ប៉ុន្តែបច្ចុប្បន្នត្រូវបែកខ្ញែកទៅប្រទេសដទៃដូចជា:

- សិលាចារឹកខ្មែរនៅ លុពបុរី "ប្រទេសថៃ"
- សិលាចារឹកនៅ វ៉ូកាញ់ ខេត្តញ៉ាត្រាង វៀតណាមខាងត្បូង
- សិលាចារឹកនៅ ភូមិខាវវ៉ាំង ជិតអរញ្ញ ដីខ្មែរពីដើម (សៀម)
- សិលាចារឹកនៅទីឯសសរបុរាណដ្ឋាន ហ៊ិនខោន ចម្ងាយប្រមាណជា ៤០ គ.ម ខាងត្បូងកូរ៉ាត់ ក្នុងស្រុកប៉ាកថុងមាយ (នៅដែនសៀម)



www.elibraryofcambodia.org

- សិលាចារឹក ពោធកា នៅក្នុងកំពែងមឿងរច្ចៈសីមាការ ឬដែនកូរ៉ាត់ ស.វទី ៧ នៃ គ.ស ( ស្រុកសៀម)
- សិលាចារឹក ខាវស្រឆែង ( នៅអរញ្ញ)
- សិលាចារឹក វត្តស៊ីថាតប្រាម័ញ្ញ នៅភូមិចម្បី ខេត្ត ឧដុន ស្រុកសៀម
- សិលាចារឹក នៅខេត្តខុនកែន ស្រុកសៀម

សិលាចារឹកជាកំណប់អក្សរសាស្ត្ររបស់ប្រជាជាតិខ្មែរ ដែលមានពាក្យពេចន៍ស្រស់ចំណាន ត្រូវបានតាក់តែងឡើងដោយកវីនិពន្ធខ្មែរពីព្រេងនាយ ។ ដូចនេះសិលាចារឹកមានប្រយោជន៍សម្រាប់កូនខ្មែរជំនាន់ក្រោយឱ្យសិក្សាពីកំណើតអក្សរសាស្ត្រ និងស្រាវជ្រាវវេយ្យាករណ៍របស់ជាតិ ។

ក្រៅពីសិលាចារឹក គេសង្កេតឃើញមានរឿងព្រេង ឬរឿងប្រជាប្រិយ ពីររឿង គឺរឿងព្រះថោងនាងនាគ និងរឿង ភ្នំបាយ័ង្គ "បាយង្កោ" ខេត្តតាកែវ ដែលប្រហែលជាកើតឡើងនៅអំឡុង ឬ មុនសម័យនគរភ្នំ ។



រឿងព្រះថោងនាងនាគ

បើតាមឯកសារកម្ពុជសុរិយា លេខ ១៩៩៤ បានសរសេរថានៅសម័យនគរភ្នំការសិក្សាបានរីកចម្រើន ហើយមានភិក្ខុសាមណេរបានទទួលការសិក្សាផលវិជ្ជាជាន់ខ្ពស់ ។ កាលនោះមានព្រះថេរៈអង្គខ្លះបានរៀន ដល់ភូមិសិក្សាកម្រិតខ្ពស់ចេះវិជ្ជាច្រើនប្រការ មានភាសាសាស្ត្រជាដើម ដូចជាព្រះមហាថេរ សង្ឃបាល ។ ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យ ស.វទី៥ នៃ គ.ស មហាថេរអង្គនេះបាននិមន្តទៅកាន់ប្រទេសចិន ។ ព្រះចៅក្រុងចិនទ្រង់ប្រោសប្រណីណាស់ ដោយសារមហាថេរអង្គនេះចេះច្រើនភាសា ហើយបានជួយបកប្រែព្រះត្រៃបិដក និងគម្ពីរវិសុទ្ធមគ្គ



www.elibraryofcambodia.org

ទៅជាភាសាចិននៅការិយាល័យនគរភ្នំនាប្រទេសចិន ។ ចំពោះការសិក្សានៅសម័យចេនឡា ក៏មានការលូតលាស់តាំងពីរជ្ជកាលព្រះបាទរុទ្រវរ្ម័ន គ.ស ៥១៤ រហូតដល់ព្រះបាទជ័យវរ្ម័នទី១ គ.ស ៦៨១។ មានមន្ត្រីម្នាក់ឈ្មោះ សិង្ហវិរៈ ជាចិន្តកវីឯកក្នុងរាជាព្រះបាទឦសានវរ្ម័ន គ.ស ៦២៦។ នៅសម័យនោះមានកវីអ្នកនិពន្ធជាច្រើនផ្សេងទៀត។

លុះដល់សម័យមហានគរមានអ្នកប្រាជ្ញជាច្រើន ទាំងអ្នកប្រាជ្ញផ្នែកពុទ្ធសាសនា និងអ្នកប្រាជ្ញផ្នែកសាសនាព្រាហ្មណ៍ ហើយមានសាកលវិទ្យាល័យស្រីជ័យ (ព្រះខ័ន) និង សាកលវិទ្យាល័យរាជវិហារ (តាព្រហ្ម) ដែលមានព្រះមហាថេរថ្នាក់បណ្ឌិត ១៨ អង្គ សាស្ត្រាចារ្យ ២ ៧៤០ អង្គ។

ដូច្នេះខ្មែរមានភាសា មានអក្សរ មានការសិក្សាតាំងពីសម័យកាលនោះមក។ តើរឿងព្រេងខ្មែរកើតមានតាំងពីពេលណាមក?

បើសិក្សាស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅពីប្រវត្តិរឿងព្រេងដែលមាននៅក្នុងប្រទេសកម្ពុជា បានបង្ហាញតាមរយៈអក្សរសិល្ប៍ប្រជាប្រិយ និងអក្សរសិល្ប៍ចំណារ ÷

### ១. អក្សរសិល្ប៍ប្រជាប្រិយ

មនុស្សខ្មែរជំនាន់ដើម សម័យសង្គមសម្ពហភាពបុព្វកាលប្រកបរបររកស៊ីផ្អែកលើធម្មជាតិ ហើយប្រើកម្លាំងផ្ទាល់ចិញ្ចឹមជីវិតដោយបរបាញ់ នេសាទ និងដាំដំណាំបន្តិចបន្តួចគ្រាន់តែចិញ្ចឹមគ្រួសារខ្លួន កុលសម្ព័ន្ធខ្លួនប៉ុណ្ណោះ។ សកម្មភាពក្នុងសង្គមជំនាន់នោះមានតិចតួចស្ទួចស្តើងជាអនេក ម្ល៉ោះហើយការទាក់ទងរវាងក្រុមនិងរវាងកុលសម្ព័ន្ធក៏មិនសូវជាស្មុគស្មាញប៉ុន្មានដែរ គ្រាន់តែនិយាយជាពាក្យសំដីរកគ្នាទៅវិញទៅមកក៏ជាការស្រេច ។ ក៏ប៉ុន្តែនៅពេលដែលកុលសម្ព័ន្ធមានកំណើនច្រើន សកម្មភាពក្នុងសង្គមក៏បែងចែកជាច្រើនវណ្ណៈ រីឯការទាក់ទងរវាងមនុស្សនិងមនុស្ស រវាងក្រុមនិងក្រុមក៏រឹតតែមានសភាពធំទូលាយឡើង។

នៅពេលមិនទាន់មានអក្សរ បុព្វបុរសខ្មែរបានបង្កើត "អក្សរសិល្ប៍តាមរយៈសំដី កាយវិការ សញ្ញា" ដើម្បីកត់ត្រាសញ្ចេតនា បទពិសោធ ការប្រយុទ្ធតស៊ូប្រឆាំងនឹងធម្មជាតិ និងរឿងរ៉ាវផ្សេងៗដែលបានកើតឡើង។ អក្សរសិល្ប៍ប្រភេទនេះនិយាយពីមាត់មួយ ទៅមាត់មួយ ឆ្លងពីតំបន់មួយទៅតំបន់មួយ ពីសម័យកាលមួយទៅសម័យកាលមួយ ជាអក្សរសិល្ប៍ដែលផុសចេញពីប្រជាជន គ្មានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទច្បាស់លាស់ ដូចនេះទើបគេហៅថាជាអក្សរសិល្ប៍ប្រជាប្រិយ។ នៅពេលមានអក្សរចំណារ អក្សរសិល្ប៍ប្រជាប្រិយនៅតែបន្តអត្ថិភាពលូតលាស់របស់ខ្លួនជានិច្ច។ អក្សរសិល្ប៍មិនត្រឹមតែជាប្រភពជំរុញផលិតកម្ម ជាអាវុធរបស់ប្រជាជនកម្ពុជាយើងប៉ុណ្ណោះទេ ថែមទាំងជាសម្បត្តិវប្បធម៌សម្បូរបែប មិនចេះរីងស្ងួត សម្រាប់ឱ្យអ្នកសិក្សាស្រាវជ្រាវ រៀនសូត្រភាសា វេយ្យាករណ៍ អក្សរសាស្ត្រជាតិទៀតផង។



www.elibraryofcambodia.org

២. អក្សរសិល្ប៍ចំណារ

ប្រជាជនកម្ពុជា ស្ថិតនៅអាស៊ីភាគអគ្នេយ៍ ហើយមានវប្បធម៌ដ៏ចំណាស់ជាងគេ និងសម្បូរបែប។ តាមសិលាចារឹកគេអាចរកឃើញបញ្ជាក់ថាអក្សរខ្មែរកើតមានជារូបរាងតាំងពីដើមស.វ ទី១។

សិលាចារឹកខ្មែរបានកត់ត្រាពីប្រវត្តិកសាង ឬចម្បាំងក្នុងរជ្ជកាលរបស់ស្តេចនីមួយៗ។ អត្ថបទសិលាចារឹកពុំមានលក្ខណៈជាអក្សរពេញលេញនៅឡើយ ។ ក្រៅពីសិលាចារឹក យើងឃើញនៅមានអត្ថបទសរសេរលើស្បែកសត្វស្លឹកឈើឬក្រដាស់ខ្មៅដោយដីសបំពង ដូច្នេះតម្រានោះបានអន្តរាយដោយសារការបំផ្លាញពីសត្វល្អិត និងធាតុអាកាស មានតែសិលាចារឹកថ្មទេដែលនៅគង់វង្សបានយូរ ។ អត្ថបទសិលាចារឹកពីមុនសរសេរជាពាក្យរាយទាំងអស់ លុះមកដល់ គ.ស ១៧០១ កវីជ័យនន្ទ បានសរសេរកំណាព្យជាភាសាខ្មែរលើកដំបូងនៅលើសិលាចារឹក។

តាមហេតុផលខាងលើបានបញ្ជាក់ថា រឿងព្រេងខ្មែរកកើតឡើងតាំងពីមានជីវិតមនុស្ស មានភាសាខ្មែរមកម្ល៉េះ។ ប៉ុន្តែរឿងខ្លះកើតមកហើយមិនបានចងក្រងក៏បាត់បង់ទៅវិញ រីឯរឿងខ្លះចងក្រងហើយត្រូវបាត់បង់ទៅវិញដោយសារការដុតបំផ្លាញនៅក្នុងសង្គ្រាម។ ម្យ៉ាងទៀត អ្នកដែលបានចងចាំរឿងដោយជាប់រវល់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងកិច្ចការប្រទេសជាតិផងនោះ ទើបពុំមានពេលផ្សព្វផ្សាយរឿងដល់កូនចៅ ជាហេតុបណ្តាលឱ្យរឿងខ្លះទៀតត្រូវបានបាត់បង់នៅសល់តែរឿងក្រោយថ្មីៗ ដែលដូនតាខ្មែរបានច្នៃប្រឌិត និងចងក្រងទុកដល់សព្វថ្ងៃ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងក្រុមជំនុំទំនៀមទម្លាប់ខ្មែរបានប្រមូល បានចងក្រងរឿងព្រេងខ្មែរពីគ្រប់ភូមិ ឃុំ ស្រុក ខេត្ត ទូទាំងប្រទេសត្រូវបានបោះពុម្ពមាន ៩ ភាគ។

រឿងទាំងនោះចាត់ជាពួកៗ គឺ :

- រឿងទាក់ទងប្រវត្តិសាស្ត្រ រឿងភ្នំប្រុសភ្នំស្រី នៅខេត្តកំពង់ចាម ភ្នំទ្រុងមាន់ ភ្នំបាណន់ ភ្នំសំពៅ នៅខេត្តបាត់ដំបង ភ្នំសែនហាន នៅខេត្តកំពត ភ្នំនាងកង្រី នៅខេត្តកំពង់ឆ្នាំង ភ្នំសន្ទុក នៅខេត្តកំពង់ធំ ...
- រឿងទាក់ទងតុលាការកាត់ក្តី រឿងសុភាទន្សាយ និងរឿងផ្សេងៗដែលមានក្នុងសាស្ត្រក៏ឯកខ្លែជាដើម
- រឿងទាក់ទងជីវភាពរស់នៅ ការបរបាញ់ ( មានការទាក់ដំរីជាដើម)
- រឿងទាក់ទងទំនៀមទម្លាប់ មានទំនៀមមង្គលការ ដូចជារឿងទាក់ទងនឹងទំនៀមឱ្យថង់រង មហាទេព នៅពេលរៀបមង្គលការ រឿងព្រេងទាក់ទងទៅនឹងទំនៀមស្លៀកពាក់នៅពេលសំពះផ្ទឹម រឿងព្រេងទាក់ទងទៅនឹងដើមកំណើតទំនៀមផ្កាស្លាបី រឿងព្រេងទាក់ទងនឹងទំនៀមក្រោកពីសំពះផ្ទឹមឱ្យកូនប្រុសតោងស្បៃកូនស្រីចូលបន្ទប់ រួមទាំងរឿងសាស្ត្រល្បែងក៏មានច្រើនឥតគណនា ដូចរឿងព្រះជិនវង្ស វរវង្ស សុរវង្ស ស័ង្ខសិល្ប៍ជ័យ ជ័យទត្តជាដើម។

ដូច្នេះទាំងរឿងព្រេង ទាំងរឿងសាស្ត្រល្បែង ជារឿងពិរោះ និង មានប្រយោជន៍ខាងផ្លូវវណ្ណគតិអក្សរសាស្ត្រ ហើយជារឿងសម្រាប់ដឹកនាំអ្នកអាន អ្នកស្តាប់ឱ្យមានសតិបញ្ញាយល់ដឹងខុសត្រូវ ស្គាល់គុណទោស ចេះពិចារណាសមហេតុផលសម្រាប់យកទៅប្រើក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។



www.elibraryofcambodia.org

ខ. ប្រភពរឿងព្រេង

ប្រជាជនកម្ពុជាជាង ៩០ភាគរយ ជាកសិកររស់នៅជិតស្និទ្ធជាមួយនិងធម្មជាតិ ហើយសម្របខ្លួនជាមួយធម្មជាតិ។ មនុស្ស និងទេសភាពតែងតែផ្សារភ្ជាប់គ្នា។ មានពេលខ្លះមនុស្សចាត់ទុកទេសភាពជាមិត្តដ៏ស្និតបួតក្នុងជីវិត។ បាតុភូតធម្មជាតិ សកម្មភាពក្នុងជីវភាពរស់នៅប្រចាំថ្ងៃបានផ្តល់កំណើតដល់រឿងនិទាន ចម្រៀង សុភាសិត ពាក្យបណ្តៅ ...។ ម្យ៉ាងទៀត ការដែលប្រជាជនមានចិត្តស្រឡាញ់រាប់រកគ្នា ចេះជួយគ្នាទៅវិញ ទៅមក ប្រាស្រ័យទាក់ទងគ្នា ហូបចុកជាមួយគ្នា ស្មោះត្រង់ជាមួយគ្នា ហើយឆ្លងកាត់ការលំបាក ការនឿយហត់ និងគ្រោះថ្នាក់ជាមួយគ្នា ក៏នៅមានសុទិដ្ឋិនិយមស្រឡាញ់ជីវិតជានិច្ច ហើយមនោសញ្ចេតនាទាំងនេះ វាបង្កលក្ខណៈបង្កើតឱ្យមានរឿងនិទាន និងចម្រៀងប្រជាប្រិយ ។ រឿងព្រេងមានប្រភពមកពីប្រជាជនដែលនិយាយតៗគ្នារៀងរហូតមក ពីមាត់មួយទៅមាត់មួយ រឿងទាំងនេះច្រើនជារឿងខ្លីៗ មានតែរឿងធនញ្ជ័យ និងអាឡេវទេដែលវែងវែងបន្តិច។ រឿងព្រេង ជារឿងជឿនលឿនសម្រាប់ដាស់ស្មារតីប្រជាជនឱ្យភ្ញាក់រលឹក។ ហេតុនេះហើយបានជាវណ្ណៈខ្លាំងពូកែសម័យមុន មិនបានយកចិត្តទុកដាក់ចងក្រងជាសាស្ត្រាស្លឹករឹត ទុកឱ្យប្រជាជនសិក្សា និងពិចារណាគ្រប់គ្នាឡើយ។ ផ្ទុយទៅវិញគេច្រើនលើករឿងផ្តេសផ្តាស បន្ទំ ដូចជាអាជ័យមេរត ហើយឱ្យយោបល់ថា រឿងទាំងនោះមិនសមរម្យចៅកទាបសម្រាប់តែ "អាមនុស្សចៅកទាបមានពូជអម្បូរទុគិត[១]" សម្រាប់តែវង់អាយ៉ៃយកទៅឡកកំផ្លុកកំប្លែងលេង ។ មានខ្លះទៀតថា រឿងព្រេងទាំងនេះ ជារឿងឆ្កួតគ្មានបានការអ្វីទេ។ បើពិនិត្យសើៗយើងអាចជឿទៅតាមយោបល់ខាងលើនេះទាំងអស់ ។

រឿងព្រេងជារឿងរបស់ប្រជាជន មានអត្ថរស ខ្លឹមសារជំទាស់ពេញទីនិងការអប់រំអយុត្តិធម៌នៃសង្គមខ្មែរសម័យមុន។ រឿងព្រេងទាំងនោះ គេបានលើកតួឯក ឬ ជនគំរូដែលជាជនសាមញ្ញកូនប្រជាជនពិតៗ គេមិនបានរើសកូនទេវតាចុះពីឋានលើ ដូចក្នុងសាស្ត្រាល្បែងឡើយ។ រឿងព្រេងច្រើននិយាយពីការទាក់ទងមនុស្សក្នុងសង្គមជាតិផងទៃ មានជាតិចិន ថ្វា ជាដើម ដែលមករកស៊ីជើរសំពៅជំនួញនៅស្រុកខ្មែរយើង។

អ្នកស្រាវជ្រាវមួយចំនួនបានចាត់ទុកអក្សរសិល្ប៍ប្រជាប្រិយ ជាកម្រងឯកសារវិទ្យាសាស្ត្រសង្គមរបស់ជនជាតិទាំងឡាយក្នុងលោក។ ក្នុងនោះដែរ ប្រវត្តិសាស្ត្រសង្គមបានបង្ហាញឱ្យឃើញថា ជនជាតិខ្មែរជាជនជាតិចូលចិត្តជិតអារម្មណ៍នូវការស្តាប់ ការនិទានរឿងព្រេង ការសូត្រ កំណាព្យ ចម្រៀងប្រជាប្រិយ ដែលបុព្វបុរស ឬ អ្នកប្រាជ្ញចាស់ទុំពីបុរមបុរាណគាត់តែងប្រឌិតឡើងដោយយករឿងវិបត្តិទំនាស់ ព្យាបាទ ឈ្នានីស ច្រណែន ប្រច័ណ្ឌ ផិតក្បត់ សាហាយស្មន់ ប្រើល្បិចកល ប្រវត្តិភូមិស្រុក ទំនៀមទម្លាប់ ប្រពៃណី និងរឿងប្រណាំងប្រជែងក្នុងសម័យកាលមួយនៃប្រវត្តិសាស្ត្រមកលើកជាសេចក្តីសម្រាប់និទានប្រាប់កូនចៅ ញាតិមិត្តជិតឆ្ងាយដោយយកហេតុផលដើម្បីប្រៀនប្រដៅណែនាំអនុជន តាមដំបូន្មាន ចរិយាសាស្ត្រ ច្បាប់ទម្លាប់ ប្រពៃណីល្អៗគ្នា។

ឧទាហរណ៍ៈ រឿងសុភាទន្សាយ រឿងមាយើង ...។ រឿងបែបនេះកាលពីមុនគ្មានការកត់ត្រាជាក្បួនខ្នាត ឬ សៀវភៅនៅឡើយ គេចាំតៗគ្នា ហើយនិយាយគ្រប់ៗគ្នា ពីកន្លែងមួយទៅកន្លែងមួយ រហូតពាសពេញប្រទេស

---

១ព្រឹត្តិបត្រសមាគមអ្នកនិពន្ធខ្មែរ លេខពុម្ពលើកទី៤ ខែមិនា ឆ្នាំ ១៩៦១ ទំព័រ៩១



www.elibraryofcambodia.org

ដែលមានប្រជាប្រិយភាពសុះសាយ ។

លុះត១មក រឿងព្រេងដែលអ្នកស្រុកបានចាំយ៉ាងស្ទាត់ជំនាញនេះ ក៏បង្កើតបានជាជំនឿ ជាការចូលចិត្ត ចាប់អារម្មណ៍ រហូតដល់បង្កើតបានជាពិធី ជាការគោរព ជាប្រពៃណីហូរហែទូទាំងប្រទេស ។

ឧទាហរណ៍: រឿងធនញ្ជ័យ ជារឿងព្រេងប្រជាប្រិយ ដែលប្រជាជនខ្មែរទាំងមូលស្ទើរតែជឿជាក់ថា ជារឿងពិត ជឿថាខ្មែរមានអ្នកប្រាជ្ញម្នាក់ដែលមានឈ្មោះថា ធនញ្ជ័យមែន ។

រឿងមរណមាតា មានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងផ្នត់គំនិតខ្មែរទូទៅ រហូតដល់មានអ្នកស្រុកខ្លះជឿថា នាងកុលកេសី ប្រពន្ធនាយកុដុម្ពីដែលបានស្លាប់ទៅ បានចាប់កំណើតជាត្រីដីរ៍ ទើបធ្វើឱ្យប្រជាជនខ្មែរមួយចំនួន មានចិត្តអាណិតអាសូរ រហូតដល់គេពុំបរិភោគត្រីដីរ៍ឡើយ ។

រឿងពុទ្ធិសែននាងកង្រី បានធ្វើឱ្យប្រជាជនរស់នៅខេត្តកំពង់ឆ្នាំងក៏ដូចជាប្រជាជនខ្មែរទូទាំងប្រទេសមួយ ចំនួននិយមជឿជាក់ថា ជារឿងពិត ព្រោះមានភស្តុតាងភ្នំជានិមិត្តរូបនៃសាកសពនាងកង្រីដែលបានទៅស្លាប់ នៅក្បែរឆ្នេរជលសារដើម្បីសម្តែងស្វាមីភក្តិចំពោះពុទ្ធិសែន ។ ម្យ៉ាងវិញទៀត មានប្រជានជននៅខេត្តកំពង់ឆ្នាំង មួយចំនួនគេពុំបរិភោគម្ទេស ព្រោះគេមានជំនឿថា ម្ទេសនេះជារោមក្លៀកខ្មាស់របស់នាងកង្រី ។

រឿងអ្នកតាឃ្លាំងមឿង អ្នកស្រុកនៃខេត្តពោធិ៍សាត់ជឿ ហើយគោរពធ្វើបុណ្យឡើងអ្នកតារៀងរាល់ឆ្នាំ សម្រាប់រំលឹកដល់គុណបំណាច់នៃវិញ្ញាណក្ខន្ធអ្នកតាឃ្លាំងមឿង ដែលមានគុណូបការៈដ៏ថ្លៃថ្លា ចំពោះប្រជាជនខ្មែរ ដោយលោកហ៊ានលះបង់អាយុជីវិតដើម្បីបុព្វហេតុជាតិ ។

នៅពេលរឿងប្រឌិតក្លាយទៅជាជំនឿ ជាទំនៀមទម្លាប់ ជាប្រពៃណីបានដក់ជាប់ក្នុងចិត្តអ្នកស្រុក ជាប់ នឹងឈ្មោះទីកន្លែង រឿងនោះមានឈ្មោះថា រឿងព្រេង ឬ អក្សរសិល្ប៍ប្រជាប្រិយ ។

វត្តអារាមជាថ្នាលបណ្តុះបណ្តាលនូវចំណេះដឹង ជាសាលារៀន ជាសាកលវិទ្យាល័យរបស់ប្រជាជនខ្មែរ នៅសម័យដើម ។ ក្រោយសម័យមហានគរ ប្រជាពលរដ្ឋតែងបញ្ជូនកូនចៅទៅនៅវត្ត ព្រះសង្ឃគឺជាសាស្ត្រាចារ្យ ជាគ្រូរបស់យុវជនខ្មែរ ហើយជាកន្លែងតម្កល់ទុកនូវឃ្លាំងអក្សរសាស្ត្រ គណិតសាស្ត្រ វោហាសាស្ត្រ សិល្បសាស្ត្រ យុទ្ធសាស្ត្រ ពេទ្យ ច្បាប់ ជំនួញ សិប្បកម្ម កសិកម្ម...។ កុលបុត្រដែលបានបួសរៀនក្នុងវត្ត អាចក្លាយជា ព្រះមហាក្សត្រ សេនាបតី នាម៉ឺន មន្ត្រីកាន់ការងារប្រទេស ។ លោកអ្នកទាំងនោះហើយជាអ្នកនិពន្ធរឿងព្រេង ជាអ្នកចារសាស្ត្រា ជាអ្នកចម្លងស័ព្ទ សេចក្តីគម្ពីរផ្សេងៗ ជាអ្នកបកប្រែភាសាបាលី សំស្ក្រឹត មកជាភាសាខ្មែរ ហើយរឿងព្រេងទាំងនោះក៏ផ្សព្វផ្សាយតៗគ្នាមក ។

នៅដើមស.វទី១ នៃគ.ស ខ្មែរបានទទួលឥទ្ធិពលពីវប្បធម៌ក្លឹង តាមរយៈការផ្សព្វផ្សាយវប្បធម៌ ពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ។ នៅក្នុងអំឡុងដើមស.វទី១នេះ ខេមរពុទ្ធសាសនិក បានធ្វើដំណើរមកទាក់ទង ជាញឹកញាប់ជាមួយប្រទេសស៊ីរីលង្កា (ឥណ្ឌា) ហើយបានចម្លងយកវប្បធម៌ក្លឹង ជាអក្សរសំស្ក្រឹត ភាគខ្លះក៏បាន រក្សាទុកច្បាប់ដើម តែមួយភាគធំបានកែច្នៃទាំងពាក្យពេចន៍ឱ្យមកជាលក្ខណៈ ខ្មែរសុទ្ធសាធ ដូចជារឿងក្បួនសមុទ្រ ទឹកដោះ រឿងមហាភារតយុទ្ធ រឿងរាមកេរ្តិ៍ ស្រីហិតោបទេសជាដើម ។ ក្រោយមកពួកអឺរ៉ុបមានឥទ្ធិពល



www.elibraryofcambodia.org

ផ្សព្វផ្សាយដល់អាស៊ី  រឿងព្រេងខ្លះក៏មានការជះឥទ្ធិពលពីគ្នាទៅវិញទៅមក  ហើយអ្នកនិពន្ធនៅប្រទេសនីមួយៗ បានកែសម្រួលខ្លឹមសារឱ្យស្របទៅនឹងតថភាពសង្គម  និងមជ្ឈដ្ឋានរស់នៅរបស់ខ្លួន។ លំហូរនៃវប្បធម៌នេះ  រឿងព្រេងពុំត្រឹមតែប្រទេសដែលមានវប្បធម៌ខ្ពង់ខ្ពស់  ជះឥទ្ធិពលដល់ប្រទេសដែលមានវប្បធម៌ទន់ទាបទេ  តែប្រទេសដែលមានវប្បធម៌ទន់ទាបក៏ធ្វើឱ្យប្រទេសដែលមានវប្បធម៌ខ្ពង់ខ្ពស់  ជ្រួតជ្រាបនូវវប្បធម៌របស់ខ្លួនផងដែរ។ រឿងព្រេងខ្លះមាននៅស្ទើរតែគ្រប់ប្រទេសមិនដឹងថា តើរឿងនេះមានប្រភពដើមមកពីប្រទេសណា ដូចជារឿង ទន្សាយ និងខ្យង ជប៉ុនក៏មាន ខ្មែរក៏មាន ឥណ្ឌូណេស៊ីក៏មាន រឿងរ៉ៃ និង ស្រមោច អាស៊ីក៏មាន អឺរ៉ុបក៏មាន។



រឿងមហាភារតយុទ្ធ ( ជញ្ជាំងប្រាសាទអង្គរវត្ត )



រឿងកូរសមុទ្រទឹកដោះ



www.elibraryofcambodia.org



រឿងព្រះវេស្សន្តរ



រឿងទុំទាវ



www.elibraryofcambodia.org

គ. ការនិទានរឿង

១. និយមន័យ

ការនិទានរឿង គឺជាការនិយាយរឿងរ៉ាវដែលបានចេះចាំកន្លងមកប្រាប់អ្នកស្តាប់ ។ ការនិទានរឿងមានទម្រង់ជាច្រើន ដូចជាការនិទានដោយផ្ទាល់មាត់ សៀវភៅរូបភាព ផ្ទាំងរូបភាព តុក្កតា ល្ខោនបាសាក់ ល្ខោនខោលយីកេ អាយ៉ៃ សាដៀវ ចាប៉ី ល្ខោនស្រមោលស្បែកតូច ធំ ខ្សែភាពយន្តជាដើម ។

២. របៀបនិទានរឿង

២.១ វិធីសាស្ត្រនិទានរឿង

ជាទូទៅការនិទានរឿង គេច្រើនប្រើវិធីរ៉ាយរ៉ាប់ សន្ទនា ចោទឆ្លើយ ដើម្បីធ្វើឱ្យខ្លឹមសារសាច់រឿងមានភាពរស់រវើក ដែលអាស្រ័យទៅដោយសម្បទា និងល្បិចរបស់មនុស្សម្នាក់ៗ ។ ការនិទានរឿងគឺជាកិច្ចការមួយដែលយើងអាចហាត់រៀនបាន ។

គេអាចចែកលំនាំនៃការនិទានរឿងជាពីរជំហានដោយប្រើរយៈពេលពី ១០នាទី ទៅ២០នាទី ។

ជំហានទី ១ : ទាញបម្រុងប្រយ័ត្ន ( រយៈពេលពី ៣ ទៅ ៥ នាទី)

ដើម្បីឱ្យការនិទានរឿងរបស់យើងទទួលបាននូវលទ្ធផលជោគជ័យ អ្នកនិទានត្រូវអប់រំដោយប្រយោល ( មិនដឹងខ្លួន) ដល់អ្នកស្តាប់តាមរយៈល្បែង និងសំណួរផ្សេងៗ ដែលខ្លឹមសារមានបង្កប់នូវ :

- ការទាញបម្រុងប្រយ័ត្ន (ភាសា គណិតវិទ្យា វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម ល្បែងសិក្សា ពាក្យបណ្តៅ ទស្សនវិជ្ជា...)
- ចំណេះដឹង និងការអប់រំ
- ខ្លឹមសាររឿង

ជំហានទី ២ : និទានរឿង ( រយៈពេលពី ១០ ទៅ ១៥ នាទី)

ផ្តើមនិទានពីដើមដល់ចប់សាច់រឿង ដោយប្រើវិធីរ៉ាយរ៉ាប់តួបផ្សំ និងល្បិចធ្វើកាយវិការ ទឹកមុខក្រសែភ្នែក និងលើកដាក់សំឡេងផង ។ ក្នុងការនិទានរឿងអ្នកនិទានត្រូវប្រើសំឡេងតាមតួអង្គ ( មនុស្សចាស់ ក្មេង កាច ស្លូត ទុក្ខព្រួយ សើចសប្បាយ...) និងសម្តីរបស់អ្នកនិពន្ធ ។

ដើម្បីឱ្យការនិទានមានភាពរលូន អ្នកនិទានរឿងត្រូវ ÷

* ចេះចាំសាច់រឿង

- អានរឿងដែលត្រូវនិទានឱ្យបានច្រើនដងទើបអាចយល់ខ្លឹមសាររឿង ឆ្លុះបញ្ចាំងពីទស្សនអប់រំ
- ធ្វើការនិទានរឿងសាកល្បងឱ្យបានច្រើនសារ ដើម្បីចងចាំដំណើររឿង ឬ ឈុតឆាក
- ប្រើពាក្យ ឃ្លា ប្រយោគឱ្យបានត្រឹមត្រូវ ដោយសង្កត់ធ្ងន់លើខ្លឹមសារ ដែលអ្នកនិទានចង់បាន
- និទានមិនឱ្យរអាក់រអួលតាំងពីដើមដល់ចប់សាច់រឿង
- ត្រូវមានភាពជឿជាក់លើខ្លួនឯង ។



www.elibraryofcambodia.org

* ចេះចូលតួអង្គ

- លើកដាក់សំឡេងតាមតួអង្គនីមួយៗ
- ប្រើសំឡេងអ្នកនិពន្ធ និងតួអង្គ
- ធ្វើកាយវិការ ទឹកមុខតាមតួអង្គក្នុងសាច់រឿង
- បង្កើតទំនាក់ទំនងរវាងអ្នកស្តាប់ និង អ្នកនិទាន ( ដោយប្រើក្រសែភ្នែកទៅអ្នកស្តាប់ ) ។

* ផ្តល់ឱកាសឱ្យកុមារបានចូលរួម

- រឿងនិទានខ្លះកុមារអាចស្ម័គ្រចិត្តចូលរួមដើរតួតាមសាច់រឿង
- ទុកឱកាសឱ្យកុមារបង្កើតរូបារម្មណ៍ ( ស្រមើស្រមៃ)
- អាចប្រើឧបករណ៍ជំនួយខ្លះៗ សម្រាប់កុមារចូលរួម ( ខ្សែពួរ ចង្អេរ កំប៉ុង ស្គរ ទ្រ... ) ។

* ចេះគ្រប់គ្រងកុមារពេលនិទានរឿង

- ប្រើក្រសែភ្នែកដើម្បីគ្រប់គ្រងកុមារ តែមិនត្រូវបញ្ឈប់ ឬ បង្ខិតបង្ខំឱ្យកុមារស្តាប់ការនិទានរឿង
- ប្រសិនបើកុមារមិនស្តាប់ អ្នកនិទានរឿងត្រូវប្តូរល្បិច ឬវិធីសាស្ត្រភ្លាម ។

* ស្វ័យវាយតម្លៃ

- ការនិទានរឿងល្អ ឬ មិនល្អ មិនចាំបាច់សួរកុមារទេ
- សកម្មភាពរបស់កុមារអាចឆ្លុះបញ្ចាំងឱ្យដឹងថា តើកុមារចូលចិត្ត ឬ មិនចូលចិត្តស្តាប់ការនិទានរឿង តាមរយៈទឹកមុខ សកម្មភាព និងក្រសែភ្នែក
- ប្រតិកម្មរបស់កុមារជារង្វាយតម្លៃរបស់អ្នកនិទានរឿង ។

### ២.២ ការជ្រើសរើសរឿងនិទាន

ការជ្រើសរើសរឿង គឺជាការងារចាំបាច់បំផុតរបស់អ្នកនិទាន ដើម្បីឱ្យកុមារស្អុងអារម្មណ៍ដោយខ្លួនឯងទៅនឹងរឿងដែលយើងយកមកនិទាន ។ វិធីជ្រើសរើសរឿងមាន ÷

- ជ្រើសរើសរឿងងាយយល់ មានតួអង្គមិនច្រើនពេក
- ជ្រើសរើសរឿងមានពាក្យងាយយល់ស្រួលស្តាប់
- ជ្រើសរើសសៀវភៅ ឬផ្ទាំងរូបភាពដែលមានពណ៌ភ្លឺច្បាស់ រូបគំនូរ និងអត្ថបទចំពេញឱ្យគ្នាទៅវិញទៅមក ហើយចំណងជើងរឿងស៊ីនឹងខ្លឹមសាររឿង
- ជ្រើសរើសរឿងឱ្យសមស្របតាមអាយុ និងកម្រិតយល់ដឹងរបស់កុមារ
- ជ្រើសរើសរឿងដែលប្រើរយៈពេលសមស្រប

### ២.៣ ទីកន្លែងនិទាន និងការរៀបចំសិស្ស

ក្នុងបន្ទប់ :



www.elibraryofcambodia.org

- បន្ទប់ត្រូវបើកទ្វារ ឬបង្អួចឱ្យមានពន្លឺ និងខ្យល់ចេញចូលគ្រប់គ្រាន់
- រៀបសិស្សឱ្យអង្គុយតាមតុ ឬកន្ទេល ទៅតាមស្ថានភាពជាក់ស្តែង
- រៀបសិស្សឱ្យអង្គុយតាមលំដាប់ពីតូចទៅធំដែលអាចមើលឃើញរូបភាព កាយវិការ និងទឹកមុខអ្នកនិទាន
- រៀបសិស្សឱ្យអង្គុយជាចំណិតព្រះចន្ទ ( ចម្ងាយពីអ្នកនិទានទៅអ្នកស្តាប់ពី១.៥០ម៉ែត្រទៅ២.៥០ម៉ែត្រ)




ទីធ្លាក្រោមដើមឈើ រោង ឬ អគារ
- សំអាតទីធ្លាឱ្យបានស្អាតមុននិទាន
- ពិនិត្យមើលដើមឈើ ឬអគារក្រែងមានការពុកផុយអាចបាក់ធ្លាក់លើកុមារ
- ឱ្យកុមារអង្គុយលើកន្ទេល ស្បែកជើង ឬវត្ថុផ្សេងៗដែលអាចអង្គុយបាន
- ឱ្យកុមារអង្គុយជាចំណិតព្រះចន្ទ
- ឱ្យអ្នកស្តាប់អង្គុយស្របនឹងពន្លឺថ្ងៃ

### ឃ. ប្រភេទនៃការនិទានរឿង

ការនិទានរឿងមានច្រើនរបៀប តាមជាតិសាសន៍នីមួយៗ ដោយផ្សព្វផ្សាយពីកេរដំណែល ទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី សាសនា ចំណេះដឹង និងគំនិតប្រាជ្ញារបស់ពួកគេ ។ ការនិទានរឿងដោយផ្ទាល់មាត់ សៀវភៅរូបភាព ផ្ទាំងរូបភាព ឬសម្ភារផ្សេងៗទៀត គឺបង្កើតឱ្យមានពិភពរឿងនិទាន ។ ប្រភេទសំខាន់ៗនៃរឿងនិទានមាន ÷

- ការនិទានរឿងដោយផ្ទាល់មាត់



www.elibraryofcambodia.org

- ការនិទានរឿងដោយសៀវភៅរូបភាព
- ការនិទានរឿងដោយផ្ទាំងរូបភាព
- ការនិទានរឿងដោយប្រើអាវអៀម
- ការនិទានរឿងដោយប្រើតុក្កតា
- ការនិទានរឿងដោយប្រើឧបករណ៍ ចាប៉ី អាយ៉ៃ ល្ខោន យីកេ សាដៀវ ទេសនា...។

១. ការនិទានរឿងដោយផ្ទាល់មាត់

ការនិទានរឿងដោយផ្ទាល់មាត់ភាគច្រើនជាសេចក្ដីតំណាល ដែលគេនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ពីស្រុកភូមិមួយទៅស្រុកភូមិមួយ ឬប្រទេសមួយទៅប្រទេសមួយទៀត ដោយគ្មានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទច្បាស់លាស់ ហើយត្រូវបានរក្សាទុកដដែលៗរហូតមកហើយ។ ដើម្បីឱ្យការនិទានរឿងដោយផ្ទាល់មាត់បានល្អ អ្នកនិទានត្រូវ ÷

- ចេះចាំសាច់រឿងឱ្យបានច្បាស់លាស់
- យល់ពីខ្លឹមសាររឿង និងដំណើររឿងតាមឈុតឆាកនីមួយៗ
- ធ្វើកាយវិការ ទឹកមុខ លើកដាក់សំឡេងតាមតួអង្គ
- បង្ហាញអំពីការរីករាយ កំហឹង ទុក្ខព្រួយទៅតាមសាច់រឿង
- សម្លឹងមើលភ្នែក និងទឹកមុខអ្នកស្ដាប់ក្នុងពេលកំពុងនិទាន
- ឈរ ឬអង្គុយឱ្យបានសមរម្យ
- កុំនិទាន ឬនិយាយពាក្យដដែលៗ
- កុំនិយាយបញ្ចេញបញ្ចូលច្រើនពេក

២. ការនិទានរឿងដោយសៀវភៅរូបភាព

- មុននិទានរឿងគួរកុំបង្ហាញចំណងជើងសៀវភៅឱ្យអ្នកស្ដាប់ឃើញ ដល់ពេលនិទានទើបបង្ហាញតែម្ដង
- កាន់ឲ្យចបន្តិច កុំបាំងរូបភាពដែលចង់បង្ហាញ
- ត្រូវហាត់ផ្ទាត់ទំព័រសៀវភៅរូបភាពឱ្យបានស្ទាត់ជំនាញដោយបញ្ចូលម្រាមដៃកុំឱ្យគេឃើញល្បិច
- រូបភាពមួយទំព័រ គួរកុំបើកបង្ហាញទាំងពីរទំព័រ ពីព្រោះទំព័រខាងអក្សរអាចទាញបម្រុងប្រយ័ត្នរបស់កុមារឱ្យខុសគោលដៅដែលអ្នកនិទានចង់បានដោយបង្ហាញតែរូបភាពមួយបានហើយ
- រូបភាពពីរទំព័រ គួរបើកបង្ហាញទាំងពីរតែម្ដង
- សៀវភៅរូបភាពខ្លះអាចកម្រើកទៅលើ ឬចុះក្រោម ទៅមុខ ឬថយក្រោយដោយប្រុងប្រយ័ត្ន
- សៀវភៅត្រូវកាន់ឱ្យមានលំនឹងល្អ ។



www.elibraryofcambodia.org

- រូបភាពពីរទំព័រជាប់គ្នាមានឈុតខុសគ្នា ត្រូវបង្ហាញម្តងមួយទំព័រ

៣. ការនិទានរឿងដោយផ្ទាំងរូបភាព

- បើកវាំងនន
- ប្រាប់ចំណងជើងដែលត្រូវនិទាន
- ផ្តើមនិទាន
- ទាញរូបភាពម្តងមួយសន្លឹកៗ រួចស៊កចូលខាងក្រោយផ្ទាំងរូបភាពដែលក្រោយគេ (បើផ្ទាំងរូបភាពមានរូបតែមួយ)
- ទាញរូបភាពពាក់កណ្តាលម្តង រួចពាក់កណ្តាលម្តងទៀត (បើរូបភាពមួយផ្ទាំងមានរូបភាពពីរ)
- ផ្ទាំងរូបភាពណាត្រូវស្រែកត់រាម ភ័យខ្លាច ឈ្លោះគ្នា គួរអ្នកនិទានទររូបភាពពីខាងខ្នងឱ្យវាកម្រើក ឬទ្រេតឱ្យញ័រ ដោយយកដៃកាន់ពីខាងខ្នងផ្ទាំងរូបភាព។

● <u>របៀបបង្ហាញផ្ទាំងរូបភាព ដោយកាន់ដៃទាំងពីរ</u>

- បង្ហាញចំណងជើងរឿង ដូចសៀវភៅរូបភាពដែរ
- ផ្តើមនិទាន
- ទាញរូបទៅឆ្វេង ទៅស្តាំ អាស្រ័យតាមសម្បទារបស់អ្នកនិទាន និងស្របតាមផ្ទាំងរូបភាព
- អាចទាញពីលើចុះក្រោម តាមសាច់រឿង
- ស៊ករូបចូលពីចំហៀង តាមលំដាប់លំដោយ
- បើរូបមួយផ្ទាំងមានពីររូប គួរទាញពាក់កណ្តាលម្តងតាមខ្លឹមសាររឿង
- អាចកម្រើកផ្ទាំងរូបភាពបានតាមសាច់រឿង។

● <u>របៀបរៀបសន្លឹកផ្ទាំងរូបភាព</u>

ត្រូវរៀបទំព័រចំណងជើងមុនគេ បន្ទាប់មកចាប់ពីទំព័រទី២ ទី៣ ទី៤ តាមលំដាប់លំដោយរហូតដល់ចប់។

<u>សម្គាល់:</u> ខ្លឹមសារនៅទំព័រទី១ នៅខាងក្រោយគេបំផុត គឺបង្ហាញរូបភាពនៅទំព័រទី២បន្ទាប់។ ខ្លឹមសារទំព័រទី២ គឺបង្ហាញរូបភាពនៅទំព័រទី៣បន្ទាប់ បន្តបន្ទាប់គ្នារហូតដល់ចប់សាច់រឿង ។ ផ្តើមនិទានតាមពីរជំហានដែលបានគ្រោងទុក។

៤. ការនិទានដោយប្រើអាវអៀម

យើងត្រូវជ្រើសរើសរឿងឱ្យសមស្របតាមវ័យរបស់កុមារ យករឿងដែលមានតួអង្គតិច ភ្ជាប់គោលបំណង



www.elibraryofcambodia.org

នៃរឿង សិក្សាខ្លឹមសាររឿង ដើម្បីរៀបប្លង់លើអាវអៀម ។

ការរៀបចំការនិទានរឿង :

- មុនពេលនិទាន ត្រូវរៀបចំទុកដាក់រូបតាមលំដាប់លំដោយនៃតួអង្គ

- ក្នុងពេលនិទាន លើកដាក់សំឡេងតាមតួអង្គឱ្យត្រូវសាច់រឿង រក្សាសំឡេងមូលដ្ឋានរបស់តួអង្គ ភ្នែកសម្លឹងទៅកុមារ ទឹកមុខអ្នកនិទានត្រូវប្រែប្រួលទៅតាមសាច់រឿង កាន់ឲ្យចូរូបកុំឱ្យបាំងដៃ ពេលនិទានត្រូវទុកពេលឱ្យកុមារគិត ។ ការនិទានដោយប្រើអាវអៀមដូចគ្នានឹងការនិទានដោយផ្ទាំងរូបភាពដែរ។ ការនិទានល្អ ឬមិនល្អ អាស្រ័យទៅលើសិល្បៈវិធីរបស់អ្នកនិទាន ។

សម្ភារត្រូវការ

អាវអៀមត្រូវយកកំណាត់សាច់ក្រាស់មកដេរ ចំណែកតុក្កតាយកកំណាត់សំឡី ឬកំណាត់ធម្មតា កំណាត់សំឡីទ្រាប់អាវ កំណាត់ស្អិតញីឈ្មោល កន្ត្រៃ អំបោះ ម្ជុល ខ្មៅដៃគូ ជ័រលុប ខ្មៅដៃពណ៌ សម្រាប់ផាត់ពណ៌ សំឡីតុក្កតា ឥ ការ បន្ទាត់ ខ្សែម៉ែត្រ ក្រដាសកាតុង និង សម្ភារផ្សេងៗទៀតទៅ តាមសាច់រឿង។

របៀបផលិត

<u>របៀបកាត់អាវអៀមៈ</u>

- សម្រុងអាវ ពី ៦៥ស.ម ទៅ ៧០ស.ម អាស្រ័យទៅលើកម្ពស់អ្នកនិទាន

- ទទឹងអាវ ពី ៥៥ស.ម ទៅ ៦០ស.ម

- ទទឹងកអាវ ២២ស.ម

- សម្រុងក្បៀក ពី ២០ស.ម ទៅ ២៥ស.ម

- ផ្ទាំងខាងក្នុង ទំហំដូចខាងក្រៅដែរ ប៉ុន្តែខ្លីជាង ៣៥ស.ម ទៅ ៤០ស.ម

- ខ្សែអាវ ៤ សម្រាប់ចង ខ្សែនីមួយៗប្រវែង ៦០ស.ម

- ហោប៉ៅ អាចដាក់ខាងមុខ ខាងក្រោយ អាស្រ័យទៅលើរឿង



www.elibraryofcambodia.org

ឧទាហរណ៍៖ រឿងពពែកាភកាភដុង







www.elibraryofcambodia.org

របៀបផលិត និងប្រើប្រាស់អាវអៀមសម្រាប់និទានរឿង

ក្នុងរឿងនេះត្រូវដេរអាវអៀមដាក់ហោប៉ៅអាវនៅខាងក្នុងសងខាង ហើយផ្នែកចំហៀងត្រូវដេរពីរជាន់។ បន្ទាប់មកគូររូបពពែបី តូច មធ្យម និងធំ ដើម្បីធ្វើជាតុក្កតា គូសលើកំណាត់ត្រួតគ្នាពីរជាន់ កាត់ដេរ ដូចគេស្រេះរន្ធឡេវអាវ ទុកចន្លោះសម្រាប់ញាត់គចូល រួចដេរភ្ជាប់ដូចមុន ស្នែង និងពុកមាត់ ដេរបន្ថែមតាមក្រោយ។ បន្ទាប់មកកាត់ដេរធ្វៃធ្វើជាយក្សថូឡូល ស្ពាន រើសមែកឈើមកក្រងនឹងលួស នៅលើអាវអៀមត្រូវចេះស្រមៃរៀបចំប្លង់ឱ្យត្រូវតាមសាច់រឿង។ មុនពេលនិទាន ត្រូវរៀបចំតួអង្គទាំងនោះ ដាក់តាមកន្លែងឱ្យបានត្រឹមត្រូវងាយស្រួលយកចេញមកបង្ហាញ។

- និទានរឿងបណ្តើរ ដៃលូកយកពពែមកបង្ហាញបណ្តើរ

- យកពពែកាភកាការដុងតូចចេញមុន បិទតាមកន្លែងដែលត្រៀមទុក បន្ទាប់មក ពពែកាភកាការដុងទី២ ហើយពពែកាភកាការដុងទី៣

- ពពែទាំងបីពិភាក្សាគ្នា ហើយពពែកាភកាការដុងទី១ដើរមកដល់ស្ពានឮសូរ តិកតក់ៗ

- យកយក្សថូឡូលចេញ ហើយស្រែកឡើងថា អ្នកណាធ្វើឱ្យស្ពានរបស់យើងឮសូរ តិកតក់ តិកតក់...

- យកយក្សថូឡូលដាក់ចូលក្នុងវិញ បន្ទាប់មកពពែកាភកាការដុងទី២បានមកដល់ ដើរឮសូរ តុក តុក តុក

- ធ្វើដូចគ្នានឹងពពែកាភកាការដុងទី១ដែរ គ្រាន់តែប្តូរជាតួអង្គពពែកាភកាការដុងទី២វិញ

- ចុងក្រោយពពែកាភកាការដុងទី៣មកដល់យក្សថូឡូលសម្លុត តែត្រូវពពែកាភកាការដុងទី៣ គំរាមវិញ ហើយប្រយុទ្ធគ្នារហូតយក្សថូឡូលស្លាប់ ពពែកាភកាការដុងទី៣ឡើងទៅស៊ីស្មៅ។

## ៥. ការនិទានរឿងដោយតុក្កតា ម៉ារ៉ុកែត ឬអាយ៉ង

សាច់រឿងដែលសម្តែងដោយប្រើតុក្កតា ឬអាយ៉ងធ្វើឱ្យអ្នកស្តាប់ ឬអ្នកទស្សនាជក់ចិត្តជិតអារម្មណ៍ អាស្រ័យដោយអ្នកសម្តែងធ្វើយ៉ាងណាឱ្យការនិទានមានភាពរស់រវើក ប៉ិនប្រសប់ និង ពោលពាក្យជាមួយផង។

របៀបកាន់និទាន

- រៀបចំសម្ភារ ( តុក្កតា ម៉ារ៉ុកែត ឬអាយ៉ងដែលផលិតចេញពីក្រដាស កំណាត់សំពត់ ស្បែក ទៅតាមសាច់រឿង )

- កំណត់ឈ្មោះ និងចំនួនតួអង្គ

- ពេលនិទានត្រូវលើកតួអង្គមកបង្ហាញតាមសាច់រឿង

- តួអង្គត្រូវមានចលនារស់រវើកតាមសាច់រឿង ដូចជា សប្បាយ ភ័យ ខឹង លោត រត់ យំ វាយតប់គ្នា ...។

## ៦. ការនិទានរឿងដោយល្ខោនស្រមោលស្បែក

នៅលើពិភពលោក គេសង្កេតឃើញមានសិល្បៈប្រភេទល្ខោនស្រមោលស្បែកទៅតាមលក្ខណៈតំណាង



www.elibraryofcambodia.org

ឱ្យវប្បធម៌ជាតិក្នុងប្រទេសនីមួយៗ ដូចជា កម្ពុជា ថៃ ឡាវ ឥណ្ឌូនេស៊ី អ៊ីរ៉ង់ ទួរគីជាដើម។ តាមការសង្កេតឃើញថា ល្ខោនស្រមោលស្បែកទាំងនេះសុទ្ធសឹងមានលក្ខណៈទាំងរូបរាង ទាំងការសម្តែង ជើត ពោល និងតន្ត្រីដែលបម្រើឱ្យសិល្បៈ ក្នុងការសម្តែងគឺមានភាពខុសប្លែកពីគ្នាទាំងអស់ដែលមានលក្ខណៈបង្ហាញសម្គាល់ភូមិសាស្ត្រ និងទំនៀមទម្លាប់ប្រពៃណីរបស់ប្រទេសជាតិនីមួយៗ។

តាមការប៉ាន់ស្មាន សិល្បៈល្ខោនស្រមោល ឬសិល្បៈ ស្បែកធំ ស្បែកធម្មតា និងស្បែកតូចទាំងនេះដែលជាដើមកំណើតរបស់សិល្បៈភាពយន្តសព្វថ្ងៃ។ ចំណែកនៅប្រទេសកម្ពុជាវិញ គេសង្កេតឃើញមានប្រភេទល្ខោនស្រមោលស្បែកនេះ បីបែបខុសៗពីគ្នាគឺ:

ល្ខោនស្រមោលស្បែកធំ

ជាចម្លាក់នៅលើស្បែកគោដែលមានទំហំធំរហូតដល់ផ្ទាំងខ្លះមានផ្ទៃក្រឡាជាង ២ម៉ែត្រការ៉េ មានទម្ងន់រហូតដល់ ៨គីឡូក្រាម ជារូបចម្លាក់នឹងថ្កល់ គ្មានចលនាកម្រើកបានទេ ហើយល្ខោនស្បែកប្រភេទនេះជាសិល្បៈចម្លាក់មួយបែបដែលប្រជារាស្ត្រខ្មែរនិយមគោរពសក្ការៈ។ ល្ខោនស្បែកប្រភេទនេះសម្តែងបានតែក្នុងរឿងរាមកេរ្តិ៍ ហើយសម្រាប់តែសម្តែងក្នុងពិធីបុណ្យសំខាន់ៗដែលទាក់ទងទៅនឹងសាសនាប៉ុណ្ណោះ។



ល្ខោនស្រមោលស្បែកមធ្យម

គឺប្រភេទចម្លាក់លើស្បែកគោមានទំហំមធ្យម ៣ ទៅ ៤គីឡូក្រាម ជាចម្លាក់នឹងថ្កល់ដូចស្បែកធំដែរ ប៉ុន្តែខុសគ្នាត្រង់ប្រភេទស្បែកមធ្យមជាស្បែកលាបពណ៌ ដូចជាគំនូរផាត់ពណ៌ធម្មតាដែរ តែមិនបង្ហាំពណ៌ (មិនត្រាំជ័រឈើ ឱ្យពណ៌ជ្រាបចូលក្នុងស្បែកដូចស្បែកធំឡើយ)។ រីឯការសម្តែងទៀតសោត គឺសម្តែងតែពេលថ្ងៃ មិនចាំបាច់បញ្ចាំងនឹងពន្លឺភ្លើងឡើយ ។ ទម្រង់នេះមិនរាប់បញ្ចូលក្នុងវង់ល្ខោនស្រមោលក៏បាន។



www.elibraryofcambodia.org



ល្ខោនស្រមោលស្បែកតូច

ជាប្រភេទសិល្បៈមួយបែបទៀតដែលប្រជារាស្ត្រខ្មែរនិយមហៅម្យ៉ាងថា "អាយ៉ង" ជាចម្លាក់លើស្បែកគោដែរ ប៉ុន្តែមានទំហំតូចៗ រូបភាពមានសកម្មភាពចលនាកម្រើករស់រវើកទាំងដៃជើង និងចលនាហាមាត់និយាយបានដែលជាសិល្បៈមានលក្ខណៈប្រជាប្រិយ ហើយប្រជារាស្ត្រខ្មែរនិយមចូលចិត្តស្តាប់ និងទស្សនា ដូចជាប៉ុ អាយ៉ៃ ល្ខោនយីកេ សាដៀវ ទេសនា ...។





www.elibraryofcambodia.org

ង. ការផ្លាស់ប្ដូរឥរិយាបថរបស់កុមារក្រោយពីការនិទានរឿង

- បណ្ដុះសមត្ថភាពគិត បង្កើនចំណេះដឹង ចេះគិតពិចារណានូវចំណុចល្អ អាក្រក់ ចេះប្រៀបធៀបតួអង្គ

- បណ្ដុះរូបារម្មណ៍ បង្កើតការស្រមើស្រមៃ

- បណ្ដុះសមត្ថភាពស្ដាប់ ( ស្ដាប់អ្នកដទៃបានល្អ)

- បណ្ដុះសមត្ថភាពនិយាយ ចេះពាក្យថ្មី ទទួលបាននូវភាពពិត ហើយពាក្យពិរោះៗ ស្គាល់ពីសំឡេងចង្វាក់នៃការនិយាយស្ដី និងសន្ទនាជាមួយអ្នកដទៃ

- លើកកម្ពស់ទម្លាប់ការអាន ចូលចិត្តអានសៀវភៅ

- មានពេលសម្រាកកំសាន្តសប្បាយ

- ចេះដោះស្រាយរាល់បញ្ហាចំពោះមុខ ។

ច. ឥទ្ធិពលរបស់កុមារទៅលើឪពុកម្ដាយ និងសហគមន៍

- បង្កើតទំនាក់ទំនងរវាងកុមារ ឪពុកម្ដាយ និងសហគមន៍ កុមារមានសមត្ថភាពនិទានរឿងដែលពួកគេបានស្ដាប់នៅបណ្ណាល័យ ប្រាប់ទៅឪពុកម្ដាយ ។ កុមារនិយាយរឿងផ្សេងៗ ឱ្យឪពុកម្ដាយស្ដាប់វិញ ហើយឪពុកម្ដាយ សប្បាយរីករាយ គាត់នៅផ្ទះក៏និយាយរឿងផ្សេងទៀតឱ្យកូនស្ដាប់វិញ ដែលបង្កឱ្យមានភាពសប្បាយរីករាយស្និទ្ធស្នាលនៅក្នុងក្រុមគ្រួសារ ។

- ស្វែងយល់ពីការលូតលាស់របស់កុមារ សៀវភៅដែលកុមារពេញចិត្ត នឹងត្រូវផ្លាស់ប្ដូរជាបន្តបន្ទាប់ក្នុងខណៈដែលកុមារមានការអភិវឌ្ឍ ។






www.elibraryofcambodia.org







www.elibraryofcambodia.org

## VI. សិប្បកម្មបត់ក្រដាស

ក. ប្រវត្តិនៃការបត់ក្រដាស

ដើមស.វ ទី៧ ការផលិត និងបច្ចេកវិទ្យាក្រដាស ត្រូវបានគេណែនាំនៅក្នុងប្រទេសជប៉ុន ដែលនាំមកពីប្រទេសចិន ។

នៅស.វ ទី១០ ក្រដាសត្រូវបានផលិតឡើងដើម្បីវេចខ្ចប់របស់របរ ឬសម្រាប់សរសេរសំបុត្រ ។ នៅក្នុងអំឡុងអ៊ីដូ Edo ឆ្នាំ១៦០០-១៨៦៨ ក្រដាសមានតម្លៃទាប ហើយគេផលិតវាបានយ៉ាងច្រើន ដូច្នេះប្រជាជនទូទៅអាចរកទិញបាន។ ប្រជាជនបត់ក្រដាសធ្វើជាសត្វក្រៀល (សត្វស្លាប) ទុក មិនត្រឹមតែដើម្បីសប្បាយប៉ុណ្ណោះទេ ថែមទាំងមានការទាក់ទងនឹងជំងឺ និងអកុសលទាំងឡាយទៀតផង។ ជាពិសេសក្រោយឆ្នាំ១៦៨០ សិប្បកម្មបត់ក្រដាសត្រូវបានគេផ្សព្វផ្សាយដល់មនុស្សទូទៅ។ ឆ្នាំ១៧៩៧ សៀវភៅសិប្បកម្មបត់ក្រដាសដែលចាស់ជាងគេ ឈ្មោះ ហ៊ីដិន សិនបាស៊ុរុ អូរីកាតា (Hiden senbazuru orikata) (របៀបធ្វើសត្វក្រៀល ១០០០ក្បាល) នៅលើពិភពលោកត្រូវបានគេបោះពុម្ពដោយ យ៉ូស៊ីណូយ៉ា តាមិហិអាឈី (Yoshinoya Tameheachi) ដែលបានណែនាំឱ្យស្គាល់ ៤៩ ប្រភេទនៃសិប្បកម្មបត់ក្រដាស។ សៀវភៅនេះមានប្រជាប្រិយភាពណាស់ ដូច្នេះរយៈពេលបីឆ្នាំក្រោយមក សៀវភៅនេះត្រូវបានគេបោះពុម្ពឡើងវិញ។ ចាប់តាំងពីពេលនោះមក អ្នកនិពន្ធជាច្រើនបានបោះពុម្ពសៀវភៅសិប្បកម្មបត់ក្រដាសឡើង។ មិនត្រឹមតែក្មេងៗដែលចូលចិត្តបត់ក្រដាសទេ សូម្បីតែមនុស្សចាស់ក៏ចូលចិត្តដែរ ។

នៅក្នុងអំឡុង មៃជិ **Meiji** សិប្បកម្មបត់ក្រដាសត្រូវបានគេប្រើជាសម្ភារបង្រៀននៅសាលាមត្តេយ្យ និងបឋមសិក្សា (ឆ្នាំ១៨៦៨-១៩១២) ។

បច្ចុប្បន្នវេជ្ជបណ្ឌិតបានទទួលស្គាល់ថា ការបត់ក្រដាសគឺមានសារៈប្រយោជន៍ដើម្បីធ្វើឱ្យខួរក្បាលប្រសើរឡើង បង្កើនការគិត និងប្រឌិតញាណរបស់មនុស្ស កាត់បន្ថយនូវភាពស្មុគ្រស្មាញរបស់មនុស្ស ធ្វើឱ្យមនុស្សមិនឆាប់ចាស់។ ស្ថិតក្រោមស្ថានភាពនេះ សិប្បកម្មបត់ក្រដាសមិនត្រឹមតែយកមកប្រើក្នុងវិស័យអប់រំប៉ុណ្ណោះទេ ថែមទាំងក្នុងវិស័យសុខាភិបាលផងដែរ ។

ខ. របៀបរៀបចំសម្រាប់ការបត់ក្រដាស

យកក្រដាសពណ៌ស្តើងៗដែលមានទំហំ ៧៨សម x ៥២សម ហើយមានពណ៌ផ្សេងៗគ្នា ។ ទំហំក្រដាសស្តង់ដា សម្រាប់បត់ គឺ ១៥សម x ១៥សម ។ យើងអាចធ្វើក្រដាសគំរូដែលមានកម្រាស់ក្រាស់ ។ យើងបត់ក្រដាសធំជា ៤ផ្នត់ ដាក់តលើគ្នា រួចកាត់ក្រដាសធំតាមគំរូ បន្ទាប់មកយកបន្ទាត់សង្កត់ យកកាំបិតឡាមមកឆូតផ្តាច់ជាការស្រេច ។



www.elibraryofcambodia.org

១. របៀបបត់ក្រដាស

- បត់ដាក់ឱ្យជ្រុងក្រដាសទាំងពីរត្រូតស៊ីគ្នា
- បត់ក្រដាសឱ្យមានផ្នត់ល្អ
- ដាក់ក្រដាសបត់លើតុ
- ធ្វើសាកល្បងយ៉ាងតិចឱ្យបានពីរដង ។ លើកទី១ ធ្វើឱ្យចេញជារាងជាក់ច្បាស់សិន ។

លើកទី២ បង្កើតបានជារូបដ៏ល្អមួយ

- អ្នកអាចបត់រូបធ្វើជាសៀវភៅផ្នត់១ យ៉ាងល្អ ។

២. របៀបបង្រៀនកុមារក្នុងការបត់ក្រដាស

- បើបង្រៀនកុមារច្រើនគ្នាត្រូវប្រើក្រដាសធំសម្រាប់បង្ហាញ
- បញ្ជាក់កុមារពីការបត់ក្រដាសឱ្យបានច្បាស់ក្នុងជំហាននីមួយៗ
- រាល់ជំហាននីមួយៗ រង់ចាំរហូតដល់កុមារបត់ហើយគ្រប់គ្នាសិន ទើបចាប់ផ្តើមជំហានបន្ទាប់ទៀត
- បង្រៀនកុមារយឺតៗមួយៗច្បាស់ៗ ចំពោះជំហានដែលអ្នកយល់ថា ពិបាក វាកាន់តែពិបាកចំពោះកុមារ
- បង្ហាញពីរបៀបលេងសម្ភារដែលបានមកពីការបត់ក្រដាស ដូចជា យន្តហោះ ខាឡុង ជាដើម ។

៣. អត្ថប្រយោជន៍នៃការបត់ក្រដាស

ការបត់ក្រដាសធ្វើឱ្យកុមារ :

. ដឹងពីសេចក្តីរីករាយនៃការងារសិល្បៈបួនយ៉ាង កើតចេញពីក្រដាសណាត (ឱ្យកុមារស្គាល់ មាឌ ទំហំ រូបរាង ពណ៌ )

- អភិវឌ្ឍសមត្ថភាពក្នុងការផ្ចិតផ្ចង់អារម្មណ៍ និងសប្បាយរីករាយចំពោះស្នាដៃខ្លួន
- អភិវឌ្ឍការហ្វឹកហាត់ម្រាមដៃទាំងអស់ដោយស្ទាត់ជំនាញ
- អភិវឌ្ឍសមត្ថភាពក្នុងការយល់ដឹងពីទ្រង់ទ្រាយនៃវត្ថុត្រឹមត្រូវ
- មានសេចក្តីរីករាយក្នុងការបង្កើតរូបភាពផ្សេងៗ ជាបន្តឱ្យកុមារដទៃទៀត
- បណ្តុះឆន្ទៈ និងអំណត់អត់ធន់ ព្យាយាម តស៊ូក្នុងការ[illegible]រផ្សេងៗ
- បង្កើតរូបារម្មណ៍ បញ្ញា ស្មារតី គំនិតច្នៃប្រឌិត គំនិតផ្តួចផ្តើម
- អភិវឌ្ឍចំណេះដឹងផ្នែកសិល្បវិជ្ជា
- ទាក់ទាញអារម្មណ៍របស់កុមារឱ្យចូលរួមក្នុងការងារយ៉ាងសកម្ម
- បង្កើនសោភ័ណភាព ។



www.elibraryofcambodia.org

## ១. ផ្កាឈូក

១. បត់ក្រដាសការេជារាងត្រីកោណឱ្យមានស្នាមផ្នត់ពីឆ្វេងទៅស្តាំ ពីស្តាំទៅឆ្វេង រួចលាវិញ



២. បត់ត្រីកោណទាំងបួនដោយដាក់កំពូលត្រង់ចំណុចកណ្តាល



៣. បត់កំពូលត្រីកោណទាំងបួនដាក់ត្រង់ចំណុចកណ្តាលពីរជាន់



៤. ត្រឡប់រូបម្ខាងទៀត បត់កំពូលត្រីកោណដាក់ត្រង់ចំណុចកណ្តាល





www.elibraryofcambodia.org

៥. បត់ជ្រុងទាំងបួនចូលក្នុង



៦. ត្រឡប់រូបម្ខាងទៀត បើកទាញស្រទាប់ផ្កា





www.elibraryofcambodia.org

## ២. សត្វក្ងាន

១. បត់ជ្រុងការ៉េពីរជាប់គ្នាដាក់ចំទ្រនុងកណ្តាល ហើយបត់ត្រីកោណពណ៌សទៅក្រោយ
បន្ទាប់មកបត់មុំខាងឆ្វេងលើក្រោមដាក់លើទ្រនុងកណ្តាល





២. រូបដែលបត់បានមានពណ៌ស បកវាត្រឡប់ទៅក្រោយវិញ យកតែស្នាមផ្នត់





៣. ចាប់ទាញស្នាមផ្នត់តាមព្រួញខាងលើ និងខាងក្រោមដូចគ្នា







www.elibraryofcambodia.org

៤. បត់មុំខាងស្តាំលើក្រោមតាមព្រួញមកឆ្វេង បន្ទាប់មកបត់កន្ទុយឱ្យមានស្នាមផ្នត់រុញចូលក្នុង



៥. បត់រូបជាពីរ បត់ក្បាលចូលក្នុងឱ្យចេញចំពុះ



៦. ទាញកន្ទុយឱ្យបះទៅលើបន្តិច





www.elibraryofcambodia.org

## ៣. ត្រីឆ្នែក

១. បត់ក្រដាសការ៉េជារាងត្រីកោណឱ្យមានផ្នត់ ហើយលាវិញ បត់ជ្រុងការ៉េទាំងពីរជាប់គ្នាដាក់ចំទ្រនុងកណ្ដាល បន្ទាប់មកបត់ជ្រុងខាងស្ដាំទាំងពីរដាក់ចំទ្រនុងកណ្ដាល តាមព្រួញឱ្យមានស្នាមផ្នត់ ហើយលាវិញ





២. ឆ្កូតឱ្យមានស្នាមផ្នត់ចាប់ទាញមុំស្រួចខាងក្នុងតាមព្រួញមកឆ្វេង បន្ទាប់មកត្រឡប់រូប បត់មុំស្រួចមកស្ដាំជិតដល់ពាក់កណ្ដាល





៣. បត់រូបជាពីរតាមព្រួញ បត់ព្រុយមកក្រោយពាក់កណ្ដាល បន្ទាប់មកបត់កន្ទុយចូលក្នុងបញ្ឈិតទៅលើ







www.elibraryofcambodia.org

នេះជារូបបញ្ចប់



## ៤. ឆាកាឆ៊ា

១. បត់ក្រដាសការ៉េជារាងត្រីកោណឱ្យមានផ្នត់ ហើយលាវិញ បត់ជ្រុងការ៉េទាំងពីរជាប់គ្នាដាក់ចំទ្រនុងកណ្តាល បន្ទាប់មកបត់ជ្រុងខាងឆ្វេងទាំងពីរដាក់ចំទ្រនុងកណ្តាលតាមព្រួញ







២. បើកមុំខាងឆ្វេងទាំងពីរទៅលើ ទៅក្រោម បន្ទាប់មកទាញមុំក្នុងទាំងពីរលើក្រោមមកខាងស្តាំតាមព្រួញ







www.elibraryofcambodia.org

៣. បានរូបទី៥ យើងត្រឡប់រូប បត់រូបជាពីរឡើងលើត្រួតស៊ីគ្នាតាមរូប



៤.បត់១ភាគ៣នៃស្លាបខាងមុខចូលក្នុងឡើងទៅលើ  បត់កន្ទុយខាងស្តាំចូលក្នុងទៅលើ បន្ទាប់មកបត់ក្បាលចូលក្នុងចុះក្រោម



នេះជារូបបញ្ចប់





www.elibraryofcambodia.org

## ៥. សត្វក្រៀល

១. បត់ក្រដាសការេឱ្យមានស្នាម៨ផ្នត់មានចំណុចកណ្ដាលរួម  ចាប់ទ្រនុងកណ្ដាលពីរផ្គុំចូលគ្នា ជ្រុងផ្សេងៗចូលតាមផ្នត់



២. យករូបដែលបត់បានខាងលើ  មកប្រើបត់ជ្រុងឆ្វេង និងជ្រុងស្តាំឱ្យចំទ្រនុងកណ្ដាល បត់មុំលើចុះក្រោមតាមព្រួញ



៣. លារូបឱ្យមានស្នាមផ្នត់  បន្ទាប់មកទាញមុំស្រួចទៅលើរុញផ្នត់ឱ្យចូលមកខាងក្នុង





www.elibraryofcambodia.org

៤. បត់ជ្រុងម្ខាងទៀតឆ្វេង ស្តាំ ឱ្យចំទ្រនុងកណ្តាល ឱ្យមានស្នាមផ្នត់ លាវិញ ត្រឡប់រូប ទាញមុំស្រួចទៅលើធ្វើដូចមុន



៥. បត់ជ្រុងខាងក្រោមឆ្វេងស្តាំដាក់ចំទ្រនុងកណ្តាលតាមព្រួញ  ត្រឡប់រូប  ម្ខាងទៀតធ្វើដូចគ្នាតាមព្រួញ





www.elibraryofcambodia.org

៦. បត់រូបខាងឆ្វេងចូលក្នុងទៅលើតាមព្រួញ រូបទី១០ជារបៀបកាន់





៧. បត់ម្ខាងទៀតទៅលើធ្វើដូចមុន បន្ទាប់មកបត់ក្បាលចូលក្នុងចុះក្រោមឱ្យចេញចំពុះតាមរូប







www.elibraryofcambodia.org

៨. ទាញស្លាបចេញក្រៅទាំងសងខាង  ផ្លុំខ្យល់បញ្ចូលតាមប្រហោងខាងក្រោម



## ៦. នាវាសំពៅ

១. បត់ក្រដាសការ៉េជារាងត្រីកោណឱ្យមានផ្នត់ ហើយលាវិញ បត់ជ្រុងការ៉េទាំងពីរជាប់គ្នាដាក់ចំទ្រនុងកណ្ដាល បន្ទាប់មកបត់ជ្រុងខាងស្ដាំទាំងពីរដាក់ចំទ្រនុងកណ្ដាលតាមព្រួញ  រួចហើយត្រឡប់រូប ។





www.elibraryofcambodia.org

២. បត់រូបជាពីរត្រួតស៊ីគ្នាតាមព្រួញ



៣. បត់រូបពាភាគ៤ ចូលក្នុងទៅលើតាមព្រួញ



៤. បត់ក្បាលចូលក្នុងចុះក្រោមធ្វើចំពុះ បន្ទាប់មកបត់កន្ទុយចូលក្នុងទៅលើ រួចទាញស្លាបហែលទឹក





នេះជារូបបញ្ចប់





www.elibraryofcambodia.org

## ៧. ប្រអប់

១. បត់ក្រដាសការ៉េឱ្យបានជាការ៉េតូចៗ ៤  ត្រឡប់ខាងពណ៌ចេញក្រៅ  បត់មុំទាំង៤ដាក់ចំណុចកណ្ដាល





២. បត់ជ្រុងការ៉េឆ្វេងស្ដាំមកកណ្ដាលបានជាចតុកោណកែង មានស្នាមផ្ចត់លាវិញ
បន្ទាប់មកបើកមុំឆ្វេងស្ដាំចេញក្រៅតាមព្រួញ





៣. បត់ខាងលើចុះក្រោមពាក់កណ្ដាល និងខាងក្រោមទៅលើពាក់កណ្ដាលតាមព្រួញ





www.elibraryofcambodia.org

៤. មានស្នាមផ្នត់ទាញមុំទាំងពីរតាមព្រួញលើកផ្នត់បញ្ឈរ




៥. ទាញមុំទាំងពីរបញ្ឈរ បន្ទាប់មកបត់តាមផ្នត់ចុះក្រោម ធ្វើដូចគ្នាទាំងសងខាង







នេះជារូបបញ្ចប់ ធ្វើដូចគ្នាឱ្យបានពីរដាក់ត្របគ្នា





www.elibraryofcambodia.org

## ៨. ផ្កាឃិតថៅ

១. បត់ក្រដាសការ៉េឱ្យមានស្នាម៨ផ្នត់មានចំណុចកណ្តាលរួម
ចាប់ទ្រនុងកណ្តាលពីរផ្គុំចូលគ្នា ជ្រុងផ្សេង១ចូលតាមផ្នត់



២. ទាញបត់ជ្រុងដែលបើកមិនបានដាក់ចំផ្នត់កណ្តាល ឆ្កូតផ្នត់ហើយលាវិញ ឱ្យបានគ្រប់ជ្រុង
លើកជ្រុងបញ្ឈរដាក់ចង្អុលដៃ ចូលក្នុងហោប៉ៅសង្កត់ឱ្យចុះតាមផ្នត់ ធ្វើដូចគ្នាឱ្យបានគ្រប់ជ្រុង



៣. បើកឱ្យឃើញពណ៌ បត់មុំឆ្វេងស្តាំមកទ្រនុងកណ្តាល លាវិញ តាមព្រួញ ចាប់ទាញមុំលើដាក់ត្រួតមុំក្រោម
រុញចូលតាមផ្នត់ បានរូបទី៦ ធ្វើដូចគ្នាឱ្យបានគ្រប់ជ្រុង យើងបានរូបទី៧





www.elibraryofcambodia.org

៤. រូបទី៧បត់មុំស្រួចទៅលើវិញទាំង៤ បត់ជ្រុងខាងក្រោមឆ្វេងស្ដាំដាក់ចំផ្នត់កណ្ដាលគ្រប់ជ្រុងតាមព្រួញ



៥. បត់ជ្រុងក្រោមមកផ្នត់កណ្ដាលរួចហើយ បត់មុំស្រួចខាងលើគ្រប់ជ្រុងតាមព្រួញចុះក្រោម



៦. ទាញស្រទាប់ផ្កាចុះក្រោម  បើចង់បានស្រទាប់ផ្កាកោងយកខ្មៅដៃមូរពីខាងចុងមុន





www.elibraryofcambodia.org

## ៩. ទូក

១. បត់ក្រដាសការ៉េជារាងត្រីកោណឱ្យមានស្នាមផ្នត់ពីឆ្វេងទៅស្តាំ ពីស្តាំទៅឆ្វេង រួចលាវិញ



២. បត់ត្រីកោណទាំងបួនដោយដាក់កំពូលត្រង់ចំណុចកណ្តាល



៣. បត់មុំឆ្វេងស្តាំចូលទៅក្នុងឱ្យកំពូលដល់ផ្នត់សងខាង  បន្ទាប់មកត្រឡប់រូប





www.elibraryofcambodia.org

៤. បត់ជ្រុងលើចុះក្រោម ជ្រុងក្រោមទៅលើតាមព្រួញ
បានជាចតុកោណកែង បន្ទាប់មកបត់មុំទាំង៤ចូលតាមព្រួញ





៥. បត់មុំខាងស្តាំលើក្រោមតាមព្រួញ បន្ទាប់មកបត់មុំខាងឆ្វេងលើក្រោមតាមព្រួញ





៦. បត់មុំលើចុះក្រោម បត់មុំក្រោមទៅលើ ឱ្យដល់ផ្នត់កណ្តាល រួចហើយទាញត្រឡប់ចេញក្រៅតាមព្រួញ







www.elibraryofcambodia.org

៧. ទាញត្រឡប់បានហើយ ទាញដំបូលឆ្វេងស្តាំទៅលើ







នេះជារូបបញ្ចប់





www.elibraryofcambodia.org

## ១០. សត្វទន្សាយ

១. បត់ក្រដាសការ៉េជាពីរទៅជារាងចតុកោណកែង

បត់ចតុកោណកែងជាពីរមកការ៉េវិញ ទាញមុំមកស្តាំតាមរូប



២. លូកហោប៉ៅសង្កត់តាមផ្នត់ទាញមកស្តាំ ត្រឡប់ម្ខាងទៀត លូកហោប៉ៅ

សង្កត់តាមផ្នត់ទាញមុំឆ្វេងតាមព្រួញ



៣. បានរូបត្រីកោណពីរជាន់ បន្ទាប់មកចាប់ផ្តើមបត់មុំឆ្វេង និងមុំស្តាំដាក់ដល់កំពូលតាមព្រួញ



៤. បត់មុំតូចកណ្តាលខាងឆ្វេង ស្តាំ មកចំផ្នត់កណ្តាល ហើយបត់មុំតូចពីរខាងលើ ចុះក្រោមតាមព្រួញ





www.elibraryofcambodia.org

៥. បត់មុំតូចពីរខាងលើបញ្ចូលក្នុងមុំកណ្ដាលតាមព្រួញ រួចហើយត្រឡប់រូប





៦.បត់មុំឆ្វេងស្ដាំមកចំផ្ចិតកណ្ដាលតាមព្រួញ បន្ទាប់មកបត់មុំក្រោមទាំងពីរចេញទៅឆ្វេង ទៅស្ដាំ តាមព្រួញ





៧. បត់មុំក្រោមឆ្វេងស្ដាំទៅលើឱ្យជ្រុង១ស្របបន្ទាត់ផ្ចិតកណ្ដាល ហើយផ្លុំខ្យល់បញ្ចូល





នេះជារូបបញ្ចប់





www.elibraryofcambodia.org

## ១១. ត្រី

១. បត់ដូចទន្សាយដែរមកដល់ចំណុចទី៧ បត់មុំខាងលើតាមព្រួញ ហើយទាញមុំក្រោមទៅលើតាមព្រួញ



២. ផ្លុំខ្យល់បញ្ចូលឱ្យប៉ោង បានជាត្រី



## ១២. កន្ទែប

១. បត់ក្រដាសការ៉េជាពីរ បានជាចតុកោណកែង បន្ទាប់មកបត់ត្រីកោណកែងខាងស្តាំចុះក្រោមតាមព្រួញ





www.elibraryofcambodia.org

២. ត្រឡប់រូប ហើយបត់ត្រីកោណកែងខាងស្តាំចុះក្រោមតាមព្រួញ



៣. បានត្រីកោណដែលមានហោប៉ៅធំ លូកហោប៉ៅបើកតាមព្រួញសង្កត់ចុះតាមផ្នត់



៤. បត់ជ្រុងខាងស្តាំមកផ្នត់កណ្តាលឱ្យមានស្នាមផ្នត់រួចលាវិញ លើកជ្រុងនោះបញ្ឈរលូកហោប៉ៅសង្កត់ចុះតាមផ្នត់





www.elibraryofcambodia.org

៥. ធ្វើដូចខាងលើឱ្យអស់គ្រប់ជ្រុង  បន្ទាប់មកបត់មុំឆ្វេង ស្តាំខាងក្រោមមកដល់ផ្នត់កណ្តាល





៦. លាស្នាមផ្នត់ដែលបត់បាន  ហើយបើកហោប៉ៅកណ្តាលរុញស្នាមផ្នត់ចូលក្នុងតាមព្រួញ





៧. ធ្វើដូចខាងលើឱ្យអស់គ្រប់ជ្រុង  បន្ទាប់មកបត់ជ្រុងខាងក្រោមឆ្វេងស្តាំចូលក្នុងដល់ផ្នត់កណ្តាល







www.elibraryofcambodia.org

៨. បត់ដូចគ្នាគ្រប់ជ្រុង បត់ជ្រុងក្រោមទាំងពីរឆ្វេងស្តាំចូលក្នុងទៅលើ បត់ដៃទាំងពីរចូលក្នុងចុះក្រោមតាមព្រួញ បត់ជើងទាំងពីរចូលក្នុងទៅឆ្វេងទៅស្តាំតាមព្រួញ



៩. បត់ដៃទាំងពីរចូលក្នុងទៅលើ បត់ជើងទាំងពីរចូលក្នុងចុះក្រោម ហើយបត់ជើងក្រោមទាំងពីរចូលក្នុងទៅលើ គ្រឡប់រូបផ្លុំ



## ១៣. ផ្កាគោម

១. បត់ក្រដាសការ៉េដូចបត់រូបកង្កែបដែរ ធ្វើដូចគ្នាពីជំហាន១ ដល់ជំហាន៤ បានរូបដូចខាងក្រោម បន្ទាប់មកបត់ឱ្យឃើញខាងពណ៌ រួចហើយបត់ត្រីកោណខាងលើទាំងពីរឱ្យចំផ្ចិតកណ្តាល





www.elibraryofcambodia.org

២. បត់ត្រីកោណពណ៌សងខាងលើចុះក្រោមតាមព្រួញគ្រប់ជ្រុង





៣. ពេលបត់បានគ្រប់ជ្រុងហើយ លាតាមផ្នត់ទាំងអស់ រួចត្រឡប់ក្រដាស





៤. ដាក់វាឱ្យផត់កណ្តាល ចាប់ផ្នត់ខ្ញីសងខាង ផ្នត់វែងបត់ទៅក្រោយ បន្ទាប់មកបត់ផ្នត់ខាងលើ ដាក់ចំផ្នត់កណ្តាល សូមធ្វើតាមសញ្ញាព្រួញ







www.elibraryofcambodia.org

៥. បត់ត្រីកោណខាងលើចុះក្រោមត្រឹមផ្នត់តាមព្រួញ រួចរុញផ្នត់ខ្លីសងខាងផ្នត់វែងទៅក្រោយធ្វើដូចមុន





៦. បត់ដូចគ្នាឱ្យអស់គ្រប់ជ្រុង





៧. ធ្វើបានជាផ្កាមួយនេះ អាចយកទៅដាក់ទងស្លឹកចងបូ តុបតែងលំអ









www.elibraryofcambodia.org

៨. បើចង់ធ្វើផ្កាគោមត្រូវបត់ផ្កានេះឱ្យបានចំនួន ៤០ ភ្ជាប់១ជុំ១០ផ្កា  ទាំងអស់៤ជុំ
បិទភ្ជាប់គ្នាដោយប្រើកាវ ម្តងមួយចំហៀងពីរជុំ យកដៃផ្តោបឱ្យមូលកន្លះរង្វង់









www.elibraryofcambodia.org







www.elibraryofcambodia.org

## VII. ការប្រើប្រាស់ឧបករណ៍បោះពុម្ពដោយដៃ

### ក. ប្រវត្តិឧបករណ៍បោះពុម្ពដោយដៃ

ឧបករណ៍បោះពុម្ពដោយដៃ បានបង្កើតឡើងក្នុងអំឡុងឆ្នាំ ១៨៩៤ ដោយលោក ស៊ិនជីរូ ហូរីអ៊ី (Mr. Shinjiro Horii) និងកូនប្រុសរបស់គាត់បានឃើញគំរូម៉ាស៊ីនរ៉ូណេអូ (ម៉ាស៊ីនបោះពុម្ព) របស់លោក ថូម៉ាស អាលវ៉ា អេឌីសាន់ (Mr. Thomas Alva Edison) ក៏បានកើតមានគំនិតបច្ចេកទេសថ្មីប្រឌិតបង្កើត ជាឧបករណ៍បោះពុម្ពដោយដៃដែលភាសាជប៉ុនហៅថា "តូសាបាន" នេះឡើងសម្រាប់ប្រើប្រាស់ដោយមិនចាំបាច់ប្រើគ្រឿងម៉ាស៊ីនឡើយ ។ ក្រោយពីបានបង្កើតឧបករណ៍បោះពុម្ពរួចមក ក៏ចាប់ផ្តើមប្រើអស់រយៈពេលជាងមួយឆ្នាំហើយនៅក្នុងប្រវត្តិសាស្ត្រប្រទេសជប៉ុន នាសម័យមេជី (Meiji Era) អ្នកប្រើប្រាស់ឧករណ៍នេះភាគច្រើនគឺជាមន្ត្រីរដ្ឋាភិបាល និងមន្ត្រីយោធា ។

លោក ស៊ិនជីរូ ហូរីអ៊ី (Mr. Shinjiro Horii) បានបើកជាក្រុមហ៊ុនរបស់លោកដោយដាក់ឈ្មោះថា ហូរីអ៊ីតូសាដូ (Horii Toshado) និងបានធ្វើការផ្សព្វផ្សាយរកទីផ្សារលក់ដូចខាងក្រោម:

- តម្លៃឧបករណ៍ថោក (ស្មើនឹងប្រាក់ខែកម្មករមួយខែ)
- ស្តង់ស៊ីល/ក្រដាសសម្រាប់គូរ សរសេរ ធ្វើពុម្ព និងទឹកខ្មៅមានលក់គ្រប់ទីកន្លែង
- ងាយស្រួលប្រើ (ផលិតបានរូប ឬអក្សរដោយអូសចេញពីពុម្ពបានចំនួន ១000សន្លឹក ហើយសម្រាប់ស្ត្រី និងកុមារក៏អាចប្រើបានដែរ)
- ប្រើបានយូរ និងបោះពុម្ពបានច្បាស់ល្អ (អាស្រ័យលើអ្នកប្រើ)
- ងាយស្រួលយកតាមខ្លួន (បោះពុម្ពកន្លែងណា ពេលណាក៏បាន)
- មិនចាំបាច់ប្រើចរន្តអគ្គិសនី ។

ឧបករណ៍បោះពុម្ពដោយដៃនេះ បានល្បីល្បាញ ហើយគេចូលចិត្តប្រើប្រាស់ចាប់ពីឆ្នាំ១៩២០ ដល់ ១៩៧០ គឺក្នុងសម័យស្វាៃនៃប្រវត្តិសាស្ត្រប្រទេសជប៉ុន ។ អ្នកដែលប្រើប្រាស់សំខាន់ៗជាច្រើន មិនត្រឹមតែមន្ត្រីរដ្ឋាភិបាល លោកគ្រូ អ្នកគ្រូ ស្មៀនការិយាល័យ អ្នកកាសែត និងអ្នកសិល្បៈប៉ុណ្ណោះទេ គឺថែមទាំងប្រជាជនទូទៅផងដែរ ។

បន្ទាប់ពីល្បីហើយ ក៏មានគេបង្កើតរោងពុម្ពជាច្រើន ដោយយកឧបករណ៍បោះពុម្ពនេះមកប្រើសម្រាប់ធ្វើជាមុខរបរជំនួញ ។ កន្លែងដែលមានសកម្មភាពប្រើប្រាស់ឧបករណ៍នេះខ្លាំងក្លាជាងគេគឺ នៅតាមសាលារៀនដែលលោកគ្រូ អ្នកគ្រូ បានបោះពុម្ពឯកសារជាច្រើនប្រភេទដូចជាវិញ្ញាសាប្រឡង សៀវភៅទំនាក់ទំនងអាណាព្យាបាលសិស្ស ក្រដាសពិន្ទុ លិខិតបញ្ជាក់ការសិក្សា រូបសម្រាប់សម្តែងល្ខោនតុក្កតា និងសម្ភារឧបទេសផ្សេងៗទៀត ...។

ក្នុងសម័យនោះមិនទាន់មានឧបករណ៍បោះពុម្ពសម្ភារសម្បូរបែបសម្រាប់ប្រើប្រាស់តាមសាលាបឋមសិក្សា និងសាលាមធ្យមសិក្សានៅឡើយទេ ។ នៅតាមសាលាដែលមានលោកគ្រូ អ្នកគ្រូបានធ្វើការងារនេះ ដោយខ្លួនឯងដូចមានពាក្យគេនិយាយថា "គ្រូល្អ គឺអ្នកប្រើប្រាស់ឧបករណ៍បោះពុម្ពដោយដៃបានល្អ" ហើយគេពិនិត្យមើលនៅតាមសាលារៀនហាក់ដូចកន្លែងមួយដែលដើរតួជារោងពុម្ពសម្រាប់បម្រើសេចក្តីត្រូវការរបស់សហគមន៍នីមួយៗ ។



www.elibraryofcambodia.org

ចំពោះការច្នៃប្រឌិតគំរូផ្សេងៗទៀត លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សបាននាំគ្នាធ្វើការបោះពុម្ពជាសារព័ត៌មាននៅតាមសាលារៀន និងសៀវភៅតែងសេចក្ដីសម្រាប់សិស្សានុសិស្ស ...។

ឧបករណ៍បោះពុម្ពផ្ដល់ប្រយោជន៍ និងបង្កភាពងាយស្រួលដល់បណ្ដាប្រទេសក្រីក្រ។ ប្រទេសមួយចំនួនបានមកសិក្សាផ្នែកបោះពុម្ពនេះ ដើម្បីយកទៅប្រើប្រាស់ក្នុងប្រទេសរបស់គេ។ ដោយឡែកនៅប្រទេសកម្ពុជាក៏កំពុងតែមានការខ្វះខាតសម្ភារក្នុងការផលិតឯកសារផ្សេងៗ និងសៀវភៅជាដើម។ ជាពិសេសក្រោយពីសង្គ្រាមបានបញ្ចប់មក ប្រទេសកម្ពុជាមានការខ្វះខាតឯកសារប្រើប្រាស់សម្រាប់បង្រៀន និងរៀន ។ កន្លែងដែលខ្វះខាតខ្លាំងជាងគេ គឺនៅតាមតំបន់ក្រីក្រ ទីជនបទដាច់ស្រយាល ដែលកំពុងជួបការលំបាកក្នុងការចម្លងឯកសារប្រើប្រាស់តាមសាលារៀន និងវត្តអារាមជាដើម។

ខ. ឧបករណ៍បោះពុម្ពដោយដៃជាអ្វី?

ជាឧបករណ៍សម្រាប់បោះពុម្ព ឬផ្ដិតចម្លងរូបភាព និងឯកសារផ្សេងៗ ដោយមិនចាំបាច់ប្រើគ្រឿងម៉ាស៊ីន គឺធ្វើការផលិតដោយដៃមនុស្សផ្ទាល់ ។

**គ. ផលប្រយោជន៍ឧបករណ៍បោះពុម្ពដោយដៃ**

- ជួយបម្រើការបោះពុម្ពជាក្បូនខ្នាត គម្រោ ឯកសារ និងធ្វើជាសៀវភៅរឿង សៀវភៅមេរៀន ព្រមទាំងឯកសារផ្សេងៗជាច្រើនប្រភេទ
- កាត់បន្ថយការចំណាយថវិកាមួយកម្រិតធំ
- មិនស្មុគស្មាញ ងាយស្រួលក្នុងការប្រើប្រាស់
- ឧស្សាហ៍ប្រើប្រាស់បោះពុម្ពធ្វើឱ្យកើនគំនិត
- ទម្ងន់ស្រាលងាយចល័តបានគ្រប់ទីកន្លែង
- បោះពុម្ពលើកំណាត់ ជារូបភាព ជាអក្សរ
- បោះពុម្ពផ្ទាំងរូបភាពសម្រាប់ផ្សព្វផ្សាយ
- ជួយសម្រួលការលំបាកនៅតាមតំបន់ដាច់ស្រយាល
- ចំណេញពេលវេលា ។



www.elibraryofcambodia.org

ឃ. ការបង្ហាញពីរបៀបប្រើឧបករណ៍បោះពុម្ពដោយដៃ

- រូបរាងឧបករណ៍បោះពុម្ព








www.elibraryofcambodia.org

- សម្ភាររួមផ្សំសម្រាប់បោះពុម្ព



ដបទឹកខ្មៅ



ដែកចារសម្រាប់សរសេរ ឬគូរ



www.elibraryofcambodia.org




ក្រដាសសម្រាប់គូរ ឬសរសេរ (ស្តង់ស៊ីល)



ក្តារសម្រាប់ទ្រាប់គូរ ឬសរសេរអក្សរ



www.elibraryofcambodia.org



ក្រដាសខាត់គ្រើមម៉ដ្ឋ



ក្រដាសភាម (A4)



www.elibraryofcambodia.org




- របៀបអនុវត្តបោះពុម្ពរូបភាព ឬ អក្សរ

ដំបូងយកក្រដាសខាត់ផ្ទារខាងគ្រើមទៅលើ រួចបិទកាវឱ្យជាប់នឹងក្ដារដើម្បីទ្រាប់គូរ ឬសរសេរ រួចយកក្រដាសពុម្ព (ស្តង់ស៊ីល) មកដាក់ពីលើដោយកាន់ឱ្យជាប់ កុំឱ្យក្រដាសពុម្ពរំកិល នៅពេលចាប់ផ្ដើមគូរ ឬសរសេរ។ ក្រោយពីគូរ ឬសរសេររួច យកក្រដាសរូប ឬអក្សរនោះមកដាក់បញ្ចូលទំពក់នៃស្បៃពុម្ព ដោយផ្កាប់រូប ឬ អក្សរទៅក្រោម ហើយហែកក្រដាសស និងក្រដាសខ្មៅដែលជាប់នឹងក្រដាសពុម្ពចេញ តាមចំណុចផ្ទេរដាច់ៗ ។ ក្រដាសខ្មៅបោះចូលក្នុងធុងសំរាម រីឯក្រដាសស ទុកសម្រាប់ពេលបោះពុម្ពរួច យកមកគ្របលើក្រដាសពុម្ពទុកប្រើប្រាស់ថ្ងៃក្រោយ ។ ត្រូវគ្របឱ្យជិតដើម្បីការពារធូលីជាប់ប្រឡាក់ សម្រាប់បោះពុម្ពនៅពេលក្រោយបានទៀត ។

បន្ទាប់ពីដាក់ក្រដាសពុម្ព លើស្បៃពុម្ពរួចរាល់ហើយ យកក្រដាសរាមមកដាក់ទ្រាប់ពីក្រោមស្បៃពុម្ព ឱ្យមានកម្រាស់ចាប់ពីកន្លះសង់ទីម៉ែត្រទៅមួយសង់ទីម៉ែត្រ ។ នៅពេលអូសពុម្ព កុំឱ្យក្រដាសនៅសល់ក្រោមកន្លះសង់ទីម៉ែត្រ ពីព្រោះនាំឱ្យឆាប់យារ និង ឆាប់រហែកស្បៃពុម្ព ។ ពេលរៀបចំរួចរាល់ហើយ ត្រូវគ្របស្បៃពុម្ពលើក្រដាសដែលរៀបចំអូសរូប ឬអក្សរ ហើយយកទឹកថ្នាំច្របាច់ដាក់ក្នុងថាស ឬប្រអប់ ឈើសម្រាប់លាយពណ៌ រួចយករូឡូមករមៀលចុះឡើងៗ ពីឆ្វេងទៅស្ដាំ រហូតដល់ទឹកថ្នាំជោគស្មើពេញនឹងកង់រូឡូ ទើបយកមកអូស ឬរមៀលចុះឡើងរហូតឃើញថា សព្វលើផ្ទៃស្បៃពុម្ពហើយ ចាប់បើកបង្ហើបយករូប ឬអក្សរ។ ពេលយកចេញមកលើកដំបូង និងបន្តបន្ទាប់កុំប្រញាប់ដាក់ពីលើគ្នា ទុកឱ្យស្ងួតបន្តិច ទើបដាក់លើគ្នាបាន ។ មើលការបង្ហាញ ដូចខាងក្រោម៖



www.elibraryofcambodia.org

សកម្មភាពទី១ ការបំពាក់ក្រដាសពុម្ពលើស្បៀពុម្ព (រូបភាពទី១)

យកក្រដាសពុម្ពមកដាក់បញ្ចូលក្នុងទំពក់នៃស្បៀពុម្ព ដោយមានរន្ធធំ១បួន ត្រូវសង្កត់បញ្ចូលរន្ធកណ្តាលទាំងពីរមុនទើបបន្តរន្ធផ្សេង១តាមក្រោយ ។




សកម្មភាពទី២ (រូបភាពទី២)

ពេលបញ្ចូលក្រដាសពុម្ពលើស្បៀពុម្ពរួច ហែកក្រដាសស និងក្រដាសខ្មៅចេញ។ ក្រដាសស ទុកសម្រាប់គ្របលើក្រដាសពុម្ព (ទុកប្រើពុម្ពពេលក្រោយ) លុះហែកក្រដាសទាំងពីររួចហើយយកស្កុតមកបិទចុងក្រដាសពុម្ពឱ្យជាប់នឹងតួពុម្ព ប៉ុន្តែធ្វើយ៉ាងណាកុំឱ្យក្រដាសពុម្ពជ្រួញ ទើបអូសរូបបានល្អ។






www.elibraryofcambodia.org

សកម្មភាពទី៣ (រូបភាពទី៣)

គ្រប ឬបិទពុម្ពជាពីរលើក្រដាសភាម ដើម្បីធ្វើការបោះពុម្ព ឬអូសពុម្ព ។





សកម្មភាពទី៤ (រូបភាពទី៤)

យកទឹកថ្នាំច្របាច់ដាក់ក្នុងចាន ឬប្រអប់ឈើសម្រាប់លាយពណ៌ បន្ទាប់មកយករូឡូរុញចុះឡើង ពីឆ្វេងទៅស្តាំ ឱ្យសព្វស្មើនឹងកង់រូឡូ រួចយកមករុញ ឬអូសចុះឡើងៗ ឱ្យទឹកថ្នាំជិតសព្វលើស្បៃពុម្ព ទើបបើកបង្ហើបយករូប ឬអក្សរចេញក្រៅ ហើយអូសពុម្ពជាបន្តទៀត ។







www.elibraryofcambodia.org

- ការផលិតសៀវភៅរូបភាព

គឺជាការចងក្រងសៀវភៅរឿងដោយមានរូបភាព ដែលបានមកពីការប្រើឧបករណ៍បោះពុម្ពដោយដៃ (TOSABAN) ។ បន្ទាប់ពីបោះពុម្ពបាន ជួនកាលគេយករូបភាពផាត់ពណ៌ ឬក៏បង្វើជាសៀវភៅរូបភាពសាច់រឿង សខ្មៅក៏បានទៅតាមការធ្វើរបស់អ្នកនិពន្ធរឿង ។

* របៀបផលិតសៀវភៅរូបភាព ឬសៀវភៅផ្សេងៗចែកជាពីរផ្នែកគឺ:

១. ការបោះពុម្ព មួយសន្លឹកមួយទំព័រ ឬ មួយសន្លឹកពីរទំព័រ (សងខាង)

- យកសាច់រឿងដែលបានសរសេរមកពិនិត្យ ថាតើត្រូវគូររូបភាពប៉ុន្មានប្លង់ហើយនៅទំព័រណាខ្លះ?

- យកក្រដាសពុម្ព (ស្តង់ស៊ីល) មកសរសេរ និងគូរឱ្យគ្រប់តាមសាច់រឿងហើយទើបចុះលេខទំព័រ ។

- យកក្រដាសពុម្ព ដែលគូរ និងសរសេរហើយទៅបោះពុម្ព

- បោះពុម្ពបានរូប និងអក្សរ ហើយបើមុននឹងកិបជាសៀវភៅផាត់ពណ៌រូបភាព ឬក៏បហើយចាំផាត់ពណ៌ ឬធ្វើសៀវភៅរូបភាពស ខ្មៅ មិនដាក់ពណ៌រូបក៏បាន ។

២. ការបោះពុម្ព មួយសន្លឹកបួនទំព័រ

- យកសាច់រឿង ដែលសរសេរបានមកគិតឱ្យបានល្អិតល្អន់កុំឱ្យច្រឡំ ក្នុងពេលសរសេរ ឬគូររូបលើក្រដាសពុម្ពនាំឱ្យខាតក្រដាសពុម្ព និងខាតពេល គឺត្រូវគិតលើក្រដាសព្រាង រួចចាប់ផ្តើមគូរ និងសរសេរលើស្តង់ស៊ីល ហើយចុះលេខទំព័រ ។

- តើរូបភាព ឬអក្សរនៅលើសន្លឹកក្រដាសទីប៉ុន្មាន និងជាទំព័រទីប៉ុន្មាន ពីព្រោះ ក្រដាស A4 ១សន្លឹក ពេលបត់ជាពីរ បាន ៤ទំព័រ តែទំព័រទី៤នេះ នៃសន្លឹកដំបូង គឺជាទំព័រលេខបញ្ចប់នៃសៀវភៅ ។

៣. ការផលិតផ្ទាំងរូបភាព

មានច្រើនប្រភេទ ទៅតាមការប្រើប្រាស់ ឬ ការផ្សព្វផ្សាយសកម្មភាពផ្សេងៗ

- ការផលិតផ្ទាំងរូបភាពជារូបភាពសុទ្ធ

- ការផលិតផ្ទាំងរូបភាពមានអក្សរតិច រូបច្រើន

- ការផលិតសម្ភារសម្រាប់បច្ចេកទេសបង្រៀន និងរៀន

- ការផលិតផ្ទាំងរូបភាពជាលក្ខណៈផ្សព្វផ្សាយ ។



www.elibraryofcambodia.org

## VIII. ការផលិតសម្ភារៈ

ក. ល្បែងទាយឈ្មោះសត្វ

១. សម្ភារត្រូវការ

- កន្ត្រៃ
- ក្រដាសសំឡី
- ម្ជុលដេរ និងអំបោះ
- កាំបិតតូច
- កំណាត់សំពត់សំឡី
- បន្ទះក្តារ ឬបន្ទះក្រដាសរឹងក្រាស់ ទំហំ 0.7 ម x 0.8ម
- កាវ
- ខ្មៅដៃ ពណ៌ទឹក និង ជក់

២. របៀបផលិត



យកក្រដាសសំឡីគូររូបសត្វតាមទំហំដែលចង់បាន ភាគច្រើនត្រឹមតែ០.១២ម x០.១២ម



យករូបសត្វដែលបានគូររួចផាត់ពណ៌ទុកឱ្យស្ងួត រួចមកផ្ចាប់ពីលើកំណាត់សំពត់ ១ផ្ទាំងផ្សេងទៀត



www.elibraryofcambodia.org



យកកន្ត្រៃកាត់តាមរឹមរូបសត្វដែលផាត់រួច ហើយគូរស្លឹកត្រចៀកសត្វលើក្រដាសសំឡីបន្ទះផ្សេង ហើយផាត់ពណ៌ បន្ទាប់មកកាត់គំនូរស្លឹកត្រចៀក



យកផ្ទាំងគំនូរសត្វដែលផាត់ពណ៌រួចលាបកាវនៅកណ្ដាលខាងខ្នង រួចក្រដាសដែលបានកាត់តាមរឹម មកបិទភ្ជាប់រូបសត្វ បន្ទាប់មកកាត់ចម្រៀកក្រដាសតូចៗពីរមកបិទជាប់នឹងរូបខាងក្រោយ បន្ទាប់មកទៀត យកស្លឹកត្រចៀកមកសិកហើយដេរភ្ជាប់នឹងចម្រៀកដែលបិទក្រដាសរូបសត្វខាងក្រោយ និងយកបន្ទះក្ដារ ឬបន្ទះក្រដាសរឹងលាបកាវ ឬកិបភ្ជាប់ផ្ទាំងកំណាត់សំពត់សំឡី ។



www.elibraryofcambodia.org

៣. របៀបប្រើ



យកក្ដារ ឬបន្ទះក្រដាសរឹងដែលបិទនឹងកំណាត់សំពត់បញ្ឈរលើតុ ឬកៅអី



យករូបសត្វបិទភ្ជាប់នឹងផ្ទាំងកំណាត់សំពត់សំឡីពេលនោះ សួរសិស្ស "តើនេះគឺជាអ្វី?" ឱ្យសិស្សឆ្លើយ គ្រូបំផុសសំណួរព្រមទាំងបង្ហើបស្លឹកត្រចៀកសត្វចេញតិចៗ



សំណួរបំផុសកាន់តែជិតស្លឹកត្រចៀកហើបកាន់តែច្បាស់ សិស្សអាចទាយត្រូវភាគច្រើន ។ គ្រូឱ្យសិស្សរាប់មួយ ពីរ បី ឱ្យបានស្រុះគ្នា ។ សិស្សរាប់មួយ ពីរ បី ទាំងអស់គ្នា ។



គ្រូបើកត្រឡប់រូប (ទន្ទឹមនឹងសិស្សរាប់មួយ ពីរ បី ) ។ ពេលនោះ សិស្សទះដៃដោយចេញពីដួងចិត្តរបស់គេ ។



www.elibraryofcambodia.org

ខ. ការផ្គុំរូបភាព

ការផ្គុំរូបដោយប្រើកំណាត់សំពត់សំឡី

១. សម្ភារត្រូវការ

- កន្ត្រៃ
- ជក់
- ពណ៌ទឹក
- កំណាត់សំពត់សំឡី
- បន្ទះក្តារ ឬបន្ទះក្រដាសរឹង
- ក្រដាសសំឡី

២. របៀបផលិត

- គូររូបសត្វ ឬរូបផ្សេង ( លើសពី២)
- ផាត់ពណ៌ហើយទុកឱ្យស្ងួត
- កាត់ច្រៀករូបជាបន្ទះៗ
- យកកំណាត់សំពត់សំឡីពាសនឹងក្តារដោយបិទការ៍ ឬកិប ។

៣. របៀបប្រើ

- រើសសិស្សស្ម័គ្រចិត្ត២នាក់ឡើងមកខាងមុខ
- ប្រាប់ឈ្មោះសត្វដល់សិស្ស
- ដាក់បំណែករូបដែលកាត់រួច ជាពីរជុំផ្សេងៗគ្នាសម្រាប់សិស្សម្នាក់ម្នាក់
- កំណត់ឱ្យសិស្សរៀប ។ បើរាប់ មួយ ពីរ បី ... តើរាប់ដល់ប៉ុន្មានទើបឈប់
- ចាប់ផ្តើមឱ្យសិស្សទាំងពីរប្រណាំងគ្នារៀប
- សិស្សនៅនឹងកន្លែងទះដៃតាមចង្វាក់ភ្លេង ឬតាមគ្រូណែនាំ
- លើកទឹកចិត្តអបអរសាទរ សរសើរដល់អ្នកឈ្នះ
- គ្រូសួរមតិភាគច្រើនតើចង់ឱ្យអ្នកចាញ់ធ្វើអ្វី ច្រៀង រាំ... ។

ល្បែងសិក្សានេះលោកគ្រូ អ្នកគ្រូ អាចអនុវត្តជាមួយកុមារនៅជំហានទី១នៃការនិទានរឿង ឬក៏អាចយកទៅប្រើជាសម្ភារបង្រៀនក្នុងជំហានទំនាក់ទំនង បំផុសសំណួរដើម្បីឈានចូលដល់មេរៀនថ្មី ទៅតាមការច្នៃប្រឌិតរបស់លោកគ្រូ អ្នកគ្រូ។ បើចង់យកសម្ភារនេះទៅបង្រៀន សូមគូររូបអ្វីដែលចង់បង្ហាញ ឬចង់បំផុសសំណួរសិស្ស



www.elibraryofcambodia.org

ដើម្បីឈានចូលមេរៀនថ្មី ។ បើលោកគ្រូ អ្នកគ្រូមានវិធីផ្សេងក្នុងការប្រើសម្ភារនេះ បានល្អជាងកាន់តែប្រសើរ ។

ការប្រើប្រាស់សម្ភារសម្រាប់ការនិទានរឿងធ្វើឱ្យកុមារមានសមត្ថភាព មានភាពក្លាហាន សប្បាយរីករាយ ទាក់ទាញ ដែលអាចទាញសតិកាកុមារចូលមកស្តាប់ការនិទានរឿង ឬការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ។

គ. ល្បែងដាំផ្កា

១. សម្ភារត្រូវការ

- ក្រដាសមួយសន្លឹក ខ្មៅដៃ ជ័រលុប
- ពណ៌សម្រាប់ផាត់

២. របៀបផលិត

- ប្រើក្រដាសផ្តេក គូរផើងផ្កានៅចំកណ្តាលទំព័រខាងក្រោមទាំងសងខាង មានរាងដូចគ្នា ទំហំប៉ុនគ្នា
- ម្ខាងដាក់បាតផើងជិតជលរឹមទំព័រ ងាយស្រួលគូរផ្កាផ្សេង១ដាក់ក្នុងផើង
- ម្ខាងទៀតដាក់មាត់ផើងជិតជលរឹមទំព័រ
- រូបផើងផ្កាទាំងពីរត្រូវឱ្យត្រួតលើគ្នា មានទិសដៅផ្ទុយគ្នា
- ផើងផ្កាទាំងសងខាងផាត់ពណ៌ឱ្យដូចគ្នា ។

៣. របៀបប្រើ

យកក្រដាសគំនូរខាងលើដែលយើងបានគូរ និងផាត់ពណ៌រួចរាល់ហើយមកប្រើ

- បត់ជ្រុងក្រោមខាងស្តាំមកឆ្វេងជារាងត្រីកោណកែងសមបាត
- បត់ជ្រុងក្រោមខាងឆ្វេងទៅក្រោយបានជារាងត្រីកោណកែងសមបាត
- ត្រឡប់ក្រដាស ឃើញមានរូបផើងផ្កា
- បត់មុំស្រួចខាងស្តាំបញ្ចូលក្នុងហោប៉ៅផើងផ្កា ដើម្បីបិទសន្លឹកផ្កា
- បត់មុំស្រួចខាងឆ្វេងទៅក្រោយ
- យករូបដែលបានបត់នេះមកកាន់បង្ហាញរូបផើងផ្កា
- ប្រាប់កុមារពីរបៀបដាក់គ្រាប់ដាំ ស្រោចទឹក
- ពេលដុះចាប់ផ្តើម ទាញមុំខាងលើឆ្វេងស្តាំដើម្បីបង្ហាញពីការដុះ ។



www.elibraryofcambodia.org

ឃ. ផ្ទាំងរូបភាព ( គូរ កាត់ បិទ និងបត់)

១. សម្ភារត្រូវការ

ក្រដាសកាតុង ខ្មៅដៃ ជ័រលុប ខ្មៅដៃពណ៌សម្រាប់ផាត់ពណ៌ ជក់ កាវ ក្រដាសពណ៌ ស្កុតពណ៌( កំណាត់) កាំបិត កន្ត្រៃ បន្ទាត់ ។

២. របៀបផលិត

ការកាត់បិទ:

- យកក្រដាសកាតុងមួយផ្ទាំងមកប្រើ ( បញ្ឈរ ឬផ្ដេក) តាមចូលចិត្ត
- យកក្រដាសពណ៌ផ្សេងៗគ្នាមកឆ្នៃកាត់បិទជារូបភាពប្លែកពីគ្នា

ឧទាហរណ៍: កាត់ជារូបភ្នំ ព្រះអាទិត្យ ស្ទឹង បឹង ត្រពាំង សត្វ ផ្កា ធម្មជាតិ ព្រៃ រុក្ខជាតិនានា ។

យកស្កុតក្រណាត់បិទរំលេចជុំវិញកាតុង

គំនូរ និងបត់បិទ:

បង្កើតផ្ទាំងរូបភាពចេញពីការគូរគំនូរផាត់ពណ៌ លើផ្ទាំងកាតុង និង យករូបដែលផលិតពីការបត់ក្រដាស មកបិទរំលេចនៅលើផ្ទាំងរូបភាព ។

ឧទាហរណ៍:
- គូររូបភាពមានដើមឈើ ( សត្វទំលើមែកឈើ)
- មានទឹក ( បិទរូបត្រី បង្កង ក្ដាម កង្កែប )
- មានវាលស្មៅ ( សេះ ទន្សាយ ដំរី សត្វផ្សេងៗ) ។

៣. របៀបប្រើ

ផ្ទាំងរូបភាពទាំងនេះ អាចយកមកតុបតែងលំអក្នុងបន្ទប់បណ្ណាល័យដែលកើតឡើង ពីការច្នៃប្រឌិតពិតៗ តាមការនឹកឃើញ និងចំណូលចិត្តរបស់បណ្ណារក្ស ដើម្បីទាក់ទាញអារម្មណ៍កុមារឱ្យកាន់តែយល់អំពីគុណតម្លៃរបស់ សកម្មភាពបណ្ណាល័យថែមទៀត ។ ការរៀបចំបង្ហាញផ្ទាំងរូបភាព នេះអាចធ្វើឱ្យកុមារមានចិត្តចង់បង្កើតស្នាដៃ របស់ខ្លួន ។

ង. បន្ទប់ចម្លែក

១. សម្ភារត្រូវការ

ក្រដាសកាតុង រូបគំនូរ ខ្មៅដៃពណ៌ ហ្វឺតពណ៌ ខ្មៅដៃ កាវ កន្ត្រៃ បន្ទាត់ ជ័រលុប ។



www.elibraryofcambodia.org

២. របៀបផលិត

យកក្រដាសកាតុងមួយសន្លឹកមកប្រើ



បត់ក្រដាសកាតុងជាពីរស្មើគ្នាតាមបណ្ដោយ ឱ្យមានស្នាមផ្នត់ រួចលាវិញ



បត់ផ្នែកបណ្ដោយលើចុះក្រោម បណ្ដោយផ្នែកក្រោមទៅលើឱ្យស្របគ្នា បត់បណ្ដោយទាំងពីរត្រួតលើគ្នា



វាស់ចុងខាងស្ដាំដៃឱ្យបានជារាងការ៉េ



បត់ចុងខាងឆ្វេងដៃដាក់មកត្រឹមជ្រុងការ៉េ



បើកហោប៉ៅលើខាងឆ្វេង សង្កត់ឱ្យស្នាមផ្នត់នៅចំទ្រនុងកណ្ដាល



បត់ផ្ទាំងខាងឆ្វេងទៅក្រោយត្រឹមទ្រនុងកណ្ដាល



www.elibraryofcambodia.org





បត់ចុងខាងស្ដាំមកឆ្វេង

បើកហោប៉ៅខាងស្ដាំ សង្កត់ឱ្យស្នាមផ្នត់នៅចំទ្រនុងកណ្ដាល





បត់ផ្ទាំងខាងស្ដាំទៅក្រោយត្រឹមទ្រនុងកណ្ដាល

បង្កើតបានជាបន្ទប់ចម្លែកមួយ





www.elibraryofcambodia.org

៣. របៀបគូររូប ឬកាត់រូបមកបិទ

- បើកបន្ទប់ឡើងឃើញមានបីផ្ទាំង ហើយនៅខាងក្រោយមានមួយផ្ទាំងទៀត

- ត្រូវគូររូបបួនដាក់តាមផ្ទាំង ហើយផ្ទាំងនីមួយៗមានរូបមួយ បើមិនចេះគូររូបអាចកាត់រូបមកបិទក៏បានដែរ

- រូបនៅក្នុងបន្ទប់រាងការេខាងលើទាំងសងខាងត្រូវដាក់រូបដូចគ្នា ផាត់ពណ៌ដូចគ្នា ឧទាហរណ៍ នំខួបកំណើត ។ នៅតាមផ្ទាំងផ្សេងៗមានរូបដូចជា ឆ្មា ទន្សាយ គោ ដំរី ...។ តាមការចូលចិត្ត ។

៤. របៀបប្រើ

- បន្ទប់ចម្លែកនេះ ប្រើក្នុងជំហានទី១នៃការនិទានរឿង ដើម្បីទាក់ទាញអារម្មណ៍សិស្ស ៥នាទី ដំបូង ដោយមានលេងល្បែង ទស្សន៍ទាយ រាំ ច្រៀង ។

- បណ្ដារក្សឱ្យសិស្សទាយ សត្វណាដែលអាចចូលស៊ីនំបាន លុះត្រាតែបានចូលទៅក្នុងផ្ទាំងកណ្ដាល បើសិស្សទាយថាសត្វឆ្មា អ្នកត្រូវបត់ឆ្មាចូលមុន រួចបង្វិលត្រឡប់ទៅក្រោយមួយជុំ ទើបបើកបង្ហាញទៀត ឃើញសត្វឆ្មាដូចបំណងកុមារមែន ។

- បណ្ដារក្សឱ្យសិស្សទាយម្ដងទៀត បើសិស្សទាយថាទន្សាយ យើងមិនចង់ឱ្យទន្សាយចូលទេ ត្រូវបត់សត្វផ្សេងចូលមុន បត់ទន្សាយចូលក្រោយគេ បង្វិលមួយជុំត្រឡប់រួចបង្ហាញម្ដងទៀត បាត់រូបទន្សាយ ។

ច. រូមវះគើ

១. សម្ភារត្រូវការ

ក្រដាសរាមប្រភេទក្រាស់ (កម្រាស់ ២០០ក្រាម ទៅ ២៥០ក្រាម) ចំនួនពីរសន្លឹក ឬក្រដាសកំទូរប្រភេទក្រាស់ មកកាត់ឱ្យបានទំហំ បណ្ដោយ៣៥ស.ម ទទឹង២៦ស.ម ចំនួនពីរសន្លឹក ខ្មៅដៃ ខ្មៅដៃពណ៌ ហ្វឹតពណ៌ កន្ត្រៃ បន្ទាត់ ជ័រលុប ។

២. របៀបផលិត

- យកក្រដាសមួយសន្លឹកខាងលើបត់ជាពីរតាមទទឹងហើយកាត់ផ្ដាច់

- បន្ទាប់មកយកក្រដាសដែលយើងបានកាត់ជាពីរនោះតែមួយសន្លឹកមកបត់កាត់ជាពីរទៀតតាមបណ្ដោយ

- ប្រើក្រដាសថ្មីមួយសន្លឹកទៀតបត់ជាពីរតាមទទឹងឆូតឱ្យបាក់ផ្នត់

- បត់ផ្ទាំងខាងមុខជាពីរ បត់ផ្ទាំងខាងក្រោយជាពីរទៅក្រោយឱ្យមានស្នាមផ្នត់ទៅមុខ

- លាត្រឹមស្នាមផ្នត់ ចែកទ្រនុងខ្នងជា៤ចំណែកស្មើគ្នា គូសបន្ទាត់បានជាចតុកោណកែង៤

- កាត់ផ្ដាច់តាមបណ្ដោយចតុកោណកែងទាំង៤ត្រឹមស្នាមផ្នត់ទាំងសងខាង រួចលាវិញ

- យកក្រដាស២ផ្ទាំងតូចៗខាងលើមកសិកបញ្ចូលឆ្លាស់គ្នាដូចត្បាញកន្ទេល ។



www.elibraryofcambodia.org



បត់ក្រដាសទទឹងជាបួនផ្គត់ស្មើៗគ្នា



គូសទ្រនុងខ្នងជាបួនស្មើៗគ្នា



កាត់ត្រឹមស្នាមគូស



យកក្រដាសតូចមកសិកឆ្លាស់គ្នា

៣. របៀបគូររូប

បង់លេខមុនពេលគូររូបមានភាពងាយស្រួល បើមិនបង់លេខទេអាចគូររូបច្រឡំគ្នា ព្រោះក្រដាសដែលធ្វើរួចនេះ អាចគូររូបបានបួនផ្នែក ជាទូទៅគូររូបតែពីរផ្នែកទេ ងាយស្រួលដល់ការប្រើប្រាស់ ។

- ក្រដាសដែលធ្វើរួចនេះ បកបង់លេខនៅចំកណ្ដាល
- រុញបញ្ចូលគ្នាទាំងបួនផ្គត់ រួចបើកចំកណ្ដាលបង់លេខ១ គូររូបបិទមុខ
- ទាញសន្លឹកទី១ទាំងឆ្វេងទាំងស្ដាំព្រមគ្នា បានផ្ទាំងធំបង់លេខ២ គូររូបបើកមុខ ។



www.elibraryofcambodia.org

## ៤. របៀបប្រើ



វ៉ូម



វ៉ះអើ

សម្ភារនេះប្រើក្នុងជំហានទី១នៃការនិទានរឿង ឬលោកអ្នកអាចយកទៅបង្រៀន ក្នុងមុខវិជ្ជាអ្វីផ្សេងទៀតក៏បាន ។

- អាចគូររូបអ្វីក៏បានតាមការចូលចិត្តឱ្យតែរូបនោះជាដែលបិទមុខមួយ បើកមុខមួយ ឬអាចផ្គាមផាត់ពណ៌ក៏បានដែរ តាមលទ្ធភាពដែលអាចធ្វើទៅបាន

- រូបនេះបត់ជាបួនផ្នត់

- សូមពិនិត្យមើលមុនពេលយករូបមកបង្ហាញកុមារ ប្រយ័ត្នបញ្ច្រាសក្បាលចុះក្រោម

- បើកចំពាក់កណ្ដាលបង្ហាញរូបបិទភ្នែក

- បណ្ដាក្យលេងជាមួយកុមារ ដោយបើករូបវ៉ូម (រូបដែលយកដៃបិទភ្នែក) ឱ្យកុមារមើល ហើយឱ្យកុមារយកដៃបិទភ្នែកខ្លួនឯងថាវ៉ូម ឬឱ្យកុមាររាប់ ឬទះដៃ ១ ២ ៣... អស្ចារ្យ បន្ទាប់មកទាយថា ជាសត្វអ្វី?

- ទាញសន្លឹកទី១ទាំងឆ្វេង ទាំងស្ដាំព្រមគ្នា ឃើញរូបបើកមុខ ថា វ៉ះអើ បើកុមារទាយត្រូវ ពួកគេសប្បាយចិត្តណាស់ ។

## ឆ. ប្រអប់៦ជ្រុង

### ១. សម្ភារត្រូវការ

ក្រដាសសម្រាប់គូរគំនូរខ្នាតធំ យកមកកាត់ ឬ ក្រដាសកាតុងពណ៌សក្រាស់អាចគូររូបផាត់ពណ៌បានកាត់ទំហំ បណ្ដោយ១០០ស.ម ទទឹង១៥ស.ម មួយសន្លឹក ខ្មៅដៃ ខ្មៅដៃពណ៌ ហ្វឺតពណ៌ កន្ត្រៃ កាវ បន្ទាត់ ជ័រលប់ ។



www.elibraryofcambodia.org

២. របៀបផលិត

- យកក្រដាសខ្នាតដូចខាងលើ
- គូសបន្ទាត់ចំពាក់កណ្ដាលស្របនឹងបណ្ដោយក្រដាសប្រវែង២០ស.ម
- បត់ក្រដាសជាត្រីកោណយកជ្រុងមុំកែងដាក់ចំលើបន្ទាត់ដែលគូស បានត្រីកោណកែង
- យកជ្រុងបាតដែលមានកំពស់ជាមុំកែងបត់ទៅក្រោយបានជាត្រីកោណសម័ង្ស( ត្រីកោណជ្រុងពាស្មើគ្នា)
- មានត្រីកោណសមង្ស៊ីមួយជាគោលបត់តគ្នាឆ្លុតឱ្យបាក់ផ្នត់រហូតដល់អស់ក្រដាស ដោយបត់មុខក្រោយត្រឡប់ចុះឡើង
- កាត់ត្រីកោណកែងចេញ
- លាត្រីកោណដែលបត់បានបង់លេខតគ្នា ពីលេខ១ ដល់លេខ១០ សល់ប៉ុន្មានកាត់ចោល
- បត់ត្រីកោណចូលវិញតាមស្នាមផ្នត់



បត់មុំកែងឱ្យចំខ្សែបន្ទាត់



កាត់ត្រីកោណកែងចេញ



លាបកាវបិទលេខ១ និងលេខ១០ភ្ជាប់គ្នា



បើកបានត្រីកោណ៦ជាប់គ្នា



www.elibraryofcambodia.org

៣. របៀបគូររូប

បង់លេខមុនពេលគូររូបមានភាពងាយស្រួល បើមិនបង់លេខទេអាចគូររូបច្រឡំគ្នា ព្រោះប្រអប់៦ជ្រុង នេះ អាចគូររូបបាន៦ផ្នែក ជាទូទៅការគូររូបតែបីផ្នែកទេ ងាយស្រួលដល់ការប្រើប្រាស់។

- ពេលបើកឡើងឃើញមានរាង៦ជ្រុង
- ប្រអប់៦ជ្រុងនេះ ត្រូវបង់លេខ១នៃកំពូលមុំនៅចំកណ្តាល
- ត្រូវរុញបញ្ចូលគ្នាទាំងអស់ឱ្យបានជារាងប្រលេឡូក្រាម ហើយបើកត្រឡប់ទៅក្រោយរហូត
- បើកត្រឡប់ម្តងបង់លេខ២ នៅចំកណ្តាល
- បើកត្រឡប់ម្តងទៀតបង់លេខ៣ នៅចំកណ្តាល
- ចាប់ផ្តើមគូររូបនៅផ្នែកដែលគេបានបង់លេខទុក
- អាចគូររូបអ្វីក៏បានតាមការចូលចិត្ត ប៉ុន្តែសូមប្រើប្រភេទដូចគ្នា។

ឧទាហរណ៍ : - ប្រភេទផ្លែឈើ ល្ហុង ស្វាយ ធូរេន

- ប្រភេទមធ្យោបាយធ្វើដំណើរ រថយន្ត រថភ្លើង យន្តហោះ
- ប្រភេទសត្វរស់នៅក្នុងទឹក ត្រី ក្តាម បង្កង
- ប្រភេទបន្លែ ល្ពៅ ត្រឡាច ត្រប់ ។

រូបនីមួយៗអាចផ្គាមផាត់ពណ៌ក៏បានដែរ តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

៤. របៀបប្រើ

សម្ភារនេះប្រើក្នុងជំហានទី១នៃការនិទានរឿង ឬលោកអ្នកអាចយកទៅបង្រៀន ក្នុងមុខវិជ្ជាអ្វីផ្សេង ទៀតក៏បាន ។

- ត្រូវយកប្រអប់៦ជ្រុងដែលគូររូបហើយបត់ទៅជារាងប្រលេឡូក្រាម
- មុនពេលបង្ហាញរូបភាពដល់កុមារ ត្រូវត្រឡេកមើលជាមុនចៀសវាងបញ្ច្រាស់រូបភាព
- បើកត្រឡប់ទៅក្រោយរហូត មុនពេលបង្ហាញរូបត្រូវឱ្យកុមារទាយថាជាអ្វី?





www.elibraryofcambodia.org

## ឧបសម្ព័ន្ធ

១. បទបញ្ជាផ្ទៃក្នុងបណ្ណាល័យ

ប្រការ ១ : សំអាតដៃឱ្យបានស្អាត មុននឹងអ្នកប្រើប្រាស់សៀវភៅ និងមិនត្រូវញ៉ាំចំណីក្នុងបណ្ណាល័យ ។

ប្រការ ២ : អ្នកអានត្រូវចុះឈ្មោះ មុននឹងចូលអាន ខ្ចី ឬ សង ។

ប្រការ ៣ : រក្សាសណ្តាប់ធ្នាប់ មិនត្រូវរំខានអ្នកដទៃ ។

ប្រការ ៤ : បំពេញប័ណ្ណសម្គាល់ មុននឹងខ្ចីសៀវភៅចេញក្រៅ ( ប្រសិនបើមាន) ។

ប្រការ ៥ : អ្នកអានអាចខ្ចីសៀវភៅចំនួន....... ក្បាល រយៈពេល....... ថ្ងៃ ។

ប្រការ ៦ : អ្នកអានត្រូវរក្សាគុណភាពឯកសារឱ្យបានល្អ ។ ប្រសិនបើធ្វើឱ្យរហែក ឬ បាត់បង់ត្រូវសងជាសៀវភៅ ឬ ជាតម្លៃសៀវភៅ ។

ប្រការ ៧ : វចនានុក្រម ទស្សនាវដ្តី ឬ ឯកសារសំខាន់ៗ មិនអនុញ្ញាតឱ្យខ្ចីចេញក្រៅឡើយ ។

ប្រការ ៨ : អ្នកអានមិនអាចខ្ចីឯកសារថ្មី នៅពេលដែលមិនទាន់យកមកសងគ្រប់ចំនួន ។

ប្រការ ៩ : អ្នកអានអាចពន្យារពេលខ្ចីបាន ដោយទាក់ទងជាមួយបណ្ណារក្ស ។

ប្រការ ១០ : ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យ បើមិនដូច្នេះទេនឹងត្រូវទទួលការណែនាំពីបណ្ណារក្ស ។

២. គំរូត្រាវាងពងក្រពើ





៣. ចំណាត់ថ្នាក់លោក ឌីវេ Dewey

**ផ្នែកទីមួយ១ ចែកចេញជា ១០ ក្រុម :**

ក្រុម ០០០ ទូទៅ

| | |
|---|---|
| ០១០ | គន្ថនិទ្ទេស |
| ០២០ | វិទ្យាសាស្ត្រគ្រប់គ្រងបណ្ណាល័យ និងវិទ្យាសាស្ត្រផ្សព្វផ្សាយព័ត៌មាន |
| ០៣០ | សព្វវចនាធិប្បាយទូទៅ |
| ០៤០ | |
| ០៥០ | ការបោះពុម្ពតាមផ្នែក តាមលំដាប់ |
| ០៦០ | ការរៀបចំទូទៅ និងវិជ្ជាខាងសារមន្ទីរ |



www.elibraryofcambodia.org

០៧០ សារព័ត៌មានវិទ្យា ការបោះពុម្ពផ្សាយសារព័ត៌មាន

០៨០ សេចក្តីសម្រាំងទូទៅ

០៩០ ឯកសារសរសេរដៃ និង សៀវភៅកម្រមាន

ក្រុម ១០០ ទស្សនវិជ្ជា និង សីលធម៌

១១០ បរមត្ថវិទ្យា

១២០ ទស្សនវិជ្ជាខាងប្រវត្តិសាស្ត្រ វិធីសាស្ត្រ និង គោលការណ៍នៃវិទ្យាសាស្ត្រ ការទាក់ទងហេតុ និង ផល

១៣០ បាតុភូតចម្លែក និង វិជ្ជាក្រៅវិទ្យាសាស្ត្រ

១៤០ ប្រព័ន្ធនានានៃទស្សនវិជ្ជា

១៥០ ចិត្តវិទ្យា

១៦០ តក្កវិទ្យា

១៧០ ក្រមសីលធម៌ (អភិសមាចារ)

១៨០ ទស្សនវិជ្ជាបូព៌ាទិសក្នុងសម័យបុរាណ និង យុគកណ្តាល

១៩០ ទស្សនវិជ្ជាទំនើបនៃបស្ចិមប្រទេស

ក្រុម ២០០ ទេវវិទ្យា និង សាសនា

២១០ សាសនាគ្រីស្ទទូទៅ

២២០ គម្ពីរគ្រិស្តសាសនា

២៣០ ទេវវិទ្យាសាសនាគ្រិស្ត

២៤០ ទេវវិទ្យាប្រៀនប្រដៅ និងដឹកនាំផ្លូវចិត្ត

២៥០ គ្រីស្ទគ្រិស្តសាសនាតាមមូលដ្ឋាន និងលំដាប់ថ្នាក់ព្រះសង្ឃគ្រិស្ត

២៦០ ទេវវិទ្យា និងសង្គម

២៧០ ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនៃគ្រីស្ទគ្រិស្ត

២៨០ ជំនឿនិកាយ និងសាសនិកគ្រិស្ត

២៩០ សាសនាផ្សេងៗទៀត

២៩៤.៣ សាសនាព្រះពុទ្ធ

២៩៧ សាសនាអ៊ីស្លាម



www.elibraryofcambodia.org

ក្រុម ៣០០ សង្គមវិទ្យា និង ច្បាប់

៣១០ ស្ថិតិ

៣២០ វិទ្យាសាស្ត្រនយោបាយ

៣៣០ សេដ្ឋកិច្ច

៣៤០ ច្បាប់

៣៥០ ច្បាប់រដ្ឋបាលសាធារណៈ

៣៦០ បញ្ហា និងការងារសង្គម

៣៧០ ការអប់រំ

៣៨០ ពាណិជ្ជកម្ម គមនាគមន៍ និង ដឹកជញ្ជូន

៣៩០ ទំនៀមទម្លាប់ សុជីវធម៌ ប្រពៃណី

ក្រុម ៤០០ ភាសាវិទ្យា

៤១០ ប្រវត្តិនៃភាសា

៤២០ ភាសាអង់គ្លេស អង់គ្លេស-អាមេរិកាំង

៤៣០ ភាសាអាល្លឺម៉ង់

៤៤០ ភាសាក្លាយពីភាសារ៉ូម៉ាំង ភាសាបារាំង

៤៥០ ភាសាអ៊ីតាលី រូម៉ានី គ្រាមភាសារ៉ូម៉ាំង

៤៦០ ភាសាអេស្ប៉ាញ៉ុល និង ព័រទុយហ្គេ

៤៧០ ភាសាអ៊ីតាលីបុរាណ ឡាតាំង

៤៨០ ភាសាក្រិក

*៤៩០ ភាសាផ្សេងៗ*

*៤៩៥.៩ ភាសាខ្មែរ*

ក្រុម ៥០០ វិទ្យាសាស្ត្រពិត

៥១០ គណិតវិទ្យា

៥២០ តារាវិទ្យា និង វិទ្យាសាស្ត្រពាក់ព័ន្ធ

៥៣០ រូបវិទ្យា

៥៤០ គីមីវិទ្យា និង វិទ្យាសាស្ត្រពាក់ព័ន្ធ

៥៥០ វិទ្យាសាស្ត្រពិភពផែនដី



www.elibraryofcambodia.org

៥៦០ បាសាណិភូតវិទ្យា

៥៧០ ជីវវិទ្យា

៥៨០ ភូតគាមសាស្ត្រ

៥៩០ សត្វវិទ្យា

ក្រុម ៦០០ បច្ចេកវិទ្យា វិទ្យាសាស្ត្រអនុវត្តន៍

៦១០ វេជ្ជសាស្ត្រ

៦២០ សិល្បៈ នៃវិស្វកម្ម និងសកម្មភាពពាក់ព័ន្ធ

៦៣០ កសិកម្ម និងបច្ចេកទេសពាក់ព័ន្ធ

៦៤០ សេដ្ឋកិច្ចគ្រួសារ ជីវភាពគ្រួសារ

៦៥០ ការគ្រប់គ្រងសហគ្រាស និងការងារពាក់ព័ន្ធ

៦៦០ បច្ចេកទេសខាងគីមី និង បច្ចេកទេសពាក់ព័ន្ធ

៦៧០ របៀបធ្វើឧស្សាហកម្ម

៦៨០ ការផលិតវត្ថុសម្រាប់ប្រើប្រាស់តាមយថាប្រភេទ

៦៩០ ការសាងសង់

ក្រុម ៧០០ សិល្បៈ និងកីឡា

៧១០ នគររូបនីយកម្ម

៧២០ ស្ថាបត្យកម្ម

៧៣០ សិល្បៈសូឡរូប និងចម្លាក់

៧៤០ គំនូរ សិល្បៈតុបតែង

៧៥០ វិចិត្រកម្ម និង ផ្ទាំងគំនូរ

៧៦០ សិល្បៈក្រាហ្វិក រូបចម្លាក់លើផ្ទាំងឈើ ឬលើលោហធាតុ

៧៧០ សិល្បៈថតរូប និងរូបថត

៧៨០ តន្ត្រី

៧៩០ ការលំហែនៅពេលទំនេរសិល្បៈខាងទស្សនីយភាព

ក្រុម ៨០០ អក្សរសិល្ប៍

៨១០ អក្សរសិល្ប៍អាមេរិកាំង



www.elibraryofcambodia.org

| | |
|---|---|
| ៨២០ | អក្សរសិល្ប៍អង់គ្លេស អក្សរសិល្ប៍អង់គ្លេស-អាមេរិកាំង |
| ៨៣០ | អក្សរសិល្ប៍អាល្លឺម៉ង់ |
| ៨៤០ | អក្សរសិល្ប៍បារាំង |
| ៨៥០ | អក្សរសិល្ប៍អ៊ីតាលី រូម៉ានី ក្រោមភាសាអ៊ីតាលី |
| ៨៦០ | អក្សរសិល្ប៍អេស្ប៉ាញ៉ុល និងព័រទុយហ្គេ |
| ៨៧០ | អក្សរសិល្ប៍អ៊ីតាលីបុរាណ អក្សសិល្ប៍ឡាតាំង |
| ៨៨០ | អក្សរសិល្ប៍ក្រិក |
| ៨៩០ | អក្សរសិល្ប៍ភាសាផ្សេងៗទៀត |
| ៨៩៥.៩ | អក្សរសិល្ប៍ខ្មែរ |

ក្រុម ៩០០ ភូមិវិទ្យា និង ប្រវត្តិវិទ្យា

| | |
|---|---|
| ៩១០ | ភូមិវិទ្យាទូទៅ ការធ្វើដំណើរ |
| ៩២០ | ជីវប្រវត្តិទូទៅ និង ពង្សាវិទ្យា |
| ៩៣០ | ប្រវត្តិវិទ្យាទូទៅនៃពិភពបុរាណ |
| ៩៤០ | ប្រវត្តិវិទ្យាទូទៅទ្វីបអឺរ៉ុប |
| ៩៥០ | ប្រវត្តិវិទ្យាទូទៅទ្វីបអាស៊ី |
| ៩៥៩.៦ | ប្រវត្តិវិទ្យាប្រទេសកម្ពុជា |
| ៩៦០ | ប្រវត្តិវិទ្យាទូទៅទ្វីបអាហ្វ្រិក |
| ៩៧០ | ប្រវត្តិវិទ្យាទូទៅនៃអាមេរិកខាងជើង |
| ៩៨០ | ប្រវត្តិវិទ្យាទូទៅនៃអាមេរិកខាងត្បូង |
| ៩៩០ | ប្រវត្តិវិទ្យាទូទៅនៃប្រទេសផ្សេងៗទៀត |



www.elibraryofcambodia.org

## ៤. តារាងចំណាត់ថ្នាក់លម្អិតលោក ដឺវេ (Dewey)

០០០ ឱភាសភាព

០០១ ចំណេះ

ចាត់ថ្នាក់ប្រវត្តិសាស្ត្រ វិធីសាស្ត្រ និងគោលការណ៍វិទ្យាសាស្ត្រនៅលេខ:១២១

.១ ជីវិតបញ្ញាវន្ត

.២ ទំនួលចំណេះដឹង និង ពុទ្ធិ

ចាត់ថ្នាក់វិធីសាស្ត្រគរុកោសល្យនៅលេខ: ៣៧១. ៣

.៣ ការសិក្សាបុរាណភាសា

.៤ ការស្រាវជ្រាវ

ឧទាហរណ៍ : ស្រាវជ្រាវភាសាប្រវត្តិ: ៤១០. ៧២

.៤២ វិធីស្រាវជ្រាវ

ឧទាហរណ៍ : ស្រាវជ្រាវនិរុត្តិសាស្ត្រ: ៤១០. ១៨

.៥៤ ទំនាក់ទំនងតាមរយៈភាសា

ចាត់ថ្នាក់ភាសាប្រវត្តិ: ៤១០

៥៤២ ទំនាក់ទំនងតាមរយៈភាសានិយាយ

៥៤៣ ទំនាក់ទំនងតាមរយៈសំណេរ

០០២ សៀវភៅ

ចាត់ថ្នាក់គន្ថនិទ្ទេសនៅលេខ: ០១០ ការបោះពុម្ពផ្សាយនៅលេខ ០៧០. ៥
សិល្បៈចងក្រងសៀវភៅនៅលេខ ៦៨៦.០៧៤ សារមន្ទីរ សមុច្ច័យ ពិពណ៌

០០៣ ប្រព័ន្ធ

ទ្រឹស្តី វិធីសម្ព័ន្ធ ការចងក្រង

០០៥ ការរៀបចំកម្មវិធី កម្មវិធី រៀបចំទិន្នន័យ

០០៦ វិធីអាំងហ្វ័រម៉ាទិកពិសេស

០១០ គន្ថនិទ្ទេស

០១១ .១ គន្ថនិទ្ទេសសកល

.២ គន្ថនិទ្ទេសជាតិ



www.elibraryofcambodia.org

.៣ គន្ថនិទ្ទេសទូទៅនៃសាធារណការក្រោមទម្រង់ប្លែកៗគ្នា

.៣១ សំណេរដោយដៃ

.៣២ សៀវភៅបោះពុម្ព

.៣៥ សារព័ត៌មាន

.៤៤ សៀវភៅកម្រមាន

.៤៧ សៀវភៅថតចម្លង

០១៤ គន្ថនិទ្ទេស បញ្ជីសៀវភៅអនាមិក និងរហស្សនាម

០១៥ គន្ថនិទ្ទេសជាតិ

ត្រូវបន្ថែមលេខភូមិវិទ្យាទៅលើលេខ ០១៥ តារាង ២

ឧទាហរណ៍ : គន្ថនិទ្ទេសជាតិបារាំង : ០១៥.៤៤

ឧទាហរណ៍ : គន្ថនិទ្ទេសជាតិខ្មែរ : ០១៥.៥៩៦

០១៦ គន្ថនិទ្ទេសតាមឯកទេស កាតាឡុកតាមមុខវិជ្ជា

ឧទាហរណ៍ : គន្ថនិទ្ទេសតារាវិទ្យា ៥២០. ១៦

០២០ វិទ្យាសាស្ត្រគ្រប់គ្រងបណ្ណាល័យ និង វិទ្យាសាស្ត្រផ្សព្វផ្សាយព័ត៌មាន

០២១ បណ្ណាល័យ និង សមាគម

.២ បណ្ណាល័យ និង បញ្ហាជុំវិញការងារសង្គម

.២៤ មុខងារអប់រំ

.២៦ មុខងារវប្បធម៌

.២៨ មុខងារផ្សព្វផ្សាយ

.៨ បណ្ណាល័យ និង រដ្ឋ

.៨៣ ប្រាក់ឧបត្ថម្ភរបស់រដ្ឋ

០២២ ការកំណត់ទីតាំងបណ្ណាល័យ និង មជ្ឈមណ្ឌលតម្កល់ឯកសារ

.១ ទីតាំង

.៣ អគារ

.៤ ការរៀបចំកន្លែង

.៧ ការរៀបចំបំភ្លឺ

៨ កំដៅ កង្ហារ

៩ សម្ភារប្រើប្រាស់

០២៣ បុគ្គលិក និង មុខងារ



www.elibraryofcambodia.org

០២៥ ការងារគ្រប់គ្រងបណ្ណាល័យ និង ឯកសារ
.១ ការងាររដ្ឋបាល និង ការងារគ្រប់គ្រង
.២ សមិទ្ធិ និង កំណើននៃសម្បត្តិយ
២៦ អំណោយ ការប្តូរឯកសារ ឯកសារតម្កល់ទុកតាមច្បាប់
.៣ ធ្វើសម្ព័ន្ធ និងត្រួតពិនិត្យគន្ថនិទ្ទេស
០២៦ បណ្ណាល័យឯកទេស
០២៧ បណ្ណាល័យទូទៅ
.១ បណ្ណាល័យឯកជន និង បណ្ណាល័យគ្រួសារ
.២ បណ្ណាល័យសម្រាប់ជួលសៀវភៅ
.៤ បណ្ណាល័យសាធារណៈ
.៥ បណ្ណាល័យជាតិ
.៦ បណ្ណាល័យសម្រាប់ក្រុមការងារពិសេស
.៧ បណ្ណាល័យសាកលវិទ្យាល័យ
.៨ បណ្ណាល័យសិក្សា
០៣០ សព្វវចនាធិប្បាយទូទៅ
០៣១ សព្វវចនាធិប្បាយភាសាអាមេរិកាំង
០៣២ សព្វវចនាធិប្បាយភាសាអង់គ្លេស
០៣៣ សព្វវចនាធិប្បាយភាសាអាល្លឺម៉ង់
០៣៤ សព្វវចនាធិប្បាយភាសាបារាំង
០៣៥ សព្វវចនាធិប្បាយភាសាអ៊ីតាលី
០៣៩. ៩១ សព្វវចនាធិប្បាយភាសាខ្មែរ
០៣៦ សព្វវចនាធិប្បាយភាសាអេស្ប៉ាញ៉ុល និង ព័រទុយហ្គេ
០៣៧ សព្វវចនាធិប្បាយភាសាស្លាវ
០៣៧. ១ សព្វវចនាធិប្បាយភាសារុស្ស៊ី
០៣៨ សព្វវចនាធិប្បាយភាសាស្កង់ឌីណាវ
០៥០ ការបោះពុម្ពជាផ្នែកៗ ហើយតាមលំដាប់
ពី ០៥១ ទៅ ០៥៩ : រៀបតាមលំដាប់ដូច ០៣១ ទៅ ០៣៩
០៦០ ក្រុមការងារទូទៅ និង ភណ្ឌនិកេតនវិទ្យា
សមាគម បណ្ឌិតសភា



www.elibraryofcambodia.org

០៦១ អាមេរិកាំងខាងជើង

០៦២ អង់គ្លេស

០៦៤ បារាំង

០៦៥ អ៊ីតាលី

០៦៦ អេស្ប៉ាញ៉ុល និង ព័រទុយហ្គេ

០៦៧ រុស្ស៊ី

០៦៩ ភណ្ឌនិកេតនវិទ្យា

.៤ ការអង្គាស និង ការថែរក្សាវត្ថុបុរាណ

.៥ សមុច្ច័យ និង ពិព័រណ៌

.៧ ការផ្សព្វផ្សាយ

.៩ សារមន្ទីរឯកទេស

ត្រូវផ្សំលេខ ០៦៩. ៩ ជាមួយលេខសំគាល់មុខវិជ្ជាណាមួយដើម្បី

បានលេខនៃ សារមន្ទីរនោះ

ឧទាហរណ៍ : សារមន្ទីរវិទ្យាសាស្ត្រ ០៦៩. ៩៥

០៧០ សារព័ត៌មានវិទ្យា សារព័ត៌មាន ការបោះពុម្ពផ្សាយ

.៤ សកម្មភាពសារព័ត៌មាន

៤៤៩ សារព័ត៌មានតាមឯកទេស

៤៨ សារព័ត៌មានសម្រាប់ក្រុមពិសេស

៤៨២ សារព័ត៌មានសាសនា

៤៨៤ សារព័ត៌មានសម្រាប់ជនជាតិភាគតិច

៥៧០. ៦ បណ្ណាគារ

៩៩២ ពាណិជ្ជកម្ម

.៩ ជីវប្រវត្តិនៃអ្នកសារព័ត៌មាន

០៨០ សេចក្ដីសម្រាំង

ពីលេខ ០៨១ ទៅ ០៨៩ ត្រូវចែក និង រៀបដូច ០៣១ ទៅ ០៣៩

០៩០ ឯកសារសរសេរដោយដៃ និង សៀវភៅកម្រមាន

០៩១ ឯកសារសរសេរដោយដៃ

០៩២ សៀវភៅរូបក្បាច់ចម្លាក់

០៩៨. ១ សៀវភៅសម្ងាត់



www.elibraryofcambodia.org

.៣ សៀវភៅបោកប្រាស់

១០០ ទស្សនវិជ្ជា និង សីលធម៌

ដើម្បីចាត់ថ្នាក់ទស្សនវិជ្ជាប្រភេទណាមួយ ត្រូវផ្សំលេខ ០១ តារាង ១ ទៅលើលេខ សម្គាល់នៃមុខវិជ្ជា នោះ ។

ឧទាហរណ៍ : ទស្សនវិជ្ជានៃវិទ្យាសាស្ត្រ ៥០១

លេខ ១០១ ទៅ ១០៩ ជាលេខរូមរបស់ទស្សនវិជ្ជា

១០១ ទ្រឹស្តីនៃទស្សនវិជ្ជា

១០២ វចនានុក្រម សព្វវចនាធិប្បាយ

១០៩ ប្រវត្តិសាស្ត្រទូទៅនៃទស្សនវិជ្ជា

១១០ មរមត្ថវិទ្យា ( ទស្សនវិជ្ជាអរូបី)

១១១ ប្រាណវិទ្យា

១១៣ លោកធាតុវិទ្យា ( ជាផ្នែកមួយនៃតារាវិទ្យា ដែលសិក្សាអំពីរចនាសម្ព័ន្ធ និង ភពនៃពិភពក្នុង លំនាំជាសំណុំ )

១៣០ បាតុភូតចម្លែក និងវិជ្ជាក្រៅវិទ្យាសាស្ត្រ

១៣៧ លេខនាវិទ្យា

១៣៨ ទឹកមុខ

១៣៩ មត្ថកវិទ្យា

១៤០ ប្រព័ន្ធនានានៃទស្សនវិជ្ជា

១៤១ ឧត្តមគតិនិយម ចេតោនិយម អញ្ញថានិយម បុគ្គលនិយម

១៥០ ចិត្តវិទ្យា

.១ ទស្សនវិជ្ជា និង ទ្រឹស្តី

១៥២ ចិត្តសរីរៈវិទ្យា

.៤ មនោសញ្ចេតនា

១៥៣ បញ្ញា

.៨ ឆន្ទៈ

១៥៤ អឡ្សសម្បជញ្ញៈ

.៦៣ សុបិន

.៧ ភាពត្រូវសណ្តំ



www.elibraryofcambodia.org

១៥៥.២ បុគ្គលិកលក្ខណៈ ចរិត

.៤ ចិត្តវិទ្យាកុមារ : ពី ១១ ឆ្នាំឡើង

.៥ ចិត្តវិទ្យាកុមារជំទង់

.៦ ចិត្តវិទ្យាកុមារមនុស្សធំ

៦៣២ ចិត្តវិទ្យាបុរស

៦៣៣ ចិត្តវិទ្យាស្ត្រី

១៥៧ វិកលចរិតវិទ្យា

១៥៨ ចិត្តវិទ្យាអនុវត្តន៍

.១ ការពង្រីក និង វិភាគលើបុគ្គលិកលក្ខណៈ

.២ ទំនាក់ទំនងជាមួយអ្នកដទៃ

.៧ ចិត្តវិទ្យាក្នុងឧស្សាហកម្ម

១៦០ តក្កវិទ្យា

១៦៧ សម្មតិកម្ម

១៧០ អភិសមាចារ ( ក្រមសីលធម៌)

១៧៣ ក្រមសីលធម៌វិជ្ជាជីវៈ

១៧៤ អភិសមាចារក្នុងការងារ ករណីកិច្ចវិទ្យា

១៧៦ អភិសមាចារបុរស នារី

១៧៨ មត្តញ្ញុតា ជំណាម

.៦ សេចក្តីក្លាហាន និង ភាពកំសាក

.៧ ការគោរព និង ការមើលងាយដល់ជីវិតមនុស្ស

.៧៦ ការរំលូតកូន

.៩ គុណធម៌ និង យុគកណ្តាល ទិសបូព៌

១៨៣ សូក្រាតនិយម

១៨៤ ប្លាតុងនិយម

១៨៥ អារិស្តូតនិយម

១៩០ ទស្សនវិជ្ជាទំនើបនៃបស្ចិមប្រទេស

១៩១ សហរដ្ឋអាមេរិក និង កាណាដា

១៩២ អង់គ្លេស

១៩៣ អាល្លឺម៉ង់ និង អូទ្រីស



www.elibraryofcambodia.org

១៩៤ បារាំង

១៩៥ អ៊ីតាលី

១៩៦ អេស្ប៉ាញ និង ព័រទុយហ្គេ

១៩៧ សហភាពសូវៀត និង ហ្វាំងឡង់

.១ ហ្វាំងឡង់

.២ ប្រទេសរុស្ស៊ី

១៩៨ ប្រទេសស្កង់ឌីណាវ

.២ ប្រទេសន័រវ៉ែស

.៥ ប្រទេសស៊ុយអែត

.៩ ប្រទេសដាណឺម៉ាក់

.១៩៩ ប្រទេសផ្សេងៗទៀត

ក្រុម ២០០ ទេវវិទ្យា និង សាសនា

២០១.១ ទស្សនវិជ្ជា និង ទ្រឹស្តី

.៣ វចនានុក្រម សព្ទវចនាធិប្បាយ

.៩ ប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រនៃសាសនា និង គំនិតសាសនា
ពីលេខ ២១០ ទៅ ២០៩ ជាលេខរួមរបស់គ្រិស្តសាសនា

.២០០ ទស្សនវិជ្ជា និង ទ្រឹស្តីនៃគ្រិស្តសាសនា

.២០១ សៀវភៅផ្សេងៗ និយាយ ពីគ្រិស្តសាសនា

.២០២ វចនានុក្រម និង សព្ទវចនាធិប្បាយនៃគ្រិស្តសាសនា

២០៧ ការសិក្សា និង បង្រៀនគ្រិស្តសាសនា

២១០ សាសនាធម្មជាតិ

២១១ គំនិតរបស់អាទិទេព

.៣ ទេវនិយម

.៤ សទិសទាននិយម

.៥ អាទិទេពនិយម

.៦ មនុស្ស

.៨ លទ្ធិបដិសេធអាទិទេព

២១៥ វិទ្យាសាស្ត្រ និង សាសនា



www.elibraryofcambodia.org

| | |
|---|---|
| ២១៦ | កុសល និង អកុសល |
| ២២០ | គម្ពីរគ្រិស្តសាសនា |
| ២២១ | បណ្តាំចុងក្រោយ |
| ២៣០ | គ្រិស្តសាសនិក |
| ២៣២ | គ្រិស្ត និង គ្រួសារ |
| .៩៦ | តណ្ហារបស់យេស៊ូ |
| .៩៧ | ការរស់ឡើងវិញ |
| ២៩៤.៣ | ព្រះពុទ្ធសាសនា |
| .៥ | សាសនាហិណ្ឌូ |
| ២៩៧ | សាសនាអ៊ិស្លាម |
| ២៩៩.៥១ | លទ្ធិខុងជឺ លទ្ធិតាវ |

ក្រុម ៣០០ សង្គមវិទ្យា និង ច្បាប់

| | |
|---|---|
| ៣០១ | សង្គមវិទ្យា |
| | សៀវភៅទាំងឡាយដែលនិយាយពីសង្គម សមាគមក្រុមហ៊ុនត្រូវដាក់នៅក្រុមនេះ ។ សៀវភៅនិយាយពីនរវិទ្យាសង្គម និង វប្បធម៌ត្រូវដាក់លេខ ៣០៦ នរវិទ្យារូបនិយមត្រូវដាក់លេខ ៥៧៣ |
| .៧២ | សង្គមនៃយុគដំបូង |
| .៧៤ | សង្គមជឿនលឿន |
| ៣០២ | ទំនាក់ទំនងក្នុងសង្គម |
| .២ | អនក្ខរភាព |
| .៥ | ទំនាក់ទំនងបុគ្គល និង សង្គម |
| | ឯកត្តនិយម ភាពដាច់តែឯង ភាពបង្កអធិករណ៍ |
| ៣០៣.៦ | អធិករណ៍ក្នុងសង្គម |
| .៦៤ | សង្គ្រាមរវាងជាតិសាសនាឯង |
| ៣០៤ | ឥទ្ធិពលធម្មជាតិមកលើអភិក្រមសង្គម |
| .៦២ | កំណើន និង ការថយចុះចំនួនប្រជាជន |
| .៨ | ចលនាប្រជាជន ទេសន្តរប្រវេសន៍ |



www.elibraryofcambodia.org

៣០៥ រចនាសម្ព័ន្ធនៃសង្គម

.៤២ តួនាទីស្ត្រីក្នុងសង្គម

.៥២ វណ្ណៈអ្នកមាន

.៥៥ វណ្ណៈមធ្យម បញ្ញវន្ត

.៥៦ វណ្ណៈពលជីវៈ កសិករ

៣០៦ វប្បធម៌ និង និយាមនៃអាកប្បកិរិយា
នរវិទ្យាសង្គម និង វប្បធម៌

.១ វប្បធម៌អន់ថយ អ្នកប្រឆាំង និង វប្បធម៌

.២ អាកប្បកិរិយាចំពោះនយោបាយ

.៤ អាកប្បកិរិយាក្នុងវិស័យវប្បធម៌

.៦ អាកប្បកិរិយាចំពោះសាសនា

៣១០ ស្ថិតិ

៣១២.១ អត្រាកំណើត

.២ អត្រាមរណៈ

.៣ អត្រាមានជំងឺ

៣១៤ ស្ថិតិទូទៅនៅអឺរ៉ុប

៣១៥ ស្ថិតិទូទៅនៅអាស៊ី

៣១៦ ស្ថិតិទូទៅនៅអាមេរិក

៣១៧ ស្ថិតិទូទៅនៅអាមេរិកខាងជើង

៣២០ វិទ្យាសាស្ត្រសង្គម : នយោបាយ និង រដ្ឋាភិបាល

.១ រដ្ឋ

.២ រដ្ឋាភិបាល

៣២០.៣ សិក្សាប្រៀបធៀបរវាងរដ្ឋាភិបាលមួយទៅនឹងរដ្ឋាភិបាលមួយ

.៤ រចនាសម្ព័ន្ធ មុខងារ សកម្មភាពរបស់រដ្ឋាភិបាល

.៥ ទ្រឹស្តី និង មនោគមវិជ្ជាខាងនយោបាយ

.៥១ សេរីនិយម

.៥២ អភិរក្សនិយម

.៥៣ សមូហភាពនិយម

.៥៣១ សង្គមនិយម



www.elibraryofcambodia.org

.៥៣៣ លទ្ធិផ្តាច់ការហ្វាស៊ីស ជាតិសង្គមនិយម

.៥៤ ជាតិនិយម

.៥៥ ទ្រឹស្តី និង មនោគមវិជ្ជាដែលយកសាសនាជាមូលដ្ឋាន

.៥៦ ប្រកាន់ពូជសាសន៍និយម

.៥៧ អនាធិបតេយ្យនិយម

៣២១ ប្រព័ន្ធរដ្ឋាភិបាល

៣២២ ទំនាក់ទំនងរវាងរដ្ឋ និង សមាគមនានា

៣២៣ ទំនាក់ទំនងរវាងរដ្ឋ និង ប្រជាពលរដ្ឋ

.១ ក្រុមជនភាគតិច

.៤ សិទ្ធិពលរដ្ឋ

.៥ សិទ្ធិនយោបាយ

៣២៤.២ បក្សនយោបាយ

.៥ ចំណាត់តាំងបេក្ខជនឈរឱ្យគេបោះឆ្នោត

.៦ ការបោះឆ្នោត

.៧ ឃោសនាបោះឆ្នោត

៣២៥ ទេសន្តរប្រវេសន៍អន្តរជាតិ

.១ អន្តោប្រវេសន៍

.២ និរប្រវេសន៍

.២១ អ្នកភៀសខ្លួនដោយនយោបាយ

.៣ អាណានិគម

៣២៦ ទាសភាព និង អត្តាធីនភាព

៣២៧ ទំនាក់ទំនងអន្តរជាតិ

៣២៨ ច្បាប់នីតិប្បញ្ញត្តិ

៣៣០ សេដ្ឋកិច្ច

៣៣១ សេដ្ឋកិច្ចគ្រប់គ្រងការងារ

.១៣៧ ភាពគ្មានការងារធ្វើ

៣៣២ ការងារគ្រប់គ្រងសេដ្ឋកិច្ច

.៦ វិនិយោគទុន

៣៣៣ ការគ្រប់គ្រងដីធ្លី



www.elibraryofcambodia.org

.១ សម្បត្តិសាធារណៈ

.៣ សម្បត្តិឯកជន

.៧ ធនធានធម្មជាតិ

.៧២ ការឃុំគ្រង និង ថែរក្សា

៣៣៣.៧៤ ព្រៃឈើ

.៧៦ ដីដាំដុះហើយ

.៧៧ ដីក្រុង

.៧៨ ទីលានកំសាន្ត ឧទ្យានធម្មជាតិ

.៧៩ ថាមពល និង ប្រេងកាត

.៨ ធនធានធម្មជាតិក្រោមដី

.៨២ ធ្យូង និង ប្រេងកាត

.៨៥ លោហធាតុ

.៨៨ ថាមពលឱ្យកំដៅ

.៩៥ រុក្ខជាតិ និង សត្វ

៣៣៤ សហករណ៍

៣៣៥ សង្គមនិយម និង ប្រព័ន្ធជាគ្រួសារ

៣៣៦ ហិរញ្ញវត្ថុសាធារណៈ ត្រូវដាក់ច្បាប់គ្រប់គ្រងសេដ្ឋកិច្ចនៅ លេខ ៣៥០.៧២

.១ ពន្ធដារនិងការដាក់ពន្ធ

៣៣៧ សេដ្ឋកិច្ចអន្តរជាតិ

.១ សហប្រតិបត្តិការសេដ្ឋកិច្ច

៣៣៨ ផលិតកម្ម

.១ កសិកម្ម

.២ ឧស្សាហកម្មរ៉ែ

៣៤០ ច្បាប់

.៣ ការកែទម្រង់ច្បាប់

៣៤១ ច្បាប់អន្តរជាតិ

.២៣ ច្បាប់អង្គការសហប្រជាជាតិ

.៣ ទំនាក់ទំនងអន្តរជាតិ



www.elibraryofcambodia.org

.៣៣ ការទូត

.៦ ច្បាប់សង្គ្រាម

.៦៤ អព្យាក្រឹតភាព

.៧ សហប្រតិបត្តិការអន្តរជាតិ

៣៤២ ច្បាប់រដ្ឋធម្មនុញ្ញ និង ច្បាប់រដ្ឋបាល

.០៥ ច្បាប់នីតិប្បញ្ញត្តិ

.០៦ ច្បាប់នីតិប្រតិបត្តិ

.០៧ ច្បាប់បោះឆ្នោត

៣៤៤ ច្បាប់សង្គមកិច្ច

៣៤៥ ច្បាប់ព្រហ្មទណ្ឌ

៣៤៦ ច្បាប់ឯកជន

.០១៦ ច្បាប់អាពាហ៍ពិពាហ៍

០១៦. ៦ ច្បាប់លែងលះគ្នា

.០៥ កេរ្តិ៍មតិក

៣៥០ ច្បាប់រដ្ឋបាលសាធារណៈ

៣៥១ រដ្ឋាភិបាលកណ្តាល

៣៥៣ សហរដ្ឋអាមេរិក : រដ្ឋាភិបាលតាមរដ្ឋ

៣៥៤ អង្គការអន្តរជាតិ

៣៥៥ សិល្បៈ និង វិទ្យាសាស្ត្រយោធា

៣៥៦ កងទ័ពថ្មើរជើង

៣៥៧ កងទ័ពប្រដាប់យានជំនិះ

៣៥៨ កងទ័ព : កាំភ្លើងធំ ទ័ពអាកាស និង អវកាស

៣៥៩ កងទ័ពជើងទឹក

៣៦០ បញ្ហានិងការងារសង្គម សមាគម

៣៦១ ជំនួយសង្គម

៣៦៦ សមាគម

៣៦៨ ធានារ៉ាប់រង

៣៧០ ការអប់រំ

.១ គោលការណ៍ ទ្រឹស្តី



www.elibraryofcambodia.org

.១៥ ចិត្ត-គរុកោសល្យ

.៧ ការសិក្សា និង ការបង្រៀនគរុកោសល្យ

.៧១ បណ្តុះបណ្តាលបុគ្គលិកសិក្សា

.៧៨ ស្រាវជ្រាវគរុកោសល្យ

៣៧១ ០២ សាលាឯកជន

.០៤ សាលាដកបទពិសោធន៍

.១០៣ ទំនាក់ទំនងរវាងគ្រូ និង មាតាបិតា សិស្ស

.១២ បណ្តុះបណ្តាលវិជ្ជាជីវៈ

.២ រដ្ឋបាលសិក្សា

.៣ វិធីបង្រៀន និង សិក្សា

.៤ តម្រង់ទិសសិក្សា និង វិជ្ជាជីវៈ

.៥ វិន័យសាលារៀន

.៦ ការសាងសង់ និង សម្ភារសិក្សា

.៧ អនាម័យសិក្សា និង សន្តិសុខនៅសាលារៀន

.៩ ការបង្រៀនដោយឯកទេសពិសេស

ឧទាហរណ៍: សិស្សពិការ សិស្សខិលខូច សិស្សបរទេស សិស្សកៀសខ្លួន

៣៧២. ២១ សាលាមត្តេយ្យ

៣៧២ អប់រំភេទ

៣៧៣ ការបង្រៀននៅមធ្យមសិក្សា

.២៤៦ សាលាបច្ចេកទេស

៣៧៤ អប់រំមនុស្សចាស់

.០២ វិធីបង្រៀន

៣៧៥ កម្មវិធីសិក្សា

៣៧៦ អប់រំស្ត្រីភេទ

៣៧៨ ការអប់រំនៅឧត្តមសិក្សា

៣៧៩ ការអប់រំ និង រដ្ឋ

៣៨០ ពាណិជ្ជកម្ម គមនាគមន៍ដឹកជញ្ជូន

.១ ពាណិជ្ជកម្ម

.៣ គមនាគមន៍



www.elibraryofcambodia.org

.៥ ការងារដឹកជញ្ជូន

៣៨១ ពាណិជ្ជកម្មក្រៅប្រទេស

៣៨២ ពាណិជ្ជកម្មក្នុងប្រទេស

.៥ ការនាំចូល

.៦ ការនាំចេញ

.៩ កិច្ចព្រមព្រៀងពាណិជ្ជកម្ម

៣៨៣ គមនាគមន៍តាមប្រៃណីយ៍

៣៨៥ ការដឹកជញ្ជូនតាមផ្លូវដែក

៣៨៦ ការដឹកជញ្ជូនតាមផ្លូវទឹក ក្នុងប្រទេស

៣៨៧ ការដឹកជញ្ជូនតាមសមុទ្រ និង អាកាស

៣៨៨ ការដឹកជញ្ជូនតាមជើងគោក

៣៩០ ទំនៀមទម្លាប់ សុជីវធម៌ ប្រពៃណីអ្នកស្រុក

៣៩១ សម្លៀកបំពាក់ បុរស នារីតាមសម័យ

.៥ ម៉ូតសក់

.៦ ការកែទម្រង់មុខ

.៧ គ្រឿងអលង្ការ

.៨ សំលៀកបំពាក់ ពេលបុណ្យគ្រប់ប្រភេទ

៣៩៣ ទំនៀមទម្លាប់ពិធីបុណ្យបូជាសព

៣៩៥ សុជីវធម៌

៣៩៨ ប្រពៃណីអ្នកស្រុក

.២ ការនិទានរឿងប្រជាប្រិយ

.៩ សុភាសិត

ក្រុម៤០០ ភាសា និង និរុត្តិវិទ្យា

៤០១ ទស្សនវិជ្ជា និង ទ្រឹស្តី

.៣ ភាសាសកល

៤០២ សៀវភៅផ្សេងៗ

៤០៣ វចនានុក្រម សព្ទវចនាធិប្បាយ តារាងប្រៀបធៀប

៤០៥ សាមាយិកប័ត្រ



www.elibraryofcambodia.org

៤០៩ ប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រ (ត្រូវបន្ថែមលេខភូមិវិទ្យា តារាង ២ លើ ៤០៩ ដើម្បីបាន : ប្រវត្តិសាស្ត្រនៃភាសាឥណ្ឌា)

៤១០ ភាសាវិទ្យា

៤១២ និរុត្តិសាស្ត្រ

៤១៣ វចនានុក្រមពហុភាសា

៤១៤ សទ្ទាវិទ្យា

៤១៥ វេយ្យាករណ៍

៤១៧.២ គ្រាមភាសាវិទ្យា

.៧ បុរាណលេខាសាស្ត្រ

៤២០ ភាសាអង់គ្លេស និង អង់គ្លេស-អាមេរិក

សម្រាប់ភាសាឥណ្ឌា អឺរ៉ុប

៤២៣ វចនានុក្រមដើម្បីឱ្យលេខវចនានុក្រមពីរភាសាដែលមានភាសាអង់គ្លេស នៅខាងដើមត្រូវយកលេខភាសាទី២មកសរសេរបន្ត:
ឧទាហរណ៍ : វចនានុក្រមអង់គ្លេស - បារាំង ៤២៣.៤
វចនានុក្រមអង់គ្លេស-ខ្មែរ ៤២៣.៩៩១

៤៣០ អាល្លឺម៉ង់

៤៤០ ភាសាក្លាយពីភាសាឡាតាំង ភាសាបារាំង

៤៥០ ភាសាអ៊ីតាលី រ៉ូម៉ានី គ្រាមភាសាឡាតាំង

៤៦០ ភាសាអេស្ប៉ាញ៉ុល និង ព័រទុយហ្គេ

៤៧០ ភាសាអ៊ីតាលីបុរាណ ឡាតាំង

៤៨០ ភាសាក្រិក

៤៩០ ភាសាផ្សេងៗ

៤៩១.២ ភាសាសំស្ក្រឹត

.៤ ភាសាឥណ្ឌាទំនើប

៤៩២.៧ ភាសាអារ៉ាប់

៤៩៥ ភាសាអាស៊ីខាងលិច និង ទិសអាគ្នេយ៍

.១ ភាសាចិន

.៤ ភាសាទីបេ

.៦ ភាសាជប៉ុន



www.elibraryofcambodia.org

.៧ ភាសាកូរ៉េ

.៨ ភាសាភូមា

.៩ ភាសាខ្មែរ ថៃ ឡាវ វៀតណាម

៤៩៥. ៩ ភាសាខ្មែរ

៤៩៦ ភាសាអាហ្វ្រិក

៤៩៩ ភាសាថ្ងា

.៩៩ ភាសាអេស្បេរ៉ង់តូ

ក្រុម៥០០ វិទ្យាសាស្ត្រពិត

៥០១ ទស្សនវិទ្យា និង ទ្រឹស្តី

៥០២ សៀវភៅផ្សេងៗ

៥០៣ វចនានុក្រម សព្វវចនាធិប្បាយ តារាងប្រៀបធៀប

៥០៤ ធ្វើដំណើរស្រាវជ្រាវវិទ្យាសាស្ត្រ

៥០៩ ប្រវត្តិវិទ្យា និងភូមិវិទ្យា

៥១០ គណិតវិទ្យា

៥១២ ពិជគណិត

៥១៣ លេខគណិត

៥១៤ ឋានវិទ្យា

៥១៥ វិភាគ

៥១៦ ធរណីមាត្រ

៥១៩ ភវនីយភាព និង គណិតវិទ្យាអនុវត្ត

៥២០ តារាវិទ្យា និង វិទ្យាសាស្ត្រពាក់ព័ន្ធ

៥២៣ តារាសាស្ត្រពិពណ៌នា

.១ លោកធាតុវិទ្យា

.២ ប្រព័ន្ធព្រះអាទិត្យ

.៣ ព្រះចន្ទ

.៤ ផ្កាយព្រះគ្រោះ

.៥ ធាតុភូតអាកាសធាតុ

.៦ ផ្កាយដុះកន្ទុយ



www.elibraryofcambodia.org

| | |
|---|---|
| .៧ | ព្រះអាទិត្យ |
| .៨ | ផ្កាយ |
| ៥២៥ | ព្រះធរណី : ភូមិវិទ្យាតារាសាស្ត្រ |
| .៥ | រដូវ |
| .៦ | ទឹកជោរនាច |
| ៥២៦ | ភូមិវិទ្យា គណិតសាស្ត្រ |
| .១ | ប្រថពីវិទ្យា |
| ៥២៨ | កាលប្បវត្តិវិជ្ជា |
| ៥៣០ | រូបវិទ្យា |
| ៥៤០ | គីមីវិទ្យា និង វិទ្យាសាស្ត្រពាក់ព័ន្ធ |
| ៥៤១.៣ | គីមីរូបនិយម |
| ៥៤៣ | គីមីវិភាគ |
| ៥៤៦ | គីមីខនិជ |
| ៥៤៧ | គីមីសរីរាង្គ |
| ៥៥០ | ការសិក្សាពីព្រះធរណី និង ពិភពដទៃទៀត |
| ៥៥១ | ភូគព្ភសាស្ត្រឧតុនិយមវិទ្យា ជលវិទ្យាទូទៅ |
| ៥៥២ | វិទ្យាសាស្ត្រស្រាវជ្រាវរកប្រេងកាត |
| ៥៥៣ | ធរណីវិទ្យាសេដ្ឋកិច្ច |
| ៥៥៤ | ធរណីវិទ្យានៅអឺរ៉ុប |
| .៤ | ធរណីវិទ្យានៅប្រទេសបារាំង |
| ៥៥៥ | ធរណីវិទ្យានៅអាស៊ី |
| ៥៥៦ | ធរណីវិទ្យានៅអាហ្វ្រិក |
| ៥៥៧ | ធរណីវិទ្យានៅអាមេរិកខាងជើង |
| ៥៥៨ | ធរណីវិទ្យានៅអាមេរិកខាងត្បូង |
| ៥៦០ | បាសាណភូតវិទ្យា |
| ៥៧០ | ជីវវិទ្យា |
| ៥៧៣ | នរវិទ្យារូបនិយម |
| ៥៧៤ | ជីវវិទ្យាទូទៅ |
| .១ | សរីរសាស្ត្រទូទៅ |



www.elibraryofcambodia.org

.២ រោគសាស្ត្រ

.៥ បរិស្ថានវិទ្យា

៥៧៥ វិវឌ្ឍន៍ ពន្ធុវិទ្យា បិតាគមន៍

៥៧៦ អតិសុខុមប្រាណ អតិសុខុមជីវសាស្ត្រ

៥៨០ រុក្ខសាស្ត្រ

៥៨៣ អន្ទបុប្ផាណជាតិ :ទីពីជបត្តជាតិ

៥៨៤ បន្ទបិប្ផាណជាតិ :ឯកពីជបត្តជាតិ

៥៨៦ បដិច្ឆន្នជាតិ : រុក្ខជាតិគ្មានគ្រាប់

៥៨៧ រុក្ខជាតិក្រុមវល្លិ

៥៨៨ រុក្ខជាតិពពួកស្លែ

៥៨៩. ២ ផ្សិត

.៣ សារាយ

៥៩០ សត្វវិទ្យា

៥៩២ សត្វគ្មានឆ្អឹងខ្នង

៥៩៣ បឋមសត្វ មជ្ឈិមសត្វ

៥៩៤ ក្រុមសត្វខ្យង ខ្ចៅ

៥៩៦ សត្វមានឆ្អឹងខ្នង

៥៩៧ សត្វមានឆ្អឹងខ្នងមានឈាមត្រជាក់ ត្រី

.៨ បាណកសត្វ

.៩ ឧរង្គសត្វ

៥៩៨ បក្សី

៥៩៩ ថនិកសត្វ

.១ ក្រុមសត្វកាំប្រមា និង ពង្រូល

.២ ក្រុមសត្វកង់កូរូ

.៣ ឧរង្គសត្វ

ឧទាហរណ៍ : សេះ រមាស

៤ ក្រុមសត្វប្រជៀវ ប្រឹង

៥ ថនិកមច្ឆា

ឧទាហរណ៍: ត្រីបាឡែន



www.elibraryofcambodia.org

៦ សោណ្ឌីសត្វ ឧទាហរណ៍: ដំរី

៧ វានរសត្វ : ក្រុមសត្វស្រដៀងមនុស្ស ឧទាហរណ៍ : ស្វា

ក្រុម៦០០ បច្ចេកទេស វិទ្យាសាស្ត្រអនុវត្ត

៦០១ ទស្សនវិជ្ជា និង ទ្រឹស្តី

៦០២ សៀវភៅផ្សេងៗ

៦០៣ វចនានុក្រម សព្ទវចនាធិប្បាយ តារាងប្រៀបធៀប

៦០៤.២ គំនូរឧស្សាហកម្ម

៦០៥ សាមយិកប័ត្រ

៦០៦ ការរៀបចំ និង គ្រប់គ្រង

៦០៨ ការរកឃើញថ្មី និង ប្រកាសនីយប័ត្រតក្កកម្ម

៦១០ វេជ្ជសាស្ត្រ

៦១៥ ឱសថសាស្ត្រ និង វិធីព្យាបាលរោគ

៦១៦ ជំងឺ

៦១៧ សិល្បសាស្ត្រ

៦២០ សិល្បៈនៃវិស្វករ និង សកម្មភាពពាក់ព័ន្ធ

៦២១ រូបវិទ្យាអនុវត្ត

៦២២ ទេពកោសល្យជីករ៉ែ និង សកម្មភាពពាក់ព័ន្ធ

៦២៣ កងទាហានជាង និងទាហានជើងទឹក

៦២៤ សិល្បៈស្ថាបនា ជាងស៊ីវិល

៦២៥ ផ្លូវដែក ផ្លូវថ្នល់

៦២៧ ទេពកោសល្យខាងជលគតិវិជ្ជា

៦២៨ បច្ចេកទេសអនាម័យក្រុង

៦៣០ កសិកម្ម និង បច្ចេកទេសពាក់ព័ន្ធ

៦៣១.៤ ធរណីសាស្ត្រ

.៦ ការរៀបចំដី ការបាចទឹកបញ្ចេញ

.៧ ការបាចទឹកបញ្ចូល

.៨ ការដាក់ជី និង កែប្រែដីឱ្យបានល្អ

៦៣២ ការខូចខាតដំណាំដោយព្រោះធម្មជាតិ ដោយជំងឺ និង ដោយចង្រៃស៊ីត



www.elibraryofcambodia.org

| | |
|---|---|
| .៩ | វិធីការពារជំលាំប្រឆាំង និង សត្វចង្រៃ និង រុក្ខជាតិដទៃទៀត |
| ៦៣៤. ៩៥ | វនវប្បកម្ម |
| ៦៣៦ | ការចិញ្ចឹមសត្វ |
| ៦៣៧ | ឧស្សាហកម្មធ្វើទឹកដោះគោ |
| ៦៣៨.១ | ការចិញ្ចឹមឃ្មុំ |
| .២ | ការចិញ្ចឹមដង្កូវនាង |
| ៦៣៩. ៩ | ការថែរក្សាធនធានធម្មជាតិ : ព្រៃឈើ និង សត្វព្រៃ |
| ៦៤០ | សេដ្ឋកិច្ចគ្រួសារ |
| ៦៤១ | ភោជនាហារ និង ភេសជ្ជៈ |
| ៤៦២ | ការរៀបចំបាយទឹក និង ការបំរើភ្ញៀវ |
| ៦៤៣ | លំនៅស្ថាន និង ប្រដាប់ប្រដាប្រើប្រាស់ |
| ៦៤៤ | ការដាក់ទឹក   ភ្លើង និងធ្វើឱ្យមានខ្យល់អាកាសល្អ |
| ៦៤៥ | ចលនវត្ថុ និង ការតុបតែង |
| ៦៤៦ | ការដេរប៉ាក់ ការរស់នៅផ្ទាល់ខ្លួន និង គ្រួសារ |
| ៦៤៧ | ការរៀបចំសណ្ឋាគារ និង ភោជនីយដ្ឋាន |
| ៦៤៨ | ការថែរក្សា និង ជួសជុល |
| ៦៤៩ | វិធីចិញ្ចឹមទារក អប់រំកុមារ និង ថែទាំអ្នកជំងឺ |
| ៦៥០ | ការគ្រប់គ្រងសហគ្រាស និង កាងារឧបសម្ព័ន្ធ |
| ៦៥៨ | ការគ្រប់គ្រងសហគ្រាសឯកជន និង សាធារណៈ |
| .១ | រៀបចំហិរញ្ញវត្ថុ |
| .២ | ការគ្រប់គ្រងអគារ |
| .៣ | ការគ្រប់គ្រងបុគ្គលិក |
| .៤ | អនុវត្តការងារគ្រប់គ្រង |
| .៥ | ការគ្រប់គ្រងផលិតផល |
| .៧ | ការគ្រប់គ្រងសម្ភារ និង វត្ថុធាតុដើម |
| .៨ | ចាត់ចែងការចែកចាយផលិតផល |
| ៦៥៩ | ការផ្សព្វផ្សាយ និង ទំនាក់ទំនងសាធារណៈ |
| ៦៦០ | បច្ចេកទេសគីមី និង បច្ចេកទេសពាក់ព័ន្ធ |
| ៦៦១ | បច្ចេកទេសផលិតផលគីមីឧស្សាហកម្ម |



www.elibraryofcambodia.org

| | |
|---|---|
| ៦៦២ | បច្ចេកទេសគ្រឿងផ្ទុះ និង គ្រឿងឆេះ |
| .៥ | ការធ្វើឈើគូស |
| ៦៦៣ | បច្ចេកទេសធ្វើភេសជ្ជៈ |
| ៦៦៤ | បច្ចេកទេសធ្វើស្បៀងដាក់ប្រអប់ ឬ កញ្ចប់ |
| ៦៦៥ | បច្ចេកទេសធ្វើប្រេង ខ្លាញ់ ក្រមួន និង ឧស្ម័នឧស្សាហកម្ម |
| ៦៦៦ | បច្ចេកទេសធ្វើភាជន៍ដី និង បច្ចេកទេសពាក់ព័ន្ធ |
| ៦៦៧ | ការសំអាត និង ឧស្សាហកម្មធ្វើថ្នាំពណ៌ |
| ៦៦៩ | ឧស្សាហកម្មលោហៈ |
| ៦៧០ | ការធ្វើឧស្សាហកម្ម |
| ៦៧១ | ឧស្សាហកម្មផលិត |
| ៦៧៥ | បច្ចេកទេសធ្វើស្បែក |
| ៦៧៦ | បច្ចេកទេសធ្វើម្សៅក្រដាស និង ធ្វើក្រដាស |
| ៦៧៧ | វាយណភ័ណ្ឌ |
| ៦៨០ | ការផលិតវត្ថុសម្រាប់ប្រើប្រាស់តាមយថាប្រភេទ |
| ៦៨៦ | ការងាររោងពុម្ព និង សកម្មភាពពាក់ព័ន្ធ |
| ៦៩០ | ការងារសំណង់ |
| ៦៩១ | សម្ភារសំណង់ |
| ៦៩២ | បច្ចេកទេសឧបសម្ព័ន្ធ : ប្លង់ គំនូរ ហិរញ្ញវត្ថុ |
| ៦៩៣ | វត្ថុសំណង់ |
| ៦៩៧ | ការដាក់គ្រឿងកំដៅ និង ធ្វើឱ្យមានខ្យល់អាកាសល្អ |
| ៦៩៨ | ការលាបថ្នាំបង្ហើយទូទៅ និង ធ្វើខឿនការពារអគារ |

ក្រុម៧០០ សិល្បៈ វិចិត្រសិល្បៈ និង សិល្បៈតុបតែង

| | |
|---|---|
| ៧០០.១ | ទស្សនវិជ្ជា និង ទ្រឹស្តីសិល្បៈ |
| .៧ | ការសិក្សា និង ការបង្រៀនសិល្បៈ |
| .៧៩ | មហោស្រព ប្រឡងសិល្បៈរង្វាន់ |
| ៧០១ | ទស្សនវិជ្ជា និង ទ្រឹស្តីនៃវិចិត្រសិល្បៈ និង សិល្បៈតុបតែង |
| .១៥ | ចិត្តវិទ្យានៃការបង្កើតសិល្បៈ |
| .១៧ | សោភ័ណភាព |



www.elibraryofcambodia.org

.១៨ វិ:តន់ និង មូលវិចារ

.៨ ចរិតជាក់ស្តែង : តែងបទភ្លេង ពណ៌ទ្រង់ទ្រាយ រចនាបទ

.៩ វិធីសាស្ត្រ

៧០២. ៨៨ ការថែរក្សាទុក កិច្ចការពារ ការធ្វើឡើងវិញ

៧០៣ វចនានុក្រម សព្វវចនាធិប្បាយនៃវិចិត្រសិល្បៈ និង សិល្បៈតុបតែង

៧០៤. ៩ បដិមាសាស្ត្រ

៧០៨ បន្ទប់តាំងវត្ថុសិល្បៈ សារមន្ទីរ ការប្រមូលផ្តុំ

៧០៩.១ សិល្បៈយុគដំបូងសម័យបុរេប្រវត្តិ និង សម័យបុរាណ

៧១០ វិជ្ជារៀបចំ និង តុបតែងក្រុង

.១ ទិដ្ឋភាពរដ្ឋបាល និង សង្គម

៧១២ រមណីយដ្ឋានធម្មជាតិ

៧២០ ស្ថាបត្យកម្ម

៧២១ គំនូរស្ថាបត្យកម្ម

៧២២ ស្ថាបត្យកម្មសម័យបុរាណ និង នៅបូព៌ាប្រទេស

៧២៣ ស្ថាបត្យកម្មយុគកណ្តាល ពី គ.ស ៣០០ ដល់ ១៣៩៩

៧២៤ ស្ថាបត្យកម្មទំនើប ចាប់ពី គ.ស ១៤០០មក

៧២៥ សំណង់សាធារណៈ

៧២៦ សំណង់សម្រាប់សាសនា

៧២៧ សំណង់អគារសិក្សា និង ការស្រាវជ្រាវ

៧២៨ សំណង់លំនៅស្ថាន

.៥ សណ្ឋាគារ

.៨ ប្រាសាទ

៧២៩ ការតុបតែងសម្ពាត

៧៣០ សិល្បៈគំនូរ ចម្លាក់

៧៣១ របៀបធ្វើ និង ការធ្វើរូបតំណាង

៧៣២ ចម្លាក់សម័យដើមនៅបូព៌ាប្រទេស និង នៅបស្ចឹមប្រទេសសម័យ
បុរាណ

៧៣៣ ចម្លាក់ក្រិក រ៉ូម៉ាំង

៧៣៤ ចម្លាក់យុគកណ្តាល :ចាប់ ពី គ.ស ៥០០ មក ១៤០០



www.elibraryofcambodia.org

| | |
|---|---|
| ៧៣៥ | ចម្លាក់សម័យទំនើប ចាប់ពី គ.ស ១៤០០ មក |
| ៧៣៦ | ការឆ្លាក់ក្បាច់ល្អិត លើឈើ ថ្ម ឆ្អឹង និង ភ្លុក |
| ៧៣៧ | ចម្លាក់គ្រឿងឥស្សរយស និង ត្រា |
| ៧៣៨ | សិល្បៈខាងធ្វើភាជន៍ |
| ៧៣៩ | វត្ថុសិល្បៈធ្វើអំពីលោហធាតុ |
| ៧៤០ | គំនូរ និងសិល្បៈតុបតែង |
| .៥ | ភាពយន្តដោយរូបភាព |
| .៦ | វិស្សុតកម្ម |
| ៧៤៦ | សិល្បៈខាងតម្បាញ លើកគោម និង ចាក់រូបលើកំណាត់ |
| ៧៤៧ | ការតុបតែងបន្ទប់ |
| ៧៥០ | វិចិត្រកម្ម និងផ្ទាំងគំនូរ |
| ៧៥៤ | ផ្ទាំងគំនូរខាងសាសនា |
| ៧៥៦ | ផ្ទាំងគំនូរប្រវត្តិសាស្ត្រ |
| ៧៥៧ | រូបតំណាងបុគ្គល |
| .២២ | គំនូរមនុស្សស្រាត |
| ៧៥៨.១ | ទេសភាព |
| .២ | ទេសភាពមាត់សមុទ្រ |
| .៣ | គំនូរសត្វ |
| .៦ | គំនូរបច្ចេកទេស និង ឧស្សាហកម្ម |
| ៧៥៩. ០៣ | ផ្ទាំងគំនូរក្នុងសតវត្ស ទី ១៥ និង ១៦ |
| ៧៦០ | សិល្បៈក្រាហ្វិក រូបចម្លាក់លើផ្ទាំងឈើ |
| ៧៦០ | របៀបឆ្លាក់រូបចេាំង |
| .២ | រូបចម្លាក់លើឈើ |
| .៨ | រូបចម្លាក់លើលោហធាតុ |
| ៧៦៤. ៨ | សេរីក្រាហ្វិក |
| ៧៦៩ | រូបចម្លងដោយត្រា |
| ៧៧០ | សិល្បៈថតរូប និងរូបថត |
| ៧៧១ | ម៉ាស៊ីនថតរូប ថតសំលេង និង សម្ភារ |
| ៧៧៨. ៥ | ការថតសំរាប់ភាពយន្ត និង ទូរទស្សន៍ |



www.elibraryofcambodia.org

៧៨០ តន្ត្រី

.១ ទស្សនវិជ្ជា និង សោភ័ណភាព

.៤២ ភ្លេងប្រជាប្រិយ៍

.៤៤ ភ្លេងសិក្សា

.៧៣ ការប្រគុំភ្លេង

៧៨១. ៩៥ ភ្លេងរាំ

.៩៧ ភ្លេងហ្សាស់

.៦ ការនិពន្ធបទភ្លេង និង អនុវត្តន៍

.៧ ភ្លេងជាលក្ខណៈជាតិ និង លក្ខណៈជនជាតិភាគតិច

៧៨២ ភ្លេងគួរឱ្យរំភើប ភ្លេងល្ខោន

.១ ភ្លេងអូប៉េរ៉ា

.៥ ភ្លេងរបាំបាលេ

៧៨៣ ភ្លេងពិសិដ្ឋ

៧៨៤. ៥ ចំរៀងប្រជាប្រិយ៍

.៧ ចំរៀងស្នេហាជាតិ និង នយោបាយ

៧៨៦ ឧបករណ៍ភ្លេងចុច : ព្យាណូ អ័ក

៧៨៨ ឧបករណ៍ភ្លេងខ្យល់ : ប៉ី ត្រុំប៉ែត ត្រែ ខ្លុយ

៧៨៩ ឧបករណ៍ភ្លេងវាយ : ស្គរ ឃ្មោះ គង

៧៩០ ការកំសាន្ត និងសិល្បៈនៃទស្សនីយភាព

៧៩១. ៣ ល្បែងសៀក

.៤៣ ភាពយន្ត

.៤៤ វិទ្យុ

.៤៥ ទូរទស្សន៍

.៥ អាយ៉ង ណាំង របាំស្បែក

.៨ ទស្សនីយភាពសួនសត្វ កីឡា ប្រយុទ្ធ និង គោ

៧៩២ ល្ខោន

.០២៥ ការរៀបចំឆាក

.០២៦ សំលៀកបំពាក់

.០២៧ ការលាបមុខ



www.elibraryofcambodia.org

.១ សោកនាដកម្ម

.២ កំប្លែង និង រឿងកំសត់

.៣ ល្ខោនគ

.៣១ របាំប្រពៃណី

៧៩៣. ៨ ល្បែងប្រើមន្តអាគម : ជាំហ៊ី ការឆ្លិនភ្នែក

៧៩៤. ១ ចត្រង្គ

៧៩៥ ល្បែងស៊ីសងដាក់លុយ

៧៩៦ អត្តពលកម្ម កីឡា

.៣២ បាល់បោះ

៣៣៤ បាល់ទាត់

៥២២ កីឡាឡើងភ្នំ

.៦ ប្រណាំងកង់

.៧២ ប្រណាំងរថយន្ត

.៧៥ ប្រណាំងទោចក្រយានយន្ត

.៨១ ប្រយុទ្ធយូដូ ការ៉ាត់តេដូ

.៨៣ ប្រដាល់

.៨៦ គុនដាវ

៧៩៧. ១៧ ស្គីលើទឹក

.៥៦ ឆ័ត្រយោង

៧៩៨.៤ ប្រណាំងសេះ

៧៩៩ នេសាទ និង បរបាញ់

.២៦ បេសកកម្មបាញ់សត្វធំៗ

## ក្រុម៨០០ អក្សរសិល្ប៍

៨០១ ទស្សនវិជ្ជានិង ទ្រឹស្តី

.៣ តំលៃ ឥទ្ធិពល អានុភាព

.៩២ ចិត្តវិទ្យានៃការបង្កើតអក្សរសិល្ប៍

.៩៣ សោភ័ណភាព

.៩៥ វិះគន់អក្សរសិល្ប៍



www.elibraryofcambodia.org

| | |
|---|---|
| ៨០៣ | វចនានុក្រម សព្វវចនាធិប្បាយ |
| ៨០៧.៩ | រង្វាន់អក្សរសិល្ប៍ |
| ៨០៨ | វោហាសាស្ត្រ និង អត្ថបទសម្រាំង |
| .០២ | បច្ចេកទេសក្នុងការតែងសេចក្តី |
| .០៦៨ | អក្សរសិល្ប៍សម្រាប់កុមារ |
| .១ | ឆន្ទវិទ្យា |
| .២ | វាគនាដកម្ម |
| ៣ | អក្សរសិល្ប៍អន្លង់អន្លោច |
| ៥ | វិញ្ញត្តិផ្ទាល់មាត់ |
| ៥៦ | សន្ទនា |
| ៦ | របៀបសរសេរសំបុត្រ |
| ៧ | របៀបសរសេរត្លុះតិះដៀល កំប្លែង ស្តូត គ្រាប់កំប្លែង |
| ៨ | ម៉ាលីបទ |
| ៨៣ | អត្ថបទរឿងប្រឌិត |
| ៨៦ | អត្ថបទឆ្លងឆ្លើយ |
| ៨០៩ | ប្រវត្តិ វិភាគ រិះគន់អក្សរសិល្ប៍ |
| ១ | ប្រវត្តិកវីនិពន្ធ |
| ២ | ប្រវត្តិស្នាដៃនាដកម្ម |
| ៣ | ប្រវត្តិស្នាដៃនៃរឿងប្រឌិត និង ប្រលោមលោក |
| ៧ | ប្រវត្តិស្នាដៃខាងសរសេត្លុះតិះដៀល និង កំប្លែង ស្តូត<br>ពី ៨១០ ទៅ៨៩០ សម្រាប់ដាក់អោយអក្សរសិល្ប៍បរទេសនានាត្រូវ<br>រៀបដាក់លេខអក្សរសិល្ប៍ទៅតាមភាសានៃអត្ថបទដើម |
| ៨១០ | អក្សរសិល្ប៍អាមេរិកាំងជាភាសាអង់គ្លេស |
| ៨១១ | កវីនិពន្ធ |
| ៨១២ | អក្សរសិល្ប៍នាដកម្ម |
| ៨១៣ | រឿងប្រឌិត |
| ៨១៧ | អក្សរសិល្ប៍ត្លុះតិះដៀល និង អក្សរសិល្ប៍កំប្លែង ស្តូត |
| ៨២០ | អក្សរសិល្ប៍ភាសាអង់គ្លេស-អាមេរិកាំង |

រៀបចំតាមលំដាប់ដូចបានធ្វើនៅ : ៨៤០



www.elibraryofcambodia.org

តារាងសម័យកាលរបស់អង់គ្លេស

១-១០៦៦-១៤០០

២-១៤០០-១៥៥៨

៣-១៥៥៨-១៦២៥

៤-១៦២៥-១៧០២

៥- ១៧០២-១៧៤៥

៦- ១៧៤៥-១៨០០

៧- ១៨០០- ១៨៣៧

៨- ១៨៣៧- ១៩០០

៩- ១៩០០

៨២១ កវីនិពន្ធ

៨២២ អក្សរសិល្បវិនោទកម្ម

៨២៣ រឿងប្រឌិត

៨២៧ អក្សរសិល្ប៍គួរឱ្យសើច និង អក្សរសិល្ប៍កំប្លែង សូត

៨៣០ អក្សរសិល្ប៍ភាសាអាល្លឺម៉ង់

របៀបចំតាមលំដាប់ដូចបានធ្វើនៅ :៨៤០

លេខសំគាល់អក្សរអាល្លឺម៉ង់ : ៨៣

១-ពីដើមមក១១៥០

២-១១៥០-១៣០០

៣-១៣០០-១៥១៧

៤-១៥១៧-១៦២៥

៥- ១៦២៥-១៧៥០

៦- ១៧៥០-១៨៣០

៧- ១៨៣០- ១៨៥៦

៨- ១៨៥៦- ១៩០០

៩- ១៩០០

.៣ អក្សរសិល្ប៍ហូឡង់ សរសេរជាភាសាអាល្លឺម៉ង់

.៥ អក្សរសិល្ប៍ស្កង់ឌីណាវ សរសេរជាភាសាអាល្លឺម៉ង់

.៧ អក្សរសិល្ប៍ស៊ុយអែត សរសេរជាភាសាអាល្លឺម៉ង់



www.elibraryofcambodia.org

៨៤០ អក្សរសិល្ប៍បារាំង អក្សរសិល្ប៍ក្លាយពីភាសាឡាតាំង

លេខសំគាល់អក្សរសិល្ប៍បារាំង : ៨៤

១- ទស្សនវិជ្ជានិង ទ្រឹស្តី

២- សៀវភៅផ្សេងៗ

៣- វចនានុក្រម សព្ទវចនាធិប្បាយ

៥- សាមយិកប័ត្រ

៦- ក្រុមការងារ

៧- សិក្សា និង ការបង្រៀន

៨- អក្សរសិល្ប៍បារាំងផ្សេងៗ តាមក្រុមជនជាតិភាគតិច

៩- ប្រវត្តិនៃអក្សរសិល្ប៍

៨៤១ កវីនិពន្ធ

៨៤២ អក្សរសិល្ប៍វិនាដកម្ម

៨៤៣ រឿងប្រឌិត

.០៦ ភាពយន្តដោយរូបភាព

៨៤៤ សំណេរសាកល្បង

៨៤៥ សន្ទរកថា

៨៤៦ សំណេរឆ្លើយឆ្លងអក្សរសិល្ប៍

៨៤៧ កវីនិពន្ធជៀលគួរ កំប្លែងស្លូត

៨៤៨ សំណេរផ្សេងៗ

៨៥០ អក្សរសិល្ប៍ភាសាអ៊ីតាលី រូម៉ានី ព្រាមភាសាអ៊ីតាលី

រៀបចំតាមលំដាប់ដូចបានធ្វើនៅ :៨៤០

លេខសំគាល់អក្សរសិល្ប៍អ៊ីតាលី : ៨៥

៨៥៩ អក្សរសិល្ប៍រូម៉ានី និង ព្រាមភាសាអ៊ីតាលី

៨៦០ អក្សរសិល្ប៍ភាសាអេស្ប៉ាញ៉ុល និង ព័រទុយហ្គេ

រៀបចំតាមលំដាប់ដូចបានធ្វើនៅ :៨៤០

លេខសម្គាល់អក្សរសិល្ប៍អេស្ប៉ាញ៉ុល : ៨៦

ពីលេខ ៨៦១ -៨៦៨ ចែកដូច ៨៤១ -៨៤៨

៨៦៩ ព័រទុយហ្គេ និង ប្រេស៊ីល

៨៧០ អក្សរសិល្ប៍អ៊ីតាលីបុរាណ និង អក្សរសិល្ប៍ឡាតាំង



www.elibraryofcambodia.org

| | |
|---|---|
| ៨៨០ | អក្សរសិល្ប៍ក្រិច |
| ៨៩០ | អក្សរសិល្ប៍ភាសាផ្សេងៗ |
| ៨៩១. ២ | អក្សរសិល្ប៍សំស្ក្រឹត |
| ៨៩៥ | អក្សរសិល្ប៍ក្រិច |
| ៨៩៥. ១ | អក្សរសិល្ប៍ចិន |
| ៨៩៥. ៩ | អក្សរសិល្ប៍ខ្មែរ |

ក្រុម ៩០០ ភូមិវិទ្យា និងប្រវត្តិវិទ្យា

ត្រូវចាត់ថ្នាក់ ប្រវត្តិសាស្ត្រសង្គមនៅលេខ ៣០៩ និង ប្រវត្តិសាស្ត្រនយោបាយនៅលេខ ៣២០. ៩ ។

ដើម្បីបញ្ចូលពាក្យថា : ភូមិវិទ្យា និង ប្រវត្តិវិទ្យា ទៅក្នុងមុខវិជ្ជាណាមួយ ត្រូវផ្សំលេខសម្គាល់នៃមុខវិជ្ជានោះជាមួយលេខភូមិវិទ្យា : ០៩

តារាងលេខ ; ១ ទំព័រ :

ឧទាហរណ៍ : ប្រវត្តិសាស្ត្រអក្សរសិល្ប៍ ៨០៩

: ប្រវត្តិសាស្ត្រវេជ្ជសាស្ត្រ ៦១០. ៩

: ប្រវត្តិសាស្ត្រកីឡា ៧៩៦. ០៩

| | |
|---|---|
| ៩០១ | ទស្សនវិជ្ជា និង ទ្រឹស្តីនៃប្រវត្តិសាស្ត្រទូទៅ |
| ៩០២ | សៀវភៅផ្សេងៗដែលទាក់ទង និង ប្រវត្តិសាស្ត្រទូទៅ |
| .០២ | កាលប្បវត្តិវិទ្យាតម្រា |
| ៩០៣ | វចនានុក្រម សព្វវចនាធិប្បាយ |
| ៩០៤ | រឿងនិទានពីព្រឹត្តិការណ៍ចម្លែក |
| .៥ | បន្ទុះភ្នំភ្លើង រញ្ជួយផែនដី |
| .៧ | បន្ទុះគ្រាប់បែក ជម្លោះ អគ្គិភ័យ មហន្តរាយបរមាណូ |
| ៩០៦ | ក្រុមការងារ |
| ៩០៧ | ការសិក្សា និង ការបង្រៀនប្រវត្តិសាស្ត្រទូទៅ |
| | សិល្បៈខាងសរសេរប្រវត្តិសាស្ត្រ |
| ៩០៩ | ប្រវត្តិសាស្ត្រទូទៅនៃពិភពលោក អារ្យធម៌ |
| | ត្រូវដាក់លេខប្រវត្តិសាស្ត្រសកលលោកបុរាណនៅលេខ : ៩៣០ និង ប្រវត្តិសាស្ត្រនាសម័យនៅលេខ :៩៤០- ៩៩០ |



www.elibraryofcambodia.org

.០៤ ប្រវត្តិសាស្ត្រនៃក្រុមជាតិសាសន៍ ជនជាតិភាគតិច និង ជាតិត្រូវផ្សំលេខ ៩០៩.០៤ ជាមួយលេខភូមិវិទ្យា ពី ០១ -៩៩ តារាងលេខ ៥ ឧទាហរណ៍: ប្រវត្តិសាស្ត្រជនជាតិជ្វីស: ៩០៩.០៤៩.២៤

.១ ប្រវត្តិសាស្ត្រទូទៅពីឆ្នាំ ៥០០ ដល់ ១១៩៩

.២ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ១៣

.៣ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ១៤

.៤ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ១៥

.៥ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ១៦

.៦ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ១៧

.៧ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ១៨

.៨ ប្រវត្តិសាស្ត្រទូទៅចាប់ពី ១៨០០

.៨១ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ១៩

.៨២ ប្រវត្តិសាស្ត្រទូទៅនៃ ស.វទី ២០

៩១០ ភូមិវិទ្យាទូទៅ ការធ្វើដំណើរ

.០១ ទស្សនវិជ្ជា និង ទ្រឹស្តី

.០១៤ ប្រជុំសព្ទបច្ចេកទេស

.០២ ភូមិវិទ្យារូបនិយម

.០៩ ការរុករក

.៤ រឿងនិទានពីការធ្វើដំណើរ : មិនកំណត់ភូមិសាស្ត្រទេ ត្រូវដាក់ការធ្វើដំណើរស្រាវជ្រាវវិទ្យាសាស្ត្រនៅលេខ : ៥០៨. ៣

.៤១ ជុំវិញពិភពលោក

.៥ ការធ្វើដំណើរ និង ការផ្សងព្រេងតាមសមុទ្រ :គ្រោះថ្នាក់តាមសមុទ្រ កំណប់នៅបាតសមុទ្រ ការផ្សងព្រេងរបស់ចោរសមុទ្រ

.៩២ ជីវប្រវត្តិនៃអ្នកប្រវត្តិសាស្ត្រ អ្នកធ្វើដំណើរ អ្នកស្រាវជ្រាវ

.៩១១ សៀវភៅផែនទីប្រវត្តិសាស្ត្រ

៩១២ ផ្ទាំងផែនដី

៩១៣ ពិភពលោកចាស់ : ភូមិវិទ្យា និង ការធ្វើដំណើរត្រូវដាក់បុរាណវត្ថុវិទ្យា នៅលេខ ៩៣០. ១

.០១ ភូមិវិទ្យា បុរេប្រវត្តិ



www.elibraryofcambodia.org

.០២ ភូមិវិទ្យារូបនិយម

.០៤ ការធ្វើដំណើរ ការរុករក ត្រូវបន្ថែមលើលេខ ៩១ លេខភូមិវិទ្យា ពី ៣១- ៣៩ តារាងលេខ២

ឧទាហរណ៍ : ភូមិសាស្ត្រ : ៩១៣. ៨ ពី ៩១៤ -៩១៩ :

ភូមិសាស្ត្រទ្វីប ប្រទេស តំបន់នៃពិភពលោកក្នុងសម័យនោះ ក៏មានរឿងនិទានអំពីការធ្វើដំណើរដែរ ។

- ត្រូវបន្ថែមលើលេខ៩១ នូវលេខភូមិវិទ្យាពី ៤-៩តារាងលេខ២

ឧទាហរណ៍: ភូមិវិទ្យាទ្វីបអឺរ៉ុប : ៩១៤

ភូមិវិទ្យាប្រទេសកម្ពុជា : ៩១៥. ៩១

ជាយថាហេតុគេត្រូវបន្ថែមលើលេខសំគាល់មុខវិជ្ជាដែល

បានផ្សំម្តងរួចហើយនូវលេខ : ០២ ភូមិវិទ្យារូបនិយម

០៤:ការធ្វើដំណើរ

ឧទាហរណ៍ : ភូមិវិទ្យារូបនិយមទ្វីបអឺរ៉ុប : ៩១៤. ០២

: ភូមិវិទ្យារូបនិយមប្រទេសបារាំង : ៩១៤. ៤០២

: ភូមិវិទ្យារូបនិយមប្រទេសកម្ពុជា : ៩១៥. ៩១០. ២

៩១៤ ភូមិវិទ្យាទ្វីបអឺរ៉ុប

៩១៥ ភូមិវិទ្យាទ្វីបអាស៊ី

៩១៦ ភូមិវិទ្យាទ្វីបអាហ្វ្រិក

៩១៧ ភូមិវិទ្យាទ្វីបអាមេរិកខាងជើង

៩១៨ ភូមិវិទ្យាទ្វីបអាមេរិកខាងត្បូង

៩២០ ជីវប្រវត្តិទូទៅ

១- ដើម្បីដាក់លេខឱ្យស្គាល់ដៃអ្នកនិពន្ធណាម្នាក់ បុគ្គល គេត្រូវយកលេខសម្គាល់មុខវិជ្ជានោះមកផ្សំជាមួយ លេខរូម ០៩២ តារាង លេខ ១

ឧទាហរណ៍ : ជីវប្រវត្តិនៃអ្នកគីមីសាស្ត្រម្នាក់ : ៩៤០. ៩២

២- ម្យ៉ាងទៀតបើចង់បញ្ជាក់ថា អ្នកគីមីសាស្ត្រនោះឈ្មោះអ្វី ត្រូវយកអក្សរមួយតួខាងដើមនៃត្រកូលអ្នកនិពន្ធទៅដាក់ក្រោម



www.elibraryofcambodia.org

លេខនៃស្លាដៃនិងអក្សរមួយខាងដើមនៃឈ្មោះអ្នកនិពន្ធផ្ទាល់ ទៅដាក់បន្តពីអក្សរត្រកូល ។

ឧទាហរណ៍ : ជីវប្រវត្តិអ្នកគីមីសាស្ត្រឈ្មោះ ដុង ឈុំ : ៤០. ៩២

ដ . ឈ

៣- បើគ្រាន់តែជីវប្រវត្តិរបស់បុគ្គល ត្រូវសរសេរអក្សរ ជ រួចដាក់ អក្សរតែពីរតួដូចខាងលើនៅក្រោមពាក្យអក្សរ ជ ។

ឧទាហរណ៍ : ជីវប្រវត្តិលោក ញ៉ុក ថែម : ជ

ញ . ថ

៤- បើឈ្មោះអ្នកនិពន្ធជាអក្សរឡាតាំង ត្រូវយកអក្សរ ៣ ពួកខាង ដើមនៃឈ្មោះ អ្នកនិពន្ធទៅដាក់ក្រោមលេខស្លាដៃ ។

ឧទាហរណ៍ : ជីវប្រវត្តិអ្នកគណិតសាស្ត្រឈ្មោះ DESCARTES

៥១០. ៩២
DES

| | |
|---|---|
| ៩២០. ៧១ | វិស្សុតបុរស |
| .៧២ | វិស្សុតនារី |
| ៩២១ | ទស្សនវិទូ និង ចិត្តវិទូ |
| ៩២២ | សន្តបណ្ឌិតខាងសាសនា បព្វជិត |
| ៩២៣ | អ្នកនយោបាយ អ្នកសេដ្ឋសាស្ត្រ អ្នកយុត្តិសាស្ត្រ អ្នកបង្ហាត់បង្រៀន។ ចូរមើលតាមលេខក្រុម ៣០០ ឧទាហរណ៍: ជីវប្រវត្តិទូទៅ នៃអ្នកបង្ហាត់បង្រៀន : ៩២៣. ៧ |
| ៩២៤ | ភាសាវិទូ |
| ៩២៥ | អ្នកប្រាជ្ញ |
| ៩២៦ | វិស្វករ |
| ៩២៧ | សិល្បករ កីឡាករ ឧ: ជីវប្រវត្តិទូទៅនៃអ្នកសិល្បករ : ៩២៧. ៥ |
| ៩២៨ | អ្នកនិពន្ធ |
| ៩២៩ | ពង្សវិទ្យា អសាធារណនាមសាស្ត្រ និមិត្តរូប |
| .២ | ប្រវត្តិគ្រួសារដែលមានឈ្មោះល្បីល្បាញ |
| .៥ | ពាក្យចរិកមុខផ្ទូរ |



www.elibraryofcambodia.org

.៧ ព្រះរាជវង្សានុវង្ស សន្តតិវង្ស

.៨ វរលញ្ឆករ

.៩២ ទង់ជាតិ

ពី ៩៣០- ៩៩០ :ប្រវត្តិសាស្ត្រទូទៅតាមទ្វីប តាមប្រទេស តាមតំបន់ នៃពិភពលោកចាស់ និង ពិភពលោកសម័យថ្មី ពិភពក្រៅ ។

- ត្រូវបន្ថែមលេខ ៩ ទៅ លើលេខភូមិវិទ្យា -៣ -៩ តារាងលេខ

ឧទាហរណ៍ : ប្រវត្តិសាស្ត្រទ្វីបអឺរ៉ុប : ៩៤០

ប្រវត្តិសាស្ត្រប្រទេស បារាំង : ៩៤៤

៩៣០ ប្រវត្តិសាស្ត្រទូទៅ នៃពិភពលោកចាស់ រហូតដល់ ឆ្នាំ ៤៩៩ នៃ គ.ស

.១ បុរាណវិទ្យា

៩៣១ ប្រវត្តិសាស្ត្រប្រទេសចិនរហូតដល់ឆ្នាំ៤២០ នៃគ.ស

៩៣២ ប្រវត្តិសាស្ត្រប្រទេសអេហ្ស៊ីបរហូតដល់ឆ្នាំ៦៤០ នៃ គ.ស

៩៣៣ ប្រវត្តិសាស្ត្រប្រទេសប៉ាលេស្ទីនរហូតដល់ឆ្នាំ៧០ នៃ គ.ស

៩៣៤ ប្រវត្តិសាស្ត្រប្រទេសឥណ្ឌារហូតដល់ឆ្នាំ៦៤៧ នៃ គ.ស

៩៣៥ ប្រវត្តិសាស្ត្រមេសូប៉ូតាមី និង ខ្ពង់រាបនៃប្រទេសអៀរ៉ង់រហូតដល់ឆ្នាំ ៦៣៧ នៃ គ.ស

៩៣៦. ១ អៀឡង់ដ៏

.២ ប្រទេសអង់គ្លេស

.៣ ប្រទេសអាល្លឺម៉ង់រហូតដល់ឆ្នាំ៦៤៧ នៃគ.ស

៩៣៧ ប្រទេសអ៊ីតាលី និង ទឹកដីឧបសម្ព័ន្ធ រហូតដល់ឆ្នាំ៤៧៦ នៃគ.ស

៩៣៨ ប្រទេសក្រិចរហូតដល់ឆ្នាំ ៣២៣ នៃ គ.ស

៩៤០ ប្រវត្តិសាស្ត្រទូទៅនៃទ្វីបអឺរ៉ុប-អឺរ៉ុបខាងលិច

.១ យុគកណ្តាល

.២ នវសម័យ ពីឆ្នាំ ១៤៥៣ រហូតមក

.២១ បុនភព ១៤៥៣ -១៥១៧

.២២ ការកែទម្រង់ ១៧៨៩

.២៧ ក្នុងរាជ្យ និង ចម្បាំងរបស់ណាប៉ូឡេអុង ពី ១៧៨៩ -១៨១៥

.៣ សង្គ្រាមសកលលោកលើកទី១ : ១៩១៥ -១៩១៨



www.elibraryofcambodia.org

.៥៣ សង្គ្រាមសកលលោកលើកទី២ : ១៩៣៩ -១៩៤៥

៩៤១ កោះរបស់រាជាណាចក្រអង់គ្លេស

.១ អេកូស

.៥ អៀរឡង់ដ៏

.៦ អ៊ុលស្ទា-អៀរឡង់ដ៏ខាងជើង

.៧ សាធារណរដ្ឋអៀរឡង់ដ៏ - អៀរ

៩៤២ ប្រទេសអង់គ្លេស និង តំបន់ខាងលិចនៃប្រទេសអង់គ្លេស

៩៤៣ អឺរ៉ុបកណ្ដាល-ប្រទេសអាល្លឺម៉ង់

.១ សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់

.៦ ប្រទេសអូទ្រីស

.៧ ប្រទេសឆេកូស្លូវ៉ាគី

.៨ ប្រទេសប៉ូឡូញ

.៩ ប្រទេសហុងគ្រី

៩៤៤ ប្រទេសបារាំង

.០២៥ ស្ដេចវ៉ាល្វ័ ពីឆ្នាំ ១៣២៨-១៤៩៨ : សង្គ្រាម១០០ឆ្នាំ

.០៤ បដិវត្ត : ១៧៨៩

.០៤២ សាធារណរដ្ឋលើកទី១ : ១៧៩២-១៧៩៩

.០៧ សាធារណរដ្ឋលើកទី២ : ១៨៤៨-១៨៧០ ណាប៉ូឡេអុងទី៣

.០៨១ សាធារណរដ្ឋលើកទី៣ : ១៨៧០-១៩៤៥

.០៨២ សាធារណរដ្ឋលើកទី៤ : ១៩៤៥-១៩៥៨

.០៨៣ សាធារណរដ្ឋលើកទី៥ : ១៩៥៨ មក

៩៤៥ ប្រទេសអ៊ីតាលី

០៥ ១៣០០- ១៤៩៤ :បុនភព

០៩១ ១៩១៨ - ១៩៤៦ : របបហ្វាស៊ីស

០៨១ សាធារណរដ្ឋ : ១៩៣១- ១៩៣៩

៩៤៧ អឺរ៉ុបខាងកើត សហភាពសូវៀត

.០១ ប្រវត្តិសាស្ត្រប្រទេសរុស្ស៊ី
